បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



# ប្រស្នាពុទ្ធប្បវត្តិពិស្តារ

២០៥.
៤៨

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២០៥-៤៨

# ប្រស្នាពុទ្ធប្បវត្តិ

## ពិស្តារ

X

រៀបរៀងដោយ

សែម-សួរ

អតីតនិស្សិតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សា ១៩៦៣

និស្សិតបច្ចុប្បន្ន នៅមហាវិទ្យាល័យអក្សរសាស្ត្រ

និងមនុស្សសាស្ត្រ ភ្នំពេញ

X X

X

LIBRARY
BUDDHIST INSTITUTE
៥០៤៥/00

ផ្សាយចេញពី

ភ្នំពេញ

ព.ស. ២៥០៨ គ.ស. ១៩៦៥

www.budinst.gov.kh www.elibraryofcambodia.org

# គោលបំណងអ្នករៀបរៀង

ក្នុងជាតិកំណើតនិងកាលៈទេសនេះ ខ្ញុំបានចូលមកនៅជ្រកកោនក្រោមម្លប់ព្រះពុទ្ធសាសនាហើយបានរៀនសូត្រ, បានទទួលការអប់រំនិងការចេះដឹងជាច្រើននៅក្នុងរង្វង់នៃព្រះពុទ្ធសាសនានេះ ទាំងផ្លូវលោក ផ្លូវធម៌ ៗ យ៉ាងនេះហើយបានជាខ្ញុំមានគោលបំណងបង្កប់ទុកជាយូរហើយថា នឹងរៀបចំក្បួនច្បាប់ខ្លះ តាមសមត្ថភាព និងការចេះដឹងរបស់ខ្លួនខាងផ្នែកព្រះពុទ្ធសាសនា ដើម្បីតបស្នងសងគុណបូជាព្រះរតនត្រ័យ និងទុកជាអនុស្សរណៈក្នុងប្រវត្តិជីវិតរបស់ខ្ញុំ ក៏ប៉ុន្តែដោយកាលវេលាពុំទាន់ហុចឲ្យ និងដោយមានកិច្ចរវល់ច្រើនពេក សេចក្តីប្រាថ្នានេះក៏ពុំទាន់បានសម្រេចនៅឡើយ រហូតទល់ពេលនេះ ក៏ពុំទាន់មានពេលវេលាឲ្យច្រើនណាស់ដែរ តែខ្ញុំប្រឹងឆ្លៀតឱកាសបន្តិច ៗ ដើម្បីយកពេលមកចងប្រស្នាពុទ្ធប្បវត្តិពិស្តារនេះឡើង ទុកជាស្នាដៃទី ២៣ ក្នុងចំណោមស្នាដៃនានាផ្នែកអក្សរសាស្ត្រ និង អក្សរសិល្ប៍ ដែលខ្ញុំបាននិពន្ធ និងបានបោះពុម្ពរួចមកហើយ ៗ

ប្រស្នាពុទ្ធប្បវត្តិពិស្តារនេះ ពុំមែនជាខ្សែរឿង ឬ ជាអត្ថបទថ្មីថ្មោងនោះឡើយ តែជារឿងដែលលោកអ្នកចេះដឹងមុន ៗ បាននិទាននិងចងក្រងទុកក្នុងគម្ពីរដីកា និងបកប្រែជាភាសាជាតិច្រើនហើយដែរ តែពុំទាន់បានហូរហែរសព្វគ្រប់ គួរឲ្យពុទ្ធបរិស័ទចេះដឹងយល់ និងពន្យល់ដំណួន

www.budinst.gov.kh www.elibraryofcambodia.org

ល្មមបាន ៗ ខ្ញុំបានប្រមូលគម្រង់អត្ថបទនេះ ពីក្នុងគម្ពីរនិងសៀវភៅនានា តាំងភាសាជាតិនិងបរទេស ព្រមទាំងតាមការចេះចាំដោយការស្ដាប់-រៀន មកចងក្រងជាសៀវភៅនេះឡើង ដើម្បីទុកជាគ្រឿងដំណែលក្នុងព្រះពុទ្ធសា-សនាផង ដើម្បីចែកចាយនូវការចេះចាំរបស់ខ្លួនដល់អនុជនផង ៗ

សូមលោកអ្នកប្រាជ្ញទាំងឡាយ មេត្តាអភ័យទោសចំពោះកំហុស ដោយអចេតនានានាក្នុងសៀវភៅនេះ ៗ

សូមឧទ្ទិសកុសលផលប្រគេនជូនចំពោះ មាតាបិតាគឺលោក ជាវ-សែម ឧបាសិកា អុក និងលោកគ្រូ ឃ្លួន-រឹម នៅភូមិលាក់តា ឃុំព្រែកក្រឹស ស្រុកកំពង់ត្រាច កំពត និងគ្រូឧបជ្ឈាយាចារ្យជាទីគោរពរបស់ខ្ញុំ មានព្រះតេជព្រះគុណធម្មាចារ្យ ឱម-ពុធ វត្តអង្គជុំព្រៃទប់ ព្រះឧបជ្ឈាយ៍ ជិន-ណាក់ វត្តអង្គសូរគី ឃុំកន្ធោរ ស្រុកកំពង់ត្រាច កំពត ជាដើម ដែលបានអប់រំខ្ញុំឲ្យប្រព្រឹត្តតាមគន្លងនៃព្រះបរមពុទ្ធោវាទ ៗ

សូមឲ្យព្រះពុទ្ធសាសនាចំរើនស្ថិតស្ថេរជាអង្វែងទៅ

ថ្ងៃទី ២៩ មិថុនា ១៩៦៤

សែម-សួរ

www.budinst.gov.kh www.elibraryofcambodia.org

# នមស្សការគាថា

នមាមិហំ ច សម្ពុទ្ធំ　　ភគុណំ អនាសវំ
សព្វធម្មេ បពុជ្ឈិតំ　　នានាសត្តំ អមតំ បទំ ។
សម្ពុទ្ធស្ស នមស្សិត្វា　　សត្ថានមសុការហំ
សព្វធម្មំ សុទេសិតំ　　និព្វានញ្ច ទភារិយំ ។
នមោ សង្ឃំ គុណុត្តមេ　　បុញ្ញក្ខេត្តំ បរិសាទំ
នមក្ការានុភាវេន　　ជយមង្គលំ ភវតុ តេ ។

សែម—សួរ ខ្ញុំសូម　　បង្គំលំអុត
ដល់ព្រះសម្ពុទ្ធ　　ទ្រង់គុណច្រើនក្រៃ
ទ្រង់ញាណត្រៀងត្រាំ　　ជាំជាប់ហឫទ័យ
ប្រកបញាណញេយ្យ　　ប្រពៃភ្លឺថ្លា
ទ្រង់ត្រាស់ដឹងធម៌　　ដ៏ល្អអស្ចារ្យ
ដឹកនាំសត្វា　　ឲ្យរួចទុក្ខសោក ។

សូមនមស្ការ　　ព្រះធម៌នៃលោក
ដែលព្រះមានជោគ　　ទ្រង់ត្រាស់ទេសន៍ទុក
ជាធម៌ប្រសើរ　　ឧត្តមនាំសុខ
ប្រយោជន៍គ្រប់មុខ　　ដល់មនុស្សទេពតា
ឈានដល់និព្វាន　　ជាស្ពានថ្លៃថ្លា
រួចចាកទុក្ខា　　ពិតភ័យអាសន្ន ។

សូមគោរពសង្ឃ　　ជាអង្គមានគុណ
ទ្រង់ជាស្រែបុណ្យ　　នៃបរិស័ទ
លោកទ្រង់បូជា　　ដោយការប្រតិបត្តិ
សង្រួមស្ងប់ស្ងាត់　　តាមធម៌វិន័យ
ដោយអានុភាព　　នៃប្រណាមត្រៃ
សូមមង្គលជ័យ　　កើតមានដល់យើង ។

សែម សួរ

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីរាយនាមអត្ថបទ

## ក្នុងសៀវភៅប្រស្នាពុទ្ធប្បវត្តិពិស្តារ


ភាគទី ១.- អាទិសិក្សាអំពីពុទ្ធប្បវត្តិ ទំព័រ ១

,, ២.- បុព្វប្រវត្តិ ៣២

,, ៣.- ព្រះបដិសន្ធិនិងការប្រសូតនៃព្រះសិទ្ធត្ថកុមារ ៤០

,, ៤.- ព្រះលក្ខណៈនិងកុមារវ័យ ៥៦

,, ៥.- ការចេញសាងព្រះផ្នួសនិងការធ្វើទុក្ករកិរិយា ៦៩

,, ៦.- ហេតុអស្ចារ្យនៅមុនពេលត្រាស់ដឹង ៨៨

,, ៧.- ពេលទ្រង់បានត្រាស់ដឹង ១០៦

,, ៨.- ព្រះពុទ្ធសកម្មភាពនៅពេលត្រាស់ដឹងហើយថ្មីៗ ១១៧

,, ៩.- ធម្មចក្កប្បវត្តនទេសនានិងការដឹកនាំសាវ័កនៅគ្រាដំបូង ១២៤

,,១០.- ការយាងទៅកាន់កបិលព័ស្តុបុរីជាលើកទី ១ និងការដឹកនាំសាក្យរាជនានា ១៤៣

,,១១.- បរិនិព្វាននៃពុទ្ធបិតា, ការប្រោសព្រះពុទ្ធមាតា និងពុទ្ធសកម្មក្នុងបឋមពោធិកាល ១៥៤

,,១២.- ព្រះពុទ្ធកិច្ចនិងពុទ្ធបរិនិព្វាន ១៦២

ភាគអវសាន.- ពុទ្ធកាលបរិច្ឆេទនិងស្ថានហេតុនានាដែលអ្នកសិក្សាពុទ្ធប្បវត្តិគួរចាំទុក ១៨៩


www.budinst.gov.kh www.elibraryofcambodia.org

## ភាគទី ១

# អាធិសិក្សាអំពីពុទ្ធប្រវត្តិ

ដើម្បីនឹងសិក្សាអំពីរឿងរ៉ាវរបស់មនុស្សអស្ចារ្យ(អច្ឆរិយបុគ្គល)ឬអំពីមហាបុរសណាមួយ ៗ, អ្នកសិក្សាគប្បីដឹងជាមុននូវស្រុកកំណើត, វង្សត្រកូល, កុមារភាព និងសកម្មភាព ព្រមទាំងការប្រព្រឹត្តផ្សេង ៗ របស់បុគ្គលនោះឲ្យច្បាស់លាស់ទើបអាចយល់នូវគុណសម្បទ ឬគុណវិបត្តិរបស់បុគ្គលនោះបាន ៗ ឯការសិក្សាអំពីពុទ្ធប្រវត្តិ ដែលជាអគ្គបុគ្គល, ជាបរមសាស្តាចារ្យ អ្នកសិក្សាក៏ត្រូវតែស្គាល់ឲ្យច្បាស់នូវដែនដីឥណ្ឌា - នេប៉ាល់ជាជាតិភូមិរបស់ព្រះអង្គជាមុន រួចត្រូវសិក្សាអំពីសភាពនយោបាយ, ការប្រព្រឹត្តទៅរបស់មនុស្សក្នុងជំនាន់នោះ, ព្រះរាជវង្ស, ព្រះសកម្មភាព របស់ព្រះអង្គតាំងពីពេលប្រសូតិហូតដល់ចូលបរិនិព្វាន និងចំណុចសំខាន់ផ្សេង ៗ ជាច្រើនអនេកដែលទាក់ទងដល់ព្រះពុទ្ធជាម្ចាស់ហើយកន្លែងខ្លះទាក់ទងទៅនឹងរឿងហេតុដ៏អស្ចារ្យទៀតផង ៗ

ដូច្នេះ ក្នុងការសិក្សាអំពីពុទ្ធប្រវត្តិជាការលំបាកច្រើន ហើយក្នុងការសិក្សានេះត្រូវមានការស្រាវជ្រាវពិនិត្យពិច័យដល់សង្គមធម៌, ចរិយាធម៌ និងអារ្យធម៌ព្រមទាំងបញ្ហាដែនដីឥណ្ឌា-នេប៉ាល់តាមផ្លូវប្រវត្តិសាស្ត្រតាំងពីបុរាណកាល មុនព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រសូតិទៀតផង ៗ

www.budinst.gov.kh www.elibraryofcambodia.org

ប្រទេសកម្ពុជាយើងដែលទើបនឹងមានប្រហែល ២០០០ ឆ្នាំប៉ុណ្ណោះ ក៏មានការប្រែប្រួល ផ្លាស់ប្ដូររាជធានី និងឈ្មោះនៃរាជធានីច្រើនកន្លែងពេកណាស់ទៅហើយ គឺកាល ដើមរាជធានី ខ្មែរមានកំណើតនៅឯអង្គរបុរី ក្នុងខេត្តតាកែវ តមកក្នុងសម័យកម្ពុជាលើ កម្ពុជាក្រោម រាជធានីក៏ត្រូវផ្លាស់ទៅកាន់សម្បូណ៌ព្រៃនគរ, ទៅលាវខាងត្បូង ( កាលណោះដែនចម្ប៉ាសាក់ជាដីរបស់ខ្មែរ) រួចហើយផ្លាស់ទៅសៀមរាប ហើយមកទួលបាសាណ( ស្រីសន្ធរ).មកភ្នំពេញ ទៅទួលបាសាណ, ទៅបន្ទាយលង្វែក, ទៅទួលបាសាណ, កោះស្លាកែត, ទៅឧដុង្គ រួចមកភ្នំពេញវិញ ។ល។ ការបង្ហាញដោយខ្ញុំប៉ុណ្ណោះនាំឲ្យយើងឃើញថា រាជធានី ឬ វដ្តធានី ឬ ក៏ទីក្រុងនីមួយ ៗ ពុំទៅស្ថិតស្ថេរតែ ១ កន្លែងឡើយ កាលណាមានកើតហេតុផ្សេង ៗ ព្រះរាជា ឬ អ្នកកាន់កាប់ការរាជការ ក៏ត្រូវផ្លាស់ប្ដូរមជ្ឈដ្ឋាននយោបាយពីកន្លែងដើមទៅកន្លែងផ្សេងទៀត ហើយកន្លែងខ្លះ បានទៅតាំងនៅពីរបីដងក៏មាន ដូចជាទួលបាសាណ (ស្រីសន្ធរ) ព្រះរាជាច្រើនអង្គបានយាងទៅគង់នៅជាច្រើនលើក ។

អាស្រ័យហេតុនេះហើយ ទើបក្នុងការសិក្សាអំពីពុទ្ធប្រវត្តិដែលទាក់ទងដល់ដែនដីឥណ្ឌៀ-នេប៉ាល់នោះ ក៏ត្រូវតែលំបាក ហើយត្រូវមានការពិចារណាជញ្ជឹងរកហេតុផលទៀតផង ព្រោះមានការផ្លាស់ប្ដូរឈ្មោះផ្លាស់

www.budinst.gov.kh www.elibraryofcambodia.org

ប្ដូរទីកន្លែងថ្មីជាច្រើនលើកច្រើនគ្រា ថែមទាំងផ្លាស់សភាពរុងរឿង ទៅកាន់សភាពទន់ទ្រាយ ឬផ្លាស់ពីសភាពទន់ទ្រាយទៅកាន់សភាពរុងរឿងទៀតផងក៏មាន ។ ក្នុងចំណោមរដ្ឋ និងរាជធានីដ៏ធំនាន់ពុទ្ធកាលដែលយើងធ្លាប់ស្គាល់ដូចជាក្រុងសាវត្ថី, វេសាលី, កបិលពស្តុ, រាជគ្រឹះជាដើម សព្វថ្ងៃផ្លាស់ទៅកាន់កន្លែងថ្មីក៏មាន ផ្លាស់ឈ្មោះជាថ្មីក៏មាន ផ្លាស់ទាំងទីកន្លែង ទាំងឈ្មោះក៏មាន ។ ក្នុងចំណោមក្រុងទាំងនោះ នៅសល់តែពារាណសី រដ្ឋកាសី១ ប៉ុណ្ណោះ ដែលនៅគង់សភាពរុងរឿងដូចដើម និងទាំងទីនៅត្រង់កន្លែងដើមរហូតទល់សព្វថ្ងៃ តែបានផ្លាស់ឈ្មោះថា "បេ-ណារែស" ទៅវិញ ។

## ដែនដីនិងជនជាតិឥណ្ឌា
## នេប៉ាល់នៅបុរាណសម័យ

នៅបុរាណកាល ប្រទេសឥណ្ឌា-នេប៉ាល់មានឈ្មោះថា "ជម្ពូទ្វីប" ឬ "ភារតវស្ស" ឬក៏ "មជ្ឈិមប្រទេស" ។

មានឈ្មោះថាជម្ពូទ្វីប ព្រោះដែនដីនេះជាកោះធំ១ នៅចន្លោះទន្លេ សិន្ធុ និងទន្លេ គង្គា ហើយមានដើមព្រីងធំ១ ដុះនៅលើកោះនេះ ជាឈើប្រចាំទ្វីប ឬប្រចាំកោះ—ទឹកដី ។

ដែលហៅថា ភារតវស្ស ឬភារតវស៌ គឺជាលំនៅរបស់ ភារតៈ

គឺជនជាតិអារ្យ ឬអារៀន ។

ដែលមានឈ្មោះថាមជ្ឈិមប្រទេស ឬមធ្យមប្រទេស ព្រោះជាប្រទេសដែលតាំងនៅកណ្ដាលនៃប្រទេសឯទៀតៗ ឬហៅថា បដិរូបទេសក៏ស (លំនៅ ឬប្រទេសដ៏សមគួរនៅ) ។

ដែលហៅថា ឥណ្ឌៀ ព្រោះតាំងនៅទិសទន្លេសិន្ធុ ហៅតាមជនជាតិក្រិចថា ឥណ្ឌុស (INDUS) តមកអង់គ្លេស ហៅថា ឥណ្ឌា (INDIA) ឥណ្ឌា ។

ពួកជនជាតិ អរិយកៈ ដែលមកតាំងនៅក្នុងជម្ពូទ្វីបនេះ មិនមែនជាម្ចាស់ស្រុកនេះទេ ឯម្ចាស់ស្រុកទេស ម្ចាស់ទឹកដី គឺជាជនជាតិមិលក្ខៈ ប៉ុន្តែដោយជនជាតិអរិយកៈជាជាតិដែលមានការចេះដឹងច្រើន ហើយខ្លាំងពូកែ ដែលមានដើមកំណើតខាងជើងភ្នំហិមាល័យ (ហេមពាន=ព្រៃភ្នំសម្បូរដោយទឹកសន្សើម) បាននាំគ្នាឆ្លងភ្នំហិមាល័យចុះមកខាងត្បូងបន្តិចម្ដងៗ ហើយទន្ទ្រានរុកកនដេញជនជាតិមិលក្ខៈជាម្ចាស់ស្រុកឲ្យថយចុះទៅកាន់ដែនដីខាងត្បូង ហើយជនជាតិអរិយកៈក៏តាំងខ្លួនជាម្ចាស់ស្រុកទឹកដីនៃជម្ពូទ្វីបនោះរហូតមក ។

ដូច្នេះ ជនជាតិអរិយកៈ ដែលនៅក្នុងប្រទេសឥណ្ឌៀ ប៉ែកខាងជើង មិនមែនជាម្ចាស់ដើមនៃជម្ពូទ្វីបនោះទេ ក៏ប៉ុន្តែជាជនជាតិដែល

www.budinst.gov.kh www.elibraryofcambodia.org

ខ្លាំងពូកែ មានសមត្ថភាពយ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងប្រទេស ក្នុងសម័យនោះ ។

## ដែនដីនិងប្រជាជនឥណ្ឌៀ នេប៉ាល់ក្នុងសម័យពុទ្ធកាល

ការវិវត្តន៍ប្រែប្រួលរបស់លោក, មនុស្សជាតិ និងសង្គមមនុស្សតែងតែបន្តសកម្មភាពទៅជាដរាប ។ ជនជាតិអរិយកៈ ដែលធ្លាប់តែមានការចេះដឹងខ្លាំងពូកែមកហើយនោះ ក៏រឹតតែចេះដឹងខ្លាំងពូកែឡើងជាលំដាប់ ។ នៅសម័យពុទ្ធកាលប្រទេសឥណ្ឌៀ-នេប៉ាល់ចែកចេញជាពីរបំណែកធំ ៗ គឺ៖

១.— ប៉ែកខាងជើងហៅថា អារ្យាវត៌ គឺចំពូលដែនដីជម្ពូទ្វីប ស្ថិតនៅកណ្តាលពីភ្នំ ហិមាល័យ ទៅភ្នំ វិន្ធ្យា ដែលគេហៅសព្វថ្ងៃថា ហិណ្ឌូស្តង់ ( Hindustan ) ។

២ — ប៉ែកខាងត្បូង ហៅថា ទក្ខិណាបថ ដែលជាដែនដីទំនាប មានជនជាតិមិលក្ខៈ នៅអាស្រ័យ ឬក៏ហៅថា ដែនដីដេកាង់ ( Dékan ) ។ នៅសម័យពុទ្ធកាល មានរឿងរ៉ាវនិយាយតាក់តែងដល់តែត្រឹមដែនដីឥណ្ឌៀប៉ែកខាងជើងនិងនេប៉ាល់ប៉ុណ្ណោះ ឯដែនដីប៉ែកខាងត្បូងពុំសូវមានរឿងរ៉ាវអ្វីតាក់តែងដល់ទេ ទាំងព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ពុំសូវដែលយាងមកកាន់ដែនដីខាងត្បូងនេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងសម័យនោះ ឥណ្ឌា (ប៉ែកខាងជើង) ជាប្រទេសរុងរឿងជាងគេ ចំពោះប្រទេសដូចគ្នា នៅក្នុងបុរាណសម័យ ៗ ក្នុងគម្ពីរវិន័យបិដកមហាវគ្គត្រង់បាលីចម្មក្ខន្ធក លោកកំណត់ព្រំដែន នៃមជ្ឈិមជនបទ ឬជម្ពូទ្វីបដូចតទៅ ៖

១ – ទិសបូព៌ា រាប់ពីមហាសាលនគរចូលមក,

២ – អាគ្នេយ៍ រាប់ពីស្ទឹងសលវតីចូលមក,

៣ – ទក្សិណ រាប់ពីស្ទឹងសេតកណ្ណិកនិគមចូលមក,

៤ – បស្ចិម រាប់ពីថូនគ្រាមចូលមក,

៥ – ឧត្តរ រាប់ពីភ្នំឧសិរធជៈចូលមក,

ដែនដីខាងក្នុងនៃព្រំទាំង៥មាននេះ គឺជាដែនដី ជម្ពូទ្វីប ៗ នៅក្នុងជម្ពូទ្វីបនេះ មានអាណាចក្ររដ្ឋធំៗ ឬហៅថាមហាជនបទ ចំនួន ១៦ ដែលមាននៅក្នុងគម្ពីរ អង្គុត្តរនិកាយតិកនិបាត ត្រង់ឧបោសថសូត្រ ៗ រដ្ឋនិងរាជធានីទាំងនោះ មានដូចតទៅ ៖

| | | |
|---|---|---|
| ១– អង្គរដ្ឋ (ដែនអង្គៈ) | រាជធានីឈ្មោះ | ចម្ប៉ា |
| ២– មគធរដ្ឋ | រាជធានីឈ្មោះ | រាជគ្រឹះ |
| ៣– កាសី | " | ពារាណសី |
| ៤– កោសល | " | សាវត្ថី |

៥– វជ្ជី រាជធានីឈ្មោះ វេសាលី

៦– មល្លៈ " កុសាវតី

(មល្លៈនេះក្រោយមកចែកជា ២ គឺៈ កុសិនារា និងបាវា)

៧– ចេតី រាជធានីឈ្មោះ សោត្ថិវតី

៨– វង្ស " កោសម្ពី

៩– កុរុ " ឥន្ទបត្ត

១០– បញ្ចាល " កម្ពិលៈ

១១– មច្ឆៈ " សាគលៈ

១២– សុរសេន " មធុរា

១៣– អស្សកៈ " បោតលិ

១៤– អវន្តី " ឧជ្ជេនី

១៥– គន្ធារៈ " តក្កសីលា

១៦– កម្ពោជៈ " ទ្វារកៈ

វង្សទាំង ១៦ នេះ ជាវង្សធំ ១ មានឥទ្ធានុភាពច្រើន ហើយមានវង្សតូច ចំនួន ៥ ទៀត គឺៈ

១៧– សក្កៈ រាជធានីឈ្មោះ កបិលពស្តុ

១៨– កោលិយៈ " រាជគ្រាម និង ទេវទហៈ

www.budinst.gov.kh www.elibraryofcambodia.org

១៩ ភគ្គៈ  រាជធានីឈ្មោះ  សុំសុមារគីរៈ

២០– វិទេហៈ  ,,  មិថិលា

២១– អង្គុត្តកបៈ  ,,  អាបណៈ ។

រដ្ឋទាំង ៤ នេះ ជារដ្ឋតូចៗ ចំណុះរដ្ឋឯទៀតៗ ហើយរដ្ឋខ្លះមានមហាក្សត្រសោយរាជ្យ រដ្ឋខ្លះគ្រាន់តែឈ្មោះត្រកូលធំៗ ប៉ុណ្ណោះ ។

នៅសម័យនោះ មានរដ្ឋពីរធំៗ ដែលមានឥទ្ធានុភាពខ្លាំងគឺ ៖

១– មគធរដ្ឋ  ព្រះរាជានាម  ពិម្ពិសារ,  អជាតសត្រូវ

២– កោសលរដ្ឋ  ,,  បសេនទិ

រដ្ឋទាំងពីរនេះ  កាលពីដើមមានឫទ្ធានុភាពស្មើគ្នា  លុះក្រោយមក មគធរដ្ឋ មានជ័យជំនះលើកោសលរដ្ឋវិញ ។

រដ្ឋទាំង ២១ នេះ មានរបៀបគ្រប់គ្រងជារាជាធិបតេយ្យខ្លះ, ជាឯកាធិបតេយ្យខ្លះ ។ រដ្ឋខ្លះដូចជាវជ្ជីរដ្ឋ មានរបៀបគ្រប់គ្រងថ្មីៗ គឺគ្មានមហាក្សត្រអង្គណាជាធំទេ  តែមានសភាសម្រាប់ប្រជុំធ្វើការងារ  ប៉ុន្តែប្រជារាស្ត្រក៏គ្មានអំណាចអ្វី  ទៅកាន់ការរដ្ឋដែរ  មានតែពួកក្សត្រលិច្ឆវីនិងវិទេហៈប៉ុណ្ណោះ ដែលអាចចូលទៅកាន់សភាបាន ។ លទ្ធិបែបនេះ ហៅថា ខត្តិយាធិបតេយ្យ គឺមានពួកក្សត្រជាធំ ។ រដ្ឋទាំងអស់ខាងលើនេះ កាលព្រះពុទ្ធទ្រង់គង់មាននៅឡើយ  ព្រះអង្គធ្លាប់ទៅគង់ចាំវស្សាក្នុង

www.budinst.gov.kh www.elibraryofcambodia.org

កន្លែងខ្លះច្រើនសោភ កន្លែងខ្លះតិច ហើយកន្លែងខ្លះគ្រាន់តែដែលយ៉ាងទៅតែប៉ុណ្ណោះ ។

ប្រជាជនឥណ្ឌានៅមុននិងក្នុងសម័យពុទ្ធកាល ព្រមទាំងសម័យក្រោយមកទៀត ជាជនជាតិដែលពោរពេញទៅដោយចិត្តមានៈប្រកាន់ជាតិប្រកាន់ត្រកូលយ៉ាងខ្លាំង ហើយគេចែកមនុស្សជា ៤ វណ្ណៈគឺ៖

១ – វណ្ណៈព្រាហ្មណ៍ គេជឿថា ជនជាតិដែលកើតមកពីព្រះឱស្ឋព្រះព្រហ្ម ។ វណ្ណៈនេះមានមុខការខាងបង្ហាត់បង្រៀននិងធ្វើពិធីផ្សេងៗក្នុងសាសនា ហើយអាចសិក្សាគម្ពីរវេទជាដើមបាន ។

២ – វណ្ណៈក្សត្រ គេជឿថា ជាអ្នកកើតពីព្រះហស្ត (ដៃ) នៃព្រហ្ម ។ វណ្ណៈនេះ មានការៈខាងគ្រប់គ្រងប្រទេសរៀនសូត្រវិជ្ជាចំបាំងការពារប្រទេស ។

៣ – វណ្ណៈវេស្សៈ គេជឿថា ជាអ្នកកើតពីផ្ទៃព្រះព្រហ្ម ជាជនជាតិដែលមានមុខងារខាងធ្វើរបរស្រែចំការ, ធ្វើជំនួញ ។

៤ – វណ្ណៈសូទ្រ គេជឿថាជាអ្នកកើតពីជើងព្រះព្រហ្ម ។ វណ្ណៈនេះមានមុខការខាងធ្វើការស៊ីឈ្នួលគេដោយកម្លាំងកាយ ។

វណ្ណៈព្រាហ្មណ៍និងក្សត្រជាវណ្ណៈខ្ពង់ខ្ពស់ ឯវណ្ណៈវេស្សៈនិងសូទ្រជាវណ្ណៈថោកទាប ហើយវណ្ណៈទាំង៤នេះស្ថិតនៅដាច់ស្រឡះពីគ្នា ផុត

www.budinst.gov.kh www.elibraryofcambodia.org

ចូលសម្ពន្ធចងមេត្រីប្ដូរម្រះសដោយទឹកខ្វែង, និងចំណីអាហារជាមួយគ្នាឡើយ ។

មានវង្ស១ទៀតគឺសាក្យវង្ស (វង្សរបស់ព្រះពុទ្ធ) ជាជនជាតិប្រកាន់ជាតិសាសន៍ខ្លាំងណាស់ គេផ្សំផ្គុំតែជាតិវង្សគេជាប្ដីប្រពន្ធជាដរាប ឯវង្សក្រៅពីនេះ សូម្បីជាតិក្សត្រក៏គេឥតឲ្យជាប់ឈាមដែរ ។ ការប្រកាន់ជាតិត្រកូលនេះហើយ ជាបុព្វហេតុនាំឲ្យមានការវិនាស ១ យ៉ាងធំ គឺនៅពេលមុនព្រះពុទ្ធបរិនិព្វាន ២ ឆ្នាំ ព្រះបាទវិឌូឌភៈបានធ្វើចម្បាំងសម្លាប់ពួកសាក្យវង្សពេលស្ទើរតែផុតពូជអស់ ។

ជនជាតិឥណ្ឌា-នេប៉ាល់ជាអ្នកសាសនា ។ ក្នុងសម័យមុនពុទ្ធកាល ជនជាតិឥណ្ឌាជាច្រើន ទោះជាមានទ្រព្យច្រើនក៏ដោយ បានលះបង់ទ្រព្យទាំងនោះ ហើយចេញទៅសាងគេចជាអ្នកបួសតាមគណាចារ្យ ខ្លះមេលទ្ធិធំៗក៏មាន ទៅស្វែងរកធម៌ហើយបង្កើតជាទ្រឹស្តីតាំងខ្លួនជាមេសាសនា មេលទ្ធិថ្មីទៀតក៏មាន ។ នៅក្នុងត្រកូលនីមួយៗតែងឲ្យមនុស្សម្នាក់ចេញទៅបួស ដើម្បីបំពេញករណីយកិច្ចសំរាប់គោត្ររបស់គេនៅក្នុងពិធីបួងសួងផ្សេងៗ ។ នៅប្រទេសឥណ្ឌាមានគោត្រជាច្រើន ដូចជាគោតមគោត្រ, វសិដ្ឋគោត្រជាដើម ។ ពាក្យថា គោត្រនេះ ប្រែថា ក្រោលគោ សំដៅយកខ្សែស្រឡាយដែលមានក្រោលគោជាមួយគ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសម័យពុទ្ធកាល ពេលដែលព្រះពុទ្ធទើបនឹងប្រសូតឡើង មានកាលទេវិលតាបសជាជីតូននៃព្រះបាទសុទ្ធោទនៈ បានចូលមកសុំជួបនឹងព្រះអង្គសិទ្ធត្ថកុមារ ហើយព្រះកុមារបានឡើងទៅប្រតិស្ឋានលើសិរសាព្រះតាបស ។ ពេលព្រះសិទ្ធត្ថចេញសាងបព្វជ្ជា ព្រះអង្គទ្រង់បានចូលទៅសិក្សាវិជ្ជាផ្សេងៗ ជាមួយឧទកតាបស និងអាឡារតាបសទាល់តែចេះហើយបានសួរដញ្ញឹកតាបសទាំងពីរ ទាល់តែតាបសទាល់ឆ្លើយមិនរួច ។

នៅពេលព្រះអង្គបានត្រាស់ដឹងហើយទ្រង់ទៅប្រោសជដិលទាំង ៣ គឺឧរុវេលកស្សប១, នទីកស្សប១, គយាកស្សប១, ជាបងប្អូនបង្កើត ហើយដែលបានចេញសាងផ្នួស តាមលទ្ធិសាសនាព្រាហ្មណ៍ ធ្វើពិធីបូជាយញ្ញនៅក្នុងព្រៃ ព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ធ្វើបាដិហារផ្សេង ៗ ហើយប្រោសជដិលទាំង៣បាន ។ ពេលដែលពុទ្ធសាសនាបានរុងរឿងផ្សាយទៅសព្វទិសទីហើយ ក៏នៅតែមានលទ្ធិសាសនាផ្សេងៗមានពួកអចេលកជាដើម បាននៅប្រកាន់តាមលទ្ធិរបស់ខ្លួន ហើយធ្វើសកម្មប្រឆាំងព្រះពុទ្ធសាសនាទៀតផង ។

ពេលព្រះពុទ្ធជាម្ចាស់បរិនិព្វានហើយលទ្ធិសាសនាផ្សេង ៗ ក៏កើតមានឡើងជាច្រើនទៀត ឧទាហរណ៍ដូចជាមហាវីរៈដែលជាមេសាសនា

www.budinst.gov.kh www.elibraryofcambodia.org

ដេន ហើយដែលបានត្រាស់ដឹងនិងខុសគ្នាច្បាប់ផ្សេងៗប្រហែលនិងព្រះពុទ្ធដែរ ។ ដទៃពីនេះមានសាសនាឯទៀតៗជាច្រើន ដូចជាសាសនាមហាម៉ាត់ជាដើម ដែលបានធ្វើឲ្យពុទ្ធបូជនីយដ្ឋានជាច្រើនរលាយបាត់បង់ ។

រួមសេចក្តីមក ជនជាតិឥណ្ឌាជាអ្នកនិយមសាសនា ហើយក្នុងប្រទេសនេះមានភាសា, ជនជាតិ, ត្រកូលនិងសាសនាច្រើនណាស់ ភាគច្រើនគឺសាសនាដែលពាក់ព័ន្ធទៅនឹងលទ្ធិព្រាហ្មណ៍ ។ សូម្បីសាវ័កឬបរិស័ទរបស់ព្រះពុទ្ធក៏មាននិកាយច្រើនដែរ ដោយមានទិដ្ឋិមានៈនិងគោលគំនិតផ្សេងៗគ្នា ហើយក៏បាក់បែកគ្នាទៅ ក្នុងកាលព្រះពុទ្ធបរិនិព្វានទៅបាន៧ថ្ងៃ ក៏មានរឿងហេតុឡើងពីសុភទ្ទភិក្ខុដែលពោលថា "ព្រះពុទ្ធបរិនិព្វានទៅហើយ យើងអាចប្រព្រឹត្តយ៉ាងណាក៏បាន" ។ រឿងនេះហើយដែលជាហេតុនាំឲ្យកើតសង្គាយនាទី១ឡើង ដើម្បីជម្រះរឿងហេតុទាំងនោះ ។ ពេលធ្វើសង្គាយនារួចហើយ ដោយមានព្រះមហាថេរធំៗជាព្រះអរហន្តនិងជាសិស្សផ្ទាល់ របស់ព្រះពុទ្ធជាម្ចាស់ផង ធ្វើជាអ្នករៀបរៀងផ្ទៀងផ្ទាត់លើកដាក់ជាកថាខណ្ឌដោយត្រឹមត្រូវហើយ ក៏នៅតែមានរឿងហេតុទៀត ដោយមានមហាថេរជាព្រះអរហន្តខ្លះ ដែលពុំបានមកចូលក្នុងពិធីសង្គាយនាទី ១ នោះបានយល់ថា អ្នកណា

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើសង្គាយនាលើកយកធម៌វិន័យបែបណា ក៏ធ្វើយ៉ាងនោះចុះ ចំណែកខ្ញុំដែលពុំបានចូលធ្វើសង្គាយនា ហើយដែលបានចេះដឹងយល់យ៉ាងណា ក៏ប្រព្រឹត្តយ៉ាងនោះទៅ ទោះខុសពីរបៀបក្នុងសង្គាយនាក៏ដោយ ។

អាស្រ័យហេតុនេះហើយ ទើបយើងអាចសន្និដ្ឋានបានថា ជនជាតិឥណ្ឌាជាអ្នកមានទិដ្ឋិមានះ ហើយប្រកាន់តាមបែបបទទំនៀមសាសនារបស់ខ្លួនខ្ជាប់ណាស់ មិនសូវចុះសម្រុងគ្នាឡើយ ។ ការប្រកាន់នេះហើយជាបុព្វហេតុនាំឱ្យឥណ្ឌាបែកបាក់គ្នារហូតទល់ធ្វើចម្បាំងជាមួយគ្នាពីរឿងសាសនា ហើយជាហេតុឱ្យឥណ្ឌាគ្មានឯកភាព ។ តាំងពីបុរាណកាលមក យើងឃើញប្រទេសនិងប្រជាជនឥណ្ឌាមានឯកភាពតែ១ពេល គឺពេលដែលព្រះបាទធម្មាសោកមហារាជ ឡើងសោយរាជ្យនៅសម័យក្រោយពុទ្ធកាល តែពេលដែលព្រះមហារាជាធិរាជអង្គនេះ ទ្រង់សុគតទៅ ឥណ្ឌាក៏បែកបាក់គ្នាទៀត ព្រោះរឿងលទ្ធិសាសនានិងភាសា ។

## ជាតិភូមិ និង ព្រះវង្ស
## នៃព្រះសិទ្ធត្ថ (ព្រះពុទ្ធ)

ការបង្ហាញរួមមកនេះ បាននាំឱ្យពុទ្ធបរិស័ទយល់បានខ្លះអំពីប្រវត្តិសាស្ត្រឥណ្ឌា-នេប៉ាល់ក្នុងបុរាណសម័យ និងសម័យពុទ្ធកាល ព្រមទាំងរដ្ឋ, រាជធានី, របៀបគ្រប់គ្រងប្រទេស និងការបែកបាក់, ការផ្លាស់ប្តូរទី

www.budinst.gov.kh www.elibraryofcambodia.org

កន្លែង, ឈ្មោះរាជធានីក្នុងអតីតសម័យ ហើយនិងវណ្ណៈ, ការប្រកាន់លទ្ធិសាសនា, ការនិយមសាសនារបស់ជនជាតិឥណ្ឌៀ-នេប៉ាល់ដែលជាកន្លែងដើមនៃព្រះពុទ្ធជាម្ចាស់រួចហើយ តទៅខ្ញុំនឹងបង្ហាញនូវជាតិភូមិព្រមទាំងព្រះរាជវង្សរបស់ព្រះពុទ្ធជាម្ចាស់ តាំងពីអតីតសម័យ រហូតដល់បច្ចុប្បន្នសម័យ និងការរកឃើញតាមវិធីស្រាវជ្រាវរបស់អ្នកប្រាជ្ញនានាទៅទៀត ។

## ជាតិភូមិនៃព្រះសិទ្ធត្ថសម្មាសម្ពុទ្ធ

កាលណាយើងឮពាក្យថា សិទ្ធត្ថ, សម្មាសម្ពុទ្ធ, ព្រះពុទ្ធ, ព្រះសមណគោតមជាដើមនេះ យើងនឹងអាចយល់បានថា ៖

សិទ្ធត្ថ គឺជាព្រះបរមនាមដើមនៃព្រះពុទ្ធអង្គ ដែលព្រះវររាជបិតា និងព្រាហ្មណ៍បុរោហិតបានថ្វាយ តាំងពីពេលប្រសូតមកម្ល៉េះ ។

សម្មាសម្ពុទ្ធ ឬ ព្រះពុទ្ធ គឺជាព្រះបរមនាមនៃព្រះសិទ្ធត្ថ ដែលបានត្រាស់ដឹងនូវព្រះធម៌ទាំងពួង ហើយដែលមនុស្សនិងទេវតាបានថ្វាយឡើង ដើម្បីឲ្យសមតាមព្រះលក្ខណៈសម្បត្តិ និងគុណសម្បត្តិរបស់ព្រះអង្គ ។

ព្រះសមណៈគោតម គឺជាបរមនាម១បែបដែលពួកព្រាហ្មណ៍តែងហៅចំពោះព្រះអង្គតាមលទ្ធិព្រាហ្មណ៍ ព្រោះព្រះអង្គជាអ្នកបួស

www.budinst.gov.kh www.elibraryofcambodia.org

របស់គោតមគោត្រ គឺគោត្រឈ្មោះគោតម (ព្រះអាទិត្យ) ។ ដូច្នេះព្រះនាមទាំងអស់នេះ គឺជាព្រះនាមរបស់ព្រះពុទ្ធបរមគ្រូតែមួយអង្គប៉ុណ្ណោះ ។

ក្នុងគម្ពីរបាលី យើងតែងឮជាញឹកនូវព្រះបន្ទូលរបស់ព្រះពុទ្ធជាម្ចាស់ ដែលតែងតែត្រាស់ថា " ខត្តិយោ ជាតិយា គោតមោ គោត្តេន... សាក្យបុត្តោ សាក្យកុលា បព្វជិតោ" ប្រែថា តថាគតជាក្សត្រដោយជាតិ, ជាគោតម ដោយគោត្រ ... ជាសាក្យបុត្រដោយត្រកូល ចេញពីសាក្យត្រកូលហើយបួស ។ ដូច្នេះយើងដឹងថាព្រះអង្គជាក្សត្រ, ជាគោតមគោត្រគឺត្រកូលដែលមានះក្រោលគោធម្មតាហើយជាអ្នកបួស ប៉ុន្តែយើងចង់ដឹងថាសាក្យត្រកូលជាអ្វី? មានហេតុយ៉ាងណាខ្លះ ? នៅឯណា ? ។

សាក្យវង្សឬសក្ក ជាឈ្មោះនៃវង្សត្រកូលព្រះសម្ពុទ្ធ ទីឯជាឈ្មោះនៃដែនដីមួយចំណែក ដែលមានរាជធានីឈ្មោះកបិលពស្តុ គឺសាក្យវង្សផ្នែកគោតមគោត្រ ។ ដល់ត្រង់នេះនាំឲ្យយើងសង្ស័យទៀតថា ក្រុងកបិលពស្តុ នៅឯណាសព្វថ្ងៃនេះ? មានអ្វីជាភស្តុតាង ។ ចំពោះប្រស្នានេះ យើងស្រាវជ្រាវរកហេតុការមកបង្ហាញដូចតទៅ ៖

ក្រុងកបិលពស្តុ រាជធានីរបស់សក្កជនបទ សាក្យវង្ស

www.budinst.gov.kh www.elibraryofcambodia.org

ផ្នែកគោតមគោត ។ ក្រុងនេះសព្វថ្ងៃនេះស្ថិតនៅក្នុងតម្បន់ ភូអ៊ីឡាក់ ( Bhuilak )ប្រទេសនេប៉ាល់ (ប្រទេសនេប៉ាល់នេះស្ថិតនៅខាងជើងប្រទេសឥណ្ឌា ជិតភ្នំហេមពាន្ត) ។ នៅព.ស. ២៤៤១ គ.ស. ១៨៩៧ មានអ្នកប្រាជ្ញម្នាក់ឈ្មោះ ខារល្បិលី បានជីករកឃើញទីបញ្ចុះព្រះបរមសារីរិកធាតុនៃព្រះពុទ្ធជាម្ចាស់ ដែលពួកសាក្យវង្សក្រុងកបិលពស្តុបានចំណែក១ ហើយយកទៅបញ្ចុះនៅទីនោះ មានចារឹកយនាមសាក្យរាជ ព្រះបាទសុទ្ធោទនៈពុទ្ធបិតា, ព្រះពុទ្ធនិងព្រះរាហុល ។ ទីដែលរកឃើញនេះសព្វថ្ងៃហៅថា " បិប្រវា (Piprava) ។

នៅខែធ្នូ ព.ស ២៤៣៩.គ.ស ១៨៩៥ (ប្រមាណជា ៦០ ឆ្នាំកន្លងមកនេះ) មានអ្នកប្រាជ្ញជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះបណ្ឌិតហ្វូហារ៉េ(Fuhrer) បានជីករកឃើញសិលាចារិក១នៅទីជិតភូមិតូច ១ ឈ្មោះភូមិបាធសំា (Padarsa) ។ សិលាចារិកនេះលិចកប់បាត់ទៅក្នុងដីប្រមាណជា ១០០០ ឆ្នាំហើយ តែតួអក្សរនៅច្បាស់ អាចឲ្យស្គាល់បានថាជាអក្សរសម័យអសោកមហារាជ (ធម្មាសោក) ។ សិលាចារិកនោះប្រាប់ថាទីនេះជាទីសួនលុម្ពិនី គឺកន្លែងដែលព្រះសិទ្ធត្ថទ្រង់ប្រសូត ។ ក្រោយពីរឆ្នាំមក គេក៏រកឃើញក្រុងកបិលពស្តុ ដូចនិយាយខាងដើមហើយ ។ ទីដែលរកឃើញសិលាចារិកទាំងពីរនេះឃើញមានចម្ងាយ ១២ គីឡូម៉ែត្រ

www.budinst.gov.kh www.elibraryofcambodia.org

ពីគ្នា ដូច្នេះ ក្រុងកបិលពស្តុនិងសួនលុម្ពិនី មានចម្ងាយ១២គីឡូម៉ែត្រពីគ្នា គឺសួនលុម្ពិនី នៅខាងកើតឆៀងខាងត្បូងនៃក្រុងកបិលពស្តុ ។

វិសួនលុម្ពិនីក្តី ក្រុងកបិលពស្តុក្តីជាស្ថានរុងរឿងពីក្នុងពុទ្ធសម័យ ក៏ប៉ុន្តែនៅបច្ចុប្បន្នសម័យនេះ បានប្រែទៅជាស្ថានទីគួរឲ្យសង្វេគ ។ កាលណាគេធ្វើដំណើរតាមរថភ្លើងពីកាល់គុត្តាកាត់តាមដែនដីបារិស្តង់ខាងកើតចូលទៅ ដារជលិង ដល់តំបន់តែរ៉ៃ (Terai) គេនឹងឃើញនៅជុំវិញអយស្ម័យយាន នូវភូមិលំនៅតូច ១ របស់អ្នកស្រុកប្រកបដោយកក់ប៉-ប៉ិច មានរនាស្មៅនិងឈើធំ ១ តិចតួច ពុំសូវមានមនុស្សម្នានៅច្រើនទេ ឯទីប្រជុំជនធំគ្មានសោះឡើយ ហើយជាកន្លែងកើតកេតគួរឲ្យខ្លាចយ៉ាងពន់ពេក ព្រោះជាដីវាំនាបក្បែរជើងភ្នំ ហើយមានសុទ្ធតែអ្នកក្រីក្រល្ហោមល្ហាមនៅតាស្រ័យ ។ គួរឲ្យសង្វេគយ៉ាងពន់ពេក កាលព្រះអង្គគង់នៅកន្លែងនេះ ប្រកបដោយសភាពរុងរឿងថ្កើងថ្កានណាស់ តែសព្វថ្ងៃជារហោស្ថានទៅវិញ ។ កាលកន្លងមកជាង ២.០១០ ឆ្នាំប៉ុណ្ណោះ ធម្មជាតិ, ស្ថានទីបានប្រែពីសភាពរុងរឿងទៅកាន់សភាពអន់ខ្សោយយ៉ាងខ្លាំង ស្ទើរតែអ្នកណាគ្មានស្គាល់ថាជាជាតិភូមិនៃព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងឡើយ ។ កន្លែងនេះហើយជាដែនសក្កៈ, ជាក្រុងកបិលពស្តុជាជាតិភូមិនៃព្រះពុទ្ធជាម្ចាស់ ប៉ុន្តែកាលវេលាកន្លងទៅទីក្រុងរុងរឿងក៏

www.budinst.gov.kh www.elibraryofcambodia.org

ធ្លាក់អន់ថយ ហើយគេបោះបង់ចោលរហូតទាល់សព្វថ្ងៃ ។ ដូច្នេះជាតិភូមិនៃព្រះសម្មាសម្ពុទ្ធ ដែលពីដើមយើងធ្លាប់ស្គាល់ថា នគរសក្កៈ, ក្រុងកបិលព័ស្តុនោះ សព្វថ្ងៃស្ថិតនៅក្នុងប្រទេសនេប៉ាល ដែលជាប្រទេស ១ តូចស្ថិតនៅខាងជើងប្រទេសឥណ្ឌា ជាប់នឹងជើងភ្នំហិមពាន ។ ប្រទេសនេះ មានព្រះមហាក្សត្រសោយរាជ្យទាល់សព្វថ្ងៃ មានទំហំដី ១៤០.០០០ គីឡូម៉ែត្រ [illegible], មានប្រជាជន ៨ លាននាក់ រាជធានីឈ្មោះកាត្មាន់ឌូ (Katmandou) មានភ្នំអេវឺរេសដែលមានកំពូលកំពស់ ៨.៨៤០ ម៉ែត្រ ជាពួកជួរភ្នំហេមពាន ផែកខាងកើត ។ ចំណែកខាងទីដែលព្រះអង្គបានត្រាស់, ទីសំដែងធម្មចក្ក ទីបរិនិព្វាន ស្ថិតនៅក្នុងប្រទេសឥណ្ឌាផ្នែកខាងជើង ជិតប្រទល់ដែននេប៉ាលនោះឯង ។

## ព្រះវង្សនៃព្រះសិទ្ធត្ថ (ព្រះសម្មាសម្ពុទ្ធ)
## និងប្រវត្តិដែនសក្កៈ សាក្យវង្ស

ការសិក្សាអំពីប្រវត្តិនៃក្រុងកបិលព័ស្តុ (កបិលវត្ថុបុរី) និងសួនលុម្ពិនី ទីដែលព្រះពុទ្ធអង្គទ្រង់ប្រសូតរួចហើយមកនេះនាំឲ្យយើងសង្ស័យពីរឿងព្រះវង្សនៃព្រះពុទ្ធអង្គ និងប្រវត្តិនៃដែនសក្កៈតទៅទៀត ។ ព្រះវង្សនិងដែនដីនេះ មានល្បីល្បាញណាស់ហើយពិតជាវង្សនិងដែនដីរបស់ព្រះពុទ្ធអង្គមែន បើមិនមែនទេ ពិតជាគ្មានឈ្មោះបោះសំឡេង

www.budinst.gov.kh www.elibraryofcambodia.org

ថែមទាំងគ្មានទៅក្នុងគម្ពីរដីកាណាឡើយ ។

តាមសេចក្តីក្នុងគម្ពីរសុមង្គលវិលាសិនី ដែលជាគម្ពីរខាងពួកទក្ខិណនិកាយ និពន្ធដោយព្រះពុទ្ធឃោសាចារ្យ មានសេចក្តីដំណាលថា ព្រះមហាក្សត្រដែលជាដើមសន្តតិវង្សនាមព្រះបាទ , មហាសម្មតៈ ហើយមានក្សត្រសោយរាជ្យតសន្តតិវង្សមកទៀត មានរាយនាមដូចតទៅៈ

| | | |
|---|---|---|
| ព្រះមហាសម្មតៈ | មានឱរសនាម | ព្រះរោជៈ |
| ព្រះរោជៈ | ,, | វររោជៈ |
| ព្រះវររោជៈ | ,, | កល្យាណៈ |
| ព្រះកល្យាណៈ | ,, | វរកល្យាណៈ |
| ព្រះវរកល្យាណៈ | ,, | មន្ធាតា |
| ព្រះមន្ធាតា | ,, | វរមន្ធាតា |
| ព្រះវរមន្ធាតា | ,, | ឧបោសថ |
| ព្រះឧបោសថ | ,, | ចរៈ |
| ព្រះចរៈ | ,, | ឧបចរៈ |
| ព្រះឧបចរៈ | ,, | មហាទេវៈ |

ព្រះមហាក្សត្រដែលសោយរាជ្យតមកទៀតមានចំនួនដល់ទៅ ៨៤.០០០អង្គ ទើបដល់មកព្រះបាទឱក្កាករាជជាបឋមក្សត្រនៃសាក្យវង្ស ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទឧក្កាកករាជមានព្រះជាយា ៥ អង្គគឺ ហត្ថា១, ចិត្តា១, ជន្តុ១, ជាលិនី១ និងវិសាខា១ ។ ព្រះនាងហត្ថា ជាជាយាអង្គធំ មាន រាជបុត្រ៤អង្គគឺ ឧក្កាកមុខ១, ករកណ្ឌ១, ហត្ថិនិក១, សិនិបុរៈ១, មានរាជធីតា៥អង្គគឺ បិយា១, សុប្បិយា១, អានន្ទា១, វិជិតា១, វិជិតសេនា១ ព្រះនាងបិយាជាច្បងលើរាជបុត្រធីតាទាំងអស់ ។ កាល ព្រះនាងហត្ថាទ្រង់សោយព្រះពិរាល័យទៅ ព្រះរាជាទ្រង់លើកព្រះនាង ខត្តិយានី១អង្គដែលមានព្រះរូបល្អកាន់ជាមហេសី ។ ព្រះខត្តិយានីអង្គ ថ្មីនេះទ្រង់មានព្រះរាជឱរស១អង្គនាមជន្តុ ។ កាលព្រះជន្មបាន៥ថ្ងៃ ព្រះមាតាក៏នាំទៅថ្វាយបង្គំព្រះឧក្កាករាជជាបិតា ៗ ទ្រង់ព្រះសព្វព្រះទ័យ ណាស់ ទ្រង់ក៏ប្រទានពរថា ឱ្យព្រះនាងសុំពរអ្វី១បានតាមប្រាថ្នា ព្រះនាងក៏សុំរាជសម្បត្តិថ្វាយរាជបុត្រ ។ ដំបូងព្រះរាជាមិនព្រមទេ តែដោយព្រះនាងអង្វរច្រើនដងពេកព្រះរាជាក៏ព្រម ហើយត្រាស់ហៅរាជ បុត្រាបុត្រីទាំង៩អង្គមកថ្វាយខ្លួនរៀបហេតុដោយសព្វគ្រប់ ហើយទ្រង់ បានប្រទានសេះដំរី, ពលជាច្រើនដល់រាជបុត្រាបុត្រីទាំង៩អង្គ ហើយឱ្យ ចេញពីព្រះនគរទៅចុះ ទំរាំពេលណាព្រះអង្គអស់ព្រះជន្ម សឹមវិលត្រ ឡប់វិញ ។ ព្រះរាជបុត្រាបុត្រីទាំង៩អង្គបានចេញពីព្រះនគរ ឯប្រ ជាជនក៏នាំគ្នាចេញតាមជាច្រើនមុឺនសែននាក់ ។ កាលយានកាត់ភ្នំ

www.budinst.gov.kh www.elibraryofcambodia.org

ហិមាល័យដល់ព្រៃដើម សក្កាៈ ក៏បានជួបនឹងតាបស១អង្គនាម
កាបិល ដែលជាគ្រូអង្គពោធិសត្វ ហើយយាងចេញសាងព្រះផ្នួស
តាំងអាស្រមបទនៅទីនោះ ។ កាលជ្រាបថាក្សត្រាក្សត្រីយាងរកទី
សាងនគរ ព្រះកបិលតាបសក៏បានថ្វាយទីអាស្រមបទ ដល់ក្សត្រា
ក្សត្រី ដើម្បីសាងព្រះនគរ ព្រោះលោកយល់ថា ជាទីជ័យភូមិ
ដោយបានឃើញសត្វធំដេញសត្វតូចមកដល់ទីនេះ សត្វធំក៏អស់អំណាច
ទៅវិញ ។ ព្រះក្សត្រាក្សត្រីទ្រង់ព្រះសណ្ដាប់ហើយក៏សាងក្រុងថ្មីត្រង់អា
ស្រមបទតាបសនោះ ហើយដាក់នាមថា កាបិលវត្ថុបុរី ប្រែថាក្រុង
ជាទ្រព្យរបស់កបិលតាបស ។

កាលក្សត្រាក្សត្រីបានសាងព្រះនគរនៅត្រង់ព្រៃដើមសក្កៈ នាអា
ស្រមតាបសកបិលៈរួចហើយ ក្សត្រាទាំង៤អង្គក៏រៀបអភិសេកជាមួយ
ក្សត្រីទាំង៤អង្គជាអនុជតាមលំដាប់ ដោយបានដំកល់ព្រះនាងបិយាជា
ក្សត្រីរៀមច្បងទុកក្នុងឋានៈជាព្រះមាតា ។ ការផ្សំផ្គុំក្សត្រាក្សត្រីជាបង
ប្អូនបង្កើតនឹងគ្នាយ៉ាងនេះ គឺដើម្បីរក្សាឈាមជ័ររបស់ព្រះវង្សព្រះអង្គឲ្យ
បរិសុទ្ធឥតឲ្យលាយឡំឈាមជ័រជាមួយជាតិវង្សដទៃ ។ កាលអភិសេក
រួចហើយ ក៏តាំងនាមរាជវង្សរបស់ទ្រង់ថាសក្ការវង្ស ឬ សាក្យវង្ស
ដើម្បីឲ្យស្របតាមស្ថានទីដែលទ្រង់បានសាងព្រះនគរនៅត្រង់ព្រៃនៃដើម

www.budinst.gov.kh www.elibraryofcambodia.org

សក្កៈនោះឯង ។ តមកពាក្យថា សក្ក ឬសាក្យនេះ ក៏បានទៅជាឈ្មោះដែន (រដ្ឋ) ផង ជាឈ្មោះពង្សផង ។ សាក្យវង្សពេលនោះមានតែ១គឺសាក្យវង្សនៃក្សត្រាក្សត្រីទាំង៨អង្គនោះឯង ។

ចំណែកខាងព្រះនាង បិយា ជាព្រះមាតាព្រះរៀម តក្នុងកាលខាងក្រោយបន្តិចមក ក៏កើតកេតឃ្លង់ពេញព្រះកាយ ។ ព្រះអនុជបានធ្វើអាស្រមមួយនៅក្នុងព្រៃ ដើម្បីថ្វាយឲ្យគង់នៅតែម្នាក់ឯងឆ្ងាយពីក្រុងកបិលពស្តុ ។ កាលណោះមានព្រះរាជា១អង្គសោយរាជសម្បត្តិនៅនគរពារាណសី ព្រះនាមរាមៈ ក៏ទ្រង់កើតកេតឃ្លង់ដែរ ។ ព្រះអង្គបានដាក់រាជ្យថ្វាយទៅរាជឱរសច្បង ហើយយាងចេញទៅគង់នៅក្នុងព្រៃដែរទ្រង់សោយផ្លែឈើជាព្រះក្រយាយូរៗទៅ ក៏ប៉ះលើផ្លែឈើដែលជាថ្នាំរម្ងាប់កេតឃ្លង់ទ្រង់ក៏បានជាសះស្បើយព្រះកេតឃ្លង់មានព្រះកាយស្អាតបាតដូចដើមហើយក៏យាងទៅទៀតបានជួបនឹងព្រះនាងបិយានៅត្រង់អាស្រមព្រះនាង ។ កាលជ្រាបថាព្រះនាងជាខត្តិយានីដែរ ទ្រង់ក៏ជួយព្យាបាលព្រះកេតឃ្លង់របស់ព្រះនាងរហូតទល់ជាស្បើយ ហើយក៏នៅរួមរក្សជាគូស្វាមីភរិយា ទើបស្តេចនាំគ្នាស្វែងរកទីសាងព្រះនគរថ្មី ១ ទៀត ទ្រង់យាងតាមស្នាមជើងខ្លារហូតទល់ដែននៃព្រៃកោលៈ កសាងក្រុងនៅទីនោះ ហើយដាក់នាមថា កោល—នគរ ។ លុះសាងក្រុងថ្មីនេះហើយ ក៏តាំងព្រះវង្សថ្មី ១ ទៀតដោយ

www.budinst.gov.kh www.elibraryofcambodia.org

យកដើមកោលៈជាតំណាង ហើយដាក់នាមត្រកូលវង្សថ្មីនេះថា កោលិយវង្ស ។ ចំណែកក្រុងនេះមានឈ្មោះថារាមគ្រាម ។ ក្រុងនេះសព្វថ្ងៃនៅតំបន់ ១ ហៅថា ដេអូគោរាល៍ ។ ប៉ុន្តែអ្នកប្រាជ្ញខ្លះ បានសរសេរទុកថាកផជាតិកោលិយ ឈ្មោះទេវទហៈ ឬ រាមគ្រាម ។ លោករីស ដេវីឌស៍ សរសេរថា ទេវទហៈ និង រាមគ្រាម ជាកផជាតិដូចគ្នា គឺជាកផជាតិរបស់ ផែនកោលិយៈ ដូចជាក់ និង កុសិនារា ជាកផជាតិ របស់ផែនមល្លៈ ។ ឯកោលិយៈ ក៏ចែកជា ២ ពួកទៀត គឺ កោលិយៈនៃទេវទហៈ និងកោលិយនៃរាមគ្រាម ។ ដូច្នេះយើងអាចប៉ូលចិត្តថា ទេវទហមានពីរគឺ ទេវទហខាងសាក្យវង្ស ១ ទេវទហខាងកោលិយៈវង្ស ១ ។ ព្រះនាងសិរីមហាមាយា ជាពុទ្ធមាតាក្ដី ព្រះនាងយសោធរាពិម្ពាព្រះមហេសីនៃព្រះសិទ្ធត្ថក្ដី ជាក្សត្រីនៃទេវទហ សាក្យវង្ស មិនមែនក្សត្រី នៃទេវទហកោលិយវង្សទេ ។

ក្នុងគម្ពីរបាលីយើងដឹងថា ផែនសក្កចែកចេញជា៣នគរគឺ កបិលព័ស្តុ១, វេធញ្ញា១, សាលាវតី១; មាននិគម៤ គឺ ទេវទហនិគម ១ មេទឡុបនិគម១, ខោមទុស្សនិគម១ និងសក្ករនិគម១; មានគ្រាម១គឺសារគ្រាម ។ នគរចែកជានិគម (នគរ=ខេត្ត) និគមស្រុក ចែកជាគ្រាម (តំបន់) ប៉ុន្តែគ្រាមខ្លះបានរីកចំរើនឡើងយូរទៅក៏ក្លាយជាទីប្រជុំធំ រហូត

www.budinst.gov.kh www.elibraryofcambodia.org

បានជារាជធានី ដូចរាមគ្រាម ជាតំបន់ទេ តែក្លាយជារាជធានីនៃកោលិយវង្ស តែនៅហៅថាគ្រាមដដែល ។ ដូច្នេះ ទេវទហខាងសាក្យវង្ស កាលដើមប្រហែលជាគ្រាមដែរ តែក្រោយមកក៏ក្លាយជារាជធានីនៃពួកសាក្យវង្ស ខាងទេវទហៈនោះវិញ ។

បញ្ហាពិសេស .- ការសិក្សារួចមកអំពីប្រវត្តិនៃសាក្យវង្ស និងកោលិយវង្សបាននាំឲ្យយើងឃើញថា វង្សទាំងពីរនេះមានការទាក់ទងសម្ពន្ធចូលគ្នាជាខ្សែស្រឡាយយ៉ាងជិតស្និទ្ធតាំងពីដើមមក ប៉ុន្តែមានបញ្ហាពិសេសខ្លះ ដែលគួរពិចារណាគឺ ៖

ក)- ការប្រទានពររបស់ព្រះបាទឧក្កាករាជ និងការត្រាស់បញ្ជាឲ្យរាជបុត្រាបុត្រី ចេញទៅនៅព្រៃដោយមានចែកដំរីសេះពលនិកាយ ជាច្រើន ។ រឿងនេះ យើងជួបប្រទះជាច្រើនក្នុងគម្ពីរពុទ្ធសាសនា, ជាតកនានា គឺព្រះរាជាច្រើនតែក្លាត់ព្រះទុស្សប្រទានពរយ៉ាងនេះ ហើយបញ្ជាឲ្យព្រះរាជបុត្រាបុត្រីច្បងៗ ឲ្យចេញទៅនៅព្រៃ ។ តាមពិតរឿងនេះជាទំនៀមរបស់ព្រះរាជានៅបុរាណសម័យក្នុងការពង្រីកទឹកដី រាត់អំណាច គឺកាលមានរាជបុត្រាបុត្រីច្រើន ក៏ឲ្យរាជបុត្រធំៗ ចេញទៅសាងនគរថ្មីទៀត ទុកនគរដើមថ្វាយព្រះរាជបុត្រតូចៗសោយ ។

ខ)- ការផ្សំផ្គុំបងប្អូនរួមមាតាបិតារបស់រាជបុត្រាបុត្រីនៃព្រះបាទ

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខកកើតជាការប្លែក ព្រោះតាមគម្ពីរវេទរបស់ពួកអរិយកៈ បានហាមដាច់មិនឲ្យយកបងប្អូនបង្កើត ឬបងប្អូនជិតខាងយកគ្នាធ្វើជាគូស្រករឡើយ តែកើតរឿងនេះ បែរជាជ្រុំតែបងប្អូនឯងនេះទៅវិញ ។ រឿងនេះ មានហេតុយ៉ាងណាៗ យើងពុំអាចដឹងដល់ តែតាមប្រកតដែលអាចឲ្យយើងយល់ យើងអាចសន្និដ្ឋានថា ការធ្វើយ៉ាងនេះជាលក្ខណៈពិសេសរបស់សាក្យវង្ស ដើម្បីរក្សាឈាមជ័រ ដូចព្រះបាទសុទ្ធោទនៈ និងព្រះនាងមាយាក្តី, ព្រះសិទ្ធត្ថ និងនាងពិម្ពាក្តី សុទ្ធតែបងប្អូនជីដូនមួយនឹងគ្នា គឺជាវង្សញាតិជិតណាស់ ។ លោកអ្នករៀនគម្ពីរក៏ប្រាប់ស្រាប់នៅក្នុងធម្មបទភាគទី៣អំពីរឿងវិឌូឌភ ជាកូនបុត្រព្រះបាទបសេនទិ និងនាងវាសភ-ខត្តិយា ។

គ)- មានរឿងពិសេស១ទៀត ដែលគួរពិចារណា គឺរឿងពង្រត់គ្នាក្នុងសាក្យវង្ស និងកោលិយវង្ស ។ រឿងនេះមិនមែនជារឿងផ្តេសផ្តាសទេ តែតាមការពិតនិងតាមក្បួនមនុស្សវិទ្យាថា ពួកក្សត្រកោលិយវង្ស តែងតែទៅពង្រត់ពួកក្សត្រីក្រមុំខាងសាក្យវង្សនៅពេលដែលចេញមកស្រង់ទឹកក្នុងស្រះធំ ហើយនាំយកទៅធ្វើជាទេពី, ជាយា ឯពួកសាក្យវង្សក៏ឥតថាអ្វីដែរ ហើយគេទុកពិធីពង្រត់នេះជាមង្គលនិងជាប្រពៃណីរបស់គេនៅសម័យនោះ ។ ដូច្នេះក្នុងសាក្យវង្សនិងកោលិយ

www.budinst.gov.kh www.elibraryofcambodia.org

វង្សមានលក្ខណៈពិសេសប្លែកពីវង្សឯទៀត ។ នៅត្រង់ចំណុច១ គឺការរក្សាឈាមជ័រនេះឯង ។

## លំដាប់នៃព្រះសិទ្ធត្ថវង្ស

យើងបានឃើញហើយថា តំបន់នៃទេវទហៈខាងសាក្យវង្សបានឡើងចំរើនរហូតដល់បានជាកន្លងនៃទេវទហៈជាគូគ្នានឹងកបិលពស្តុ ក្នុងកាលជាខាងក្រោយ ។ ចំណែកខាងផែនសាក្យ និងផែនកោលិយ ដែលមានវង្សទាំងពីរនេះគង់នៅឋានៈជាប់គ្នា មានស្ទឹងរោហិណីខាំងនៅកណ្ដាល ហើយអ្នកផែនទាំងសងខាង បានអាស្រ័យនិងយកទឹកស្ទឹងសំរាប់ធ្វើស្រែរៀងខ្លួន ។

សាក្យវង្ស និងកោលិយវង្សមានការទាក់ទងគ្នាបានយូរប៉ុន្មានឆ្នាំ ប៉ុន្មានសតវត្ស តាំងពីពេលកើតមានវង្សទាំងនេះឡើង យើងពុំបានដឹងដល់ឡើយ យើងដឹងតែតាមគម្ពីរថា មានចំនួនពីរជួរមនុស្សមុនពុទ្ធកាលប៉ុណ្ណោះ ប៉ុន្តែនៅពេលនោះរឿងកោលិយវង្ស ដែលមានព្រះនាងបិយា និងព្រះបាទពាមៈជាដើមវង្សនេះ ក៏មិនមាននិយាយដែរ គឺនិយាយតែពីរឿងសាក្យវង្សទាំងពីរគឺសាក្យវង្សខាងកបិលពស្តុ និងសាក្យវង្សខាងទេវទហៈនេះទៅវិញ ។ រឿងថ្មីដែលយើងនិងនិយាយក្នុងពេលនេះមានលំដាប់នៃក្សត្រក្នុងវង្សទាំងពីរដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

| ខាងនគរកបិលព័ស្តុ | ខាងនគរទេវទហៈ |
|---|---|
| ព្រះបាទជ័យសេន | ព្រះបាទអញ្ជនៈ |
| មានៈ | មានៈ |
| — បុត្រនាម សីហហនុ | · ប្អូនស្រីនាម កាញ្ចនា |
| — ធីតានាមយសោធរា | |

លុះព្រះបាទជ័យសេនសោយទិវង្គតទៅ ព្រះបាទសីហហនុ ឡើងសោយរាជ្យគ្រងនគរតំណែង បានយកព្រះនាង កាញ្ចនា ជាកនិដ្ឋភគិនី (ប្អូនស្រី) របស់ព្រះបាទអញ្ជនៈ នគរទេវទហៈ មកអភិសេក ជាមហេសី ឯព្រះបាទអញ្ជនៈ នគរទេវទហៈ ក៏បានយកព្រះនាងយសោធរាជាកនិដ្ឋភគិនីនៃព្រះបាទសីហហនុ មកអភិសេកជាមហេសីដែរ ។ គប្បីចំណាំថាក្សត្រទាំងពីរអង្គនេះ គឺសីហហនុ និង អញ្ជនៈបានប្តូរប្អូនស្រីគ្នាយកធ្វើជាមហេសីទៅវិញទៅមក ។

ព្រះបាទសីហហនុ និងព្រះនាងកាញ្ចនា មានបុត្រ ៥ អង្គគឺ សុទ្ធោទនៈ ១, សុក្កោទនៈ ១ អមិតោទនៈ ១, ធោតោទនៈ ១ ឃណិ-តោទនៈ ១ មានកញ្ញាធីតា ២ អង្គ គឺ បមិតា ១ អមិតា ១ ។

ព្រះបាទអញ្ជនៈ និងព្រះនាងយសោធរាមានបុត្រ ២អង្គគឺ សុប្បពុទ្ធ ១ ទណ្ឌបាណិ ១ និងកញ្ញាធីតា ២ អង្គដែរគឺមហាមាយា ១ បជាបតិ (គោតមី) ១ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្សរពិចារណា.— ពាក្យថា បជាបតិ នេះ តាមពិតមិនមែនជាឈ្មោះទេ ឯឈ្មោះពិតគឺគោតមី ។ កាលនាងមហាមាយាសោយទិវង្គតទៅ ព្រះបាទសុទ្ធោទនៈ បានតាំងនាងគោតមី ជាធំក្នុងដំណែងជាអ្នកថែទាំព្រះសិទ្ធត្ថកុមារ ។ ដូច្នេះព្រះនាមពិតគឺគោតមី ឯពាក្យថាបជាបតិគ្រាន់តែជានាមដែលមានក្នុងដំណែងប៉ុណ្ណោះដូចកាលគេហៅថាបជាបតិគោតមីក៏មាន ។

ព្រះវង្សទាំងពីរនេះ បានផ្សំផ្គុំគ្នាហើយមានកូនបុត្រចៅតាដូចតទៅៈ

ព្រះសុទ្ធោទនៈនិងព្រះនាងសិរិមហាមាយា មានកូនបុត្រតែមួយគឺព្រះសិទ្ធត្ថកុមារលុះនាងសិរិមហាមាយាសោយទិវង្គតទៅ ព្រះបាទសុទ្ធោទនៈក៏តាំងនាងគោតមីជាជាយាធំ មានកូនបុត្រ១គឺ នន្ទកុមារ និងកូនធីតា១គឺនាងរូបនន្ទា ។ សូមបញ្ជាក់ថា " ព្រះបាទសុទ្ធោទនៈបានយកនាងគោតមីធ្វើជាជាយាបន្ទាប់ តាំងពីដើមមក គ្រាន់តែមិនទាន់តាំងជាធំ ព្រោះមានព្រះនាងសិរិមហាមាយាជាធំនៅហើយ ដូច្នេះបានជានន្ទកុមារ មានព្រះជន្មតិចជាងព្រះសិទ្ធត្ថកុមារតែពីរបីថ្ងៃប៉ុណ្ណោះ ។ សូមកុំច្រឡំនន្ទកុមារ និងអានន្ទកូនបុត្រព្រះសុក្កោទនៈ ហើយជាប្អូនជីដូន១ នឹងព្រះសិទ្ធត្ថកុមារ ។ អានន្ទប្រសូតថ្ងៃដំណាលនឹងព្រះសិទ្ធត្ថកុមារដែរ ។ ព្រះសុប្បពុទ្ធខាងទេវទហៈ ផ្សំនឹងនាងបមិតាខាងកបិលព័ស្តុ

www.budinst.gov.kh www.elibraryofcambodia.org

បានរាជបុត្រ១គឺទេវទត្តនិងរាជធីតា១គឺនាងពិម្ពាយសោធរា ។ ព្រះបាទសុទ្ធោទនៈបានរៀបរាជាភិសេក ព្រះសិទ្ធត្ថកុមារនិងព្រះនាងពិម្ពាយសោធរាជាព្រះរាជានៅនគរកបិលពស្តុ ។ ១៣ ឆ្នាំក្រោយមកទើបមានរាជបុត្រមួយនាមរាហុលកុមារប្រសូតនៅថ្ងៃព្រះសិទ្ធត្ថជាបិតាយាងចេញទៅបួស ។

## សេចក្ដីសន្និដ្ឋាន

តាំងពីក្នុងការសិក្សាអំពីពុទ្ធប្រវត្តិហូតមកទល់ដល់នេះ យើងបានស្គាល់ប្រវត្តិដោយត្រួសត្រាយអំពីប្រទេសឥណ្ឌា ទាំងក្នុងបុរាណសម័យ និង សម័យពុទ្ធកាល បានស្គាល់ប្រជាជនឥណ្ឌា-ទាំងបានស្គាល់ទឹកដីដែលជាជាតិភូមិរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៅទីណា ។, បានស្គាល់ប្រវត្តិដើមរបស់ព្រះវង្សរបស់ព្រះអង្គព្រមទាំងបញ្ហាផ្សេងៗទៀតជាច្រើនខ្លះហើយ ដែលមានហេតុនាំឲ្យយើងមានការចាប់អារម្មណ៍ជាច្រើនក្នុងការសិក្សាអំពីពុទ្ធប្រវត្តិតទៅទៀត ។ សូមបញ្ជាក់បន្ថែមថា កាលបុត្រាបុត្រីទាំង៩អង្គរបស់ព្រះបាទឱក្កាករាជ បានសាងនគរហើយបានដាក់នាមរាជធានីថាកបិលពស្តុបុរី ហើយមានក្សត្រសោយរាជជាច្រើនអង្គនៅក្នុងរាជធានីតែ១នេះ អស់ច្រើនឆ្នាំ រហូតដល់ព្រះបាទសិវិរាជ ក៏ផ្លាស់នាមនគរនិងរាជធានីថា ជេតុត្តរវិញ ។ ព្រះបាទសិវិរាជ, ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

បាទសញ្ជ័យ, ព្រះបាទវេស្សន្តរ[១] ជាតួអង្គពោធិសត្វ, ព្រះបាទជាលី (និងនាងក្រឹស្នា ដែលព្រះវេស្សន្តរបានផ្សំផ្គុំជាស្វាមី–ជាយា), ព្រះបាទសិរិវាហនៈ, ព្រះបាទសីហសរកជ, រួចមានព្រះរាជាសោយរាជ្យត ៗ មកទៀតរហូតដល់ទៅ ១៦.១០០ អង្គ ទើបមកដល់រាជ្យព្រះបាទជ័យសេន ។ ព្រះបាទសីហហនុ ជាបុត្ររបស់ព្រះបាទជ័យសេន បានរាជាភិសេកហើយ ក៏ផ្លាស់នាមនគរជេតុត្តរថា កបិលវត្ថុវិញ ។

## ឃ្លាភ្ជាប់សេចក្ដី

ការសិក្សារួចមកហើយ ពុទ្ធបរិស័ទទាំងឡាយគ្រាន់តែបានឃើញថា រឿងរ៉ាវទាំងប៉ុន្មាន គឺជារឿងរ៉ាវធម្មតាដូចមនុស្សក្នុងលោក ឬ សកម្មរបស់មនុស្ស ។ នេះគឺប្រវត្តិដើមរបស់ប្រជាជននិងទឹកដីឥណ្ឌា នៅសម័យដើម ដែលប្លែកពីបច្ចុប្បន្នកាលនេះ ដោយមានការចែកទឹកដីជាឥណ្ឌា ជានេប៉ាល ។ តទៅទៀត យើងនឹងសិក្សាអំពីពុទ្ធប្រវត្តិ ដែលជារឿងធម្មតាផង រឿងអស្ចារ្យកម្រមានផង ព្រោះបើប្រវត្តិរបស់មនុស្សធម្មតា គេមិនដែលលើកយកហេតុដែលមិនបានឃើញមកនិយាយ

---

១– ព្រះវេស្សន្តរនេះ ជាតួអង្គពោធិសត្វដែលមានកំណើតចុងក្រោយបង្អស់ មុនកំណើតជាព្រះសិទ្ធត្ថ ។ កាលព្រះវេស្សន្តរសោយទិវង្គតទៅ បានទៅកើតនៅស្ថានតុសិត មាននាមថា សន្តុសិតទេវបុត្រ មានព្រះជន្ម ៤.០០០ ឆ្នាំ ទិព្វ ត្រូវជា ៥៧ កោដិ ៦សែនឆ្នាំ មនុស្សទើបច្យុតមកយកជាតិជាព្រះសិទ្ធត្ថ គឺព្រះពុទ្ធហ្នឹងឯង ។ សូមមើលចម្លើយខាងមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

ទេ ឯពុទ្ធប្រវត្តិ មានលើកយករឿងដែលមិនបានឃើញមកនិយាយផង ឧទាហរណ៍ដូចជាការនិយាយថា កាលមុនព្រះពោធិសត្វ ដែលសោយពីព្រះជាតិជាវេស្សន្តរហើយទៅយកកំណើតក្នុងស្ថានតុសិត មាននាមថា សន្តុសិតទេវបុត្រ កាលរៀបនឹងច្យុតចុះមានហេតុផ្សេងៗ មានការស្រពោនស្វិតនៃកម្រងផ្កាជាដើម ឯព្រះមាតាគឺនាងសិរិមហាមាយា មានសុបិននិមិត្តប្លែកៗ ។

ចំណែកខាងរឿងដែលធ្លាប់ឃើញ ក៏មានសភាពប្លែកពីមនុស្សធម្មតា ឬ ពីមហាបុរសនានាដែរ ដូចជាទ្រង់ប្រសូតហើយភ្លាម ទ្រង់ដើរយាងបាន ៧ ជំហានជាដើម ។ រឿងទាំងនេះហើយ ដែលធ្វើឲ្យពុទ្ធប្រវត្តិទៅជារឿងប្លែកសំរាប់ធ្វើជាគ្រឿងសិក្សាពិសេសជាងរឿងធម្មតា ។ តទៅខាងមុខៗទៀត ចេះតែមានលក្ខណៈប្លែកច្រើន ជាហេតុឲ្យយើងសន្និដ្ឋានបានថា ព្រះពុទ្ធជាបរមគ្រូ, ជាអគ្គបុគ្គល, ជាកំពូលនៃអ្នកប្រាជ្ញ, ជាមនុស្សអស្ចារ្យ (អច្ឆរិយបុគ្គល), ជាសាស្ដាចារ្យរបស់មនុស្ស និងទេពតាទាំងឡាយក្នុងត្រៃភព ហើយជាទីគោរពសក្ការៈរបស់ប្រជាពលរដ្ឋខ្មែរយើងនៅក្នុងកាលទាំងពួង ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រស្នាពុទ្ធប្រវត្តិពិស្តារ

## ភាគទី២

## បុព្វប្រវត្តិ

សំនួរទី១.– ពុទ្ធប្រវត្តិគឺជាអ្វី ? ហេតុដូចម្តេចជាគេត្រូវរៀនពុទ្ធប្រវត្តិ ? មានប្រយោជន៍ដូចម្តេចខ្លះ ?

ចម្លើយ.– ពុទ្ធប្រវត្តិ គឺជារឿងរ៉ាវផ្សេងៗរបស់ព្រះពុទ្ធជាបរមគ្រូនៃយើងគ្រប់គ្នា ។ បានជាត្រូវសិក្សាអំពីពុទ្ធប្រវត្តិនេះ គឺដើម្បីឲ្យស្គាល់នូវការប្រព្រឹត្តទៅរបស់ព្រះពុទ្ធជាម្ចាស់ផង ដើម្បីទុកជាគ្រឿងពិចារណាឲ្យដឹងថា ព្រះពុទ្ធជាបុគ្គលដែលមានការចេះដឹង យល់ដ៏ជ្រៅជ្រះជាងគណាចារ្យគ្រូឯទៀតផង និងដើម្បីនាំចិត្តយើងឲ្យកើតតែមានជំនឿដ៏មុតមាំចំពោះព្រះពុទ្ធអង្គនិងពុទ្ធសាសនាផង ។ ការរៀនពុទ្ធប្រវត្តិមានប្រយោជន៍សំខាន់ក្នុងការដឹងនូវការប្រតិបត្តិដ៏មោះមុត របស់ព្រះអង្គនិងដើម្បីប្រតិបត្តិតាមព្រះអង្គសំរាប់ធ្វើដំណើរទៅកាន់សុគតិភព ។

ស. ២– ហេតុដូចម្តេច បានជាពុទ្ធបរិស័ទថ្វាយនាមព្រះពុទ្ធជាម្ចាស់ថា “ បរមគ្រូ,,?

ច– បានជាពុទ្ធបរិស័ទថ្វាយនាមថា “បរមគ្រូព្រោះព្រះពុទ្ធជាគ្រូកំពូលលើគ្រូឯទៀតៗ ក្នុងត្រៃភព ទោះគ្រូនោះជាមនុស្សក្តី ទេវតាឬព្រះឥន្ទព្រះព្រហ្មក្តី ក៏នៅតែស្តាប់គោរពខ្លាចហើយគោរពនូវការត្រាស់

www.budinst.gov.kh www.elibraryofcambodia.org

ដឹងរបស់ព្រះពុទ្ធជាដរាប ។

ស ៣– ព្រះពុទ្ធជាគ្រូដែលបានត្រាស់ដឹង, តើការត្រាស់ដឹងនោះយ៉ាងណា ? ចូរពន្យល់អំពីពាក្យថា ត្រាស់ដឹង នេះឲ្យស្តាប់បានផង ។

ច.– ពាក្យថាត្រាស់ដឹង បានដល់ការរិះគិតរកឃើញ ឬធ្វើអ្វី១ ដែលមិនដែលមានសោះ ឲ្យឃើញ, ឲ្យមានឡើង ឧទាហរណ៍ដូចជា អ្នកច្នៃរកវិធីធ្វើគ្រឿងយន្ត, អ្នកផ្សំធាតុ អ្នកផ្សំថ្នាំព្យាបាលរោគ, អ្នកធ្វើអាកាសយាន ឬអ្នកធ្វើគ្រាប់បែកបរមាណូ ធ្វើកាំជ្រួចចក្រកំរូជាដើម សុទ្ធតែជាអ្នកត្រាស់ដឹងទាំងអស់ ប៉ុន្តែការត្រាស់ដឹងរបស់អ្នកទាំងនោះ មិនមែនជាការសំខាន់ ជាការត្រាស់ដឹងតែ១ផ្នែកៗមួយមុខវិជ្ជាតែប៉ុណ្ណោះ ឯព្រះពុទ្ធជាគ្រូដែលបានត្រាស់ដឹងដែរនោះ គឺព្រះអង្គបានរកធម៌ទាំង ៨៤.១០០ ព្រះធម្មក្ខន្ធឃើញ ហើយមានប្រាជ្ញាញាណចាក់ធ្លុះសុះសាយ ជ្រាបហេតុផលសព្វយ៉ាងដោយឥតទើសទាក់ទៀតផង ។ ការត្រាស់ដឹងនេះបានមកពីពុទ្ធការកធម៌របស់ព្រះពុទ្ធអង្គនេះឯង ។

ស ៤– អ្វីដែលហៅថាពុទ្ធការកធម៌ ? មានប៉ុន្មានយ៉ាង ?

ច ធម៌សំរាប់ធ្វើខ្លួនឲ្យទៅជាព្រះពុទ្ធ ហៅថាពុទ្ធការកធម៌ មានបារមី ៣០ គឺទាន១, សីល១, នេក្ខម្មៈ (ការចេញបួស)១, បញ្ញា១, វីរិយៈ១, ខន្តី១, សច្ច១, អធិដ្ឋាន១, មេត្តា១, ឧបេក្ខា១ ។ ក្នុងបារមីមួយៗចែក

www.budinst.gov.kh www.elibraryofcambodia.org

ជាថ្មី ៗ ទៀតគឺ ទានបារមី១, ទានឧបបារមី១, ទានបរមត្ថបារមី១,

៣×១០=៣០ ។ មានមហាបរិច្ចាគ ៥ គឺ

១– អង្គបរិច្ចាគ = ការលះអវយវៈឲ្យជាទាន,

២– ធនបរិច្ចាគ = ការលះទ្រព្យសម្បត្តិឲ្យជាទាន,

៣– បុត្តបរិច្ចាគ = ការលះកូនឲ្យជាទាន,

៤– ទារបរិច្ចាគ = ការលះប្រពន្ធឲ្យជាទាន,

៥ – ជីវិតបរិច្ចាគ = ការលះជីវិតឲ្យជាទាន ។

ព្រមទាំងមានចរិយា ៣ ទៀតគឺ

១– លោកត្ថចរិយា = ការប្រព្រឹត្តិធ្វើប្រយោជន៍ដើម្បីលោ

២ - ញាតត្ថចរិយា = ការប្រព្រឹត្តប្រយោជន៍ដល់ព្រះញាតិ

៣ - ពុទ្ធត្ថចរិយា = ការប្រព្រឹត្តប្រយោជន៍ដើម្បីបានត្រា

ដឹងហើយយាងប្រោសសត្វ ។

ស·៥· ពុទ្ធប្រវត្តិ ដែលបំព្រួញឲ្យខ្លីមក តើមានលក្ខណៈផ្សេ

យ៉ាងណា ? ចូរពន្យល់និងប្រាប់ប្រយោជន៍និងលក្ខណៈមួយ ៗ

ច - ពុទ្ធប្រវត្តិ ដែលបំព្រួញមក នឹងឃើញមានលក្ខណៈ ៣

ផ្សេងគ្នាគឺ :

លក្ខណៈម្យ៉ាងស្ថិតនៅត្រង់ដំណើររឿងដំហូរទៅ តាំងពីអតីត

www.budinst.gov.kh www.elibraryofcambodia.org

របស់ព្រះអង្គហេតុទាល់បាននិព្វាន ។ លក្ខណៈទី១នេះ នឹងមានប្រយោជន៍ដល់ការចេះដឹងរឿងរបស់ព្រះអង្គចំពោះអ្នកសិក្សា ។

នៅក្នុងដំណើររឿងនេះ មានលក្ខណៈ១ផ្នែកផ្សេងទៀតគឺ ការសាងសន្សំដ៏ស្វិតស្វាញរបស់ព្រះអង្គក្នុងជាតិនីមួយៗ ដែលទ្រង់បានបំពេញក្នុងពុទ្ធភូមិ ជាហេតុឲ្យអ្នកចេះរឿងរ៉ាវ នឹកស្ងើចអស្ចារ្យណាស់ទៅទៀត ។

រឿងរ៉ាវដ៏ចំឡែកៗ នឹងការកសាងដ៏សម្បើមអស្ចារ្យរបស់ព្រះអង្គ ជាលក្ខណៈទី៣ដែលនាំឲ្យអ្នកសិក្សាកើតចិត្តជ្រះថ្លានឹងមាន ជំនឿចំពោះព្រះអង្គ ។

ស ៦– ពុទ្ធភូមិ គឺអ្វី ? មានប៉ុន្មាន ? ព្រះពុទ្ធនៃយើងទ្រង់សាងបារមីក្នុងភូមិណា ? មានរយៈពេលប៉ុន្មាន ? ចូរពន្យល់ ។

ច– ទីប្តូរកំណើតដែលព្រះអង្គបានសាងបារមីដើម្បីបានត្រាស់ ហៅថាពុទ្ធភូមិ មាន៣យ៉ាងគឺ

១– បញ្ញាធិក= ការសាងបារមីដោយយកបញ្ញាជាធំ

២– សទ្ធាធិក = ការសាងបារមីដោយយកជំនឿជាធំ

៣– វីរិយាធិក= ការសាងបារមីដោយយកព្យាយាមជាធំ ។

ព្រះពុទ្ធជាម្ចាស់នៃយើងទ្រង់សាងបារមីជាបញ្ញាធិក មានរយៈវេលា៤–

www.budinst.gov.kh www.elibraryofcambodia.org

អសង្ខេយ្យ និង១សែនកប្ប ។

ស.៧– ក្នុងរយៈកាលប៉ុណ្ណោះ តើមានហេតុកេរយ៉ាងណាខ្លះ ដែលជាប្រភពនាំឲ្យព្រះអង្គមានព្យាយាមបំពេញបារមី ដើម្បីត្រាស់ជាព្រះពុទ្ធ ?

ច– ព្រះអង្គ ( ពោធិសត្វជាម្ចាស់នៃយើង ) បានទទួលទំនាយអំពីព្រះពុទ្ធទាំងឡាយចំនួន ២៤ អង្គគឺ ព្រះពុទ្ធទីបង្ករ១, កោណ្ឌញ្ញ១, សុមង្គល១, សុមន១, រេវតៈ១, សោភិត១. អនោមទស្សី១, បទុម១, នារទៈ១, បទុមុត្តរ១, សុមេធ១, សុជាត១, បិយទស្សី១, អត្ថទស្សី១, ធម្មទស្សី១, សិទ្ធត្ថ១, តិស្ស១, ផុស្ស១, វិបស្សី១, សិខី១, វេស្សភូ១, កកុសន្ធ១, កោនាគមន១, កស្សប១ ។ ការបានទទួលទំនាយនេះជាហេតុនាំឲ្យព្រះអង្គប្រឹងបំពេញបារមីដោយស្វិតស្វាញណាស់ ។

ស ៨– ក្នុងពុទ្ធកាលនៃព្រះពុទ្ធទីបង្ករ និងព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ តើព្រះពោធិសត្វនៃយើង ទ្រង់សោយព្រះជាតិជាអ្វី ? បានធ្វើអ្វីខ្លះ ? ហើយបានទទួលព្យាករណ៍យ៉ាងណា ?

ច – ក្នុងពុទ្ធកាលនៃព្រះពុទ្ធទីបង្ករព្រះពោធិសត្វនៃយើងទ្រង់សោយព្រះជាតិជាព្រាហ្មណ៍ឈ្មោះ សុមេធៈ បានលះទ្រព្យសម្បត្តិចេញទៅបួសជាតាបសក្នុងព្រៃ ១ ហើយបានសម្រេចឈាននិងអភិញ្ញា ។ ពេល

www.budinst.gov.kh www.elibraryofcambodia.org

មួយព្រះតាបសបានហោះចេញពីអាស្រម បានឃើញប្រជាជនធ្វើផ្លូវថ្វាយព្រះពុទ្ធទីបង្ករ ក៏សុំចំ ១ ដើម្បីធ្វើឲ្យល្អថ្វាយព្រះពុទ្ធដែរ លុះព្រះពុទ្ធយាងមកដល់ តាបសធ្វើផ្លូវមិនទាន់ហើយក៏ប្រែខ្លួនសឹងលើភក់ធ្វើជាស្ពានហើយនិមន្តព្រះពុទ្ធនិងសាវ័កឲ្យនិមន្តពីលើខ្លួន ។ ព្រះពុទ្ធទីបង្ករនិងសាវ័កយាងហួសហើយ ក៏ព្យាករណ៍ថ្វាយព្រះសុមេធតាបសថា តាបសនេះនឹងបានជាព្រះពុទ្ធ ១ អង្គនាម គោតម ក្នុងអនាគតកាល ។

លុះមកដល់ពុទ្ធកាលនៃព្រះកស្សបៈព្រះពោធិសត្វនៃយើងដែលមានបារមីចាស់ក្លាហើយ ក៏បានសោយជាតិជាជោតិបាលមាណព ១ នេះបានចូលបួសជាភិក្ខុក្នុងពុទ្ធសាសនា ហើយបានទទួលព្យាករណ៍ដូចមុនទៀត ។ ព្រះអង្គក៏ចំបំពេញបារមីរហូតដល់ព្រះជាតិជាព្រះវេស្សន្តរមហាកដ ។

ស ៩.-- ព្រះវេស្សន្តរ ជាអ្វី ? បានធ្វើអ្វីខ្លះ ? ស្ថិតនៅក្នុងជាតិទីប៉ុន្មានមុននឹងបានត្រាសជាព្រះពុទ្ធ ?

ច-- ព្រះវេស្សន្តរជាតួអង្គពោធិសត្វជាម្ចាស់នៃយើង ។ ព្រះអង្គបានបំពេញនូវបារមីទាំង ១០ ក៏ប៉ុន្តែទ្រង់បំពេញទានបារមីខ្លាំងជាងគេ ។ ទ្រង់បានសោយជាតិក្នុងមនុស្សលោកទី ២ មុននឹងព្រះជាតិដែលបាន

www.budinst.gov.kh www.elibraryofcambodia.org

ត្រាស់ជាព្រះពុទ្ធនេះឯង (ព្រះជាតិជាសិទ្ធត្ថគឺព្រះពុទ្ធអង្គនេះជាជាតិទី ១ ឬ ជាតិទីបំផុត) ។

ស. ១០– តាមសេចក្តីដំណាលនិងទំនៀមខ្លះថា កាលព្រះវេស្សន្តរប្រទានជាលីក្រឹស្នាទៅតាជូជក ហើយជូជកវាយជាលីក្រឹស្នា ទ្រង់ក៏ក្រោធចង់ប្រហារជីវិតតាជូជកពេល បានជាមិនបានត្រាស់ក្នុងជាតិនោះ បើកុំធ្វើយ៉ាងនេះព្រះអង្គនឹងបានត្រាស់ទៅហើយ ។ តើរឿងនេះ ពិត ឬ មិនពិត?

ច– មិនពិតទេ ព្រោះក្នុងព្រះជាតិជាព្រះវេស្សន្តរនោះ មិនមែនជាជាតិដែលត្រូវបានត្រាស់ឡើយ មកពីបារមីមិនទាន់ចាស់ក្លាផង មកពីពេលវេលាមិនទាន់ដល់ផង ហើយខុសពីប្រពៃណីនៃព្រះពុទ្ធពីបុរាណផង ។

ស. ១១– ពាក្យថាពោធិសត្វ, ពុទ្ធង្កុរ, និងកៃន្យសារពេជ្ញ មានន័យយ៉ាងណា? ចូរបង្ហាញ ។

ច– ពាក្យថាពោធិសត្វនិងពុទ្ធង្កុរ មានន័យថា អ្នកដែលសាងបារមី ដើម្បីត្រាស់ជាព្រះពុទ្ធហ្នឹងឯង ឯពាក្យថា កៃន្យសារពេជ្ញ គឺជាស្ត្រីដែលជាគូព្រេងរបស់ព្រះពោធិសត្វគ្រប់ព្រះអង្គ ហើយត្រូវតែបានជួបនឹងព្រះពោធិសត្វ បានគ្នាជាស្វាមីភរិយាជាដរាប បើព្រះពោធិសត្វបាត់ព្រះជន្មទៅ ស្រីជាកៃន្យសារពេជ្ញមិនដែលយកស្វាមីទៀតទេ ។

ស. ១២– ព្រះពោធិសត្វដែលយកកំណើតជាសត្វតិរច្ឆានដែរ ?

www.budinst.gov.kh www.elibraryofcambodia.org

ប់ដែលយកកើតសត្វនោះមានលក្ខណៈយ៉ាងណា ?

ប– ព្រះអង្គដែលយកកំណើតជាសត្វតិរច្ឆានដែរ ។ បើទ្រង់យកំណើតក្នុងពពួកសត្វជំពូកនេះ ព្រះអង្គតែងមានប្រាជ្ញាញាណខ្ពង់ខ្ពស់ាំងគេជាដរាប ។ ម្យ៉ាងទៀតក្នុងកំណើតជាសត្វតិរច្ឆាន តែងមានិតយ៉ាងនេះគឺ ៖

–បើសោយព្រះជាតិជាសត្វមានរាងកាយធំ មានទំហំធំជុតត្រឹមប៉ុនស្តួចដំរីសារ ។

–បើសោយជាតិជាសត្វមានរាងកាយតូច មានទំហំតែត្រឹមប៉ុនសត្វាបទៀបកប្បាស ។

ទំហំធំជាងដំរីសារ ឬ តូចជាងសត្វចៀបកប្បាសព្រះអង្គពុំដែលយកំណើតឡើយ ។

X

X X

ភាគទី៣

# ព្រះបដិសន្ធិនិងការប្រសូតិ
# នៃព្រះសិទ្ធត្ថកុមារ

ស.១៣– កាលព្រះបាទមហាវេស្សន្តរទ្រង់ទិវង្គតទៅ តើបានទៅកើតជាអ្វីទៀត? នៅស្ថានណា? ឈ្មោះអ្វី? មានជន្មាយុប៉ុន្មាន? ព្រោះហេតុអ្វី?

ច· ទ្រង់បានទៅកើតជាទេវបុត្រនៅស្ថានតុសិត ឈ្មោះសន្តុសិតទេវបុត្រ មានព្រះជន្មាយុ ៤ ពាន់ឆ្នាំទិព្វ ត្រូវជា៥៧កោដិ ៦ សែនឆ្នាំមនុស្ស ។ កំណើតនោះ គឺជាធម្មតារបស់ព្រះពោធិសត្វគ្រប់ព្រះអង្គ នៅពេលមុននឹងជាតិដែលបានត្រាស់ជាព្រះពុទ្ធ ។

ស ១៤– កាលផុតកំណត់អាយុក្នុងស្ថានតុសិតហើយ តើមានហេតុយ៉ាងណា? ទ្រង់ទៅយកបដិសន្ធិនៅឯណា? នៅថ្ងៃ-ខែ- ឆ្នាំណា? ពេលថ្មើរណា មានហេតុយ៉ាងណាខ្លះ ចូរអធិប្បាយឲ្យល្អមស្ដាប់បាន ។

ច– កាលសន្តុសិតទេវបុត្តផុតអស់ព្រះជន្មហើយ មានកើតកោលាហល ( ការជ្រួលជ្រើម ) ៥ យ៉ាងគឺ :

១– កប្បកោលាហល = ការជ្រួលជ្រើមថា នៅមួយសែនឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

ទៀត ភ្លើងនឹងឆេះកប្ប មនុស្សត្រូវនាំគ្នាធ្វើបុណ្យឲ្យទានរក្សាសីល ។

២– ពុទ្ធកោលាហល= ការជ្រួលជ្រើមថា នៅមួយសែនឆ្នាំទៀត ព្រះពុទ្ធនឹងមានក្នុងលោកនេះ ។

៣– ចក្កវត្តិកោលាហល = ការជ្រួលជ្រើមថា នៅ១សែនឆ្នាំទៀតស្តេចចក្រពត្តិ នឹងមានឡើងក្នុងលោកនេះ ។

៤– មង្គលកោលាហល= ការជ្រួលជ្រើមថា នៅ១សែនឆ្នាំទៀត ព្រះពុទ្ធនឹងសំដែងមង្គលសូត្រ ៣៨ ប្រការ ។

៥– មោនេយ្យកោលាហល= ការជ្រួលជ្រើមថា នៅ១សែនឆ្នាំទៀត ព្រះពុទ្ធនឹងសំដែងមោនេយ្យបដិបត្តិ ។

កោលាហលទាំង ៥ យ៉ាងនេះ ពុទ្ធាកសមហាព្រហ្មបានប្រកាសប្រាប់ទេវតានិងព្រហ្មទាំងឡាយ ។ ទាំងមួយម៉ឺនលោកធាតុឮហើយក៏ទៅអារាធនាអញ្ជើញសន្តុសិតទេវបុត្តឲ្យច្យុតចុះ ទៅយកកំណើតក្នុងមនុស្សលោក ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធដោយពាក្យថា ៖

កាលោយន្តេ មហាវីរ ឧប្បជ្ជ មាតុកុច្ឆិយំ
សទេវកំ តារយន្តោ ពុជ្ឈស្សុ អមតំ បទំ ។

បពិត្រព្រះមហាបុរសអ្នកមានព្យាយាម កាលនេះជាកាលគួរដល់ព្រះអង្គហើយ សូមព្រះអង្គច្យុតចុះទៅយកព្រះបដិសន្ធិក្នុងផ្ទៃនៃព្រះមាតា

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីបានត្រាស់ហើយចម្លងមនុស្សនិងទេវតា ឲ្យបានដល់នូវស្ថានបរមសុខ ។

កាលព្រះសេចក្តីអញ្ជើញដូច្នោះ សន្តុសិតទេវបុត្ត បានគិតពិនិមើលនូវហេតុ ៥យ៉ាងគឺៈ

១ -កាល= ពេលដែលមនុស្សមានអាយុច្រើនផុតត្រឹម ១សែនឆ្នាំ និងតិចផុតត្រឹម១រយឆ្នាំ ទើបព្រះពុទ្ធយកព្រះកំណើត ។

២ - ប្រទេស= ទ្រង់ប្រមើលប្រទេស គឺព្រះពុទ្ធគ្រប់អង្គ ពុំដែលយកព្រះកំណើតក្នុងបច្ចន្តប្រទេសទេ ទ្រង់កើតតែក្នុងមជ្ឈិមប្រទេសតែប៉ុណ្ណោះ ។

៣-ត្រកូល= ព្រះពុទ្ធតែងយកព្រះកំណើតក្នុងត្រកូលពីរគឺ ត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ឯត្រកូលក្រៅពីនេះ ទ្រង់ពុំដែលកើតទេ។

៤ - ទ្វីប= ព្រះពុទ្ធតែងយកព្រះកំណើតតែក្នុងជម្ពូទ្វីប១ប៉ុណ្ណោះ ទ្វីប៣ទៀតគឺ បុព្វវិទេហទ្វីប, ឧត្តរកុរុទ្វីប និងអមរគោយានទ្វីប ព្រះពុទ្ធគ្រប់អង្គពុំដែលកើតទេ ។

៥ - មាតា= ព្រះពុទ្ធតែងតែយកកំណើត ក្នុងផ្ទៃនៃមាតាណាដែលមានអភិនីហារកសាងមកអស់១សែនកប្ប ដើម្បីបានជាពុទ្ធមាតា ។

កាលទ្រង់ប្រមើលមើលសព្វគ្រប់ហើយ សន្តុសិតទេវបុត្ត ក៏មាន

www.budinst.gov.kh www.elibraryofcambodia.org

បុព្វនិមិត្ត ៥ យ៉ាង កើតដល់ព្រះអង្គគឺ :

១– បុប្ផាទិព្វ ដែលទ្រង់ពាក់តែងកាយក្រៀវស្រពោន

២– សំពត់ទិព្វ មានពណ៌សៅហ្មង

៣– ញើសហូរចេញពីក្លៀក

៤– ព្រះកាយទ្រង់ចាស់ដកទ្រុឌទ្រោម

៥– ទ្រង់អផ្សុកព្រះទ័យ មិនចង់ស្ថិតនៅក្នុងស្ថានទិព្វ ។

កាលមានបុព្វនិមិត្តនិងទ្រង់បានប្រមើលមើលមហាវិលោកនៈទាំង ៥ រួចហើយទ្រង់ក៏យាងចុះចាប់បដិសន្ធិក្នុងផ្ទៃនៃ ព្រះនាងសិរីមហាមាយា ជាព្រះអគ្គទេពីនៃព្រះបាទសុទ្ធោទនៈ ក្សត្រនៅដែនសក្កៈ ក្រុងកបិលពស្តុ ក្នុងសាក្យត្រកូល ដែនដីជម្ពូទ្វីប, មជ្ឈិមប្រទេស នៅថ្ងៃព្រហស្បតិ៍ពេញបូរមី ខែអាសាឍ ឆ្នាំរកា ពេលទៀបភ្លឺ ។

**ស.១៥.–** តាមធម្មតា ពេលដែលសត្វចុះចាប់បដិសន្ធិ មាតាតែងមានសុបិននិមិត្តប្លែក ៗ ចុះកាលព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ តើព្រះនាងសិរីមហាមាយាជាព្រះមាតាមានសុបិននិមិត្តដែរឬគ្មាន បើមានតើសុបិននិមិត្តយ៉ាងណា ?

www.budinst.gov.kh www.elibraryofcambodia.org

ច– មាន គឺព្រះនាងសិរិមហាមាយាទ្រង់សុបិនថា "ស្តេចនៃទេវតាក្នុងទិសទាំង ៤ គឺព្រះបាទកុវេរ១, ធតរដ្ឋ១ វិរូបក្ខ១, វិរុឡ្ហក១ បានមកលើកយកព្រះនាងទាំងព្រះសយនាទៅកាន់ភ្នំហិមពាន្តដាក់លើមនោសិលា ទំហំ ៦០ យោជន៍ ក្នុងក្រោមដើមរាំងធំ ១ កំពស់ ១០០ យោជន៍ រួចមានទេវធីតាមកសុំយាងព្រះនាងទៅស្រង់ទឹកក្នុងអនោតត្តស្រះ ។ នៅជិតស្រះ មានភ្នំប្រាក់ ១ មានវិមានមាស ១ នៅលើភ្នំប្រាក់ ។ កាលស្រង់ហើយព្រះនាងយាងទៅផ្ទំក្នុងវិមានមាស លើភ្នំប្រាក់បែរព្រះសិរទៅទិសខាងកើត ។ មានដំរីស ១ ចុះមកពីភ្នំមាស ១ ដែលនៅជិតភ្នំប្រាក់ ហើយកាន់ផ្កាឈូកបទុមសម្ព័ន្ធដូចក្រៀល ឡើងទៅលើភ្នំប្រាក់រួចចូលទៅក្នុងវិមានមាស ដើរប្រទក្សិណព្រះនាង ៣ ជុំ រួចហាក់ដូចជាចូលទៅក្នុងឧទរព្រះនាងខាងស្តាំ ។ គឺពេលនេះហើយដែលព្រះពោធិសត្វនៃយើងទ្រង់ចាប់បដិសន្ធិ ។

ស. ១៦ – កាលមុនពេលព្រះពោធិសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាង តើព្រះនាងសិរិមហាមាយាបានធ្វើអ្វីខ្លះ ?

ច– ព្រះនាងសិរិមហាមាយា ទ្រង់ក្រសាលមហោស្រពអស់ពេល ៧ ថ្ងៃជាមួយអ្នកនគរមុនថ្ងៃពេញបូរមី លុះដល់ថ្ងៃពេញបូរមីព្រះនាងបានបរិច្ចាគទ្រព្យចំនួន ៤ សែនកហាបណៈឲ្យទាន រួចក៏សមាទានឧបោសថ

www.budinst.gov.kh www.elibraryofcambodia.org

សីលស្រេច ទើបចូលផ្ទុំ ។

ស.១៧ – នៅពេលដែលព្រះពោធិសត្វទ្រង់យាងចុះចាប់បដិសន្ធិ តើមានហេតុភេទណា ទាក់ទងដល់មនុស្សធម្មជាតិនិងនៃត្រកាលនោះដែរឬទេ ?

ច – មាន គឺមានហេតុចម្លែកនៅក្នុងមនុស្សលោក ធម្មជាតិទាំងពីរលោកៈ ទាំងមូលចំនួន៣២បែបគឺ ៖ ១ ប្រឹថពីកម្រើកមានពន្លឺភ្លឺលោកធាតុ, ២ - លោកខ្លះមហានរកដែលងងឹតក៏មានពន្លឺឡើង, ៣ - មនុស្សខ្វាក់ បែរជាមើលឃើញ, មនុស្សថ្លង់បែរជាឮ,មនុស្សគបែរជានិយាយបាន, មនុស្សគមបែរជាត្រង់, មនុស្សខ្វិនដើររួច; ៤ - មនុស្សសត្វដែលត្រូវជាប់គុកច្រវាក់ខ្នោះត្រូវរួចចេញបាន, ៥ – ភ្លើងក្នុងនរកទាំងឡាយមានអវិចីជាដើម បែរជារលត់, ៦ - សេចក្តីស្រេកឃ្លានរបស់ពួកប្រេតក៏បាត់បង់, ៧ – បង្អួចទ្វារដែលបិទជិតត្រូវរបើកចេញ, ៨ - សំពៅនិងទូកបានទៅដល់កំពង់តាមប្រាថ្នា, ៩ សត្វតិរច្ឆានទាំងឡាយមិនភ័យភក់ស្លុត, ១០ – រោគរបស់មនុស្សសត្វបានរំងាប់, ១១ - សត្វដែលមានពៀរនឹងគ្នា បែរជាមានមេត្តាដល់គ្នានឹងគ្នា, ១២ – មនុស្សសត្វនិយាយសំដីជាពីរោះស្រឡាញ់ចូលចិត្តដល់គ្នានឹងគ្នា, ១៣ – ពពួកសេះទាំងឡាយបន្លឺសម្លេងរកគ្នា, ១៤ – ពពួកដំរីបានបន្លឺសម្លេងគឹកកងរកគ្នា, ១៥ – តូរ្យតន្ត្រីបានបន្លឺសំឡេងដោយខ្លួនឯង, ១៦ - គ្រឿងអាក

រណៈរបស់មនុស្សមានពន្ធ ហើយបែះគ្នាចេញជាសំឡេងក្រោកដឡើង, ១៧- ទិសទាំងឡាយភ្លឺប្រាលឡើង, ១៨– គ្មានខ្យល់ព្យុះបក់បោក, ១៩– មានខ្យល់តិចៗល្មមហើយត្រជាក់ដល់មនុស្សសត្វ, ២០. មហាមេឃបង្អុរភ្លៀង, ២១– ទឹកទំលាយផែនដីផុសហូរឡើង, ២២– ហ្វូងសត្វស្លាបឥតហើរទៅក្នុងអាកាស, ២៣– ទឹកក្នុងស្ទឹងនៅនឹងថ្កល់ដូចទឹកស្រះ, ២៤ ទឹកប្រៃក្នុងសមុទ្រប្រែជាផ្អែម, ២៥– ផ្កាឈូកមានពណ៌ ៥ ដុះកើតក្នុងសមុទ្រស្ទើរនឹងផ្ទៃផែនដី, ២៦– ផ្កាកើតទាំងអស់, ២៧– រុក្ខជាតិ, វល្លិទាំងឡាយ កើតមានផ្កាឈូកចេញតាមដើម, មែក, ទង, ២៨-ឈូកទាំងឡាយ ទម្លាយផែនថ្មផុសឡើងមកមួយកន្លែង មានផ្កាប្រាំពីរ ១ ត្រួតផែនថ្ម, ២៩ មានផ្កាឈូកដុះសំយុងចុះពីអាកាស, ៣០– រុក្ខជាតិនានាមានផ្កាផ្លែក្នុងពេលនោះ, ៣១ ភ្លៀងផ្កាទិព្វមានផ្កាមន្ទាបុស្សជាដើមក៏ធ្លាក់ចុះមក, ៣២–ដូរ្យតន្ត្រីគំបង្គំសំឡេងឯអាកាស ទន់ដ៏យទិព្វបានកើតឡើងដូចគ្នា ពេញទាំងមួយម៉ឺនលោកធាតុ ហើយមានពណ៌និងពន្លឺអស្ចារ្យៗ

ហេតុដ៏ចំឡែកអស្ចារ្យនេះ ហៅថាបុព្វនិមិត្ត ៗ

ស ១៥– នាងសិរិមហាមាយា កាលគេនឡើងហើយ តើធ្វើយ៉ាងណាដែរ ?

ច– កាលព្រះនាងគេនឡើងហើយ ក៏ទូលព្រះស្វាមីដោយសព្វ

គ្រប់ ព្រះស្វាមីបានហៅព្រាហ្មណ៍មកទាយសុបិននិមិត្តថ្វាយព្រះនាង ។

ស ១៩ - ព្រាហ្មណ៍ប៉ុន្មាននាក់ ដែលទាយសុបិននិមិត្តថ្វាយព្រះនាង ? ទាយថាយ៉ាងណា ?

ច — មាន ៦៤ នាក់ ។ ទាំង ៦៤ នោះបានទាយថា ព្រះនាងនឹងមានបុត្រ បើបុត្រនោះនៅជាឃរាវាស នឹងបានជាស្តេចចក្រ, បើយាងចេញបួសនឹងបានត្រាស់ជាព្រះពុទ្ធ ។

ស ២០—ព្រះពោធិសត្វ ទ្រង់គង់ក្នុងគភ៌ដោយអាការៈយ៉ាងណា ? អស់វេលាប៉ុន្មាន? មានអ្នកណាថែរក្សាខ្លះ?

ច - ទ្រង់គង់ពែនព្រះអង្គ បែរភក្ត្រទៅរកខ្នងព្រះមាតា បែរខ្នងទៅខាងផ្ទៃព្រះមាតាអស់វេលា ១០ ខែ មានមហារាជទាំង៤នៅថែរក្សា ។

ស . ២១— ព្រះពោធិសត្វ ទ្រង់ប្រសូតនៅទីណា ? ព្រោះហេតុអ្វី ? នៅថ្ងៃខែឆ្នាំណា ? ពេលថ្មារម៉ោង ?

ច — ប្រសូតនៅសួន លុម្ពិនី ជាឧទ្យានដែលនៅត្រង់ចន្លោះនគរទាំងពីរ គឺ កបិលពស្តុ និងទេវទហៈ ។ ទីប្រសូតនេះ សព្វថ្ងៃហៅថា តំបន់ បាំងដារិយ៉ា ជាទីរហោស្ថានគ្មានមនុស្សនៅឡើយ ។ តាមសេចក្តីដំណាលក្នុងគម្ពីរពុទ្ធសាសនាថា បានជាទ្រង់ប្រសូតនៅទីឧទ្យាន ដែលមិនមែនជាព្រះរាជវាំង ឬជាមជ្ឈមណ្ឌល មានប្រសូតិគ្រឹះដូច្នោះ

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះនៅពេលនោះ ព្រះនាងសិរិមហាមាយា ទ្រង់យាងទៅសួរសុខ
ទុក្ខព្រះមាតាបិតា លុះទ្រង់ដល់ទៅទីនោះ ទ្រង់ក៏ប្រឈួនព្រះទ័យ
ហើយយាងចូលទៅក្រោមដើមសាលព្រឹក្សព្រះនាងក៏ប្រសូតិរាជបុត្រមក ។
ម្យ៉ាងទៀតថា តាមធម្មតារបស់លទ្ធិព្រាហ្មណ៍ បើកាលណាស្ត្រីមានគភ៌
គ្រប់ខែហើយ គឺតែងតែទៅប្រសូតនៅផ្ទះខាងមាតាបិតារបស់ខ្លួនជាដរាប
មិនដែលប្រសូតនៅផ្ទះរបស់ខ្លួន ឬនៅផ្ទះខាងមាតាបិតាក្មេកទេ ។

គោលនាំពីខាងលើនេះ សមស្របគួរឲ្យជឿហើយ តែយើងត្រូវ
ពិចារណាថា បើព្រះនាងចង់យាងទៅសួរសុខទុក្ខឬយាងទៅដើម្បីប្រ
សូតព្រះរាជបុត្រខាងព្រះមាតាបិតា ម្តេចក៏មិនយាងទៅមុនពេលនេះ ?
ព្រោះព្រះនាងជាអគ្គមហេសីនៃព្រះមហាក្សត្រផង ហើយមានព្រាហ្មណ៍
ហោរដែលចេះក្បួនតម្រាយ៉ាងជំនាញៗផង ក៏គង់នឹងដឹងថ្ងៃខែថាព្រះគភ៌
មានប៉ុន្មានខែៗដែរ ម្តេចក៏ទាល់តែព្រះគភ៌គ្រប់១០ខែគត់ ( ពីថ្ងៃពេញ
បូរមីខែអាសាឍ ដល់ថ្ងៃពេញបូរមីខែពិសាខ ) ទើបព្រះនាងយាងទៅ
ហើយយាងចំពេលថ្ងៃត្រង់ទៀតផង ។ បើយ៉ាងនេះ គោលសំ
អាងទាំងពីរខាងលើពុំចាន់សមស្របត្រឹមត្រូវមែនទែនទេ តែយើងអាចសន្និ
ដ្ឋានបានយ៉ាងនេះទៅវិញថា " ព្រះសិទ្ធត្ថកុមារពោធិសត្វ ជាអនាគត
នៃព្រះពុទ្ធអង្គនោះ ជាតួអង្គអស្ចារ្យ ហើយត្រូវតែមានសភាពនិង

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណៈទាំងអស់ប្លែកពីមនុស្សឯទៀតៗយ៉ាងនេះ ។ ដូច្នេះ បានជាពេលទ្រង់ប្រសូតនោះ ព្រះមាតាទ្រង់ឈរ ហើយមានបំណងនឹងទាញមែកសាលព្រឹក្សា ក៏ទោរទន់មកជាប់ព្រះនាងទាញ ព្រះនាងទាញហើយក៏ប្រសូតមកដោយស្រួល ។

**ទ្រង់ប្រសូតនៅសួនលុម្ពិនី នៅពេលថ្ងៃជិតត្រង់ នៃថ្ងៃសុក្រពេញបូរមី ខែពិសាខ ឆ្នាំ ប ។**

ស - ៦៦.- ពេលដែលព្រះពោធិសត្វប្រសូតនោះ ទ្រង់មានលក្ខណៈ និងអាការៈប្លែកដែរ ឬយ៉ាងណា ? មានហេតុគួរឲ្យចំឡែកទេ ?

ច - ពេលដែលព្រះកុមារទ្រង់ប្រសូតនោះ មានសភាពប្លែកពីការប្រសូតនៃមនុស្សធម្មតាគឺ៖

- ព្រះមាតាទ្រង់ឈរទាញមែកសាលព្រឹក្ស,
- ពេលប្រសូតមក មានសុទ្ធាវាសមហាព្រហ្មទាំង ៤ បានយកបណ្ដាញមាសមកទទួលព្រះពោធិសត្វ, មហារាជទាំង ៤ បានទទួលព្រះកុមារពីមហាព្រហ្ម, ពួកស្រីស្នំទទួលយកពីមហារាជទៅទៀត ។
- ព្រះកុមារទ្រង់ចុះពីដៃស្រីស្នំ ហើយយាងទៅដោយព្រះបាទបាន ៧ ជំហាន ទើបលើកព្រះហស្តស្ដាំឡើង រួចទ្រង់បន្លឺព្រះវាចាថា

www.budinst.gov.kh www.elibraryofcambodia.org

« ខ្លួនយើងជាកំពូលនៃលោក, ជាបុគ្គលប្រសើរវិសេសជាងគេនៅក្នុងលោក, ជាចម្បងជាងគេទាំងអស់ក្នុងលោក, ជាតិនេះ ជាកំណើតចុងបំផុតនៃយើង, តទៅយើងលែងកើតទៀតហើយ » ។

- មហាព្រហ្ម បានយកស្វេតច្ឆត្រមកបាំងថ្វាយ,

- សុយាមទេវរាជយកផ្លិតកេមមកបក់ថ្វាយ,

- ទេវបុត្រ១ អង្គកាន់កែវប្រការ,

- ទេវបុត្រ១ អង្គកាន់ស្បែកជើងមាស,

- ទេវបុត្រ១ អង្គកាន់គ្រឿងប្រដាប់សពប់កត្សទាំង៥គឺ ម្កុដ១ព្រះខ័ន១ ស្វេតច្ឆត្រ១, សុពណ៌បាទ១, វាលវិជនី១ ឈរអែម ។

- មានទឹកក្តៅទឹកត្រជាក់ហូរធ្លាក់ពីអាកាសមក លាងមន្ទិលព្រះគភ៌របស់ព្រះនាងសិរិមហាមាយា ។

- មានកើតហេតុចម្លែកអស្ចារ្យ ដូចជាការកម្រើកផែនប្រថពីជាដើមប្រហែលគ្នានឹងពេលទ្រង់ចុះចាប់បដិសន្ធិដែរ ។

ស- ៦៣- ព្រះពោធិសត្វទ្រង់ប្រសូតហើយភ្លាមក៏ចេះយាង, ចេះនិយាយភាសាដូចមនុស្សចាស់នេះ តែក្នុងជាតិនេះឬមានក្នុងជាតិឯណាទៀតដែរ ?

ច. មានពីរជាតិពីមុនទៀតគឺ កាលទ្រង់យកព្រះកំណើតជាព្រះ

www.budinst.gov.kh www.elibraryofcambodia.org

មហោសថ ពេលប្រសូតហើយ ក្លាមព្រះឥន្ទបានយកឱសថទិព្វមកដាក់ក្នុងព្រះហស្តព្រះកុមារ ក៏ក្តាប់ព្រះហស្តហើយលើកឡើង បន្លឺវាចាថា "ម៉ែ នេះជាថ្នាំ" ។

សេដ្ឋីសិរីវឌ្ឍក៏ជាបិតា ដែលមានរោគឈឺក្បាល៧ឆ្នាំ រួចហើយ ១ ព្យាបាលពុំជាសោះ ក៏យកថ្នាំរបស់បុត្រទៅជូនទឹកហើយផឹក បានជាសះស្បើយក្លាម ។ កាលទ្រង់យកកំណើតជាព្រះវេស្សន្តរ (១) ពេលប្រសូតឡើងក្លាម ក៏បន្លឺវាចាសួរមាតាថា "ទ្រព្យក្នុងផ្ទះយើងមានដែរឬ? ខ្ញុំនឹងឲ្យទាន" ។

ដូច្នេះ ក្នុងកំណើតជាពោធិសត្វ ទ្រង់ប្រសូតក្លាមហើយពោលនិយាយក្លាមដូច្នេះ មាន៣ព្រះជាតិ គប់ទាំងជាតិចុងបំផុតនេះផង ។

ស ៤៤– នៅថ្ងៃដែលព្រះពោធិសត្វទ្រង់ប្រសូតនោះ មានអ្វីកើតក្នុងថ្ងៃជាមួយដែរ ហើយមានការទាក់ទងគ្នាយ៉ាងណា ?

ច– មាន មនុស្ស ៤ នាក់គឺ ៖

១– នាងពិម្ពាយសោធរាជាដើម ១ នឹងព្រះអគ្គហើយជារាជធីតាព្រះ

---

១– បានជាមាននាមថា វេស្សន្តរ ( វេស្ស: ពួកឈ្មួញ= អន្តរ=ចន្លោះ) ពីព្រោះកាលនាងផុស្សតី យាងទៅទតភពនៅចន្លោះផ្លូវពួកឈ្មួញក្នុងនគរ ព្រះនាងក៏ព្រះឈឺផ្ទៃហើយប្រសូតបុត្រនៅទីនោះ ។ ព្រះស្វាមីក៏ថ្វាយនាមយ៉ាងនេះទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

បានសុប្បពុទ្ធនៅនគរទេវទហៈ ។ ព្រះនាងនេះបានជាអគ្គមហេសីនៃព្រះពោធិសត្វ ។

២– ព្រះអានន្ទជាបុត្តនៃព្រះសុក្កោទនៈ ជាជីដូន ១ នឹងព្រះអង្គដែរ ហើយពេលក្រោយព្រះអានន្ទបានជាពុទ្ធុបដ្ឋាករបស់ព្រះអង្គ ដែលបានបំរើព្រះពុទ្ធនឹងចេះចាំយ៉ាងស្ទាត់ច្បាស់នូវព្រះពុទ្ធវចនៈទាំងអស់ (១) ។

៣– នាយឆន្នអាមាត្យ · បានជាអាមាត្យហូតទល់ព្រះពោធិសត្វចេញសាងព្រះផ្នួស ។ តាមសេចក្ដីដំណាលថាឆន្នអាមាត្យនេះជាទីទំនុកទុកព្រះទ័យ ទីងជាមនុស្សស្និទ្ធស្នាលនឹងព្រះសិទ្ធត្ថណាស់ គឺហ៊ានចរចាតស៊ូ, ហ៊ានក្រាបទូលរឿងហេតុផ្សេង ៗ ដល់ព្រះអង្គ តាមគំនិតគិតឃើញរបស់ខ្លួន ។ កាលព្រះសិទ្ធត្ថដាស់ឆន្នអាមាត្យឱ្យទៅនាំសេះមកថ្វាយព្រះអង្គនៅពេលអាធ្រាត្រដើម្បីចេញទៅបួស ឆន្នអាមាត្យប្រកែករអើះអ៊ើះ មាត់ករប្រើនថា "មិនដឹងទៅជាទ្រង់យាងទៅណា ទាំងកណ្ដាលកត្រពេលកំពុងងុយដេកយ៉ាងនេះ" ។ តែទោះជាយ៉ាងណាក៏ព្រះសិទ្ធត្ថឥតដែលយកទោសពៃរ៍អ្វីសោះដែរ ព្រោះទ្រង់ដឹងនិស្ស័យ

---

១- ព្រះអានន្ទមានព្រះជន្ម ១២០ ឆ្នាំ គឺព្រះពុទ្ធបរិនិព្វាននៅព្រះជន្ម ៨០ ឆ្នាំ ព្រះអានន្ទគង់នៅ ៤០ ឆ្នាំទៀត ទើបបរិនិព្វានទៅ ។ ព្រះមហាថេរអង្គនេះហើយជាអ្នកឆ្លើយព្រះសូត្រ និងព្រះអភិធម្មនៅពេលធ្វើបឋមសង្គាយនា ។ ទ្រង់បរិនិព្វាននៅលើអាកាស ។

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណៈរបស់គាត់ច្បាស់ ហើយជាអ្នកមានអាយុស្មើគ្នាទៀត ។ ពេលព្រះសិទ្ធត្ថទ្រង់បួសហើយ ។ ឲ្យយកគ្រឿងអលង្ការត្រឡប់មកវិញ ឆន្នអាមាត្យក៏ប្រកែកផង យំស្តាយផងថា ខ្លាចព្រះសុទ្ធោទនៈធ្វើទោស, ជាថ្ងៃក្រោយខ្លួននឹងនៅជាមនុស្សគ្មានទីពឹង ព្រោះព្រះអង្គចេញបួសបាត់យ៉ាងនេះ តែដោយព្រះសិទ្ធត្ថបង្គាប់ ឆន្នអាមាត្យក៏ដឹកសេះ ស្តាយចង្កិចគ្រឿងត្រឡប់មកនគរវិញ ។ ពេលព្រះសិទ្ធត្ថ បានត្រាស់ហើយ ។ ព្រះបាទសុទ្ធោទនៈ បានបញ្ជូនអាមាត្យ ៩ នាក់ឲ្យនាំបរិវារមួយពាន់ ។ ម្នាក់ទៅ ក៏បាត់ដំណឹង ទើបព្រះរាជាបញ្ជូនឆន្នអាមាត្យឲ្យនាំបរិវារ ១ ពាន់ទៅទៀត ព្រោះព្រះរាជាយល់ថា ឆន្នអាមាត្យធ្លាប់ស្និទ្ធស្នាលហើយមិនសូវខ្លាចព្រះរាជបុត្រព្រះអង្គផង ។ ឆន្នអាមាត្យទៅជួប នឹងព្រះសាស្តា ហើយបានបួសជាមួយបរិវារ រួចទើបក្រាបទូលថាព្រះបិតាឲ្យរកសុំនិមន្តព្រះអង្គទៅ ហើយឆន្នអាមាត្យក៏ការណិនាំភិក្ខុទៅកាន់ក្រុងកបិលពស្តុយ៉ាងនេះ ។

ពេលដែលព្រះសាស្តាគង់ព្រះផ្ទះនៅ ឆន្នត្ថេរ ពុំសូវខ្លាចពួកសាវ័កធំៗឡើយ ដោយគិតថា កាលលោកបាននាំព្រះសិទ្ធត្ថចេញបួស ឥតមានអ្នកណាហែហមឡើយ ឥឡូវស្រាប់តែមានមោគ្គល្លាន, សារីបុត្ត, អានន្ទ... ពោរពេញ ។ ព្រះសាស្តាជ្រាបច្បាស់នូវអធ្យាស្រ័យចិត្តរបស់

www.budinst.gov.kh www.elibraryofcambodia.org

ឆន្នត្ថេរឡាស់ ទ្រង់ត្រាស់បន្ទូលទោសហើយផ្តាំថា កាលណាអស់តថាគតទៅត្រូវឲ្យព្រះអានន្ទធ្វើព្រហ្មទណ្ឌ គឺការមិនស្តីនិយាយរក ទើបឆន្នត្ថេរបានមគ្គផលនឹងគេ ។ លុះព្រះសាស្តាបរិនិព្វានហើយ ព្រះអានន្ទក៏ធ្វើព្រហ្មទណ្ឌដល់ឆន្នត្ថេរ ដែលបានដេកគក់សោកធំ ៗ នោះ តាមព្រះពុទ្ធបណ្តាំ ឆន្នត្ថេរភ្ញាក់ស្មារតីហើយប្រឹងស្មឹងស្មាធិ៍ ក៏បានសម្រេចព្រះអរហត្តផលឡើង ។

៤– កាឡុទាយីអាមាត្យ ជាអាមាត្យក្នុងព្រះរាជវាំងកបិលពស្តុដូចឆន្នដែរ ។

មានសេះ ១ គឺសេះកណ្ឋកៈ មានប្រវែងខ្លួន ១៨ ហត្ថជាជំនិះព្រះសិទ្ធត្ថ ហើយបាននាំព្រះសិទ្ធត្ថចេញសាងព្រះផ្នួស ។ ពេលម្ចាស់បួសហើយសេះមានសេចក្តីស្តាយណាស់ ដល់ឆន្នអាមាត្យដឹកមកវិញដល់កណ្តាលផ្លូវក៏បែកទ្រូងស្លាប់ទៅកើតនៅស្ថានតុសិតឈ្មោះកណ្ឋកទេវបុត្ត។

មានដើមពោធិព្រឹក្ស ១ ដើមនៅគយាសីសប្រទេស ជាឈើដែលព្រះសិទ្ធត្ថទ្រង់គង់ហើយ បានត្រាស់នៅក្រោមនោះ ។

មានកំណប់ទ្រព្យ ៤ គឺ ៖

១– សង្ខនិធិ មានសំណុំមាត់ជុំវិញ ១ គាវុត

២– ឯលនិធិ ,, កន្លះយោជន៍

www.budinst.gov.kh www.elibraryofcambodia.org

៣– ឧបលនិធិ " ៣ គាវុត

៤– បុណ្ឌរីកនិធិ " ១ យោជន៍

កំណប់ទ្រព្យទាំងនេះ មានជម្រៅទៅដល់ទីបំផុតផែនដីដូចគ្នា ។ ព្រមទាំងអស់ មនុស្ស, សត្វ, រុក្ខជាតិ ទីងវត្ថុឯទៀតដែលកើតពេលជាមួយនឹងព្រះពោធិសត្វត្រូវជា ៧ ហៅថា សហជាតវត្ថុ ។

**សេចក្តីសន្និដ្ឋាន** - ការសិក្សាខាងមកហើយ អំពីការចុះចាប់បដិសន្ធិ និងការប្រសូតរបស់ព្រះពោធិសត្វនេះហើយ បាននាំឲ្យយើង ដឹងស្គាល់ព្រះពោធិសត្វថាជាបុគ្គលមានលក្ខណៈប្លែកពីមនុស្សដទៃទាំងអស់ ហើយជាហេតុឲ្យយើងសន្និដ្ឋានបានថា ព្រះកុមារនឹងបានជាអគ្គបុគ្គល, ជាកំពូលអ្នកប្រាជ្ញនៅអនាគតកាលមិនខាន ។ ការចាប់បដិសន្ធិ និងការប្រសូតរបស់ព្រះអង្គមានការទាក់ទងទៅនឹងទេវៈ ហើយបង្កើតជាហេតុអស្ចារ្យប្លែកគួរឲ្យស្ងើចសរសើរណាស់ ។

**ឃ្លាភ្ជាប់សេចក្តី** .– បើដូច្នេះនៅអនាគតកាល ព្រះកុមារពិតជានឹងបានជាទីពំនឹងរបស់មនុស្ស, សត្វ, ទេវតា, ព្រហ្មនិងគ្រប់ភពយ៉ាងពិតប្រាកដ ៗ យើងនឹងសិក្សាអំពីលក្ខណៈផ្សេង ៗ និងកុមារវ័យបន្ទាប់ពីការប្រសូតនេះតទៅទៀត ។

x x

x

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ៤

# ព្រះលក្ខណៈ និងកុមារវ័យ

ស. ៤៥– ព្រះពោធិសត្វទ្រង់ប្រសូតហើយ តើគេថ្វាយនាមថាដូចម្តេច ?

ច– ព្រាហ្មណ៍បានថ្វាយនាមថា សិទ្ធត្ថកុមារ ។

ស. ៤៦– ព្រះសិទ្ធត្ថកុមារ មានលក្ខណៈរូបដូចកុមារឯទៀតៗដែរឬប្លែកគ្នា ? បើមានប្លែកសូមអធិប្បាយឲ្យសព្វគ្រប់ ?

ច ព្រះសិទ្ធត្ថកុមារ មានលក្ខណៈរូបពុំដូចកុមារឯទៀតៗឡើយ គឺមាន ៖

លក្ខណរូប៣២គឺ ១ ផ្ទៃព្រះបាទតាំងរាបស្មើ, ២. លើផ្ទៃព្រះបាទមានរូបចក្រ, មានកងនិងដុំ ព្រមទាំងកាំរួមពាន់ហើយមានចន្លោះៗស្មើគ្នា, ៣, មានកែងវែង គឺមួយភាគ ៤ ជាតួកែង ។ ៤ ម្រាមព្រះហស្តនិងម្រាមព្រះបាទវែង ១ គឺម្រាមព្រះហស្តទាំង៤ស្មើគ្នា ឯម្រាមព្រះបាទទាំង ៥ វែងស្មើគ្នា ហើយម្រាមទាំងអស់ទៀវល្អដូចម្សៅដំល្អិត ដែលគេល្មុញលាបប្រេង ។ ៥- ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទទន់ល្មួនដូចសំឡី ។ ៦-ផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាល្អិត ១ ដូចសំណាញ់ ។៧-កព្រះបាទអណ្តែតឡើងហាក់ដូចមិនជាប់នឹងព្រះបាទៗ

www.budinst.gov.kh www.elibraryofcambodia.org

៨- មានស្នូនជើងមូលស្រដៀងនឹងស្នូនសត្វក្រោយ ,  ៩ ទ្រង់អាចឈរ ហើយស្ទាបផ្ទាល់ដោយព្រះហស្តទាំងពីរបាន ដោយមិនបាច់ឱន ។ ១០ មានព្រះអង្គជាតស្ថិតនៅក្រោមស្បូនអង្គជាតគោឈ្មោលឬដំរី ។ ១១- មាន ពណ៌សម្បុរថ្ង ( ឥរីវណ្ណា ) គឺលោះដូចពណ៌មាស ។ ១២ សម្បុរថ្ង ល្អិតស្តួរផង់ហើយនៅលោះស្រិល ធូលីមិនអាចជាប់បាន ។ ១៣- មាន រោមតែមួយ ១ ក្នុងរណ្ដៅមួយ ១ គ្រប់រណ្ដៅ ។ ១៤- មានរោមខៀវ ស្រស់ដូចផ្កាត្រគួន ចុងពីរៀងរឹបកឡើងទៅខាងស្ដាំ ។ ១៥-ព្រះកាយ ត្រង់ដូចកាយព្រហ្ម ។ ១៦- មានសាច់ពក៧កន្លែង ខ្នងព្រះហស្តទាំងពីរ,ខ្នង ព្រះបាទទាំងពីរ ទីនឹកពេញបរិបូណ៌ល្អ កអត់មើលឃើញសរសៃឡើយ; ១៧- ទូព្រះ កាយដែលគួរខ្ពង់,កែង,ស្មា,ដាក់,មូល,សំប៉ែត ក៏ខ្ពង់,កែង,ស្មា, ដាក់, មូល, សំប៉ែតតាមគួរ ។ ១៨- ចន្លោះខ្នងពេញស្និទ្ធតគត, ខូងឡើយ, ១៩- មាន ទ្រង់ទ្រាយព្រះកាយដូចបរិមណ្ឌលដើមជ្រៃ គឺដើមជ្រៃមានដើមនឹងមែក ប្រវែងស្មើគ្នាមិនលើសមិនខ្វះ ។ ២០- ព្រះកន្ធូបសរ ។ ២១- មានសរសៃ ប្រសាទ ៧ ពាន់ល្អិតប្រជុំត្រង់កសម្រាប់ទទួលនាំអាហារទៅផ្សព្វផ្សាយ ក្នុងព្រះកាយឥតវេសចាក់ សូម្បីអាហារ១គ្រាប់តូចប៉ុនគ្រាប់ល្ងក៏ដោយ ។ ២២- មានព្រះចង្កាពេញបរិបូណ៌ប្រហែលនឹងថ្ពាល់ព្រះខែនៃថ្ងៃ១២កើត ។ ២៣-មានព្រះទន្ត ៤០ គត់ គឺលើ ២០, ក្រោម ២០ ។ ២៤-ព្រះទន្តទាំង

www.budinst.gov.kh www.elibraryofcambodia.org

៤០ ករបស្មើល្អ ។ ២៥– ព្រះទន្តទាំង ៤០ ជិតស្និតល្អ ។ ២៦– មានព្រះចង្កូមកែវទាំង ៤ ស្អាត ភ្លឺជាងពន្លឺផ្កាយព្រឹក ។ ២៧ មានអណ្តាតល្មម ប្លែកពីអណ្តាតមនុស្សទាំងពួង ។ ២៨– ព្រះសូរសៀងក្រានក្រអៅដូចសម្លេងរាជសីហ៍ ហើយពីរោះដូចសំឡេងករវិក ។ ២៩- ព្រះនេត្រ ត្រង់កន្លែងខៀវក៏ខៀវស្រស់ដូចផ្កាត្រកៀត, ត្រង់កន្លែងលឿងក៏លឿងដូចផ្កាកណ្ណិកា, ត្រង់កន្លែងដែលក្រហមក៏ក្រហមដូចផ្កាច្បារ ត្រង់កន្លែងដែលស ក៏សត្រចះដូចផ្កាយព្រឹក, ត្រង់កន្លែងដែលខ្មៅក៏ខ្មៅដូចផ្លែក្លាំ ។ ៣០– ដួងព្រះនេត្រថ្លាយង់ដូចភ្នែកកូនគោដែលទើបនឹងកើត ។ ៣១– ព្រះកេមផុះត្រង់ចន្លោះចិញ្ចើមសទន់ដូចសំឡី, ៣២– ព្រះសិរមូលល្អដូចពពុះទឹកឬដូចវត្ថុដែលគេក្រឡឹង ។

អនុព្យញ្ជនៈ ៨០ គឺ ៖ ១– ម្រាមព្រះហស្តនិងម្រាមព្រះបាទមានពណ៌លឿង ។ ២– ម្រាមព្រះហស្តនិងម្រាមព្រះបាទពណ៌ខៀវ, ៣– ម្រាមព្រះហស្តនិងម្រាមព្រះបាទមូលល្អ, ៤– ក្រចកទាំង ២០ មានពណ៌ក្រហម, ៥– ក្រចកទាំង ២០ ងស្មើតឡើង, ៦– ក្រចកមានពណ៌រលោងរលើប, ៧– កព្រះហស្តនិងកព្រះបាទគ្រួតនៅក្នុងសាច់, ៨– ព្រះបាទស្មើគ្នា, ៩– ព្រះដំណើរល្អយាងយាសដូចដំណើរដំរី, ១០– ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍, ១១– ព្រះដំណើរល្អដូចជាដំណើរ

www.budinst.gov.kh www.elibraryofcambodia.org

នៃហង្ស, ១២– ព្រះដំណើរដូចជាដំណើរនៃគោឧសភរាជ, ១៣– បើទ្រង់ឈរ ហើយត្រូវយាងទៅ តែងតែលើកព្រះបាទខាងស្តាំបោះទៅមុនជាដំបូង, ១៤– ព្រះមណ្ឌលជង្គង់មូលល្អ, ១៥– មានព្យញ្ជនៈជាបុរសពេញគ្រប់គ្រាន់ គឺមិនមានកិរិយាដូចស្ត្រីឡើយ, ១៦– ផ្ចិតមិនខូងមិនផត, គឺមូលស្មើល្អ ១៧ ពោះមានសណ្ឋានជ្រៅ, ១៨ ពោះមានសណ្ឋានខ្ចៅវិលទៅខាងស្តាំ (ទក្ខិណាវដ្ដ), ១៩– ភ្លៅទាំងគូមូលល្អ, ២០– ព្រះហស្តទាំងគូល្អ, ២១– ព្រះអវយវៈ ធំតូចទាំងអស់មានលក្ខណៈល្អតាមចំណែកៗ, ២២– សាច់ដែលគួរគ្រាសក៏គ្រាស, ២៣– សាច់មិនយារជ្រួញជ្រីវ ២៤– កាយគ្មានប្រជ្រុយឬគាច់ឡើយ, ២៥– ព្រះកាយាវយវៈសមគ្នាតាមលំដាប់លំដោយលើក្រោម, ២៦– ព្រះកាយបរិសុទ្ធ គ្មានមន្ទិល, ២៧– មានព្រះកម្លាំងច្រើន, ២៨– មានច្រមុះខ្ពស់សម, ២៩– សណ្ឋានច្រមុះល្អ, ៣០– បបូរព្រះឱស្ឋលើ-ក្រោម មិនបានចូលចេញលើសគ្នា ៣១– ព្រះទន្តឥតគ្រឿងសៅហ្មង, ៣២– ព្រះទន្តសម្បុរស័ន្ធ, ៣៣– ព្រះទន្តលើនស្អាត, ៣៤– ព្រះឥន្ទ្រិយ៍ទាំង ៥ បរិសុទ្ធល្អ, ៣៥– ព្រះចង្កូមទាំង ៤ មូលពេញលេញ, ៣៦– វង់ព្រះភក្ត្រមានទម្រង់មូលទ្រវែងសមល្អ, ៣៧– ថ្ពាល់ទាំងគូល្អក្លីថ្លាស្មើគ្នា, ៣៨– អក្ខញព្រះហស្តមានស្នាមជ្រៅ, ៣៩– អក្ខញព្រះហស្តមានស្នាមវែង, ៤០– អក្ខញព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ហស្តមានស្នាមត្រង់, ៤១ អណ្តាញព្រះហស្តមានស្នាមក្រហមរុងរឿង, ៤២- ស្បែព្រះកាយមានពន្លឺជាបរិមណ្ឌល, ៤៣- ថ្ពាល់ទាំងគូពេញកំពុងរៃណាទល្អ, ៤៤- ត្របកព្រះនេត្រទូលាយវែងសម, ៤៥- ព្រះនេត្រប្រកបដោយប្រសាទទាំង៥, ៤៦- ចុងសរសៃព្រះលោមាទាំងឡាយមិនបានវៀច, ៤៧- អណ្តាតមានទម្រង់ល្អ, ៤៨ - អណ្តាតទន់មិនរឹង, ៤៩ - ផោះទាំងគូ មានទម្រង់វែងដូចជាត្របកបទុមជាតិ, ៥០ រន្ធព្រះកមានទម្រង់មូល, ៥១ សរសៃទាំងក្នុងស្អួតឥតរង្រួញ, ៥២ - ផ្ទួរសរសៃទាំងឡាយត្រូតនៅក្នុង សាច់ទាំងអស់ ៥៣ - ព្រះសិរមានទម្រង់ដូចឆត្រកែវ ៥៤ - បរិមណ្ឌលថ្ងាសទូលាយវែងល្មម, ៥៥ - ថ្ងាសមានទម្រង់ដ៏ល្អ, ៥៦ - ចិញ្ចើមមានទម្រង់ដ៏ល្អដូចធ្នូ, ៥៧ - ព្រះរោមចិញ្ចើម មានសរសៃដ៏ល្អិត, ៥៨ - សរសៃព្រះរោម ចិញ្ចើមដុះហ៊ុំសម្រួលរាបទៅដោយលំដាប់, ៥៩ - ព្រះចិញ្ចើមធំល្មម, ៦០ ព្រះចិញ្ចើមវែងផុតចុងព្រះនេត្រ, ៦១ សម្បុរថ្ងៃល្អិតឆ្អារពេញព្រះកាយ, ៦២ ព្រះកាយរុងរឿងទៅដោយសិរី ៦៣ - ព្រះសរីរកាយតែងតែថ្លា មិនស្អាប់សៅហ្មង, ៦៤ - ព្រះសរីរកាយស្រស់ថ្លាដូចផ្កាឈូក, ៦៥ ព្រះសរីរកាយមានសម្ផស្សទន់ក្ងន់, ៦៦ ក្លិនព្រះកាយក្រអូបឈ្ងុយដូចក្លិនផ្កា, ៦៧ - ព្រះរោមមានសរ

www.budinst.gov.kh www.elibraryofcambodia.org

សៃស្ទើក្នុងទាំងអស់, ៦៨ ព្រះលោមមានសរសៃល្អិតឆ្មារ , ៦៩ ព្រះដង្ហើម ចេញចូលល្អិត , ៧០ ព្រះទន្ត មានទម្រង់ល្អហាក់ដូចជាទ្រង់ព្រះ ញញឹមជានិច្ច. ៧១– ក្លិនព្រះទន្តក្រអូបដូចក្លិនឧប្បល, ៧២– ព្រះ កេសាខ្មៅរលោងស្រិល, ៧៣– ព្រះកេសាមានក្លិនក្រអូបឈ្ងុយឈ្ងប់, ៧៤– ព្រះកេសាមានក្លិនដូចជាក្លិននៃផ្កាកោមល, ៧៥ - ព្រះកេសាមាន ទម្រង់មូល តំណព្រះកេស, ៧៦– ព្រះកេសាខ្មៅស្និទ្ធ, ៧៧– សរសៃព្រះ កេសាឆ្មារល្អិត, ៧៨– សរសៃព្រះកេសាស្អូត, ៧៩– សរសៃព្រះកេសា វៃលតំណព្រះកេសនៅខាងស្តាំ, ៨០ - មានព្រះរស្មីគួចក្លាចលើព្រះសិរ ។

## ទ្រង់ប្រកបដោយមង្គល ១០៨ គឺ

ត្រង់ផ្ទៃព្រះបាទទាំងគូប្រកបដោយកង់ចក្រមួយម្ខាង នៅត្រង់កណ្តាលផ្ទៃ ព្រះបាទ ។ កង់ចក្រមានកាំ ១ ពាន់មានកង់ទីងជុំ ។ ខាងក្រៅកង់ចក្រ មានរូបមង្គល ១០៨ យ៉ាងគឺ. ១· រូបលំពែង, ២- រូបកញ្ចក់ផ្ទុះ, ៣- រូប ផ្កាខ្លួនស្រី, ៤· រូបខ្សែសយ, ៥ រូបសង្វារ, ៦ រូបថាសមាស, ៧ រូប ជើងតាំង, ៨- រូបមច្ឆាទាំងគូ, ៩· រូបប្រាសាទ, ១០· រូបកង្វេរ, ១១- រូប សសេរទៀន, ១២· រូបស្វេតច្ឆ័ត្រ, ១៣ រូបព្រះខ័ន, ១៤- រូបផ្លិតស្លឹក ត្នោត, ១៥- រូបផ្លិតកន្ទុយក្ងោក, ១៦ រូបផ្លិតកោមម្រឹគ, ១៧- រូបមកុដ, ១៨- រូបបាត្រ, ១៩- រូបកម្រងផ្កាម្លិះ, ២០- រូបផ្កាឧប្បលខៀវ , ២១- រូបផ្កា

www.budinst.gov.kh www.elibraryofcambodia.org

ឧប្បលស, ២២- រូបផ្កាឧប្បលក្រហម, ២៣- រូបផ្កាឈូកក្រហម, ២៤-
រូបផ្កាឈូកស, ២៥- រូបផ្ទាំងមានទឹកពេញ, ២៦- រូបថាសមានទឹកពេញ
២៧- រូបមហាសមុទ្រទាំង៤, ២៨ រូបភ្នំចក្រវាឡ, ២៩- រូបព្រៃហេម
ពាន, ៣០- រូបភ្នំសុមេរុ, ៣១- រូបព្រះចន្ទ, ៣២- រូបព្រះអាទិត្យ, ៣៣-
រូបពួកផ្កាយនក្ខត្តឫក្ស, ៣៤- រូបមហាទ្វីបទាំងបួន, ៣៥- រូបទ្វីបតូចៗ ទាំង
ពាន់, ៣៦- រូបព្រះបរមចក្រពត្តិរាជនឹងបរិវារ, ៣៧- រូបស័ង្ខទក្ខិណាវដ្ដ,
៣៨- រូបត្រីមាស, ៣៩- រូបចក្រទាំងគូ, ៤០- រូបស្ទឹងទាំងប្រាំពីរ, ៤១-
រូបស្រះធំទាំង ៧, ៤២- រូបភ្នំបរិភណ្ឌទាំងប្រាំពីរ, ៤៣- រូបស្តេចគ្រុឌ,
៤៤- រូបក្រពើ, ៤៥- រូបទង់ជ័យសំពត់ទាំងផ្ទត់, ៤៦- រូបរតនបល្ល័ង្ក,
៤៧- រូបកៅអី, ៤៨- រូបភ្នំកៃលាស, ៤៩- រូបរាជសីហ៍, ៥០- រូបស្តេចខ្លា
៥១- រូបដំរីឯរាវ័ណ្ណ, ៥២- រូបស្តេចវលាហក, ៥៣- រូបវាសុកិនាគរាជ
៥៤- រូបស្តេចហង្ស, ៥៥- រូបមាន់ព្រៃ, ៥៦- រូបគោឧសភរាជ, ៥៧-រូប
ស្តេចដំរីឧបោសថ, ៥៨ រូបស្តេចដំរីឆទ្ទន្ត (ដំរីមានភ្លុក៦) ៥៩- រូបមករ
មាស, ៦០- រូបមហាព្រហ្មមុខ៤, ៦១ រូបផ្ទះមាស, ៦២- រូបអណ្តើកមាស
៦៣- រូបមេគោព្រមទាំងកូន, ៦៤- រូបកិន្នរឈ្មោល, ៦៥- រូបកិន្នរញី,
៦៦- រូបសត្វករវិក, ៦៧- រូបសត្វក្រៀល, ៦៨- រូបសត្វក្ងោក, ៦៩- រូប
សត្វតាក្រពាក, ៧០- រូបស្តេចគ្រហឹត, ៧១-រូបកាមាសួគ៌ទាំង៦ ជាន់

www.budinst.gov.kh www.elibraryofcambodia.org

៧២- រូបសោឡសមហាព្រហ្មទាំង ១៦ ជាន់ ។ រូបទាំងនេះស្ថិតនៅជុំវិញកង់ចក្រត្រង់កណ្ដាល ព្រះបាទទ្វេងស្ដាំដូចគ្នា ។

ស. ២៧. កាលព្រះសិទ្ធត្ថកុមារប្រសូតហើយ តើព្រះបិតាបានធ្វើពិធីអ្វី ថ្វាយដែរ? ប៉ុន្មានថ្ងៃក្រោយពីការប្រសូត ?

ច– ព្រះបិតាបានធ្វើពិធី ១ ដើម្បីអញ្ជើញព្រាហ្មណ៍មកទាយព្រះលក្ខណៈថ្វាយព្រះសិទ្ធត្ថកុមារ ។

ស ២៨ បើដូច្នេះ តើមានព្រាហ្មណ៍ប៉ុន្មាននាក់ ដែលបានទាយលក្ខណៈថ្វាយព្រះកុមារឈ្មោះអ្វីខ្លះ? ទាយជាយ៉ាងណា ?

ច – មាន ៨ នាក់ ឈ្មោះរាមព្រាហ្មណ៍ ១ លក្ខណៈព្រាហ្មណ៍ ១, យញ្ញព្រាហ្មណ៍ ១, ធជព្រាហ្មណ៍ ១, ភោជព្រាហ្មណ៍ ១, សុទត្តព្រាហ្មណ៍ ១, សុយាមព្រាហ្មណ៍ ១ កោណ្ឌញ្ញព្រាហ្មណ៍ ១ (១) ។

ព្រាហ្មណ៍ទាំង ៨ នាក់នោះ, ៧ នាក់ខាងដើម បានទាយតាមដំណើរ ២ យ៉ាង គឺ ថាបើនៅជាឃរាវាសរហូត នឹងបានជាស្ដេចបរមចក្រពត្តិ បើយាងចេញទៅបួសនឹងបានត្រាស់ជា ព្រះសព្វញ្ញុពុទ្ធ ឯកោណ្ឌញ្ញព្រាហ្មណ៍ ដែលមានវ័យក្មេងជាងគេបានទាយថ្វាយតែម៉្យាង

(១) ជាព្រះសុទ្ធោទនៈ យកព្រាហ្មណ៍ចេះ ហោរាសាស្ត្រ ចំនួន ១០៨ នាក់មកប្រជុំគ្នាហើយ ជ្រើសរើសសម្រិតសម្រាំងយកតែព្រាហ្មណ៍ ៨ នាក់ដែលចេះជាងគេឲ្យទាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ថា ព្រះកុមារមុខជាខឹងយាងចេញទៅបួសហើយនឹងបានត្រាស់ជាព្រះពុទ្ធ យ៉ាងពិតប្រាកដ ។ ព្រាហ្មណ៍ ៧ នាក់ខាងដើម មានវ័យចាស់ ជរាក៏ស្លាប់អស់ តែបានផ្តាំកូនរបស់ខ្លួន ឲ្យចេញបួសគ្រប់គ្នា ។ ឯកោណ្ឌញ្ញព្រាហ្មណ៍បានរស់នៅហើយ ចេញបួស ជាមួយកូនព្រាហ្មណ៍ ៤ នាក់ទៀតមានឈ្មោះថា "បញ្ចវគ្គិយភិក្ខុ" ហើយ កាលព្រះពុទ្ធ បានត្រាស់ថ្មីៗ ក៏បានសំដែងធម្មចក្រប្រោសបញ្ចវគ្គិយភិក្ខុ ។ ក៏បាន សម្រេចមគ្គផល ដែលក្នុងចំណោមនោះព្រះកោណ្ឌញ្ញត្ថេរ បានជា រត្តញ្ញូ គឺ ជាអ្នកដ៏ស្គាល់ច្បាស់នូវយាមវេលាត្រីកាល ។

សំ ២៩ – ព្រះកុមារមានគុណវិសេសយ៉ាងណា នៅពេលប្រសូតហើយថ្មីៗ ? មានហេតុកើតដូចម្តេច ?

ច – មានហេតុអស្ចារ្យយ៉ាងនេះ គឺថ្ងៃ១ព្រះកាឡទេវិលតាបស ជាជីតូន របស់ព្រះបាទសិរីសុទ្ធោទនៈបាននិមន្តចូលទៅកាន់ព្រះតំណាក់ ដើម្បីសុំជួប សុំឃើញព្រះកុមារៗព្រះសុទ្ធោទនៈបានឲ្យគេនាំព្រះកុមារមកថ្វាយបង្គំ ព្រះតាបសតែព្រះបាទរបស់ព្រះកុមារបែរជាទៅប្រតិស្ឋានលើជដាតាបស ទៅវិញៗឃើញដូច្នោះតាបសក៏ធ្វើនមស្ការហើយសើចរួចយំៗព្រះសុទ្ធោទន ឃើញដូច្នេះ ក៏ថ្វាយបង្គំព្រះរាជបុត្រ រួចសួរព្រះតាបស ។ ទូលថាអាត្មាសើច ព្រោះតែសប្បាយនឹងព្រះកុមារ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

អាក្នាយំ ព្រោះនឹកថា ខ្លួនចាស់ណាស់ហើយ មុខជាស្លាប់ខានជួបព្រះកុមារ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ទៅអនាគតកាលនោះជាមិនខាន ។

ព្រះកាឡទេវិលតាបស បានទាយព្រះលក្ខណៈព្រះកុមារថា "ពិតជានឹងបានត្រាស់ជាព្រះពុទ្ធមិនខានឡើយ" ។ កាលនិមន្តត្រឡប់ទៅវិញ ក៏ប្រាប់ក្មួយម្នាក់ឈ្មោះនាឡកមាណពឲ្យចេញបួស ដើម្បីនឹងចាំការបានត្រាស់នៃព្រះសិទ្ធត្ថ ។ នាឡកចេញបួសហើយកាលព្រះពុទ្ធបានត្រាស់ឡើង ក៏បានជួបនឹងព្រះអង្គ ។ បានសំដែងមោនេយ្យបដិបត្តិឲ្យស្តាប់ ក៏បានសម្រេចអរហត្តផល ។ ឯព្រះកាឡទេវិលតាបសកាលស្លាប់ទៅ បានទៅកើតក្នុងស្ថានព្រហ្មអរូបភព ។

ម្យ៉ាងទៀត កាលព្រះសិទ្ធត្ថកុមារបានព្រះជន្ម ៧ ថ្ងៃ ទ្រង់បានសម្រេចបឋមជ្ឈាន នៅពេលដែលព្រះបិតាចេញច្រត់ព្រះនង្គ័លហើយទុកព្រះកុមារឲ្យផ្ទំក្រោមដើមព្រីងធំ ។ ព្រះបិតាកាលឃើញព្រះរាជបុត្រគង់ពែនភ្នែនស្ងប់ស្ងាត់តាំងសមាធិដូច្នោះ ក៏ថ្វាយបង្គំម្ដងទៀតជាលើកទីពីរ ។

ស- ៣០- ព្រះសិទ្ធត្ថកុមារ ជារាជបុត្រតោលឬមានបងប្អូនដែរ ?

ច- ព្រះអង្គគ្មានបងប្អូនរួមឧទរមាតាជាមួយទេ ព្រោះពេលព្រះអង្គប្រសូតហើយបាន ៧ ថ្ងៃ ព្រះនាងសិរិមហាមាយាជាព្រះមាតាទ្រង់សោយព្រះទិវង្គតទៅ ។ ទ្រង់មានតែព្រះអនុជរួមបិតាជាមួយពីព្រះអង្គគឺ

www.budinst.gov.kh www.elibraryofcambodia.org

នន្ទកុមារនិងនាងរូបនន្ទា ។

ស- ៣១- ព្រះនាងសិរិមហាមាយាសោយទិវង្គតព្រោះអ្វី ? ទ្រង់បានទៅកើតនៅទីណា ? អ្នកណាទៅថែរក្សាព្រះសិទ្ធត្ថកុមារ ?

ច- ទ្រង់ទៅកើតនៅស្ថានតុសិត ៗ ព្រះនាងឥតមានជម្ងឺអ្វីទេ តែធម្មតារបស់ពុទ្ធមាតាកាលប្រសូតព្រះរាជបុត្រហើយតែងនឹងសោយទិវង្គត-ស្លាប់ យ៉ាងនេះជាឧបមាដូចជាដើមចេក ឬ ដើមអំពៅ កាលមានត្រយូង, មានផ្កាផ្លែហើយ ក៏តែងតែងាប់ ឥតដែលមានត្រយូង ផ្កា - ផ្លែ ជាលើកទីពីរទៀតទេ ម្យ៉ាងទៀតព្រះពុទ្ធមាតាដែលប្រសូតព្រះរាជកុមារហើយ បើនៅមានព្រះជន្មតទៅទៀត ហើយបើព្រះបាទសុទ្ធោទនជាព្រះស្វាមី បានទៅរួមមគ្គសំវាស ព្រះស្វាមីនេះនឹងត្រូវបែកព្រះសិរជា៧ភាគមិនខាន ព្រោះទ្វារយោនីនៃពុទ្ធមាតា ដែលប្រសូតព្រះកុមារហើយជាទ្វារយោនីដ៏ល្អបរិសុទ្ធ ឥតមានបុត្រណាប្រសូតជាលើកទីពីរទេ ប្រសិនបើមានបុត្រណាប្រសូតអំពីព្រះនាងបុត្រនោះក៏នឹងត្រូវបែកព្រះសិរសា ៧ភាគដែរ ។ នេះជាធម្មតារបស់ព្រះពុទ្ធ និងពុទ្ធមាតាគ្រប់ព្រះអង្គទាំងអស់ ។

កាលព្រះនាងសិរិមហាមាយាទិវង្គតទៅព្រះនាងគោតមីទទួលចិញ្ចឹមព្រះកុមារហើយព្រះនាងនេះជាមហេសីទី២របស់ព្រះសុទ្ធោទនៈមានបុត្រ២ គឺនន្ទកុមារ រូបនន្ទាផង ជាម្ដាយមីង(មាតុច្ឆា)របស់ព្រះសិទ្ធត្ថកុមារផង ។

www.budinst.gov.kh www.elibraryofcambodia.org

ស ៣២ – ព្រះសិទ្ធត្ថកុមារជាទីស្រឡាញ់រាប់អានរបស់ព្រះញាតិទេ? គេបានធ្វើអ្វីថ្វាយព្រះអង្គខ្លះ ?

ច – ព្រះអង្គជាទីស្រឡាញ់នៃញាតិណាស់ ព្រះញាតិខាងមាតា ៨០ ពាន់ ខាងបិតា ៨០ ពាន់ សុទ្ធតែបានថ្លែងថា បើព្រះសិទ្ធត្ថបានជាស្តេចក្តី ជាព្រះពុទ្ធក្តី នឹងថ្វាយបុត្រមួយអង្គ ១ ម្នាក់ ៗ

កាលទ្រង់មានព្រះជន្ម ៧ ឆ្នាំ វិស្សកម្មទេវបុត្របាននិម្មិតស្រះបោក្ខរណីប្រកបដោយកែវ ៧ ប្រការថ្វាយ ។ កាលទ្រង់ព្រះជន្ម១៦ ឆ្នាំ ព្រះបិតាបានឲ្យជាងធ្វើប្រាសាទ ៣ ថ្វាយគឺចន្ទប្រាសាទ១មាន៩ជាន់ សម្រាប់គង់នៅហេមរដូវ, កោកនទប្រាសាទ ១ មាន ៥ ជាន់ សម្រាប់គង់នៅគិម្ហរដូវ, កោញ្ចប្រាសាទ ១ មាន ៣ ជាន់ សម្រាប់គង់នៅវស្សានរដូវ ។

ស-៣៣- កាលនៅពីយុវវ័យ តើព្រះសិទ្ធត្ថ បានទៅរៀនសិល្បសាស្ត្រដែរ ? ទ្រង់ចេះសិល្បសាស្ត្រយ៉ាងណាខ្លះ ?

ច – បានរៀនជាមួយអាចារ្យពិស្វាមិត្រដែរ, ទ្រង់ចេះសិល្បសាស្ត្រច្រើន គួរយ៉ាងកាលព្រះបាទសុទ្ធោទនៈត្រាស់បញ្ជាឲ្យព្រះញាតិយកកុលធីតាមកថ្វាយ ពួកញាតិប្រកែកថាព្រះសិទ្ធត្ថមិនចេះសិល្បសាស្ត្រអ្វី ព្រះអង្គក៏សំដែងឫទ្ធិគឺលើកធ្នូដ៏មានកម្លាំង ១ ពាន់ ហើយបាញ់ឡើងលាន់

www.budinst.gov.kh www.elibraryofcambodia.org

កក្រើកព្រះធរណី ។ ពួកសាក្យរាជក៏ខ្លាចព្រះបរិទ្ធត្ថខ្លាំងណាស់ ។

## ការឡើងសោយរាជសម្បត្តិ

ស ៣៤-ព្រះសិទ្ធត្ថកុមារទ្រង់ឡើងសោយរាជសម្បត្តិនៅថ្ងៃ- ខែ - ឆ្នាំណា ? មានមហេសីព្រះនាមអ្វី ? ក្នុងព្រះជន្មប៉ុន្មាន ?

ច - ទ្រង់ឡើងសោយរាជសម្បត្តិនៅថ្ងៃសៅរ៍ ពេញបូរមី ខែអាសាឍ ឆ្នាំឆ្លូវ ដោយមានព្រះនាងពិម្ពាយសោធរា ជារាជធីតានៃព្រះបាទសុប្បពុទ្ធនៅនគរទេវទហៈជាព្រះអគ្គមហេសី ក្នុងព្រះជន្ម ១៦ ព្រះវស្សា ។

**សេចក្តីសន្និដ្ឋាន.** ព្រះលក្ខណៈនិងកុមារវ័យរបស់ព្រះសិទ្ធត្ថរាជកុមារ ពោរពេញទៅដោយអាការៈ និងហេតុពិសេសចម្លែក ៗ នាំឲ្យមនុស្សផងទាំងពួងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមុខជានឹងបានជាទីពឹងពំនាក់នៃសត្វលោកមិនខាន ។

**ឃ្លាភ្ជាប់សេចក្តី.**- បើដូច្នេះពាក្យទំនាយរបស់កាឡទេវិលតាបសក្តី របស់កោណ្ឌញ្ញព្រាហ្មណ៍ក្តី មុខជានឹងបានទៅជាការពិតប្រាកដមិនខាន ពោលគឺព្រះសិទ្ធត្ថមហាបុរសនឹងយាងចេញទៅស្វែងរកមោក្ខធម៌ ក្នុងភេទជាអ្នកបួសក្នុងពេលណា ១ ដ៏ពិតប្រាកដ ។

x x

x

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ៤

## ការចេញសាងព្រះផ្នួស
## និងការធ្វើទុក្ករកិរិយា

ស-៣៤- តាំងពីពេលព្រះសិទ្ធត្ថកុមារប្រសូតហូតដល់ពេលបាន សោយរាជ្យសម្បត្តិនេះ តើព្រះបាទសុទ្ធោទនៈ មានការថប់អារម្មណ៍ ចំពោះរាជបុត្រយ៉ាងណា ? ទ្រង់ធ្វើយ៉ាងណាខ្លះ ? ព្រោះហេតុអ្វី ?

ច- ព្រះសុទ្ធោទនៈជាបិតា មានការថប់អារម្មណ៍យ៉ាងខ្លាំងចំពោះ ព្រះរាជបុត្រតែ ១ ដែលជាទីស្រឡាញ់ពេញព្រះទ័យ ខ្លាចក្រែងតែព្រះ រាជបុត្រយាងចេញទៅបួស ។ ការថប់អារម្មណ៍នេះ ព្រោះព្រាហ្មណ៍ ហោរក្តី កាឡទេវិលតាបសក្តី សុទ្ធតែព្យាករទាយថា "ព្រះសិទ្ធត្ថកុមារ ពិតជានឹងចេញទៅបួសព្រោះឃើញទេវទូតទាំង ៤ ហើយកាលបួសរួច នឹងបានត្រាស់ជាព្រះពុទ្ធមិនខាន" ។ គឺដោយបានដឹងជាមុននេះហើយ ដែលជាហេតុនាំឲ្យព្រះសុទ្ធោទនៈទ្រង់ប្រយ័ត្នខ្លាំងណាស់ គឺហាមដាច់ មិនឲ្យមានមនុស្សចាស់,ឈឺ,ស្លាប់ មកជិតឲ្យព្រះរាជបុត្រឃើញឡើយ ។ មិនតែប៉ុណ្ណោះសោតព្រះអង្គប្រឹងធ្វើយ៉ាងណាដើម្បីឲ្យព្រះរាជបុត្រនៅគ្រង រាជសម្បត្តិជាមហាក្សត្រ នឹងបានជាស្តេចបរមចក្រក្នុងលោកនេះឯង ។ ការប្រឹងនេះគឺដោយបានឮទំនាយរបស់ហោរាផង ដោយការយល់ នឹង

ចំណាន់របស់ព្រះអង្គផង ។

ស ៣៦- ព្រះសិទ្ធត្ថមុននឹងយាងចេញទៅសាងព្រះផ្នួស ទ្រង់បានឃើញអ្វី ? ដោយហេតុយ៉ាងណា ? នៅឯណា ?

ច - ទ្រង់ទតឃើញទេវទូតតាំង ៤ ដែលមកនិម្មិតធ្វើជាមនុស្សចាស់ម្តង ។ ៤ ខែទៀតទ្រង់ទតឃើញមនុស្សឈឺម្តង ។ ៤ ខែកន្លងមកទៀតទ្រង់ទតឃើញមនុស្សស្លាប់ម្តង ។ ៤ ខែទៀតទ្រង់ទតឃើញអ្នកបួសម្តងទៀតនៅក្នុងឧទ្យាន ពេលដែលទ្រង់យាងទៅក្រសាល ។

ស-៣៧- ព្រះសិទ្ធត្ថទ្រង់យាងទៅសាងព្រះផ្នួស ព្រោះតែឃើញទេវទូតតាំងនោះតែម្យ៉ាង ឬព្រោះហេតុផ្សេងដែរ ។

ច - តាមពិតមិនមែនត្រឹមតែទេវទូត ដែលសុទ្ធាវាសទេវតាមកនិម្មិតថ្វាយនោះទេ គឺប៉ុន្តែដោយអភិនីហារបារមីដ៏ចាស់ក្លាផង ដោយព្រះពុទ្ធិញ្ញាណរបស់ព្រះអង្គផង ឯទេវទូតគ្រាន់តែជានិមិត្តរូប ឬជាហេតុនាំឲ្យព្រះអង្គធុញទ្រាន់នឹងឃរាវាសតែប៉ុណ្ណោះ ពោលគឺកាលព្រះអង្គទតឃើញទេវទូតតាំង ៣ ខាងដើម ទ្រង់មានព្រះទ័យភ័យខ្លាចញាប់ញ័រខ្លាំងណាស់ ហើយមានការធុញទ្រាន់ជិនណាយនឹងកាមសុខផង លុះដល់ទ្រង់ទតឃើញទេវទូតទី ៤ គឺភេទអ្នកបួស ទ្រង់ក៏ជ្រះថ្លានឹងភេទនេះយ៉ាងខ្លាំង ហើយក៏មានព្រះទ័យចង់យាងសាងផ្នួសនេះឥតមានអ្វីមកឃាត់

www.budinst.gov.kh www.elibraryofcambodia.org

ឃាំងបានឡើយ ។

ស៣៨ ព្រះសិទ្ធត្ថទ្រង់យាងចេញសាងព្រះផ្នួស ថ្ងៃ ខែ-ឆ្នាំណា ? វេលាថ្វារណា ? ដោយសារអ្វី ? ជាមួយអ្នកណា ? ទ្រង់សោយរាជ្យបានប៉ុន្មានឆ្នាំហើយ ? ក្នុងព្រះជន្មប៉ុន្មាន ? ទ្រង់មានរាជបុត្រាបុត្រីរឺទេ ?

ច– ទ្រង់យាងចេញសាងផ្នួស នៅថ្ងៃព្រហស្បតិ៍ពេញបូរមីខែ អាសាឍ ឆ្នាំថោះ វេលាអធ្រាត្រ ដោយសារព្រះទីនាំងសេះ ឈ្មោះកណ្ឋកៈ មានឆន្នអាមាត្យជូនព្រះដំណើរផង ក្រោយពីពេលទ្រង់សោយរាជ្យបាន ១៣ ឆ្នាំ ក្នុងជន្មាយុ ២៩ ឆ្នាំ ។ តាមសេចក្ដីដំណាលថា នៅពេលថ្ងៃទ្រង់យាងទៅប្រពាតឧទ្យាន លុះត្រឡប់មកវិញទ្រង់ឮ នាងកីសាគោតមីខត្តិយកញ្ញា ទូលថាព្រះនាងពិម្ពាប្រសូតព្រះរាជបុត្រ ហើយ ព្រះសិទ្ធត្ថទ្រង់ដោះគែមុក្តាថ្វាយព្រះនាងនោះ ហើយទ្រង់ឡើងប្រាសាទ ស្រង់សោយរួចផ្ទុំយ៉ាងស្កប់ស្កល់ហួតផុតបឋមយាម ។ តើនឡើងក្នុងមជ្ឈិមយាមទ្រង់ព្រះវិតក្កថា " រាជបុត្រនេះជាចំណងធំណាស់ ,, ហើយទ្រង់ទតទៅឃើញស្ត្រីបាំដេកប្រគរគ្នាដោយអាការៈប្លែក ៗ ជាហេតុនាំឲ្យព្រះអង្គនឹកនឿកក្នុងព្រះទ័យថា ទីនេះពារពេញទៅដោយសាកសព ហើយទ្រង់ដាស់ឆន្នអាមាត្យឲ្យទៅដឹកសេះកណ្ឋកៈមក

www.budinst.gov.kh www.elibraryofcambodia.org

ឯព្រះអង្គទ្រង់យាងចូលទៅក្នុងបន្ទប់នាងពិម្ពា ដោយមានប្រាថ្នានឹងបីពរទើបព្រះរាជបុត្រ តែព្រះនាងពិម្ពាដាក់រាជបុត្រឲ្យផ្ទំក្បែរព្រះនាង, ព្រះមហាបុរសទ្រង់ខ្លាចព្រះនាងពិម្ពាភ្ញាក់ ទ្រង់ក៏យាងចុះពីប្រាសាទដោយព្រះចិន្តាថា "ត្រាស់ក្រោយសឹមជួបកូនបុត្រវិញ,, ។ ព្រះសិទ្ធត្ថរាជទ្រង់យាងគង់លើខ្នងសេះ ហើយជិះចេញទៅដល់ខាងក្រៅប្រាសាទ ទ្រង់ក៏ងាកទតមកព្រះរាជវាំងវិញ ។ ទីនោះមានឈ្មោះថា "អនិវត្តនចេតិយ,, ។

ស ៣៩ · ទ្រង់បរសេះកាត់ទីណាខ្លះ? មានចម្ងាយផ្លូវប៉ុន្មានហើយយាងទៅទ្រង់ព្រះផ្នួសនៅទីណា ? ជួនជួបនឹងអ្នកណាខ្លះទេ ? ទ្រង់មានព្រះបន្ទូលយ៉ាងណាខ្លះដែរ ?

ច– ទ្រង់បរសេះកាត់នគរ ៣ គឺ កបិលព័ស្តុ១ សាវត្ថី១ វេសាលី១ ចម្ងាយផ្លូវ៣០យោជន៍ ខ្ទង់ទៅតាមត្រើយខាងនាយនៃស្ទឹងអនោមា ។ កាលចេញទៅផុតពីព្រះជំណាក់ ទ្រង់ជួបនឹងទេវបុត្រមារមកឃាត់ព្រះអង្គថា "នែព្រះសិទ្ធត្ថ! កុំចេញទៅបួសអី ព្រោះនៅតែ ៧ ថ្ងៃទៀតទ្រង់នឹងបានសម្បត្តិចក្រហើយ,, ព្រះសិទ្ធត្ថឆ្លើយតបថា "នែមារចិត្តបាប! យើងដឹងហើយ តែយើងមិនអាឡោះអាល័យឡើយ ។ មារបៀសចេញទៅ ព្រះអង្គក៏ទ្រង់មានព្រះបន្ទូលថា "គហុលោ=អាត្មាអញត្រូវកហូបាប់ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ស-៤០- តើគួរឲ្យជឿបានថា ទេវបុត្រមានមកឃាត់ព្រះអង្គដែរ ឬយ៉ាងណា ? បើគ្មានទេ តើហេតុនេះមានលក្ខណៈយ៉ាងណាទៅវិញ ?

ឆ- បើតាមការពិចារណារបស់យើងទៅ ឃើញថាគ្មានទេវបុត្តគ្មានមកឃាត់ទេ ព្រោះការដែលព្រះអង្គចេញបួសនេះ គ្មានបញ្ហាអ្វីទាក់ទងនឹងទានដល់ទេវបុត្តមារឡើយ ក៏ប៉ុន្តែតាមគតិដែលថាមានមារមកឃាត់ព្រះអង្គនៅពេលនោះ គឺគំនិតសាក្រក់ឬការស្តាយបន្តិចបន្តួចកើតចេញពីសន្តានព្រះទ័យរបស់ព្រះអង្គផ្ទាល់នោះឯង មកធ្វើឲ្យព្រះបំណងដ៏មុតមាំរបស់ព្រះអង្គឲ្យមានការរារែកខ្លះ ៗ នោះឯង ។ គំនិតសាក្រក់, ការខ្វល់ស្តាយខ្លះ ៗ នេះហើយ ដែលលោកទុកជាមារឬជាចិត្តបាប ។

ស-៤១- ព្រះរាជឱរសព្រះអង្គដែលប្រសូតនៅថ្ងៃព្រះអង្គចេញសាងព្រះផ្នួសនោះតើមាននាមដូចម្តេច ? អ្នកណាថ្វាយនាមនេះ ? ព្រោះហេតុអ្វី ?

ឆ- មាននាមថា រាហុល ។ តាមសេចក្តីដំណាលថា "ពេលឆន្នអាមាត្យត្រឡប់ពីជូនដំណើរព្រះមហាបុរស ដែលយាងទៅសាងព្រះផ្នួសនោះ ក៏បានទូលរឿងហេតុដោយសព្វគ្រប់ ហើយក្រោយពីការស្តីបន្ទោស នឹងតាមការសោយសោកស្តាយព្រះអង្គរួចហើយព្រះបាទសុទ្ធោ-ទនៈ ទ្រង់សួរឆន្នអាមាត្យថា " ព្រះសិទ្ធត្ថមានផ្តាំពាក្យណាដល់បុត្រ-

www.budinst.gov.kh www.elibraryofcambodia.org

ករិយាទេ ? ហើយផ្តាំឲ្យថ្វាយនាមព្រះរាជបុត្តថាអ្វី ៗ ដែរ ? ឆន្នអា-មាត្យទូលថា ឥតផ្តាំអ្វីទេ តែពេលដែលទ្រង់យានចេញផុតទៅពីព្រះរាជវាំងទ្រង់មានព្រះបន្ទូលតែម្នាក់ឯងថា " រាហុលោ រាហុលោ " ប៉ុណ្ណោះ ៗ ព្រះបាទសុទ្ធោទនៈ ទ្រង់ចាប់ព្រះទ័យនឹងវាចានេះ ក៏ថ្វាយនាមព្រះនត្តាថា " រាហុល " នេះឯង ៗ

ស-៤៦. កាលទ្រង់ឲ្យឆន្នអាមាត្យ ដឹកសេះត្រឡប់មកវិញហើយ តើព្រះសិទ្ធត្ថរាជទ្រង់ធ្វើយ៉ាងណាទៀត ? មានអ្នកណាទៅជួយឧបត្ថម្ភក្នុងពិធីសាងព្រះផ្នួសនោះដែរ ?

ឆ—ទ្រង់គង់លើថ្មក្បែរមាត់ស្ទឹងអនោមា ហើយមានព្រះទ័យនឹងកាត់ព្រះកេសា ព្រះខ័នទិព្វធ្លាក់មកថ្វាយព្រះអង្គ ៗ ទ្រង់កាត់ព្រះកេសាដោយព្រះអង្គឯងឲ្យសល់ប្រវែងតែពីរធ្នាប់ប៉ុណ្ណោះ ៗ លុះកាត់រួចហើយទ្រង់អធិដ្ឋានមោលីរួចបោះទៅក្នុងអាកាស ៗ គ្រានោះព្រះឥន្ទ្រាធិរាជយកប្រអប់កែវមកទ្រព្រះកេសារួចយកទៅបញ្ចុះក្នុងចូឡាមណីចេតិយ នៅស្ថានតាវត្តិង្ស ៗ សូមបញ្ជាក់ថាព្រះកេសាព្រះអង្គទ្រង់កាត់តែម្តងនេះប៉ុណ្ណោះ រហូតទល់បរិនិព្វាន ឥតកាត់ទៀតទេ ហើយព្រះកេសាប្រវែងពីរធ្នាប់នោះ នៅតែដដែលដោយវិលព័ទ្ធព្រះកេសនៅខាងស្តាំយ៉ាងល្អ ៗ

លុះកាត់ព្រះកេសារួចហើយឃដិការមហាព្រហ្មបានយកបរិក្ខារ៨មុខ

មកថ្វាយគឺ ស្បង់ ១, ចីពរ ១, សង្ឃាដី ១, បាត្រ ១ កាំបិតកោរ ១ បំពង់ម្ជុល ១, វត្ថពន្ធចង្កេះ ១, តម្រងទឹក ១, ។ ឯសំពត់ដែលទ្រង់ស្លៀកនោះមហាព្រហ្មបានយកទៅបញ្ចុះទៅទុស្សចេតិយ ដែលមានកំពស់ ១២ យោជន៍ នាព្រហ្មលោក ។

ស-៦៣- ការយាងចេញទៅសាងព្រះផ្នួសរបស់ព្រះសិទ្ធត្ថរាជ ជាហេតុចំឡែកអស្ចារ្យណាស់ព្រោះទ្រង់នឿយណាយក្នុងរាជសម្បត្តិ , ក្នុងកាមសុខ និងដោយមានព្រះរំពឹងថាទ្រង់ស្វែងរកមោក្ខធម៌ផង តែមានមនុស្សខ្លះយល់ថា ថ្វីព្រះរាជកំណើតជាវិចទៀតចង្អល់ ហើយដោយព្រះញាតិខ្លះធ្វើបុករុកគួនផង តើរឿងនោះពិតឬទេ ហើយតើព្រះសិទ្ធត្ថរាជយាងចេញបួសដោយមានហេតុអ្វីជាធំ ? ចូរធ្វើអត្ថាធិប្បាយពន្យល់ឲ្យល្មមស្តាប់បាន ?

ច— ព្រះសិទ្ធត្ថអគ្គបុគ្គល ជាតួអង្គមានលក្ខណៈប្លែកពីមនុស្សឯទៀត ៗ ទាំងអស់ ចាប់តាំងពីពេលទ្រង់ចាប់ព្រះបដិសន្ធិរហូតដល់ប្រសូតតាំងព្រះសរីរកាយ និងចរិយា, កាយវិការរបស់ព្រះអង្គក៏ប្លែកពីតួអង្គឯទៀត ៗ ដែរ ។ លក្ខណៈ ដ៏ចម្លែកនេះគឺការបង្ហាញឲ្យយើងដឹងយល់បានថា ព្រះអង្គនឹងបានទៅជាអ្វីមួយដែលប្លែក ហើយប្រសើរវិសេសលើសពីព្រះបាទ របស់ព្រះអង្គជាព្រះរាជាសោយរាជសម្បត្តិនោះ

មិនខាន ៗ បើនិយាយពោលទៅដល់ព្រះរាជាដែលព្រះអង្គទ្រង់ចន្ទិឡើង នៅពេលប្រសូតរួចភ្លាមនោះ ក៏អាចដឹងបានថាព្រះអង្គនឹងទៅជាអគ្គបុគ្គល ជាបរមសាស្តាចារ្យនៅក្នុងលោកជាមិនខានដែរ ។

ដូច្នេះ ការដែលព្រះអង្គចេញបួសនោះ ថាជាការដែលព្រះអង្គមាន ព្រះទ័យនឿយណាយក្នុងកាមសុខ, ក្នុងរាជសម្បត្តិនោះ ជាការសមរម ដែរហើយ ព្រោះព្រះឋានៈរបស់ព្រះអង្គដែលមានក្នុងរាជសម្បត្តិនោះពុំ ទាន់សមគ្នានៅឡើយ គឺព្រះអង្គត្រូវតែស្វែងរកផ្លូវ ១ ទៀត ដើម្បីសាង សេចក្តីសុខ និងដើម្បីធ្វើប្រយោជន៍ដល់មនុស្សលោក និងទេវតាក្នុងត្រៃ ភព ។ ឋានៈថ្មីនោះគឺការចេញបួស ដើម្បីស្វែងរកមោក្ខធម៌នេះឯង ។

ផ្ទុយទៅវិញ ការពោលថាព្រះអង្គចេញសាងព្រះផ្នួសដោយមានការ ក្រគួនថ្នាំដោយអាក់អន់ព្រះទ័យនឹងព្រះញាតិណា ១ នោះជាការពុំសមហេតុ ផលឡើយ ព្រោះបើយើងនឹកគិតទៅដល់អភិនីហារនិងការកសាងបារមី របស់ព្រះអង្គពីអតីតជាតិនោះ យើងនឹងបានដឹងថា គោលបំណងរបស់ ព្រះអង្គមានតែ ១ គឺការចេញស្វែងរកមោក្ខធម៌ក្នុងភេទជាអ្នកបួសជាតាបស ឫសីក្តី, ជាអ្វីៗក្តីនោះឯង ហើយការស្វែងរកអោក្ខធម៌នោះ ទោះខ្លួនមាន ឋានៈជាអ្វីក៏ដោយ ក៏ត្រូវតែលះបង់ចោលឲ្យអស់ ។

ដោយសារបុមក ទោះជាព្រះអង្គមានបញ្ញាញាណដ៏មោះមុតក្តី,

www.budinst.gov.kh www.elibraryofcambodia.org

មានព្រះឋានៈនឹងសេចក្ដីសុខដ៏ខ្ពស់លើសលុបក្ដី មានចំណង់ណា១ចង់ដ៏ផាប់យ៉ាងណាក្ដី, មានចំណេះវិជ្ជាប្រចាំព្រះអង្គដ៏ច្រើនក្ដី ក៏ព្រះអង្គពុំយករបស់ទាំងនោះជាធំ ជាប្រធាននៃសេចក្ដីសុខរបស់ព្រះអង្គ និងសម្រាប់ផ្ដល់ឲ្យផលផ្ទៃដៃ មានតែព្រះសព្វញ្ញុ ១ ប៉ុណ្ណោះ ដែលជាទីប្រាថ្នារបស់ព្រះអង្គ ។ ការចេញសាងព្រះផ្នួសនេះ មិនមែនទើបតែនឹងផ្ដើមព្រះទ័យឡើងក្នុងពេលនេះទេ ក៏ប៉ុន្តែជាយូរណាស់មកហើយ ដែលព្រះអង្គតែងនឹកគិត តែការនឹកគិតនោះ ស្ថិតនៅត្រង់ការលះសម្បត្តិនិងអ្វី ១ ផ្សេងទៀតទាំងអស់ ហើយចេញទៅរកទីស្ងប់ស្ងាត់ ដើម្បីតាំងសេចក្ដីព្យាយាមពឹងរកផ្លូវត្រាស់ដឹងនោះឯង បានសេចក្ដីថា ការចេញបួសដោយការលះបង់សម្បត្តិនានា គឺកើតចេញពីសហជញ្ញាណ, ពីការភ្ញាក់រលឹកដោយព្រះអង្គឯងតែម្យ៉ាង ឯការឃើញទេអ្នកបួស ដែលទេវទូតបានបង្ហាញដល់ព្រះអង្គនៅទីឧទ្យាននោះ គ្រាន់តែជាឧបករណ៍មួយជួយបន្ថែមគំនិតឲ្យព្រះអង្គខ្លះតែប៉ុណ្ណោះទេ ។

ស-៤៤– តាមទំនាយរបស់ព្រាហ្មណ៍ក្ដី តាមសំដីរបស់មារដែលឃាត់ព្រះអង្គក្ដី ថាព្រះអង្គបើនៅជាឃរាវាស នឹងបានជាស្ដេចបរមចក្រវត្តិ បើយាងទៅបួសនឹងបានជាព្រះពុទ្ធ, ថានៅ ៧ ថ្ងៃទៀតទ្រង់នឹងបានជាស្ដេចចក្រ ។ ចូរឆ្លើយបង្ហាញហេតុផលទៅមើល តើឫទ្ធានុភាពនៃ

www.budinst.gov.kh www.elibraryofcambodia.org

ផាសុកតឿនព្រះហឫទ័យព្រះអង្គគ្រប់ពេល ឥតមានអ្នកណាបន្ទុំឡើយ ។

ស.៤៩ – ពេលទ្រង់ព្រះផ្នួសហើយថ្មី ៗ តើព្រះអង្គបានធ្វើយ៉ាងណាខ្លះ ? អ្នកណាដែលបានជួបនឹងព្រះអង្គជាដំបូង ? បាននិយាយយ៉ាងណាខ្លះនឹងព្រះអង្គដែរ ?

ច - ទ្រង់យាងទៅគង់នៅអនុបិយម្ពវ័ន ហើយទ្រង់មិនសោយអាហារចំនួន ៧ ថ្ងៃ ដោយសេចក្តីសុខកើតអំពីបព្វជ្ជា ។ លុះថ្ងៃទី ៨ (ថ្ងៃព្រហស្បតិ៍ ៨ កើត ខែអាសាឍ) ហើយស្តេចចូលទៅបិណ្ឌបាតក្នុងនគររាជគ្រឹះ ។ ពួករាជបុរសបានឃើញព្រះមហាបុរសមានព្រះអាការចម្លែក ក៏ទៅទូលព្រះបាទពិម្ពិសារ ។ បើកព្រះបង្អួចទតមើលឃើញចម្លែក ក៏ចាត់ឲ្យរាជបុរសតាមឃ្លាំមើល ។ ព្រះមហាបុរសកាលបានភត្តល្មមហើយ ក៏និមន្តទៅគង់ក្នុងញកភ្នំបណ្ឌវៈ ហើយប្រារព្ធឆាន់ចង្ហាន់ ។ រាជបុរសលបមើលឃើញអាការៈចម្លែក ក៏មកទូលព្រះបាទពិម្ពិសារវិញតាមដំណើររឿង ។ ទ្រង់ព្រះសណ្តាប់ហើយព្រះរាជាក៏យាងទៅភ្នំបណ្ឌវៈដោយព្រះអង្គឯង ហើយបានជួបនឹងព្រះមហាបុរសទ្រង់សាកសួររឿងហេតុសព្វគ្រប់ ព្រះរាជាទ្រង់សុំឲ្យព្រះពោធិសត្វសោយរាជ្យពាក់កណ្តាល តែព្រះពោធិសត្វមិនទទួលដោយបានទូលដំណើររឿងសព្វគ្រប់ ។ ព្រះបាទពិម្ពិសារទូលព្រះពោធិសត្វថា បើព្រះអង្គបានត្រាស់ហើយ សូមទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ស្តេចបរមចក្រនិង ពុទ្ធានុភាព ខាងណាមានគុណវិសេសជាង ព្រោះហេតុអ្វី ?

ចៈ- សម្បត្តិទាំងពីរនេះ ព្រះអង្គនឹងបានសម្បត្តិណា ១ មិនខាន គឺបើមិនយាងទៅបួស ក៏ត្រូវតែបានជាស្តេចចក្រ បើយាងទៅបួសនឹងបានជាព្រះពុទ្ធអង្គ ក៏ប៉ុន្តែឋានៈស្តេចចក្រ និងឋានៈព្រះពុទ្ធផ្សេងគ្នា ហើយធ្វើផលឲ្យសត្វលោកក៏ផ្សេងគ្នាដែរ គឺស្តេចចក្រធ្វើប្រយោជន៍បានចំពោះតែមនុស្ស ហើយឲ្យបានតែសម្បត្តិមនុស្សនិងសម្បត្តិសួគ៌តែប៉ុណ្ណោះ ឯព្រះពុទ្ធអង្គវិញទ្រង់បានធ្វើប្រយោជន៍ទូទៅចំពោះមនុស្សសត្វ ទេវតា ឥន្ទព្រហ្ម ហើយអាចដឹកនាំពួកសត្វលោកឲ្យបាននិព្វានសម្បត្តិដែលជាស្ថានបរមសុខទៀត ។ ត្រង់នេះហើយដែលជាគោលបំណងនៃព្រះពុទ្ធ-អង្គ ដែលទ្រង់បានបំពេញចរិយា ៣ គឺ លោកត្ថចរិយា, ញាតត្ថចរិយា និងពុទ្ធត្ថចរិយា ។ ដូច្នេះ បានជាព្រះអង្គកាលយាងចេញទៅពីព្រះរាជវាំងបន្តិច ហើយមានព្រះទ័យនឹកដល់សម្បត្តិបរមចក្រនោះ ក៏មានព្រះទ័យ ១ មកកំចាត់បង់ចេញវិញ ហើយយាងទៅទ្រង់ព្រះផ្នួសទាល់តែបាន ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ការចេញសាងព្រះផ្នួសរបស់ព្រះសិទ្ធត្ថមហាបុរស គឺជាការចាំបាច់ ដែលការភ្ញាក់រលឹករបស់ព្រះអង្គផ្ទាល់បាន

www.budinst.gov.kh www.elibraryofcambodia.org

មកក្រាបសុំព្រះករុណាជាព្រាមមុនគេ ។ ព្រះពោធិសត្វក៏ទ្រង់ទទួលព្រមហើយព្រះរាជាក៏យាងចូលទៅព្រះរាជវាំងវិញ ។

ស.៤៦ ព្រះពោធិសត្វទ្រង់យាងទៅកន្លែងណាទៀត ? ទ្រង់ដែលទៅរៀនជាមួយគ្រូអាចារ្យណាដែរ ? ឬព្រះអង្គស្វែងរកធម៌តែ ១ ព្រះអង្គឯង ?

ច– ទ្រង់និមន្តចេញពីក្រុងបណ្ណារះ ឆ្ពោះទៅអាស្រមបទ អាឡារៈតាបស ហើយទ្រង់សិក្សានិងចំរើនបានសមាបត្តិ ៧ រួចនិមន្តទៅកាន់សំណាក់ឧទកតាបស ហើយទ្រង់ចំរើនបានសមាបត្តិ ៨ រួចក៏ទ្រង់សួររកឬសគល់នៃធម៌វិសេស ៗ នឹងតាបស ។ តាបសឆ្លើយមិនរួច ព្រះពោធិសត្វទ្រង់សន្និដ្ឋានថា "ផ្លូវនេះមិនមែនជាផ្លូវត្រាស់ដឹងទេ" ទើបទ្រង់យាងចេញពីទីនោះឆ្ពោះទៅកាន់ឧរុវេលនិគម ហើយតាំងស្មឹងស្មាធិ៍ដើម្បីស្វែងរកសម្ពោធិញ្ញាណតែ ១ ព្រះអង្គឯងនៅទីនោះ ។

ស.៤៧- នៅឧរុវេលនិគម ព្រះពោធិសត្វទ្រង់ធ្វើយ៉ាងណាខ្លះ ? អស់រយៈវេលាប៉ុន្មាន ? មានអ្នកណានៅជាមួយដែរ ?

ច– ទ្រង់តាំងសេចក្ដីព្យាយាមដ៏ធំ (មហាបធាន) ដើម្បីស្វែងរកសម្មាសម្ពោធិញ្ញាណ ដោយការរិះរកតែងគិតពិចារណាតាមព្រះបញ្ញាញាណរបស់ព្រះអង្គផ្ទាល់ ចំពោះហេតុផលផ្សេង ៗ ។ លុះទ្រង់ធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងនេះហើយមិនបានឃើញផលអ្វីមួយនោះ ទ្រង់បានកាន់ព្យាយាមតែ
តែខ្លាំងហើយតឹងតែងណាស់ទៅទៀត ដោយទ្រង់ព្យាយាមបន្ថយព្រះ
ក្ដាហារបន្តិចម្ដងៗរហូតដល់ឈប់សោយអ្វីទាំងអស់ ។ គឺនៅពេលនោះ
ហើយដែលព្រះអង្គមានព្រះសរីរកាយស្គមស្គាំងនៅសល់តែស្បែកដណ្ដប់
ឆ្អឹង ហើយទ្រង់ដួលផ្កាប់លើព្រះធរណីស្ដុកស្ដឹង ។ ត្រង់នេះហើយដែល
យើងស្ដាប់ដឹងមកថា "ទ្រង់ធ្វើទុក្ករកិរិយា" គឺការបំពេញព្យាយាមដ៏តឹង
តែងកម្រមានអ្នកណាធ្វើបានដូចព្រះអង្គ ។ នៅពេលដែលព្រះអង្គដួល
នោះ មានសេចក្ដីដំណាលថា: ព្រះឥន្ទបានយកពិណមានខ្សែ៣ទៅ
ដេញថ្វាយព្រះពោធិសត្វស្ដាប់, ព្រះឥន្ទបានរឹតខ្សែ១ធូរពេក ដេញឥត
ពីរោះ គឺរឹតខ្សែ១តឹងពេក ហើយដេញទៀត ក៏ឥតពីរោះ ទើបរឹតខ្សែ ១
ចុងក្រោយយ៉ាងល្មមមិនធូរមិនតឹង ក៏មានសំឡេងពីរោះ ។ ព្រះពោធិសត្វ
ស្ដាប់ហើយក៏ពិចារណាថា: អាត្មាអញបានធ្វើព្យាយាមតឹងពេកបានជា
មិនបានត្រាស់ដូចខ្សែពិណដែលរឹតតឹងពេក ក៏គ្មានសំឡេងពីរោះ ហេះ
ទើបព្រះអង្គទ្រង់ត្រឡប់មកឆាន់ចង្ហាន់វិញ ញុំាំងព្រះសរីរកាយឱ្យមាន
សម្ផស្សស្រស់ដូចដើម ។

ពេលដែលព្រះពោធិសត្វធ្វើមហាបធានទិងធ្វើទុក្ករកិរិយាអស់រយៈពេ
ល៦ឆ្នាំនោះ មានភិក្ខុ៥អង្គគឺ: ភទ្ទិយៈ១, វប្បៈ១, មហានាម១, អស្ស-

ផង (ទាំង៤អង្គនេះជាកូនព្រាហ្មណ៍៤នាក់ដែលទាយលក្ខណៈព្រះសិទ្ធត្ថ
មារ) និងព្រះកោណ្ឌញ្ញៈ១ (ជាអ្នកទាយលក្ខណៈព្រះពោធិសត្វដោយផ្ទា
ដែលបានចេញបួស ហើយតាមទៅនៅបំរើព្រះអង្គនៅឧរុវេលនិគ
ហៅថា បញ្ចវគ្គិយភិក្ខុ ។ ប៉ុន្តែកាលភិក្ខុទាំង៥អង្គ បានឃើញព្រះព
ធិសត្វត្រឡប់ឆាន់អាហារវិញនោះ ក៏នាំគ្នាចេញចោលព្រះអង្គ ទៅគ
នៅព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី រដ្ឋកាសី ចម្ងាយ
១៨យោជន៍ដោយយល់ឃើញថា ព្រះសិទ្ធត្ថ ប្រឹងអត់អាហារហើយនៅ
មិនបានត្រាស់ ចុះទម្រាំត្រឡប់ឆាន់អាហារវិញដូច្នេះ មុខជាលែងបា
ត្រាស់ដឹងរួចហើយ ។

ស.៤៨– ពេលដែលព្រះអង្គដួលលើព្រះធរណីនោះ មានដំណាល
ព្រះឥន្ទ្រយកពិណមានខ្សែ៣មកដេញថ្វាយ ទើបព្រះពោធិសត្វមានស្មា
គិតពិចារណារកហេតុផលខុសត្រូវបាន ។ តើរឿងនេះពិតឬទេ ? 
ពិតតើទីងទាត់ថា ព្រះពោធិសត្វជាអ្នកមានបញ្ញាច្រើនជាងមនុស្សសាមញ្
បានដែរ ?

ច– តាមពិតមិនមែនដូច្នេះទេ ការដែលអដ្ឋកថាចារ្យ ឬ ចាស់
តែងដំណាលយ៉ាងនេះ គឺជាការប្រៀបធៀបឲ្យងាយស្ដាប់តែប៉ុណ្ណោ
តែតាមពិតពុំដូច្នោះឡើយ គឺពេលព្រះអង្គអស់ព្រះកាយពលខ្លាំងពេ

www.budinst.gov.kh www.elibraryofcambodia.org

ហើយដួលស្លក់ស្តិនលើព្រះធរណីនោះ ព្រះអង្គនៅតែមានស្មារតី, មានវិញ្ញាណញាណគ្រប់គ្រាន់នៅឡើយ ហើយព្រះអង្គក៏ពិចារណាដោយហេតុ ៣ យ៉ាងគឺ ទី ១ ទ្រង់ពិចារណាថា បើទ្រង់ប្រព្រឹត្តធូរពេក ទ្រង់ក៏ពុំបានត្រាស់ដឹងនូវធម៌ណា ១ ដែរ ដូចជាខ្សែពិណដែលគេតែធូរពេកក៏គ្មានសូរសៀងពីរោះ, ទី ២ ទ្រង់ពិចារណាថា បើទ្រង់ប្រព្រឹត្តតឹងពេកក៏នាំឲ្យអត្តកិលមថៈមិនអាចកេធម៌ណា ១ ឃើញដែរ ដូចខ្សែពិណដែលគេរឹតតឹងពេកក៏គ្មានសម្លេងពីរោះនោះឯង ។ ទី ៣ ទ្រង់ពិចារណាថា បើផ្លូវធូរពេកក៏មិនបានត្រាស តឹងពេកក៏មិនបានត្រាស មានតែផ្លូវកណ្តាលមួយប៉ុណ្ណោះទើបបានត្រាស ដូចខ្សែពិណដែលគេតែល្មមមិនតឹងពេកធូរពេកក៏មានសម្លេងពីរោះ ដូច្នេះគួរព្រះអង្គដើរតាមផ្លូវកណ្តាលវិញ ។ លុះពិចារណាយ៉ាងនេះហើយ ទ្រង់ក៏ត្រឡប់សោយអាហារតាមវិធីដ៏ល្មម ។ ផ្លូវតឹងពេកហៅថា អត្តកិលមថានុយោគ គឺការប្រព្រឹត្តធ្វើកាយឲ្យលំបាកលំបិន, ផ្លូវកណ្តាលគឺ មជ្ឈិមាបដិបទា គឺការប្រតិបត្តិយ៉ាងសមគួរ ជាកណ្តាលមិនតឹងមិនធូរ ។ រឿងនេះមានផលយ៉ាងវិសេសនៅពេលទ្រង់បានត្រាសជាព្រះសម្ពុទ្ធ ។

ដូច្នេះ គ្មានព្រះឥន្ទ្រឯណាមកដេញពិណថ្វាយព្រះអង្គទេ, បើដូច្នោះមែន ព្រះអង្គបែរជាអ្នកគ្មានប្រាជ្ញាស្មារតី គ្មានវិចារណញ្ញាណទៅវិញ

ហើយការត្រាស់ដឹងរបស់ព្រះអង្គ ទៅជាការត្រាស់ដឹងដោយមានគេដឹកនាំ ទៅវិញដែរ គឺព្រះអង្គមិនមែនជាសម្មាសម្ពុទ្ធឡើយ ផ្ទុយទៅវិញ ការពិចារណាឃើញដោយការយកខ្សែពិណមកធ្វើជាគ្រឿងប្រៀបធៀបនោះ ជាវិចារណញ្ញាណដែលផុសចេញពីផ្ទៃហឫទ័យរបស់ព្រះអង្គផ្ទាល់តែម្តង ៖

ស. ៤៩ – ការធ្វើទុក្ករកិរិយារបស់ព្រះអង្គ មានផលប្រយោជន៍ខ្លះដែរ ឬគ្មានប្រយោជន៍ទេ បានជាព្រះអង្គលះបង់ទៅវិញ ?

ឆ - គ្មានប្រយោជន៍សោះទេ នៅពេលដែលព្រះអង្គមិនទាន់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ តែមានប្រយោជន៍ធំសំខាន់នៅពេលដែលបានត្រាស់ដឹងរួចហើយ គឺមានប្រយោជន៍ក្នុងការប្រៀនប្រដៅសត្វលោកទូទៅ ដែលច្រើនស្វែងរកធម៌ដោយការធ្វើខ្លួនឱ្យលំបាកវេទនា ឧទាហរណ៍ ពេលដែលទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ ទ្រង់បានលើកយកអត្តកិលមថានុយោគនេះមកបង្ហាញហេតុផលដល់បញ្ចវគ្គិយភិក្ខុឱ្យឃើញច្បាស់ថា ការស្វែងរកផ្លូវត្រាស់ដឹងដោយធ្វើខ្លួនឱ្យលំបាកមានការអត់អាហារជាដើមនោះ ជាផ្លូវខុស ។ ដូច្នេះ បានជាតថាគតលះបង់វិធីនោះចោល ហើយស្វែងរកការត្រាស់ដឹងដោយផ្លូវកណ្តាល គឺបានរកឃើញធម៌ពិតមែន ។

ស. ៥០– តាំងពីព្រះពោធិសត្វទ្រង់យាងចេញសាងព្រះផ្នួសហើយ

www.budinst.gov.kh www.elibraryofcambodia.org

ប់ពេលនេះ តើព្រះអង្គទ្រង់យាងទៅកាន់ក្រុងកបិលពស្តុឬទេ ? តើ
ះបិតា , នាងពិម្ពានិងញាតិវង្ស ដែលជួបប្រទះនឹងដំណឹងយ៉ាងណាខ្លះដែរ?

ប - ប្រាំមួយឆ្នាំកន្លងផុតទៅ ព្រះអង្គពុំដែលយាងទៅកាន់ក្រុង
ពិលពស្តុសោះទេ ទាំងព្រះបិតា ក៏ញាតិវង្សក៏ពុំមាននរណាដែលតាម
សាកសួរយ៉ាងណាៗនោះឡើយ ព្រោះមនុស្សជំនាន់នោះ មានការ
ជឿថា មនុស្សដែលកាត់កោរសក់ដូចព្រះពោធិសត្វនោះ ជាអមង្គល
១ បើទោះជាត្រឡប់មកវិញក្នុងពេលដែលមិនទាន់បានត្រាស់ដឹង ដើម្បី
កាន់ផលសម្បត្តិវិញ ក៏គ្មាននរណាគេរាប់រកឡើយ ក៏ប៉ុន្តែព្រះបិតា
នាងពិម្ពាក្តី នៅតែសង្ឃឹមរកព្រះអង្គជានិច្ច ហើយតែងដឹងដំណឹង
ឮច្បាស់ថាព្រះអង្គទ្រង់ធ្វើអ្វីៗ ការនឹងប៉ះទៀតផង ជាពិសេសគឺទ្រង់នៅ
ជឿថា ព្រះសិទ្ធត្ថបើមិនទាន់បានត្រាស់ដឹងទេ នឹងមិនវិលត្រឡប់ឡើយ
ក៏ដូចកាលព្រះអង្គអត់ឃ្លានហើយដួលលើព្រះធរណី មានទេវតា
ពួកមារបានទៅប្រាប់ព្រះបាទសុទ្ធោទនថា ព្រះសិទ្ធត្ថដួលស្លាប់ហើយ
ព្រះរាជាពុំជឿឡើយ ។ ចំណែកខាងនាងពិម្ពាវិញ នាងនៅតែមាន
ពយ៉ាងរឹងប៉ឹងហើយស្មោះត្រង់ចំពោះព្រះភស្តាជាដរាប គួរយ៉ាង
លបានឮថា ព្រះសិទ្ធត្ថទ្រង់ផ្ទំលើផ្ទាំងថ្មក្តី ដោយមិនក្រាលថ្នក្តី
ហារក្តី នាងក៏ឈប់ផ្ទំលើសិរីយសយនា , ដោយរឹតសៅហ្មង ,

មិនសោយអាហារតាមព្រះកំស្ដាំដែរ ។ មានពួកសាក្យខ្លះ មាន ព្រះទ័យប្រតិពទ្ធព្រះនាង ហើយចង់បាននាងជាទេពី កំព្រះនាងមិន ព្រមដាច់ខាត ស្ងួតនៅមេម៉ាយយ៉ាងអភ័ព្វជាមួយបុត្រតូចជានិច្ច ។ ដោយសារបមកព្រះពោធិសត្វ ទើបញាតិនឹងបានជួបសុខទុក្ខគ្នាទៅវិញ ទៅទៀតយ៉ាងច្បាស់ គ្រាន់តែមិនបានជួបគ្នាតែប៉ុណ្ណោះ ។

**សេចក្ដីសន្និដ្ឋាន** -- ដូច្នេះការយាងចេញសាងព្រះផ្នួស ទឹង ការបំពេញទុក្ករកិរិយារបស់ព្រះសិទ្ធត្ថពោធិសត្វ នៅក្នុងព្រៃស្មសានក្នុង ថេរវេលា ៦ ឆ្នាំកន្លងទៅនេះ ស្ថិតនៅក្នុងគោលបំណងតែ ១ គឺការ ស្វែងរកសម្ពោធិញ្ញាណ ដើម្បីជាប្រយោជន៍ដល់សព្វសត្វនេះឯង ហើយសកម្មភាពដែលព្រះអង្គបានបំពេញហើយ បើនៅលើផ្លូវខុស ក៏ព្រះអង្គទ្រង់ភ្ញាក់ស្មារតីឡើងវិញដោយព្រះអង្គឯង ឥតមានអ្នកណាមួយ ទៅដាស់តឿនព្រះអង្គឡើយ ហើយទ្រង់ប្រឹងកែប្រែព្រះគំនិតតទៅទៀត ដើម្បីយាងទៅតាមផ្លូវត្រូវវិញ ។

**ឃ្លាភ្ជាប់សេចក្ដី** -- ថិរវេលា ៦ ឆ្នាំកន្លងផុតទៅ ជាការល បាកបំផុត ក្នុងសកម្មភាពប្រយុទ្ធនឹងអវិជ្ជា ដើម្បីស្វែងរកវិជ្ជា សម្មាសម្ពោធិញ្ញាណនេះឯង ។ ថ្ងៃ ១៣ កើតខែពិសាខកន្លងផុតទៅ ថ្ងៃ ១៤ កើតចូលមកដល់ ព្រះពោធិសត្វជាម្ចាស់នៅតែគង់នៅក្នុងព្រះ

www.budinst.gov.kh www.elibraryofcambodia.org

លេខនិគម ដើម្បីតាំងសតិបញ្ញាសុទ្ធិស្មាធិរកមោក្ខធម៌ជានិច្ច ប៉ុន្តែពេលនេះព្រះទ័យនឹងស្មារតីរបស់ព្រះអង្គ បែរតែក្លាយទៅឡើង ៗ ជាលំដាប់ ៗ ដូច្នេះសេចក្ដីសង្ឃឹមក្នុងការព្យាយាមនេះ មុខជាបានសម្រេចមិនខាន ពោលគឺព្រះអង្គដែលប្រឹងស្វែងរកសម្មាសម្ពោធិញ្ញាណនេះ មុខជានឹងបានឃើញដឹងស្គាល់ក្នុងអនាគតកាលនេះយ៉ាងពិតប្រាកដ ។

x

x x

## ដំណឹង

បន្ទាប់ពីសៀវភៅប្រស្នាពុទ្ធប្បវត្តិពិស្ដារនេះទៅ នឹងមានផ្សាយចេញនូវសៀវភៅ ៖

១–ប្រវត្តិពុទ្ធសាសនា និងសង្គាយនា ៨,

២–ប្រស្នាវិន័យ សំរាប់ភិក្ខុសាមណេរ,

៣ ធម៌ឧបស្ថារ និងវិន័យឧបាសក

រៀបរៀងដោយ សែម-សូរ

# ហេតុអស្ចារ្យ
# នៅមុនពេលត្រាស់ដឹង

ស-៩១- ថ្ងៃណាជាថ្ងៃមុនពេលត្រាស់ដឹងនៃព្រះពុទ្ធជាម្ចាស់ ? ទ្រង់មានហេតុហេតុយ៉ាងណាក្នុងព្រះអង្គផងឬទេ ?

ច- ថ្ងៃ១៤កើតខែពិសាខរហូតដល់កណ្តាលអាធ្រាត្រ និងដើមថ្ងៃ១៥កើតខែពិសាខ គឺចាប់ពីដើមអាធ្រាត្រ ( បន្ទាប់ពីថ្ងៃ១៤កើតទៅ ) ជាថ្ងៃមុនពេលត្រាស់ដឹងជាព្រះសម្ពុទ្ធនៃអង្គព្រះសិទ្ធត្ថពោធិសត្វ ។ នៅពេលទៀបភ្លឺ គឺដើមថ្ងៃ១៥កើតខែពិសាខ ព្រះអង្គទ្រង់សុបិនចម្លែកអស្ចារ្យ ជាហេតុនាំឲ្យព្រះអង្គយល់ និងកំណត់ក្នុងព្រះទ័យថា: ព្រះអង្គពិតជានឹងបានត្រាស់ដឹងជាមិនខាន ។

ស-៩២.- សុបិនចម្លែកនោះយ៉ាងណាខ្លះ ? ទ្រង់រកអ្នកណាទាយឲ្យទេ ? ហើយមានសេចក្តីសន្និដ្ឋានយ៉ាងណាទៅវិញ ?

ច - សុបិននោះមាន៥ប្រការយ៉ាងនេះគឺ ៖

១ ទ្រង់ឃើញថា ព្រះអង្គផ្ទំផ្ងារលើមហាប្រឹថពីជាក្រឡាបន្ទំ , មានភ្នំហេមពាន្តជាខ្នើយ , ហើយព្រះហស្តឆ្វេងសណ្ដូកទៅក្នុងមហាសមុទ្រទិសខាងកើត, ព្រះហស្តស្តាំសណ្ដូកចុះក្នុងមហាសមុទ្រទិសខាងលិច

www.budinst.gov.kh www.elibraryofcambodia.org

ព្រះបាទទាំងគូសណ្ដូកចុះក្នុងមហាសមុទ្រទិសខាងត្បូង ទ្រង់ផ្ទុំបើកព្រះនេត្រ ហើយឃើញពន្លឺភ្លឺហូតដល់នគរព្រហ្ម ។

២ – ទ្រង់ទតឃើញស្មៅចិញ្ចៀនដុះចេញពីផ្ចិតហើយលូតឡើងទៅលើរហូតអាកាសវេហាស៍ ។

៣ – ទ្រង់ទតឃើញពួកដង្កូវមានក្បាលខ្មៅខ្លួនស វារឡើងពីចុងព្រះបាទរហូតទល់ជង្គង់ ។

៤ - ទ្រង់ទតឃើញសត្វបក្សីពួកមានពណ៌សម្បុរផ្សេងៗហើរមកពីទិសទាំង៤ មកក្រាបទៀបព្រះបាទព្រះអង្គ ហើយក៏មានសម្បុរសដូចគ្នាទាំងអស់ទៅវិញ ។

៥ - ទ្រង់ឃើញថា ទ្រង់យាងចង្ក្រមលើភ្នំលាមកដ៏ធំ តែព្រះបាទមិនប្រឡាក់លាមកនោះឡើយ ។

កាលទ្រង់តើនឡើងហើយទ្រង់ដឹងថា ព្រះអង្គនឹងបានត្រាស់ ទ្រង់ក៏ទាយសុបិននិមិត្តនោះដោយព្រះអង្គឯងថា៖

–ការផ្ទុំលើផែនដី គឺការបាននូវសម្មាសម្ពោធិញ្ញាណ ,

–ភ្នំហេមពានជាខ្នើយ គឺការបាននូវខ្នើយ សព្វញ្ញុតញ្ញាណ ។

– ការសណ្ដូកព្រះហស្តនិងព្រះបាទក្នុងមហាសមុទ្រ ជាបុព្វនិមិត្តនៃការសំដែងធម្មចក្រ ដល់មនុស្សនិងទេវតា ។

www.budinst.gov.kh www.elibraryofcambodia.org

—ការផ្ទំផ្ងារលើផែនដី ជាបុព្វនិមិត្តនៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ ឲ្យផ្ងារឡើង ។

—ការផ្ទំបើកព្រះនេត្រ ជាបុព្វនិមិត្តនៃការបាននូវទិព្វចក្ខុ ។

—ការឃើញធ្នូរពន្លឺភ្លឺដល់កំពូលព្រហ្ម ជាបុព្វនិមិត្តនៃអនាវរណញ្ញាណ ។

—ការឃើញតិណជាតិដុះអំពីផ្ចិត ជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គ ។

—ការឃើញថា ដង្កូវវារឡើងជាបុព្វនិមិត្តនៃបរិស័ទទាំង ៤ ដែលដល់នូវត្រៃសរណគមន៍ស្មើជីវិត ។

—ការឃើញសត្វបក្សី៤ពួកប្រែក្លាយខ្លួនជាបុព្វនិមិត្តនៃត្រកូលទាំង៤ចេញបួសហើយប្រព្រឹត្តតាមធម៌វិន័យរបស់ព្រះអង្គ ។

—ការយាងចង្ក្រមលើភ្នំលាមក ជាបុព្វនិមិត្តនៃចតុប្បច្ច័យជាលាភសក្ការៈដែលកើតឡើងដល់ព្រះអង្គ តែព្រះទ័យមិនជាប់ជំពាក់ក្នុងលាភសក្ការៈនោះឡើយ ។

ស.៤៣.— នៅព្រឹកនៃថ្ងៃ ១៥ កើតខែពិសាខនោះ ព្រះពោធិសត្វទ្រង់យាងទៅណាទៀត ? ទ្រង់បានធ្វើអ្វីខ្លះ ?

ច—ព្រឹកនោះ ព្រះពោធិសត្វទ្រង់ជម្រះព្រះកាយហើយ ក៏រៀបចំ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គប្រថិមទ្ធទៅគង់នៅក្រោមដើមព្រះជ្រៃ ១ ជិតទុរវេលនិគមនោះឯង ដើម្បីរង់ចាំពេលនឹងត្រាច់ទៅបិណ្ឌបាត្រ ។ នៅទីនោះព្រះអង្គក៏បានទទួលមធុបាយាសអំពីនាងសុជាតា ជាធីតានៃសេនកុដុម្ពិកដែលមានលំនៅ នៅភូមិ ១ ជិតទុរវេលនិគមនោះឯង ។

ស.៨៤. នាងសុជាតាបានថ្វាយមធុបាយាសដល់ព្រះបរមពោធិសត្វនោះ គឺជាការថ្វាយតាមធម្មតារៀងរាល់ថ្ងៃឬទើបនឹងថ្វាយថ្ងៃនេះទេ ? មានរឿងហេតុយ៉ាងណាខ្លះដែរ ? នាងសុជាតាស្គាល់ព្រះអង្គឬទេ ?

ច. ក្នុងរឿងនេះ យើងអាចឆ្លើយតាមប្រកពពីរយ៉ាងគឺ ៖

ទី ១.– មានសេចក្ដីពណ៌នាថា "កាលនាងនៅក្រមុំ នាងបានធ្វើការបន់ស្រន់បួងសួងប្រាថ្នានូវហេតុពីរយ៉ាងគឺ ៖

ក–នាងប្រាថ្នាសុំឲ្យបានស្វាមី មានជាតិត្រកូលស្មើគ្នា ហើយមានចិត្តប្រកបដោយធម៌ទៀតផង ។

ខ–នាងប្រាថ្នាសុំឲ្យបានកូនប្រុសជាដំបូង ហើយឲ្យកូនប្រុសនោះស្ដាប់បង្គាប់មាតាបិតានិងជាកូនប្រកបដោយធម៌ ។ បើនាងបានដូច្នោះមែន នាងនឹងធ្វើពលីកម្មណា ១ មានតម្លៃ ១ សែនថ្វាយដល់ទេពតាក្បែរដើមព្រះជ្រៃផែល ។

សេចក្ដីប្រាថ្នាទាំងពីរនេះ បានដូចបំណងមែន លុះដល់ពេលមុន

ថ្ងៃពេញបូណ៌មី ខែពិសាខនោះ នាងបានឲ្យនាយគង្វាលគោនាំមេគោមួយពាន់ក្បាលទៅលែងឲ្យស៊ីក្នុងព្រៃឈើឯម ហើយដល់ពេលល្ងាចនាងឲ្យយកការដោះ ៥០០ ទៅគ្រងទឹកដោះមេគោ ៥០០ ហើយយកទៅឲ្យមេគោ ២៥០ ទៀតផឹក ៗ នាងឲ្យធ្វើយ៉ាងនេះរហូតទល់សល់មេគោ ៨ ក្បាល ក៏ឲ្យគេគៀតយកទឹកដោះពីមេគោទាំង ៨ មកដើម្បីធ្វើមធុបាយាស គឺទំផ្អែមដូចទឹកឃ្មុំ ៗ កាលគេយកកាផន់ទៅជិតដោះមេគោ ទឹកដោះក៏ហូរចេញមកដោយខ្លួនឯង ៗ នាងសុជាតាឃើញដូច្នោះក៏ចាត់ចែងធ្វើដោយដៃខ្លួនផ្ទាល់ ៗ ពួកចតុលោកបាល, មហាព្រហ្ម, ព្រះឥន្ទ្រនឹងទេវតាជានានាបានចុះមកជួយក្បោចក្រាន, ជួយបាំងស្វេតច្ឆត្រ, ជួយថែរក្សា និងជួយបន្ថែមឱជារសមកដាក់ក្នុងមធុបាយាសនោះ នៅពេលដែលនាងសុជាតាបានចំអិនមធុបាយាស ៗ នាងសុជាតាឃើញហេតុអស្ចារ្យប្លែកដូច្នោះ ក៏ប្រាប់ទាសីម្នាក់ឈ្មោះនាងបុណ្ណាឲ្យទៅបោសសំអាតគល់ព្រះជ្រៃជាមុន ៗ នាងបុណ្ណា បានដើរទៅជិតដើមជ្រៃ ក៏បានឃើញព្រះពោធិសត្វដែលកំពុងគង់ពីខាងក្រោមដើមជ្រៃពីខាងកើត បែរព្រះភក្ត្រទៅកើតទតលោកធាតុ មានរស្មីដូចពណ៌មាសផ្សាយពីព្រះកាយ ក៏ស្មានថាជាទេវតាចុះមករង់ចាំទទួលមធុបាយាសលាបំណន់របស់នាងសុ-ជាតា នាងក៏រត់ត្រឡប់ទៅប្រាប់នាងសុជាតាថា ទេវតាចុះមករង់ចាំង

គល់ព្រះព្រៃឯណោះ សូមនាងប្រញាប់ឡើង ៗ នាងសុជាតាបាន យកកាថ៍មាសតម្លៃ ១ សែនមកដាក់មធុបាយាស រួចតាក់តែងខ្លួនហើយ ក៏ទូលដើរសំដៅដើមព្រះព្រៃភ្លាម ៗ

ដូច្នេះក្នុងរឿងទី ១ នេះ នាងសុជាតា ពុំស្គាល់ព្រះបរមពោធិសត្វ ទេ គឺនាងស្មានព្រះបរមពោធិសត្វថាជាទេវតាទៅវិញ ៗ

ទី ២.- មានសេចក្ដីដំណាលថា នាងសុជាតាស្គាល់ព្រះបរមពោធិ-សត្វយ៉ាងជាក់ច្បាស់ណាស់ គឺឧរុវេលនិគមនោះជាស្រុកទេសរបស់នាង ព្រៃដែលព្រះពោធិសត្វគង់តាំងធម៌ និងផ្ទះនាងនៅជិតល្មមហើយព្រះពោធិ សត្វធ្លាប់យាងទៅភូមិនាង ដើម្បីបិណ្ឌបាត្រស្ទើរតែរាល់ថ្ងៃ ឯនាងក៏ធ្លាប់ប្រ គេនភត្ត, ធ្លាប់គោរពព្រះពោធិសត្វថាជាអ្នកប្រុស មានគុណធម៌នៅ ក្នុងព្រះអង្គផង ៗ លុះដល់ថ្ងៃមុនថ្ងៃពេញបូណ៌មីនោះ នាងគិតថា" ព្រះ សិទ្ធត្ថជាសមណៈ ប្រឹងគង់ធ្វើធម៌នៅជិតភូមិស្ថាននាងជាយូរហើយ ៗ ធ្លាប់និមន្តមកបិណ្ឌបាត្រនៅផ្ទះនាងជាញឹកញាប់ណាស់ បិតានាងក្ដី ប្ដី នាងក្ដី ក៏មានសេចក្ដីស្រឡាញ់រាប់អាននិងគោរពព្រះសិទ្ធត្ថដូចជានាងដែរ តែ ៦ ឆ្នាំមកហើយ នាងពុំដែលបានភោជនាហារផ្ញើប្រគេនព្រះសិទ្ធត្ថ ឲ្យបានឆ្ងាញ់ម្ដងសោះ ដូច្នេះនៅថ្ងៃពេញបូណ៌មីខែពិសាខនេះ គួរអញ ធ្វើមធុបាយាសប្រគេនព្រះសិទ្ធត្ថឲ្យបានឆ្ងាញ់ម្ដង,, រួចនាងក៏ចាត់ចែង

ដូចនិយាយមកខាងដើមដើម្បីយកទៅថ្វាយព្រះពោធិសត្វ នៅក្រោមព្រះជ្រៃជាទីដែលទ្រង់តែងតែគង់នៅរៀងរាល់ព្រឹក មុនពេលចេញទ្រង់បិណ្ឌបាត្រ ។

ដូច្នេះក្នុងរឿងទី ២ នេះបញ្ជាក់ឲ្យឃើញថា នាងសុជាតាស្គាល់ព្រះពោធិសត្វដោយជាក់ច្បាស់ ហើយនាងប្រគេនមធុបាយាសនោះជាការសម្តែងសេចក្តីគោរពចំពោះគុណធម៌របស់ព្រះអង្គតែប៉ុណ្ណោះ តែឥតបានបែបបទអ្វីឡើយ ឯនាងបុណ្ណាជាប្អូននាងសុជាតា មិនមែនជាអ្នកបំរើទេ ។ រឿងទាំងពីរនេះ សូមឲ្យអ្នកសិក្សាពិចារណាផងទៀតចុះ ។

ស. ៩៩ ព្រះពោធិសត្វទទួលភត្តពីនាងសុជាតានោះ ដោយអាការៈយ៉ាងណា ទ្រង់សោយភ្លាម ឬ យកទៅសោយនៅទីណា ? ទ្រង់ធ្វើយ៉ាងណាខ្លះ ?

ច – កាលនាងសុជាតាលើកភាជន៍មធុបាយាសប្រគេន ព្រះអង្គទ្រង់បែររកបាត្រដែលឃដិការមហាព្រហ្មប្រគេនក៏មិនឃើញ នាងសុជាតាដឹងហេតុដូច្នោះ ក៏ប្រគេនទាំងភាជន៍នោះទៅព្រះអង្គ ។ ទទួលហើយទ្រង់មិនទាន់សោយភ្លាមទេ ទ្រង់កាន់ភាជន៍មធុបាយាសនោះយាងទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ហើយដាក់ភាជន៍មធុបាយាសលើឆ្នេរស្ទឹង រួចទ្រង់យាងចុះស្រង់ទឹក ហើយទើបឡើងមកសោយមធុបាយាស តែមុននឹងសោយ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ពូតជាដុំតូចៗ ប៉ុនគ្រាប់ត្នោត បាន ៤៩ ដុំតូច រួចទើបសោយ ៗ ទ្រង់សោយអស់ទាំង ៤៩ដុំតូច រួចក៏ចុះយកភាជន៍នោះចុះទៅក្នុងស្ទឹង ហើយផ្សងថា " បើអាត្មាអញបានត្រាស់ដឹងមែន សូមឲ្យភាជន៍មាសនេះអណ្តែតច្រាសទឹកទៅ ,, ផ្សងរួចក៏បោះភាជន៍មាសទៅក្នុងទឹកស្ទឹង ភាជន៍មាសបានអណ្តែតឡើងបញ្ច្រាសទឹកទៅបាន៨០ហត្ថ ទើបលិចចុះៗ ព្រះអង្គកាន់តែជ្រាបច្បាស់ថាទ្រង់នឹងបានត្រាស់យ៉ាងពិត ប្រាកដ ៗ

ស. ៩៦– ភាជន៍មាសលិចចុះទៅដល់ទីណា ?

ច – ភាជន៍លិចចុះទៅដល់ពិភពកាឡនាគ ហើយទង្គិចនឹងភាជន៍មាស ៣ របស់ព្រះពុទ្ធ ៣ ព្រះអង្គពីមុនក្នុងកប្បនេះ រួចក៏ស៊កសៀតចូលខាងក្រោមភាជន៍ទាំង ៣ នោះ ៗ

ស. ៩៧ មានអ្នកណាបានដឹងឮខ្លះ ? បានធ្វើយ៉ាងណាដែរ ?

ច - មានស្តេចកាឡនាគ ( នាគខ្មៅ ) បានឮភាជន៍ទង្គិចគ្នា ក៏ភ្ញាក់ថា ៖ ពីម្សិលមិញព្រះពុទ្ធត្រាស់១អង្គ ថ្ងៃនេះមានព្រះពុទ្ធត្រាស់១អង្គទៀត ៗ និយាយរួចក៏ពោលសរសើរពុទ្ធគុណដោយប្រការផ្សេងៗ ៗ

ស. ៩៨.– ពុទ្ធបរិស័ទយើងខ្លះកាលណាធ្វើបុណ្យពុទ្ធាភិសេក តែងធ្វើពិធីថ្វាយចង្ហាន់ព្រះនៅពេលយប់ ដោយមានជំនឿថា ព្រះអង្គពាល់តែឆាន់ចង្ហាន់នាងសុជាតា ទើបបានត្រាស់ ៗ តាមរឿងពិត តើ

ព្រះអង្គបានត្រាស់ ព្រោះតែទ្រង់បានឆាន់ចង្ហាន់នាងសុជាតា ឬ យ៉ាងណា ? ព្រោះហេតុអ្វី ?

ច — ព្រះអង្គបានត្រាស់ដឹង មិនមែនដោយសារបានឆាន់ចង្ហាន់មធុបាយាសរបស់នាងសុជាតានោះទេ គឺបានត្រាស់ដោយពុទ្ធការកធម៌ និងការចំរើនស្មឹងស្មាធិ៍របស់ព្រះអង្គតែប៉ុណ្ណោះ ប៉ុន្តែពុទ្ធបរិស័ទយើងខ្លះ មានជំនឿកាន់ច្រឡំយ៉ាងខ្លាំងថា ព្រះអង្គបានត្រាស់ដោយការឆាន់មធុបាយាសរបស់នាងសុជាតា ។ តាមពិត ការថ្វាយចង្ហាន់ដល់ព្រះអង្គ នៅពេលបញ្ចប់នៃពិធីបុណ្យពុទ្ធាភិសេកដូច្នេះជាកំហុស១ធំណាស់ ឯការយល់ជឿនិងប្រកាន់ថាព្រះអង្គបានត្រាស់ ដោយសារការឆាន់ចង្ហាន់នាងសុជាតាដូច្នោះគឺត្រូវមានកំហុសមានទោសដូចដែរ ។ បើធ្វើចង្ហាន់ថ្វាយ គឺគួរធ្វើថ្វាយវេលាព្រឹក ហើយផ្សាយនោះ គ្រាន់តែធ្វើឡើងដើម្បីទុកជាទីរលឹកដល់ថ្ងៃនៃការបានត្រាស់ដឹងរបស់ព្រះពុទ្ធអង្គតែប៉ុណ្ណោះ បានហើយ ព្រោះនាងសុជាតាជាស្ត្រីម្នាក់ដែលបានជួបបានថ្វាយចង្ហាន់ដល់ព្រះបរមពោធិសត្វនៅថ្ងៃដែលព្រះអង្គបានត្រាស់ដឹង គ្មានអ្នកណាមានភ័ព្វដូចនាងឡើយ ។ ម្យ៉ាងទៀត យើងមិនមែនបដិសេធចង្ហាន់នាងសុជាតាថាគ្មានប្រយោជន៍នោះឡើយ គឺមានប្រយោជន៍ខ្លាំងណាស់ ព្រោះជាចង្ហាន់មានរសជាតិ ហើយកាលព្រះអង្គឆាន់អស់ហើយ ក៏គាត់

www.budinst.gov.kh www.elibraryofcambodia.org

ខានឆាន់ ៤៩ ថ្ងៃនៅពេលត្រាស់ដឹងថ្មីៗ ក៏ដោយមានឧទុជាសេនៃចង្ហាន់ នោះជួយឧបត្ថម្ភព្រះកាយព្រះអង្គ ១ ចំណែកដែរ តែមិនមែនបានត្រាស ដោយសារតែឆាន់ចង្ហាន់របស់នាងនោះឡើយ គឺដោយបារមីរបស់ព្រះ អង្គទៅវិញ ។

ស ៥៩. កាលព្រះពោធិសត្វទ្រង់សោយមធុបាយាសនិងបណ្តែត កាដមាសរួចហើយ តើព្រះអង្គយាងទៅគង់នៅទីណា ? បានជួបនឹង អ្នកណាដែរ ?

ច — ទ្រង់ប្រថាប់សំរាកព្រះកាយនៅក្នុងសាលវ័នក្បែរស្ទឹងនេ — រញ្ជរា លុះដល់ពេលល្ងាចទើបទ្រង់យាងទៅកាន់ដើមពោធិព្រឹក្ស ។ នៅតាមផ្លូវទ្រង់បានជួបនឹង សោត្ថិយព្រាហ្មណ៍ ដែលកំពុងច្រូតស្មៅសំរាប់ ប្រក់ ។ តាមធម្មតា ព្រាហ្មណ៍កាលកំពុងធ្វើអ្វី ហើយបានជួបនឹងអ្នក បួស គឺតែងតែឲ្យវត្ថុនោះ ដូច្នេះបានជាសោត្ថិយព្រាហ្មណ៍ បានថ្វាយស្មៅ សម្រាប់ប្រក់ (ស្គាបុស្ស) ៨ ក្តាប់ដល់ព្រះពោធិសត្វ ដើម្បីសំដែង សេចក្តីគួរសម ។ ព្រះពោធិសត្វ ទទួលយកស្មៅនោះហើយ គឺយាងសំ ដៅទៅគល់ពោធិព្រឹក្ស រួចយកស្មៅដែលព្រាហ្មណ៍ថ្វាយទៅក្រាលហើយ គង់ពីលើ ។

ស — ៦០— ដើមពោធិព្រឹក្សនោះនៅឯណា ? ដុះពីកាលណា?

www.budinst.gov.kh www.elibraryofcambodia.org

មានអាយុនិងកំពស់ប៉ុន្មានដែរ ? ព្រះអង្គទ្រង់គង់ពីខាងណា ហើយទ្រង់ធ្វើយ៉ាងណាទៀត មានហេតុកើតដូចម្ដេចខ្លះ ? ចូររៀបរាប់ត្រង់កន្លែងនេះឲ្យសព្វគ្រប់តាមការចេះដឹង !

៥- ដើមពោធិព្រឹក្សនោះ នៅឧរុវេលានិគមគយាសីសប្រទេស បានដុះនៅថ្ងៃដំណាលគ្នានឹងព្រះពោធិសត្វទ្រង់ប្រសូត មានអាយុ៣៥ឆ្នាំហើយ មានកំពស់៥០ហត្ថ ។ កាលព្រះបរមពោធិសត្វយាងទៅដល់ទ្រង់គង់នៅពីខាងត្បូង, រួចគង់ពីខាងលិច, រួចគង់ពីខាងជើងហើយបែរព្រះភក្ត្រទៅកាន់គល់ពោធិព្រឹក្ស ក៏ប៉ុន្តែទីតាំងប៉ុន្មាននោះ ហាក់ដូចជារើបរុបទ្រុបទ្រេល ព្រមទាំងមានការញាប់ញ័រហាក់ដូចជាទូលព្រះអង្គថា "ទីនេះមិនមែនជាទីកើតរតនបល្លង្កទេ" ។ ព្រះអង្គទ្រង់យាងទៅគង់ពីខាងកើតរួចទ្រង់បែរព្រះភក្ត្រទៅរកគល់ពោធិព្រឹក្ស ក៏មានសភាពស្រួល ហាក់ដូចជាទូលថា ទីនេះជាទីកើតរតនបល្លង្ក ។ ព្រះអង្គទ្រង់ក្រាលស្មៅដែលព្រាហ្មណ៍ថ្វាយហើយគង់ពីលើ ។ ខណៈនោះរតនបល្លង្កក៏ផុសឡើងមានកំពស់ ១៤ ហត្ថទ្រព្រះអង្គពីក្រោមដើមពោធិព្រឹក្សក្សម ។

កាលរតនបល្លង្កផុសឡើងហើយ ព្រះពោធិសត្វទ្រង់គង់ដោយព្រះភ្នែនពីលើរួចទ្រង់អធិដ្ឋានដោយអង្គ ៤ ថា "បើអាត្មាអញមិនបានត្រាស់ដឹងទេ ស្បែក, សរសៃ, សាច់, ឈាមរបស់អាត្មាអញ ចូររីងស្ងួតទៅចុះ អញ

www.budinst.gov.kh www.elibraryofcambodia.org

ទីនឹងមិនក្រោកពេលរតនបល្ល័ង្កនេះឡើយ, ៗ ទ្រង់អធិដ្ឋានហើយទ្រង់បែរខ្នងទៅកេគល់ពោធិព្រឹក្ស បែរព្រះភក្ត្រទៅកាន់បូព៌ាទិសវិញម្ដងៗ សូមបញ្ជាក់ថាតាំងពីពេលដែលទ្រង់យាងពីសាលវ័នមក ពួកទេវតាទាំងមួយម៉ឺនលោកធាតុ បានធ្វើសក្ការបូជាដោយកម្រងផ្កាទិព្វផ្សេង ៗ ជាច្រើន ហើយថ្វាយសព្វសាធុការពរដល់ព្រះអង្គយ៉ាងគឹកកង ឯសាលព្រឹក្ស , វល្លិជាតិ, រុក្ខជាតិនានា ក៏បញ្ចេញផ្ការយោនយានដើម្បីបូជាព្រះពោធិសត្វជាម្ចាស់ដែរ ។ លុះបានគង់លើរតនបល្ល័ង្កហើយ ព្រះឥន្ទបានផ្លុំស័ង្ខថ្វាយ , គន្ធព្វទេវបុត្រប្រគំពិណថ្វាយ , សុយាមទេវបុត្រយកចាមរទិព្វមកបក់ថ្វាយ , សហម្បតិព្រហ្មយកស្វេតច្ឆត្រមកបាំងថ្វាយ, កាឡនាគរាជបាននាំពួកកញ្ញាមករាំថ្វាយ , ឯទេវតាជាច្រើនអនេកបានបូជាកម្រងផ្កានិងសព្វសាធុការពរដល់ព្រះអង្គយ៉ាងណែនណាន់តាន់តាប់ ៗ

ស. ៦១— រតនបល្ល័ង្កដែលទ្រង់គង់នោះ កើតពីស្មៅដែលព្រាហ្មណ៍ថ្វាយ ឬកើតពីអ្វី ?

ច— មិនមែនកើតពីស្មៅប្រក់នោះទេ តែកើតដោយបុញ្ញានុភាពនិងបារមីរបស់ព្រះអង្គ ដែលទ្រង់បានធ្វើសន្សំមកហើយអស់ច្រើនអសង្ខេយ្យនោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

# ការផ្ចាញ់មារ

ស. ៦៦ – នៅពេលដែលព្រះពោធិសត្វទ្រង់គង់លើរតនបល្ល័ង្កនា រសៀលថ្ងៃនោះ តើមានជនណាក្រៅពីទេវតា មកជួបនឹងព្រះអង្គដែរ ?

ច ក្រៅពីទេវតាដែលបានមកធ្វើសក្ការបូជា មានទេវបុត្រមារ បានកេណ្ឌទ័ពមក ដើម្បីជ្រែកដណ្ដើមរតនបល្ល័ង្កអំពីព្រះមហាបុរស ។

ស. ៦៧ – មានកេណ្ឌទ័ពមកចំនួនប៉ុន្មាន ? មកនៅទីណា ? មានអាការៈនិងធ្វើយ៉ាងណាខ្លះ ?

ច – ទ័ពមារមានច្រើនជាអនេក គឺខាងមុខកម្រាស ១២ យោជន៍ ខាងឆ្វេង-ស្តាំ មានកម្រាស ១២ យោជន៍ដូចគ្នា ។ ទ័ពទាំងនេះបាន ស្រែកឮខ្ទរខ្ទារទៅចម្ងាយមួយសែនយោជន៍ ។ មេទ័ពជាទេវបុត្រមារ ជិះលើដំរីគិរីមេខលា កំពស់ ១៥០ យោជន៍ និម្មិតដៃមួយពាន់សុទ្ធ តែកាន់អាវុធ ឯសេនាក៏និម្មិតកាយមានពណ៌ខៀវលឿងជាដើម, ខ្លះ ធ្វើជាយក្ស, ជាម្រឹគ មានកំពស់ ១ គាវុតខ្លះ, ២គាវុតខ្លះ, ៣គា-វុតខ្លះ, ១ យោជន៍ខ្លះ ហើយនាំគ្នាដើរចូលសំដៅទៅដើមពោធិ៍រកព្រះ ពោធិសត្វជាម្ចាស់ ត្រង់ខាងក្រោយ,ឆ្វេង-ស្តាំ ។ ព្រះពោធិសត្វ ទ្រង់គង់តែមួយព្រះអង្គឯងនៅលើរតនបល្ល័ង្ក ឯពួកទេវតាបានរត់ចោល ព្រះអង្គទៅកាន់ទីដទៃអស់ ។ ទេវបុត្តមារបានបណ្ដាលឲ្យកើតជាខ្យល់

www.budinst.gov.kh www.elibraryofcambodia.org

ភ្លៀងធំ , ភ្លៀងដុំៗ , ភ្លៀងគ្រឿងប្រហារ , ភ្លៀងរងើកភ្លើង , ភ្លៀងផេះក្តៅ , ភ្លៀងដីខ្សាច់ ភ្លៀងភក់ បាចសាចមកលើព្រះអង្គ តែមិនអាចត្រូវព្រះពោធិសត្វបានឡើយ ។ ធ្វើយ៉ាងណាមិនកើត ក្រុងមារបានបរដំរី ដៃកាន់អាវុធ ១ ពាន់ចូលទៅស្រែកថា " នែសិទ្ធត្ថ ! ចូរដើរចេញពីលើបល្ល័ង្កនេះ ព្រោះជារបស់យើង ,, ។ ព្រះពោធិ-ទ្រង់បាននឹកដល់បារមីទាំង ៣០ ប្រការ ដែលព្រះអង្គបានបំពេញអស់ជាច្រើនអសង្ខេយ្យកប្ប ទ្រង់គ្មានខ្លាចសោះ ហើយបានតបទៅនឹងមារថា " ម្នាលមារ ! បល្ល័ង្កនេះមិនមែនកើតសម្រាប់អ្នកទេ គឺកើតសម្រាប់យើងដែលជាអ្នកបានបំពេញបារមី ៣០ , មហាបរិច្ចាគ ៥ , ចរិយា ៣ ទេតើ ។ មារឮដូច្នោះកាន់តែក្រោធខ្លាំងឡើង ហើយបានបោះអា-វុធ , លើកកំពូលភ្នំបោះសំដៅព្រះអង្គ តែវត្ថុទាំងនោះក្លាយជាកម្រងផ្កាថ្វាយព្រះអង្គទៅវិញ ។

ព្រះសិទ្ធត្ថទ្រង់ព្រះចិន្តាថា " នៅថ្ងៃត្រាស់ដឹង បល្ល័ង្ករតន៍តែងកើតដល់ព្រះពោធិសត្វគ្រប់ព្រះអង្គជាដរាប ឯបល្ល័ង្កនេះក៏កើតដល់អា-ត្មាអញហើយសម្រាប់តែអាត្មាអញដែរ ,, រួចទ្រង់សួរទៅមារថា " បើបល្ល័ង្កនេះជារបស់អ្នក តើអ្នកមានអ្នកឯណាជាសាក្សី ? មារតបថា " ពលសេនាទាំងអស់ជាសាក្សីរបស់យើង ចុះសិទ្ធត្ថឯងមានអ្នកណា

www.budinst.gov.kh www.elibraryofcambodia.org

ជាសាក្សីដែរ? ព្រះពោធិសត្វទ្រង់ត្រាស់ថា “ សាក្សីរបស់អ្នកសុទ្ធតែជាអ្នកមានចិត្តចេតនា ឯសាក្សីរបស់យើងគឺមហាប្រឋពីនេះឯង,,។ គ្រានោះព្រះមហាប្រឹថពីក៏លាន់កក្រើកឡើង ដូចជាទទួលថាជាសាក្សីមែន ៗ ជ្រាបដូច្នោះព្រះបរមពោធិសត្វទ្រង់នឹកដល់ដំរីបច្ច័យនាគេន្ទ្រ ដែលព្រះអង្គបានប្រទានដល់អ្នកស្រុកកលិង្គរាស្ត្រ កាលទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ ។ គ្រានោះដំរីនោឡាគិរីក៏លុតជង្គង់ ក្រោមក្បាលចុះ ឯក្រុងមារឃើញដូច្នោះ ក៏លើកដៃពោលសរសើរថា “

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មិំ លោកស្មិំ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆិន្ទា តិណ្ណោ តារេសិមំ បជំ ៗ

,,បពិត្រព្រះមហាបុរសអ្នកមានញាណញេយ្យខ្ញុំព្រះអង្គសូមនមស្ការចំពោះអង្គជាកំពូលនៃបុរស ហើយដែលគ្មានបុគ្គលណាប្រៀបបាន នៅក្នុងលោកនេះនិងទេវលោក, ព្រះអង្គជាអ្នកត្រាស់ដឹង ជាសាស្តាចារ្យ ជាអ្នកប្រាជ្ញអាចគ្របសង្កត់នូវពួកមារបាន ព្រះអង្គទ្រង់កាត់ផ្តាច់នូវគ្រឿងត្រាំគឺកិលេស ហើយអាចនាំពួកសត្វឲ្យឆ្លងផុតពីភព៣ ជាក់ដល់ស្ថានបរមសុខ ជាអវសាន,, ។ កាលពោលយ៉ាងនេះហើយពួក

www.budinst.gov.kh www.elibraryofcambodia.org

មារ ក៏នាំគ្នាចេញបាត់អស់ទៅ នៅពេលល្ងាចថ្ងៃជិតលិច ។ ពួកទេពតាឃើញដូច្នោះ ក៏ហោះត្រឡប់មកកាន់ពោធិព្រឹក្សវិញ ហើយធ្វើសក្ការបូជាព្រះបរមពោធិសត្វដោយកម្រងមាលា និងសព្វសាធុការពរជាច្រើនអនេក ។ ព្រះមហាប្រឹថពីក្តី រុក្ខជាតិក្តី បានសំដែងកាយវិការរបស់ខ្លួនបូជាព្រះបរមពោធិសត្វដោយអាការផ្សេងៗយ៉ាងច្រើន ។

ស - ៦៤ — កាលព្រះពោធិសត្វយាងចេញសាងបព្វជ្ជា មានមារមកឃាត់ព្រះអង្គដែរ ក៏ប៉ុន្តែមារនោះ គឺជាព្រះទ័យស្តាយស្រណោះរបស់ព្រះអង្គបន្តិចបន្តួចចំពោះភេទគ្រហស្ថនោះឯងទៅវិញ ចុះពួកមារដែលមកចង់ដណ្តើមរតនបល្ល័ង្កនេះ តើជាមារកើតប្រាកដឬជាមារយ៉ាងណា? ចូរដោះស្រាយឲ្យល្មមស្តាប់បានទៅមើល !

ច -- មារមកដណ្តើមរតនបល្ល័ង្កធ្វើទុក្ខបុកម្នេញព្រះពោធិសត្វនៅពេលមុនទ្រង់បានត្រាស់នេះ បើតាមការពិចារណាទៅក៏មិនមែនជាមារមនុស្សជារូបឬទេវបុត្តមារនោះដែរ គឺជាកិលេសមារ , ជាព្រះទ័យហាញាំមិនទាន់ផុតអាល័យពីធម៌របស់បុថុជ្ជននោះឯង ។ ព្រះទ័យរបស់ព្រះអង្គជាបុថុជ្ជននេះ ហើយដែលកំពុងប្រឆាំងតយុទ្ធគ្នាយ៉ាងខ្លាំង ហើយស្មុគ្រស្មាញជាទីបំផុតនៅក្នុងបេះដូងព្រះអង្គដែលលោកប្រៀបបានទៅនឹងខ្យល់ព្យុះសង្ឃ្យក ឬភ្លៀងគ្រប់យ៉ាងធំៗ បោកបក់មកទឹងព្រះទ័យព្រះអង្គ ក៏ប៉ុន្តែព្រះទ័យ

www.budinst.gov.kh www.elibraryofcambodia.org

ករុណា, សេចក្តីព្យាយាម, បុញ្ញាភិនិហាររបស់ព្រះអង្គបាននាំព្រះទ័យព្រះអង្គឲ្យកាត់ផ្តាច់នូវកិលេសមារដោយឥតការស្រណោះអាល័យ ហើយផ្តាច់ព្រះទ័យបួងចំតែគោលដៅ ១ គឺតស៊ូដើម្បីបាននូវសម្មាសម្ពោធិញ្ញាណនេះឯង ។ គឺទៅត្រង់សេចក្តីមេត្តាករុណា និងការលះបង់ដោយឥតអាល័យនេះហើយ ដែលយើងបានដឹងថា ''នាងគង្ហីងព្រះធរណីច្របាច់សក់បញ្ចេញទឹកឲ្យជន់លិចពួកពលមារអស់,, ។

ប្រសិនបើពួកពលមារលើកទ័ពមកដូច្នោះមែន ប្រហែលរុក្ខជាតិ, ភូមិស្ថានអ្នកស្រុកនៅទីនោះទាំងប៉ុន្មានត្រូវលាយអស់ដោយសារទ័ពមារជាន់ញាំញីឬត្រូវទឹកជន់របស់មារទៅហើយ កំប៉ុន្តែដោយមារនោះជាកិលេសមារ ដែលមាននៅតែក្នុងព្រះទ័យ, ក្នុងតួអង្គព្រះពោធិសត្វតែប៉ុណ្ណោះ បានជាគ្មានអ្នកស្រុកអ្នកភូមិណាដឹង ឯធម្មជាតិក៏នៅគង់វង់បញ្ចេញឥទ្ធានុភាពរបស់ខ្លួនបូជាព្រះអង្គវិញ ។

ដូច្នេះការដែលព្រះអង្គបានធ្វើចំបាំងឈ្នះមារនោះ គឺឈ្នះកិលេសមារ ពោលគឺកត់តណ្ហានោះឯងទៅវិញទេ ។

**សេចក្តីសន្និដ្ឋាន** .— ធម្មជាតិមានវិញ្ញាណក្តីឥតវិញ្ញាណក្តី ហេតុការដ៏អស្ចារ្យផ្សេងៗក្តី ពួកទេវតាក្នុងមនុស្សលោកជាតក្តី សុទ្ធតែបានសំដែងកាយវិការ, សំដែងអាការនិងចិត្តដ៏រីករាយរបស់ខ្លួន ថ្វាយគំនាប់

www.budinst.gov.kh www.elibraryofcambodia.org

គុណចំពោះការព្យាយាមរបស់ព្រះបរមពោធិសត្វ ដែលកំពុងតែតស៊ូស្វិតស្វាញស្វែងរកសម្មាសម្ពោធិញ្ញាណទាំងអស់ ។ អំពើទាំងអស់នេះគឺដោយសារសម្មាសម្ពោធិញ្ញាណ របស់ព្រះអង្គជាគុណសម្បត្តិ ១ ដែលនាំមកនូវប្រយោជន៍ដ៏ច្រើនដល់សត្វលោកក្នុងត្រៃភពនេះឯង ។

**ឃ្លាភ្ជាប់សេចក្តី.** មកដល់ដំណាក់ការត្រង់នេះ យើងបានឃើញនិងមានសេចក្តីសង្ឃឹមថា ការស្វែងរកការត្រាស់ដឹងនូវព្រះធម៌ថ្មី ដើម្បីពន្យល់ណែនាំសត្វលោករបស់អង្គព្រះសិទ្ធត្ថបរមពោធិសត្វ កាន់តែខិតចូលទៅជិតការរកឃើញណាស់ហើយ ព្រោះសុបិននិមិត្តក្តី ការផ្សងថាសមាសក្តី ធម្មជាតិជុំវិញព្រះអង្គក្តី ការបានទទួលរតនបល្ល័ង្កក្តី ជ័យជំនះលើពួកមារក្តី សុទ្ធតែបានបញ្ជាក់នូវការបានទទួលសម្មាសម្ពោធិញ្ញាណ ដែលជាទីប្រាថ្នានៃព្រះអង្គ និងទេវតានិករមនុស្សសត្វទាំងអស់ដោយជាក់ច្បាស់ ។ ដូច្នេះយើងនឹងឃើញនូវការសម្រេចនេះ ក្នុងការសិក្សាតទៅទៀតយ៉ាងពិតប្រាកដ ។

X X

X

www.budinst.gov.kh www.elibraryofcambodia.org

## ភាគទី៧

# ពេលទ្រង់បានត្រាស់ដឹង

ស – ៦៩ កាលព្រះបរមពោធិសត្វទ្រង់ឈ្នះមារហើយ តើព្រះអង្គទ្រង់យាងទៅណាទៀត ឬទ្រង់គង់នៅលើរតនបល្លង្កដដែល? ទ្រង់បានធ្វើយ៉ាងណាទៅទៀត?

ឆ– កាលទ្រង់បានរម្ងាប់បង្ក្រាបកិលេសមារហើយ ទ្រង់ប្រឹងស្មឹងស្មាធ៍ពិចារណារកធម៌លើរតនបល្លង្កទៅទៀត ក៏ប៉ុន្តែទ្រង់នៅពុំបានឃើញ ទ្រង់ក៏ចាប់ផ្ដើមពិចារណាយ៉ាងនេះថា ៖

„កាលមុនដែលអញមកអង្គុយលើរតនបល្លង្កនេះ អញអង្គុយបែរមុខទៅលិចសំដៅមុខទៅគល់ពោធិព្រឹក្ស, មុននេះអញអង្គុយខាងត្បូងគល់ពោធិព្រឹក្ស, មុននេះទៀតអញអង្គុយខាងលិច–ខាងជើងគល់ពោធិព្រឹក្ស មុននេះទៅទៀតអញមកពីសាលវ័ន–ពីស្ទឹងនេរញ្ជរា. មុននេះទៅទៀតអញឆាន់បង្ហាន់អស់៤៩ដុំ រួចផ្សងថាសមាសក្នុងទឹក.... ។ ទ្រង់ពិចារណាច្រាសឡើង រហូតដល់ពេលទ្រង់ទទួលបង្ហាន់នាងសុជាតាឡើងទៅខាងលើ ខាងដើមរហូតទល់កាលពេលព្រះអង្គទ្រង់យាងចេញសាងព្រះផ្នួស, ទ្រង់ពិចារណាច្រាសឡើងទៅទៀតរហូតដឹងថា ព្រះអង្គជាកសបុត្រ, ជាក្សត្រវង្សណា មានជាតិជាអ្វី ទ្រង់បានប្រសូតពីពេល

www.budinst.gov.kh www.elibraryofcambodia.org

ណាៗ មាតាបិតាឈ្មោះអ្វីៗ ហើយពិចារណាឡើងលើពីពេលនោះទៅទៀត ក៏គិតលែងឃើញ ទាល់ត្រឹមទ្រង់ដឹងថាទ្រង់ជាជាតិ, ជាបុត្រជាអ្នកត្រកូលណាៗតែប៉ុណ្ណោះ ទ្រង់ក៏ពិចារណាបណ្ដោយចុះស្របមកជាលំដាប់រហូតដល់ពេលដែលទ្រង់គង់លើរតនបល្ល័ង្កវិញដែល តែទ្រង់ពុំបានឃើញអ្វីទេ ៗ កាលពិចារណាដុតមកដល់នេះហើយ នៅចុញទាល់ត្រឹមនេះ ក៏ទ្រង់ពិចារណាការកេះទៅដើមវិញរហូតទល់ពេលទ្រង់ប្រសូត ៗ ការពិចារណាសារចុះសារឡើងយ៉ាងនេះ ហៅថា ការពិចារណាតាមបដិលោមវិធី និងអនុលោមវិធី ហើយការពិចារណាបែបនេះ ទ្រង់ទើបនឹងរកឃើញក្នុងពេលដែលទ្រង់គង់លើរតនបល្ល័ង្កតែប៉ុណ្ណោះ ពេលមុនៗនេះទ្រង់ពុំដែលនឹកឃើញយ៉ាងនេះទេ ៗ

កាលព្រះអង្គពិចារណាជាអនុលោម បដិលោមយ៉ាងនេះ ព្រះបញ្ញាញាណព្រះអង្គកាន់តែភ្លឺឡើងៗជាលំដាប់ ហើយកាលទ្រង់ពិចារណាច្រាសឡើងម្ដងទៀត រហូតទល់ពេលប្រសូត ទ្រង់ក៏ការកេះឃើញជាដំបូងថា កាលមុនជាតិជាសិទ្ធត្ថនេះ អាត្មាអញជាសន្តុសិតទេវបុត្ត, កាលមុននេះអាត្មាអញជាព្រះវេស្សន្តរនៅជេតុត្តរនគរ---ៗ កាលមានញាណនេះហើយទ្រង់ក៏ពិចារណារកឃើញនូវព្រះជាតិជាច្រើន ហៅថាអនេកជាតិ ៗ នៅក្នុងបឋមយាមនៃរាត្រីកាល១៥កើតខែពិសាខនេះទ្រង់បាន

www.budinst.gov.kh www.elibraryofcambodia.org

នូវបុព្វេនិវាសានុស្សតិញ្ញាណ គឺការដឹងដោយការរលឹកឃើញនូវទីកន្លែង និងជាតិដែលទ្រង់ធ្លាប់យោនយកមកពីមុនទាំងអស់ ព្រមទាំងសភាព, គោត្រ, ត្រកូល, សេចក្ដីសុខទុក្ខ, អាយុសង្ខារ, ចំណីអាហារ និងហេតុផ្សេងៗក្នុងជាតិនោះៗ ។

កាលព្រះបរមមហាបុរស បាននូវបុព្វេនិវាសានុស្សតិញ្ញាណក្នុងបឋមយាមហើយ ដល់មជ្ឈិមយាមទ្រង់ពិចារណានូវនិស្ស័យរបស់សត្វដទៃក្រៅពីព្រះអង្គទៀត ហើយទ្រង់ក៏បានឃើញនូវអំពើ, ការកើតស្លាប់របស់មនុស្សសត្វផ្សេងៗទៀត ព្រះអង្គក៏បាននូវញាណទី២ គឺ ចុតូបបាតញ្ញាណ= ការដឹងនូវការច្យុតនិងការកើត ព្រមទាំងកម្មផលរបស់សត្វលោកដោយឥតទើសទាក់ ។

កាលទ្រង់បានដឹងស្គាល់នូវការកើត និងការស្លាប់របស់មនុស្សសត្វហើយ បច្ឆិមយាមក៏ចូលមកដល់ ហើយទ្រង់គង់ពិចារណារកនូវហេតុនៃការកើតស្លាប់ និងហេតុនៃការរំលត់នូវការកើតការស្លាប់នោះតទៅទៀត ដោយទ្រង់ទាញនូវបដិច្ចសមុប្បាទធម៌មកពិចារណាថា៖

“ សេចក្ដីសោក - ខ្សឹកខ្សួល - ទុក្ខព្រួយ - ចង្អៀតចង្អល់ តូចចិត្ត កើតមានព្រោះជរា និងមរណៈដែលមានជាតិជាបច្ច័យ, ជាតិកើតមានមកពីភព, ភពកើតមកពីឧបាទាន, ឧបាទានកើតពីតណ្ហា, តណ្ហាកើត

www.budinst.gov.kh www.elibraryofcambodia.org

ពីវេទនា , វេទនាកើតពីសម្ផស្ស, សម្ផស្សកើតពីអាយតនទាំង ៦ , អាយតនទាំង ៦ កើតពីនាមនិងរូប , នាមនិងរូបកើតពីវិញ្ញាណ , វិញ្ញាណកើតពីសង្ខារ, ឯសង្ខារកើតមកពីអវិជ្ជា ៗ ដូច្នេះអវិជ្ជាគឺការល្ងិតល្ងង់សូន្យសុង ជាប្រភពដំបូងនាំឲ្យមានការកើតស្លាប់ទុក្ខព្រួយនោះឯង ៗ បើអវិជ្ជារលត់, សង្ខារ, វិញ្ញាណ, នាមរូប , អាយតនទាំង ៦, សម្ផស្ស , វេទនា , តណ្ហា , ឧបាទាន , ភព , ជាតិ , ជរា និងមរណៈ ក៏រលត់ទៅឯង ៗ ហើយទុក្ខសោកខ្សឹកខ្សួល ការចង្អៀតចង្អល់ក្នុងចិត្តសព្វយ៉ាង ក៏រលត់ទៅទាំងអស់ដែរ ៗ គឺទៅត្រង់ការរលត់អស់នេះហើយ ដែលសត្វលោកទើបដល់នូវស្ថានព្រះនិព្វានជាស្ថានបរមសុខ គោលគឺសេចក្តីសុខតែមួយ ឥតប្រែត្រឡប់មកកាន់សេចក្តីទុក្ខវិញដូចស្ថានឯទៀត ៗ ៗ

ពេលជិតផុតបច្ឆិមយាមទៅហើយ ព្រះពោធិសត្វក៏បានពិចារណានូវបដិច្ចសមុប្បាទធម៌ដោយវិធីប្រាសបណ្ដោយចុះឡើង ហើយក៏ទ្រង់បាននូវញាណ ទី ៣ ហៅ អាសវក្ខយញ្ញាណ ពោលគឺការដឹងនូវហេតុនៃការកើតនិងរលត់នៃអាសវក្ខ ( គ្រឿងសៅហ្មង ) , ព្រះធរណីក៏កម្រើករំពើកអស់វារៈ ១២ ដង ជានិមិត្តរូបនៃការបូជានូវការបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណរបស់ព្រះសិទ្ធត្ថគោតមជាបរមសម្មាសម្ពុទ្ធ ៗ ធម្មជាតិ

www.budinst.gov.kh www.elibraryofcambodia.org

ទេពតានានា បានបញ្ចេញកម្រងផ្កា ; បានលើកទង់ជ័យឡើងថ្វាយ នូវសេចក្ដីត្រេកអររបស់ខ្លួន ចំពោះការបានត្រាស់ដឹងរបស់ព្រះសិទ្ធត្ថជាព្រះពុទ្ធអង្គពេញលក្ខណៈ ។ ព្រះពុទ្ធបរមគ្រូកាលបាននូវសម្មាសម្ពោធិញ្ញាណហើយទ្រង់បានបន្លឺគាថាជាដំបូងថា ៖

អនេកជាតិ សំសារំ សន្ធាវិសំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ
វិសំខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលពីអង្គអញតថាគត អន្ទោលក្នុងវិលវដ្ដសង្សារ
ច្រើនអសង្ខេយ្យកោដិកប្ប តែងបានទុក្ខរាល់ជាតិភព ។
ឥឡូវតណ្ហាគឺជាងផ្ទះ តថាគតយល់ច្បាស់ក្នុងចិត្តស៊ប់
បានដឹងបានឃើញដោយសព្វគ្រប់ អ្នកឈប់សង់ផ្ទះបានទៀតហើយ ។
ឆ្អឹងជំនីនិងដំបូលអ្នក ត្រូវអញបំបាក់ឥតសល់ឡើយ
ចិត្តតថាគតបានដល់ត្រើយ ឥតតណ្ហាឡើយគឺនិព្វាន ។

ស. ៦៦ ញាណទាំង៣គឺបុព្វេនិវាសានុស្សតិញ្ញាណ ១ ចុតូបបាតញ្ញាណ ១ អាសវក្ខយញ្ញាណ ១ ជាចំណេះកើតមកពីការពិចារ

www.budinst.gov.kh www.elibraryofcambodia.org

ណារបស់ព្រះអង្គ តើនឹងហៅថាអ្វីផ្សេងទៀតបានទេ ?

ប នឹងហៅថាវិជ្ជាក៏បាន ព្រោះថាការចេះដោយការពិចារណា គឺ បុព្វេនិវាសានុស្សតិវិជ្ជា , ចុតូបបាតវិជ្ជា និង អាសវក្ខយវិជ្ជា ដែលយើងធ្លាប់ដឹងថាព្រះអង្គមានវិជ្ជា ៣ នោះឯង ។

ស-២៧ ព្រះសម្មាសម្ពុទ្ធ មានវិជ្ជាដែលកើតពីព្រះអង្គឯងតែ ៣ នេះទេឬមានផ្សេងទៀត ?

ប- មាន ៨ ទៀតគឺ វិបស្សនាវិជ្ជា ១, មនោមយិទ្ធិវិជ្ជា ១, ឥទ្ធិវិធិវិជ្ជា ១, ទិព្វសោតវិជ្ជា ១, ចេតោបរិញ្ញាវិជ្ជា ១, រួមទាំងវិជ្ជា៣ ខាងលើ ត្រូវជាវិជ្ជា ៨ ។

ស-២៨.- ព្រះសិទ្ធត្ថជាបរមគ្រូ ទ្រង់បានត្រាស់ជាព្រះពុទ្ធនៅទីណា ? នៅថ្ងៃខែឆ្នាំណា ? ក្រោយពីពេលទ្រង់ព្រះផ្នួសបានប៉ុន្មានឆ្នាំ ? ក្នុងព្រះជន្មប៉ុន្មាន ? មានអ្នកណាបានជួបប្រទះខ្លះ ? ហើយតើធម៌ណាខ្លះដែលព្រះអង្គ បានដឹងទើបអាចសន្និដ្ឋានថាព្រះអង្គបានត្រាស់ដឹងមែន ?

ប- ទ្រង់បានត្រាស់នៅក្រោមដើមពោធិព្រឹក្ស ដែលដុះលំណាលគ្នានឹងថ្ងៃដែលព្រះអង្គទ្រង់ប្រសូត នៅគយាសីសប្រទេស ឬឧរុវេលនិគម នៅថ្ងៃពុធពេញបូរមីខែពិសាខឆ្នាំរកា (បានត្រាស់ដឹងដោយសព្វគ្រប់នៅ

www.budinst.gov.kh www.elibraryofcambodia.org

ដើមថ្ងៃព្រហស្បតិ៍ ១ កើតខែពិសាខ ព្រោះកត្រីថ្ងៃពុធពេញបូរមីខែពិសាខ នោះទ្រង់ទើបនឹងបានញាណពីរ ក្នុងបឋមយាមនិងមជ្ឈិមយាម ដល់បច្ឆិមយាមផុតពីរាត្រ (ចូលក្នុងថ្ងៃព្រហស្បតិ៍ទើបបានញាណទី ៣ ទៀត) ក្រោយពីទ្រង់បានសាងព្រះផ្នួសបាន៦ឆ្នាំ ក្នុងព្រះជន្ម ៣៥ ព្រះវស្សា ។ ពេលទ្រង់បានត្រាស់នោះគ្មានមនុស្សទៅបានឃើញទេ មានតែទេវតាប៉ុណ្ណោះដែលបានទៅធ្វើសក្ការបូជានមស្ការព្រះអង្គ ។

ដោយហេតុថា ព្រះអង្គជ្រាបច្បាស់ហេតុនិងផល នៃសមុទយធម៌និងនិរោធធម៌ ពោលគឺហេតុដែលនាំឲ្យកើតទុក្ខសោកពេកភ័យនិងហេតុនៃការរលត់ទុក្ខសោកដាំដើមនោះ ដោយព្រះពុទ្ធញ្ញាណយ៉ាងពិតប្រាកដព្រមទាំងទ្រង់រកឲ្យឃើញក្នុងការប្រតិបត្តិដើម្បីរលត់ទុក្ខគឺការ ដើរតាមផ្លូវមានអង្គ៨ប្រការគឺ ៖

សម្មាទិដ្ឋិ = ការយល់ឃើញត្រូវ,

សម្មាសង្កប្ប= ការត្រិះរិះត្រូវ,

សម្មាវាចា = សំដីត្រូវ,

សម្មាកម្មន្តា = ការងារត្រូវ,

សម្មាអាជីវោ = ការចិញ្ចឹមជីវិតត្រូវ,

សម្មាវាយាមោ = ព្យាយាមត្រូវ,

www.budinst.gov.kh www.elibraryofcambodia.org

សម្មាសតិ = ការរលឹកនឹកឃើញត្រូវ

សម្មាសមាធិ = ការដំកល់ចិត្តត្រូវ ។

ទ្រង់យល់ថាផ្លូវប្រកបដោយអង្គ៨ប្រការនេះហើយ ដែលនាំសត្វឲ្យផុតទុក្ខ ពោលគឺអាចដើរទៅកាន់ស្ថានព្រះនិព្វានបាន ។ អាស្រ័យហេតុនេះហើយទើបអាចសន្និដ្ឋានបានថាព្រះអង្គជាអ្នកត្រាស់ដឹង ។ ការប្រឹងប្រែងបំពេញទុក្ករកម្មក្តី ការលះរាជសម្បត្តិនិងមាតាបិតាក្តី ការបំពេញបារមីអស់ច្រើនអសង្ខេយ្យក្តី គឺដើម្បីនឹងឃើញនូវធម៌ប៉ុណ្ណោះ ហើយធម៌នេះព្រះអង្គទ្រង់ទើបនឹងបានឃើញនៅពេលដែលទ្រង់គង់លើរតនបល្ល័ង្ក នៅព្រឹកនៃថ្ងៃ១៥កើតនោះឯង ពីដើមមកព្រះអង្គពុំបានដឹងយ៉ាងនេះទេ ។ កាលទ្រង់មានញាណញេយ្យយ៉ាងនេះហើយ ទើបទ្រង់ជ្រាបថាសកម្មភាពរបស់ព្រះអង្គដែលបានធ្វើមកតាំងពីមុនៗមានលក្ខណៈត្រូវខ្លះ ខុសខ្លះ ឯពួកសត្វទាំងអស់ត្រូវកិលេស,តណ្ហារុំព័ទ្ធជិត ដូចសត្វជាប់ក្នុងសំណាញ់ មកពីមិនដឹងហេតុផលយ៉ាងណា ដើម្បីដោះខ្លួនឲ្យរួចបាននោះឯង ។

**សេចក្តីសន្និដ្ឋាន.** — ការប្រឹងប្រែងខំស្វះស្វែងមកតាំងពីមុនៗរបស់ព្រះសិទ្ធត្ថជាម្ចាស់ដើម្បីរកឃើញនូវសម្មាសម្ពោធិញ្ញាណ ឥឡូវទ្រង់បានឃើញដោយសព្វគ្រប់តាមសេចក្តីប្រាថ្នារបស់ព្រះអង្គ និងសត្វលោកហើយ គឺព្រះអង្គដឹងនូវអតីតភាពនិងអនាគតភាពរបស់ព្រះអង្គឯងផង

www.budinst.gov.kh www.elibraryofcambodia.org

របស់សត្វលោកផង ព្រមទាំងមានចិត្តញាណជ្រាបនូវហេតុនិងផលនៃសេចក្ដីទុក្ខផង ថែមទាំងដឹងនូវឧបាយសម្រាប់ធ្វើឲ្យរលត់ទុក្ខផង ។ ការដឹងដោយព្រះពុទ្ធញាណដោយមិនទើសទាស់នេះហើយ ហៅថាសម្មាសម្ពុទ្ធ ហៅថាព្រះសព្វញ្ញូ ។

**អនាគតសក័ម្មភាពនៃព្រះសព្វញ្ញូ** .– ការឃើញនិងការបាននូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះសិទ្ធត្ថពុទ្ធអង្គនេះ មិនមែនដើម្បីគ្រាន់តែឃើញ ដឹង - យល់ - ស្គាល់តែ ១ អង្គឯងហើយនៅទំនេរព្រះអង្គទៅអនាគតកាលនោះទេ ក៏ប៉ុន្តែទ្រង់នឹងយកការចេះដឹងយល់របស់ព្រះអង្គដែលទ្រង់បានឃើញនោះ ទៅពន្យល់ប្រាប់ដល់សត្វលោកទៀត ។ ការធ្វើយ៉ាងនេះគឺជាពុទ្ធបំណងរបស់ព្រះអង្គដែលបានប្រឹងប្រែងអស់ច្រើនអសង្ខេយ្យនោះឯង ។ ដូច្នេះការត្រាស់ដឹងរបស់ព្រះអង្គទើបបានទៅជាការត្រាស់ដឹងរបស់សត្វលោក ក្នុងត្រៃភពនេះដែរ ដើម្បីដោះខ្លួនចេញចាកវាលវដ្ដសង្សារ , ផុតពីមហាសមុទ្រប្រកបដោយទុក្ខភ័យដ៏ច្រើនមហិមានេះ ។

x x

x

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ៨

# ព្រះពុទ្ធសកម្មភាព
# នៅពេលត្រាស់ដឹងហើយថ្មីៗ

ស, ៦៩– កាលព្រះពុទ្ធបរមគ្រូត្រាស់ដឹងនូវញេយ្យធម៌ហើយ តើទ្រង់យាងទៅពន្យល់សត្វលោកភ្លាម ឬទ្រង់ធ្វើយ៉ាងណាខ្លះ ? មានអ្នកណាខ្លះដែលជួបនឹងព្រះអង្គ ?

ច–ទ្រង់ពុំទាន់យាងទៅប្រោសសត្វ ឬ ចាំសំដែងធម៌ដែលព្រះអង្គទើបនឹងរកឃើញនោះទេ គឺទ្រង់ធ្វើសកម្មភាពផ្សេង ១ អស់ ៤៩ ថ្ងៃ មានរយៈកាលដូចតទៅនេះ ៖

ក្នុងសប្តាហ៍ទី ១ គឺចាប់ពីថ្ងៃព្រហស្បតិ៍ ១ កើតខែពិសាខទៅទល់ថ្ងៃព្រហស្បតិ៍ ៨ កើត ទ្រង់គង់នៅលើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្សត្រង់ទីដែលទ្រង់បានត្រាស់នោះដដែល ដើម្បីពិចារណាធម៌ដែលទ្រង់បានត្រាស់ដឹងហើយ ។

ក្នុងសប្តាហ៍ទី ២ ចាប់ពីថ្ងៃព្រហស្បតិ៍ ៨ កើតទៅ, ពេលព្រឹកទ្រង់ធ្វើយមកបាដិហារ្យដោះសេចក្តីសង្ស័យរបស់ទេវតា ហើយទ្រង់ចុះទៅគង់នៅខាងទិសឦសាននៃរតនបល្ល័ង្ក រួចទតរតនបល្ល័ង្កដោយព្រះនេត្រមិនប៉ព្រិចសោះអស់ ៧ ថ្ងៃ រហូតទល់ថ្ងៃព្រហស្បតិ៍ ១៥ កើតខែ

www.budinst.gov.kh www.elibraryofcambodia.org

ពិសាខ ។ ទីនោះហៅថាអនិមិស្សកចេតិយ ។

សត្តាហ៍ទី ៣ ចាប់ពីព្រឹកនៃថ្ងៃព្រហស្បតិ៍ ១៥ រោចខែពិសាខ ទៅដល់ព្រឹកនៃថ្ងៃព្រហស្បតិ៍ ៧ កើតខែជេស្ឋ ទ្រង់យាងចង្ក្រមលើផ្ទះកែវហៅថា រតនចេតិយ ដែលព្រះឥន្ទបាននិម្មិតថ្វាយ នៅចន្លោះរតនបល្ល័ង្កនិងអនិមិស្សកចេតិយ អស់ ៧ ថ្ងៃទៀត ។

សត្តាហ៍ទី ៤ ចាប់ពីព្រឹកនៃថ្ងៃព្រហស្បតិ៍ ៧ កើតខែជេស្ឋទៅទ្រង់គង់នៅក្នុងផ្ទះកែវដែលទេវតានិម្មិតថ្វាយ នៅខាងទិសពាយព្យនៃគល់ពោធិព្រឹក្សអស់ ៧ ថ្ងៃទៀត ។ ផ្ទះកែវនេះតាមពិតមិនមែនជាផ្ទះទេ តែជាវិការៈនៃព្រះសទ្ធម្មទាំងអស់ គឺសតិបដ្ឋាន ៤ ជាទីលាន , ឥទ្ធិបាទ ៤ ជាសសរ , ព្រះវិនយបិដកជាជញ្ជាំង , សម្មប្បធាន ៤ ជាគ្រប សមាបត្តិ ៨ ជាគេនិនផ្ទូ , ព្រះសុត្តន្តបិដកជាគ្រឿងដំបូល , ព្រះអភិធម្មបិដកជាប្រដាប់ប្រក់ ។

ក្នុងសត្តាហ៍ទី ៥ ចាប់ពីថ្ងៃព្រហស្បតិ៍ ១៤ កើតខែជេស្ឋទៅ ទ្រង់យាងទៅគង់នៅក្រោមដើមអជបាលនិគ្រោធ ( ដើមជ្រៃដែលពួកអ្នកគង្វាលចៀម-ពពែតែងជ្រកអាស្រ័យនៅ) អស់ ៧ ថ្ងៃដើម្បីពិចារណាព្រះសទ្ធម្ម នឹងមនុស្សដែលទ្រង់គួរប្រោសបាន ៦ ពួក ។ នៅទីនោះ ទេវបុត្តមារបានមកអារាធនាព្រះអង្គឲ្យបរិនិព្វាន ។ គមកធីតានៃមារគឺ

www.budinst.gov.kh www.elibraryofcambodia.org

ាងតណ្ហា , អារតី , រាគា , បានមកលួងលោមព្រះអង្គដោយកា
ារផ្សេង តែមិនបានសម្រេចក៏ត្រឡប់ទៅស្ថានរបស់ខ្លួនវិញ ។

នៅសប្តាហ៍ទី ៦ ចាប់ពីថ្ងៃព្រហស្បតិ៍ ៦ កើតខែជេស្ឋទៅ ទ្រង់
ាងទៅគង់នៅក្បែរស្រះមុច្ចលិន្ទ ។ នៅទីនោះមាននាគរាជ ឈ្មោះ
ុច្ចលិន្ទបានចេញមកនិម្មិតកាយដ៏ធំពែនខ្លួនធ្វើជាបល្ល័ង្កហើយបើកពពារធ្វើ
ឆ័ត្រថ្វាយព្រះសាស្តាដើម្បីបាំងភ្លៀងខ្យល់ ដែលបង្អុរធ្លាក់មក ៗ
ទ្រង់គង់អស់ ៧ ថ្ងៃទៀត ៗ

ក្នុងសប្តាហ៍ទី ៧ ចាប់ពីថ្ងៃព្រហស្បតិ៍ ១៣ កើតខែជេស្ឋទៅដល់
ថ្ងៃ ៥ កើតខែអាសាឍ ទ្រង់យាងទៅគង់នៅក្រោមដើមកែស ១ ដើម
អស់៧ថ្ងៃទៀត ៗ នៅថ្ងៃទាំង ៤៩ រាប់តាំងពីពេលបានត្រាស់មក
ទ្រង់ពុំបានសោយចង្ហាន់ទេ គឺសោយតែវិមុត្តិសុខរហូត ៗ លុះដល់
ថ្ងៃនៃសប្តាហ៍ទី ៧ នេះ ទើបព្រះឥន្ទយកផ្លែស្រម៉វិញមកថ្វាយព្រះអង្គ ១
ទ្រង់ទទួលមកសោយ ៗ បន្ទាប់មកមានពាណិជពីរនាក់ជាបងប្អូនមិន
ា បងឈ្មោះតបុស្សៈ ប្អូនឈ្មោះភល្លិក បាននាំឈ្មួញរទេះ ៥០០
គ្រឿងដើម្បីនាំទំនិញទៅលក់ឯឧក្កលាជនបទ លុះដល់ដងព្រៃជិតដើម
កែស មានទេវតាជាសាច់ញាតិពីអតីតជាតិបានប្រាប់ពាណិជទាំងពីរ
ា ព្រះពុទ្ធទើបនឹងបានត្រាស់ថ្មី ១ ឥឡូវគង់នៅក្រោមដើមកែស

www.budinst.gov.kh www.elibraryofcambodia.org

ចូរអ្នកទៅថ្វាយបង្គំ ថ្វាយសក្ការផ្សេង ១ ចុះ ។ ពាណិជបានចូលទៅថ្វាយបង្គំ ហើយបានថ្វាយសក្ការព្រមទាំងសូមដល់សរណគមន៍ពីរថ្វាយខ្លួនជាសាវ័កយកព្រះពុទ្ធព្រះធម៌ជាទីពឹងទីរលឹកស្មើជីវិត ។ ពាណិជទាំងពីរនេះហើយជាឧបាសកដែលយកព្រះពុទ្ធព្រះធម៌ ជាសរណគមន៍មុនគេបង្អស់ក្នុងលោក ។ លុះពាណិជថ្វាយបង្គំលាហើយសុំនូវវត្ថុទុកជាទីរលឹកអំពីព្រះអង្គ ១ គឺយកព្រះហស្តអង្អែលព្រះសិរ រួចជាប់ព្រះកេសា ៨ សរសៃទីនព្រះហស្ត ទ្រង់ក៏ប្រទានព្រះកេសាទៅពាណិជទាំងពីរ ១ បានខ្ចប់ព្រះកេសា ហើយយកទៅបញ្ចុះនៅសិង្គុត្តរចេតិយ ។

សូមបញ្ជាក់ថាសិង្គុត្តរចេតិយនោះ ស្ថិតនៅក្នុងប្រទេសភូមាសព្វថ្ងៃនេះ ហើយគេបានបញ្ចុះពុទ្ធបរិក្ខាររបស់ព្រះពុទ្ធ ៤ អង្គហើយគឺ ធម្មក្រករបស់ព្រះពុទ្ធនាម កកុសន្ធ ១ វត្ថពន្ធរបស់ព្រះកោនាគមន ១ សាដករបស់ព្រះពុទ្ធនាម កស្សប ១ និងព្រះកេសធាតុរបស់ព្រះសិទ្ធត្ថគោតម ៨ សរសៃ ។ នៅពេលដែលពាណិជទាំងពីរធ្វើបុណ្យបញ្ចុះព្រះកេសធាតុនោះ ព្រះបាទឧបលាបពជទ្រង់បានជួយឧបត្ថម្ភផង ឯព្រះកេសធាតុក៏បានធ្វើបាដិហារ្យយ៉ាងខ្លាំង ជាហេតុនាំឲ្យមនុស្សទេវតាជ្រះថ្លាដ៏ច្រើន ។

ស. ៧០– កាលទ្រង់សោយចង្ហាន់របស់ពាណិជហើយ តើព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធជាម្ចាស់ទ្រង់យាងទៅណាទៀត ? ហើយបានធ្វើយ៉ាងណា ?

ច – ទ្រង់យាងទៅគង់ក្រោមដើមអជបាលនិគ្រោធវិញ ។ នៅទីនោះព្រះអង្គទ្រង់គន់ពិចារណាធម៌ដែលព្រះអង្គបានរកឃើញហើយ ទ្រង់ព្រះតម្រិះក្នុងព្រះទ័យថា “ ធម៌ដែលអង្គអញតថាគតបានរកឃើញហើយមានសភាពជ្រាលជ្រៅល្អិតសុខុមពេកណាស់ ពពួកសត្វទាំងឡាយដែលមានកិលេស ,មានគ្រឿងសៅហ្មងនៅក្នុងចិត្ត មិនងាយនឹងដឹងបានទេ ដូច្នោះបើតថាគតយកធម៌ដែលមានន័យជ្រៅទៅសំដែងឲ្យសត្វលោកទាំងនោះស្តាប់ គឺជាការឥតប្រយោជន៍ដែរ ” ។ អាស្រ័យហេតុនេះហើយ ទើបព្រះអង្គមានព្រះទ័យរួញរាក្នុងការសំដែងធម៌ ដើម្បីដឹកនាំសត្វលោកឲ្យប្រតិបត្តិតាម នឹងបានសម្រេចប្រយោជន៍ រួចខ្លួនពីវដ្តសង្សារនេះបាន ។

ស. ៧១– ព្រះទ័យរារែកនេះ បាននាំឲ្យអ្នកណាដឹង ? តើព្រះអង្គមិនសំដែងធម៌រហូតឬមួយទ្រង់សំដែងដែរ ? ការសំដែងនោះដោយទឹកព្រះទ័យព្រះអង្គឯង ឬដោយអ្នកណាអារាធនា ?

ច– តាមសេចក្តីដំណាលថា រឿងនេះជ្រាបដល់ទៅសហម្បតីមហាព្រហ្ម ។ ក៏ចុះមកអារាធនាព្រះអង្គ ឲ្យសំដែងធម៌ដែលទ្រង់បានរកឃើញហើយ ដើម្បីជាប្រយោជន៍ដល់សត្វលោក ប៉ុន្តែតាមការពិចារ-

www.budinst.gov.kh www.elibraryofcambodia.org

ណារបស់យើងទៅឃើញថា  តួអង្គព្រះពុទ្ធជាអគ្គបុគ្គល , ជាបរមគ្រូក្នុងលោក ហើយការស្វែងរកធម៌របស់ព្រះអង្គគឺដើម្បីនឹងយកព្រះធម៌នោះមកពន្យល់ណែនាំសត្វលោកឲ្យយល់ដឹងឃើញ ហើយនឹងរកមធ្យោបាយផ្សេងៗ ដើម្បីដើរចេញពីវដ្ដសង្សារនេះឯង បានសេចក្ដីថា ការរកបាននូវធម៌ថ្លៃរបស់ព្រះពុទ្ធអង្គ ទ្រង់មិនលាក់ទុកតែ ១ ព្រះអង្គឯងទេ ព្រះអង្គពិតជាចែករំលែកព្រះធម៌នោះដល់សត្វលោកជាមិនខាន ។ កាលបើគេនិយាយថា ព្រះអង្គរកធម៌ឃើញហើយ ទ្រង់គាំងព្រះទ័យថាមិនព្រមសំដែង ដោយទ្រង់ព្រះទ័យកន្ដើយ តាល់តែសហម្បតិមហាព្រហ្មមកអារាធនា ទើបព្រះអង្គសំដែងនោះ ជាការមិនពិត , មិនសមហេតុផលឡើយ ការនិយាយដូច្នេះហាក់ដូចជាសហម្បតិព្រហ្មនោះដឹងសុខទុក្ខ និងអាការចិត្តរបស់សត្វលោកជាងព្រះអង្គទៅទៀត ឯព្រះអង្គជាព្រះសព្វញ្ញូ បែរជាមិនដឹងស្មើនឹងសហម្បតិព្រហ្មទៅវិញ ។

ដូច្នេះ ការនឹកគិតពិចារណារបស់ព្រះពុទ្ធអង្គថា "ធម៌ដែលព្រះអង្គបានត្រាស់នោះ មានន័យជ្រៅឆ្ងាយណាស់ សត្វដែលមានកតាទិកិលេសមិនងាយនឹងបានឃើញបានយល់ ,, នោះក៏មានយ៉ាងនេះពិតមែន ដូចមនុស្សម្នាក់ដែលរៀនសូត្របានវិជ្ជាជំនួញខ្ពស់ណា ១ ក៏តែងគិតថាអ្នកដទៃដែលមានបញ្ញាទន់ខ្សោយ មិនងាយនឹងយល់បេះដឹងនូវវិជ្ជាដែលខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

បានចេះនោះឡើយ ម្លោះហើយក៏នឹកគិតធុញទ្រាន់នឹងយកវិជ្ជានោះ ទៅបង្រៀនអ្នកដទៃទៅវិញ ៗ ឯព្រះពុទ្ធអង្គកាលគង់នៅក្រោមដើមអជបាលនិគ្រោធនោះហើយផ្ទឹងគិត ១ ភ្លែតក៏មានព្រះចិន្តាស្ទុះទៅយ៉ាងនោះមែន តែកាលទ្រង់ព្រះចិន្តាតទៅទៀត ក៏មានព្រះគំនិត ១ ថាត្រូវតែសំដែងធម៌ដែលព្រះអង្គរកឃើញហើយ ដើម្បីជាប្រយោជន៍ដល់សត្វលោក ទោះបានតិចក្ដីច្រើនក្ដី ត្រូវតែសំដែង ៗ ព្រះទ័យករុណាមេត្តានេះហើយ ដែលហៅថាព្រហ្ម គោលគឺការកំណត់ដោយព្រះអង្គឯង ថានឹងសំដែងធម៌ដល់សត្វលោកដែលជាការចាំបាច់ ហើយដែលយើងធ្លាប់ដឹងថា ព្រហ្មអារាធនា តែតាមពិត គ្មានព្រហ្មឯណាមកអារាធនាទេ គឺនឹកព្រះទ័យអាណិតអាសូរចំពោះសត្វលោកនោះឯង ជាតួសហម្បតិព្រហ្ម ៗ

ស- ៧២. កាលទ្រង់ផ្ដើមព្រះទ័យនឹងសំដែងធម៌នោះ ព្រះអង្គទ្រង់ចាត់ទុកសត្វលោកជា ៤ ពួកថា "បរិស័ទ ៤ ជំពូកដូចផ្កាឈូក–ក្នុងផលប៉ាន,, ៗ តើបុគ្គលជាបរិស័ទទាំង ៤ ជំពូកនោះមានលក្ខណៈ–ខុសគ្នាយ៉ាងណាខ្លះ ?

ច– កាលទ្រង់តាំងព្រះទ័យនឹងសំដែងធម៌ក៏ដោយហេតុព្រះអង្គទ្រង់យកបុគ្គល ៤ ជំពូកមកប្រៀបប្រដូចនឹងផ្កាឈូក ៤ ផ្នែកដែលមានលក្ខណៈខុសគ្នាយ៉ាងនេះគឺ ៖

www.budinst.gov.kh www.elibraryofcambodia.org

ឧគ្ឃដិតញ្ញូ.- ជនដែលមានបញ្ញាបារមីចាស់ក្លា កាលណាបាន ស្ដាប់សៅនៃព្រះធម៌ទោះភ្លាម ប្រៀបដូចផ្កាឈូកដែលផុសផុតពីទឹកហើយ កាលណាមានពន្លឺព្រះអាទិត្យក៏រីកភ្លាម ។

វិបច្ចិតញ្ញូ ជនដែលមានបញ្ញាបារមីពុំទាន់ចាស់ក្លាខ្លាំងពេក កាល បើបានស្ដាប់ធម៌ហើយ ទាល់តែព្រះធម៌នោះមានន័យពិស្ដារវែងឆ្ងាយទើប ចាក់ធ្លុះយល់បានដូចផ្កាឈូកដែលផុះផុតពីទឹកហើយ តែពុំទាន់ដល់កាល វេលានឹងរីកក្នុងថ្ងៃនេះ ។

នេយ្យបរិស័ធ .- ជនដែលមានបញ្ញាបារមីពុំទាន់រឹងប៉ឹងនៅ លុះតែទ្រង់ទេសនាទូន្មានជាញឹកញយពេក ទើបចេះដឹងយល់បាន ដូចផ្កា ឈូកដែលនៅបប្រះទឹក លុះតែផុះផុតពីទឹកហើយត្រូវពន្លឺព្រះអាទិត្យ ជា ច្រើនដងទើបរីកបាន ។

បទបរមបរិស័ធ.- ជនដែលជាអ្នកគ្មានបារមីសោះ គឺមិន ព្រមស្ដាប់មិនព្រមប្រតិបត្តិតាម ការទូន្មានដឹកនាំរបស់ព្រះអង្គ ដូចផ្កា- ឈូកទើបនឹងប៉ុចពកនៅក្នុងទឹក រាំតែនឹងត្រូវចំណីត្រីជាដរាប ។

កាលទ្រង់ទតឃើញយ៉ាងនេះហើយ ទ្រង់គិតតាំងព្រះទ័យថា នឹងសំ ដែងធម៌ដើម្បីទូន្មានសត្វលោក តាមគួរដល់ឧបនិស្ស័យរបស់សត្វលោក នីមួយៗដែលបានកសាងពីអតីតជាតិមក ។

www.budinst.gov.kh www.elibraryofcambodia.org

**សេចក្ដីសន្និដ្ឋាន** .— ពេលបានត្រាស់ដឹងហើយថ្មីៗ ព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់បានបំពេញសកម្មភាពមួយតែមួយព្រះអង្គឯង គឺការនឹកគិតពិចារណានូវធម៌ដែលទ្រង់បានត្រាស់ដឹងហើយ និងឧបនិស្ស័យរបស់សត្វនានា ដែលព្រះអង្គត្រូវយកចំណែកនៃធម៌របស់ព្រះអង្គទៅប្រោសដឹកនាំនេះឯង ។

**ឃ្លាភ្ជាប់សេចក្ដី** .— តាំងនេះទៅយើងនឹងបានឃើញថា ព្រះអង្គមុខនឹងជាយកនូវព្រះបរមត្ថោក់ទ ដែលទ្រង់នឹងរកឃើញនោះទៅដឹកនាំសត្វលោកក្នុងត្រៃភពឲ្យរំដោះ ខ្លួនរួចចាកវដ្ដសង្សារជាមិនខាន ។

x

x x

## ភាគទី ៤

# ធម្មចក្កប្បវត្តនទេសនា
# និងការដឹកនាំសាវ័កនៅគ្រាដំបូង

ស- ៧៣. - កាលទ្រង់តាំងព្រះទ័យថានឹងសំដែងធម៌ហើយ តើព្រះអង្គទ្រង់នឹកដល់អ្នកណាមុនគេ ? ព្រោះហេតុអ្វី ?

ច ទ្រង់នឹកដល់ឧទកតាបសកាលាមគោត្រនិងអាឡារតាបសរាមបុត្រមុនគេ ព្រោះតាបសទាំងពីរនេះ មានឧបនិស្ស័យគួរដល់ការត្រាស់ដឹង ហើយជាគ្រូបាធ្យាយរបស់ព្រះអង្គកាលទ្រង់ទើបនឹងបានបួសហើយថ្មីៗផង តែមិនបានជួបទេ ព្រោះតាបសទាំងពីរធ្វើមរណៈកាលអស់ទៅហើយក្នុងពេលដែលទ្រង់ទើបនឹងបានត្រាស់ថ្មីៗឯណោះ ។

ស-៧៤. កាលអស់ពីតាបសទាំងពីរហើយ តើព្រះសាស្តាទ្រង់បានទៅសំដែងធម៌ប្រោសអ្នកណាមុនគេ នៅឯណា ? នៅថ្ងៃ ខែ· ឆ្នាំណា ? ធម៌នោះឈ្មោះអ្វី ? ហេតុដូចម្តេចបានជាទ្រង់សំដែងយ៉ាងនេះ ?

ច- ទ្រង់យាងចេញពីគយាសីសប្រទេស ទៅកាន់រដ្ឋកាសី ហើយសំដែងព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសដល់ពួកបញ្ចវគ្គិយភិក្ខុ ដែលធ្លាប់ទៅបំរើព្រះអង្គពីមុន ហើយដែលរត់ចោលព្រះអង្គនៅពេលទ្រង់ត្រឡប់

www.budinst.gov.kh www.elibraryofcambodia.org

ឆាន់អាហារវិញ ។ ទ្រង់សំដែងក្នុងព្រៃឥសិបតនមិគទាយជិតក្រុងពារាណ-
សី នៅថ្ងៃពេញបូរមីខែអាសាធឆ្នាំរកា (កុក្កុដេ សព្វញ្ញូ ពុទ្ធោ ធម្ម ចក្កំ ប-
វត្តយិ) ។ បានជាទ្រង់លើកយកធម៌នោះមកសំដែង ព្រោះទ្រង់មានគោល
បំណងនឹងបង្ហាញនូវអន្តធម៌ពីរប្រការគឺ កាមសុខល្លិកានុយោគ = ការប្រ
ព្រឹត្តិធ្វើខ្លួនឲ្យជាប់ជំពាក់ដោយកាម គឺសេចក្តីប្រាថ្នា ១ អត្តកិលមថានុ-
យោគ=ការប្រព្រឹត្តិធ្វើខ្លួនឲ្យលំបាកលំបិន ១ ដែលជាធម៌ថោកទាប, ជា
ធម៌របស់អ្នកស្រុក,ជាធម៌របស់បុថុជ្ជន,មិនមែនជាធម៌របស់ព្រះអរិយឡើយ
ហើយធម៌នេះព្រះអង្គធ្លាប់ប្រព្រឹត្តរួចមកហើយតែគ្មានបានគុណប្រយោជន៍
អ្វីសោះ មានតែផ្លូវ១គឺមជ្ឈិមាបដិបទា = ការប្រតិបត្តិយ៉ាងកណ្តាល គឺមគ្គ
មានអង្គ ៨ ប៉ុណ្ណោះទើបជាធម៌នាំឲ្យកើតបញ្ញាចក្ខុ---នាំឲ្យរលត់ទុក្ខ ។

សូមបញ្ជាក់ថា កាលព្រះអង្គបង្ហាញនូវការប្រព្រឹត្តទាំង ៣ បែបនេះ
ហើយ ទ្រង់ក៏សំដែងអំពីអរិយសច្ចទាំងបួន គឺ ទុក្ខសច្ច ១ សមុទយសច្ច
១ និរោធសច្ច ១ មគ្គសច្ច ១ ព្រមទាំងញាណ គឺ សច្ចញ្ញាណ ១ កិច្ច
ញ្ញាណ ១ កតញ្ញាណ ១ ។ ទេពតាទាំងឡាយក៏បន្លឺសម្លេងត ៗ គ្នា តាំង
ពីភុម្មទេវតារហូតដល់ព្រហ្មលោក ឯលោកធាតុទាំង ១ហ្មឺនក៏កក្រើកញាប់
ញ័រគ្រប់ទិសទី ចំណែកខាងកោណ្ឌញ្ញ ក៏បាននូវសោតាបត្តិផល ។
ពេលនោះព្រះបរមសាស្តាបានទ្រង់បន្លឺព្រះពុទ្ធដីកាថា ''អញ្ញាសិ វត ភោ

www.budinst.gov.kh www.elibraryofcambodia.org

កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ៗ កោណ្ឌញ្ញ បាន ចេះដឹងហើយហ្ន៎ ។

ទ្រង់សម្តែងធម្មចក្រនេះដល់វប្បក្នុងថ្ងៃ ១ កើត, ដល់ភទ្ទិយ ក្នុងថ្ងៃ ២ កើត, ដល់មហានាមក្នុងថ្ងៃ ៣ កើត, ដល់អស្សជិក្នុងថ្ងៃ ៤ កើត តមកក៏ឲ្យឧបសម្បទាដល់បញ្ចវគ្គិយភិក្ខុ រួចទ្រង់សម្តែងអនត្តលក្ខណសូត្រឲ្យភិក្ខុទាំងនោះស្តាប់ដោយព្រះអង្គបានបន្ទូលថា ‹‹ រូបំ ភិក្ខវេ អនត្តា ម្នាលភិក្ខុទាំងឡាយ រូបជារបស់មិនទៀងជាដើម ។ កាលចប់ធម្មទេសនាអំពីអនត្តលក្ខណសូត្រនោះហើយ បញ្ចវគ្គិយភិក្ខុក៏បានសម្រេចព្រះអរហត្តផល រួចចាកអាសវនានា ។

ស.៧៤. – កាលព្រះពុទ្ធជាម្ចាស់ទ្រង់ប្រោសបញ្ចវគ្គិយភិក្ខុហើយ ទ្រង់បានប្រោសជនណាទៀត ។

ច. ព្រះអង្គប្រោសយសកុលបុត្ត ជាកូននាងសុជាតាដែលបានថ្វាយបង្ហាន់ព្រះអង្គនៅថ្ងៃដែលទ្រង់បានត្រាស់ ។ យសកុលបុត្តនេះ កាលបានឃើញអាការៈប្លែកគួរឲ្យធុញទ្រាន់របស់ស្រីបំរើទាំងឡាយ នៅពេលរាត្រីមួយ ក៏កើតចិត្តនឿយណាយ ហើយបានដើរចេញពីលំនៅចូលទៅក្នុងព្រៃឆ្ងាយទៅ ៗ ក៏បានជួបនឹងព្រះបរមគ្រូ ៗ ទ្រង់សម្តែងអនុបុព្វីកថាឲ្យយសកុលបុត្តស្តាប់ក៏បានសម្រេចសោតាបត្តិផល ។

www.budinst.gov.kh www.elibraryofcambodia.org

ពេលជាបន្ទាប់មកមាតាបិតា នៃយសកុលបុត្ត បាត់កូនក៏តាមរក ហើយសេដ្ឋីជាបិតាបានទៅដល់ទ្វារចូល ព្រៃឥសិបតនៈ ក៏បានឃើញស្បែកជើងរបស់កូន ហើយតាមទៅរក បានជួបនឹងយសកុលបុត្តនៅចំពោះព្រះភក្ត្រព្រះសាស្តា ។ ទ្រង់សម្តែងអនុបុព្វីកថាឲ្យស្តាប់ ក៏បានសម្រេចសោតាបត្តិផល ដល់នូវត្រៃសរណគមន៍ស្មើជីវិត ។

សេដ្ឋីបាននិមន្តព្រះសាស្តាឲ្យយាងទៅទទួលភត្តឯផ្ទះ ព្រះអង្គទ្រង់យល់ព្រម ឯសេដ្ឋីបិតាយសកុលបុត្តត្រឡប់ទៅផ្ទះមុន ចំណែកខាងយសកុលបុត្ត បានសូមបព្វជ្ជាជាឯហិភិក្ខុព្រះសាស្តាក៏ទ្រង់ប្រទាន ។

ព្រឹកឡើងព្រះសាស្តាទ្រង់យាងទៅកាន់ផ្ទះសេដ្ឋីនិងនាងសុជាតាជាមួយយសត្ថេរ , មាតាបិតានិងភរិយាព្រះយស បានថ្វាយចង្ហាន់ដល់ព្រះអង្គ ។ ក៏សម្តែងអនុបុព្វីកថាឲ្យស្តាប់ក៏បានសោតាបត្តិផល ដល់នូវត្រៃសរណគមន៍ស្មើជីវិតដែរ ។ សេដ្ឋីនិងនាងសុជាតានេះហើយ ជាឧបាសកសិកាដែលដល់ត្រៃសរណគមន៍មុនគេបង្អស់ក្នុងព្រះពុទ្ធសាសនា ។

ពេលបន្ទាប់មកបុត្រសេដ្ឋី ៤ នាក់ឈ្មោះវិមល ១ សុពាហុ ១ បុណ្ណជិ ១ គវម្បតិ ១ ជាសំឡាញ់នឹងព្រះយសបានចូលសូមបព្វជ្ជាឧបសម្បទា ព្រះសាស្តាទ្រង់អនុញ្ញាត ។ តមកទៀតមានសម្លាញ់របស់ព្រះយសត្ថេរ ចំនួន៥០នាក់បានចូលបួស ហើយបានសម្រេចអរហត្តទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងរយៈវេលាប៉ុណ្ណោះមានព្រះអរហន្តចំនួន ៦១ អង្គ ក្នុងលោកគឺព្រះពុទ្ធ ១ បញ្ចវគ្គិយភិក្ខុ ៥ ព្រះយសនិងសម្លាញ់រួមជា ៥៥ ត្រូវជា ៦១ ។

ស. ៧៦ . កាលទ្រង់ប្រោសយសកុលបុត្តនិងមាតាបិតា ព្រមទាំងសម្លាញ់ទាំងនោះរួចហើយ ព្រះសាស្តាទ្រង់បានចាត់ការយ៉ាងណាខ្លះ ? ទ្រង់បានយាងទៅកាន់ទីណាទៀត ហើយប្រោសអ្នកណា ?

ច — កាលមានព្រះអរហន្តៈច្រើនគួរសមហើយព្រះសាស្តាទ្រង់ចាត់ឲ្យចេញទៅក្នុងទិសផ្សេងៗ ដើម្បីប្រកាសសាសនា . ឯព្រះសាស្តាទ្រង់យាងទៅកាន់ឧរុវេលនិគមដោយព្រះអង្គឯង ។ នៅតាមផ្លូវក្នុងព្រៃកប្បាសិកព្រះអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទាដល់យុវជនចំនួន៣០នាក់ ។ កាលយាងទៅដល់ឧរុវេលនិគមហើយ ទ្រង់បានធ្វើបាដិហារ្យផ្សេងៗជាច្រើនចំនួន១.៥០០បែបផ្ចាញ់ជដិលទាំង៣ជាបងប្អូននឹងគ្នា គឺ ឧរុវេលកស្សបមានបរិវារ៥០០នាក់ , នទីកស្សបមានបរិវារ៣០០នាក់ និងគយាកស្សបមានបរិវារ២០០នាក់ឲ្យចុះចាញ់ ហើយប្រទានឯហិភិក្ខុឧបសម្បទាដល់ជដិលទាំង១០០៣នាក់ រួចទ្រង់សំដែងអាទិត្តបរិយាយសូត្រប្រោសជដិលទាំងនោះៗ ក៏បានសម្រេចព្រះអរហត្តផល ។ ព្រះសាស្តាទ្រង់បានព្រះអរហន្តជាសាវកចំនួន១០៩៣អង្គហើយ ។

ស. ៧៧. — កាលព្រះសាស្តាទ្រង់ទើបនឹងសាងព្រះផ្នួសហើយថ្មីៗ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បានទទួលនិមន្តព្រះបាទពិម្ពិសារថា នឹងយាងទៅប្រោសព្រះរាជាមុនគេ ហេតុអ្វីក៏ព្រះអង្គទៅប្រោសអ្នកដទៃៗ មុនទៅវិញ? មានប្រយោជន៍យ៉ាងណា ? ព្រោះអ្វី ?

ប — ពិតមែនតែបានទទួលពាក្យប្តេជ្ញាមែន ក៏ប៉ុន្តែពេលនោះព្រះអង្គក៏ពុំទាន់ជ្រាបនិស្ស័យសត្វលោក ដោយព្រះប្រាជ្ញាញាណជាព្រះពុទ្ធនោះទេ គឺព្រះអង្គនៅជាបុថុជ្ជននៅឡើយ លុះព្រះអង្គបានត្រាស់ហើយទ្រង់ប្រមើលមើលនិស្ស័យសត្វលោក ក៏ទ្រង់ឃើញថា គួរទុកព្រះរាជាគង់ពេលជាខាងក្រោយចុះ ត្រូវប្រោសជនអ្នកមានប្រាជ្ញាបារមីចាស់ក្លាមុន ចំណែកខាងយសកុលបុត្ត និងមាតាបិតាព្រមទាំងសម្លាញ់ព្រះយសជាដើម ក៏មាននិស្ស័យចាស់ក្លាផង មានការទាក់ទងជួបនឹងព្រះអង្គជាបន្តបន្ទាប់គ្នាផង បានជាព្រះអង្គទ្រង់ប្រោស ហើយដើម្បីបានជាអ្នកជំនួយដល់ព្រះអង្គផង ។ល។

តពីនោះមកទ្រង់ព្រះចិន្តាថាទ្រង់នឹងយាងទៅកាន់មគធរដ្ឋក្រុងរាជគ្រឹះ ដើម្បីសំដែងធម៌ថ្វាយព្រះបាទពិម្ពិសារ ក៏ប៉ុន្តែដោយទ្រង់យល់ថា នៅនគររាជគ្រឹះមានតែព្រះរាជា១ព្រះអង្គប៉ុណ្ណោះ ដែលទ្រង់ស្គាល់ព្រះអង្គជាសាស្តាចារ្យ ឯព្រាហ្មណ៍គហបតី, សេដ្ឋី, មន្ត្រីឯទៀតៗទទួលស្គាល់តែគ្រូកស្សបប្អូនជដិលផ្សេងៗថាជាមេលទ្ធិ, ជាគ្រូបារបស់គេទៅវិញ គេពុំទទួល

www.budinst.gov.kh www.elibraryofcambodia.org

ស្គាល់ព្រះឫទ្ធិផងទេ ។ ហេតុដូច្នេះបានជាទ្រង់យាងទៅប្រោសជដិលទាំង ៣ ដែលជាទីគោរពសក្ការៈរបស់អ្នកស្រុក ,, អ្នកនគរក្នុងពេលនោះជាមុនសិន សឹមនាំផងជដិលទាំងនោះដែលបាក់ធ្មឹង ។ បាក់ចិត្តមានះចូលទៅកាន់ទីប្រជុំជន ទើបបានផលល្អ ។

អាស្រ័យហេតុនេះហើយ បានជាទ្រង់យាងទៅធ្វើបាដិហារ្យផ្ចាញ់ពួកជដិលទាំង ៣ ឲ្យបាក់បបខូចខ្ទាច សុំចូលជាសាវ័ករួចបានសម្រេចព្រះអរហត្តផលបានសព្វគ្រប់ហើយ ក៏នាំចូលទៅនគររាជគ្រឹះ ៗ ទៅទីនោះ ប្រជាជនមានសេចក្ដីសង្ស័យថា ‟ ព្រះសិទ្ធត្ថសមណៈជាសិស្សរបស់កស្សបទាំង៣ ឬក៏កស្សបទាំង៣ជាសិស្សរបស់ព្រះសិទ្ធត្ថសមណៈ? កាលព្រះសាស្ដាទ្រង់ជ្រាបយ៉ាងនេះហើយ ទ្រង់ក៏ឲ្យឧរុវេលកស្សបៈហោះឡើងហើយចុះមកថ្វាយបង្គំព្រះសាស្ដាអស់វារៈ ៧ ដង ទើបបន្លឺវាចាថា ‟ ព្រះពុទ្ធសមណៈគោតមជាបរមគ្រូក្នុងលោក, ជាគ្រូរបស់ខ្ញុំ, ខ្ញុំជាសាវ័ករបស់ព្រះអង្គ ៗ ប្រជាជនឃើញទិដ្ឋភាពដូច្នេះក៏មានចិត្តគោរពនិងស្ញើចចំពោះព្រះបរមសាស្ដាយ៉ាងខ្លាំង, ព្រះសាស្ដាទ្រង់សម្ដែងធម៌មហានារទជាតកប្រោស លុះចប់ព្រះរាជានិងព្រាហ្មណ៍គហបតី,សេដ្ឋីព្រមទាំងបរិវារ ១១ ម៉ឺននាក់បានសម្រេចសោតាបត្តិផល ចំណែកខាងឯកបរិវារ ១ម៉ឺននាក់ បានដល់ព្រះត្រៃសរណគមន៍ ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយសរុបមក ការដែលព្រះពុទ្ធបរមសាស្តាទ្រង់បានយាងទៅប្រោសជនដទៃ ៗ មុនការយាងទៅប្រោសព្រះបាទពិម្ពិសារនោះ មានផលប្រយោជន៍ម្យ៉ាង ត្រង់ការបាននូវសាវកជាជំនួយក្នុងការប្រកាសសាសនាជាដំបូង ម្យ៉ាងទៀតមានប្រយោជន៍ត្រង់ព្រះអង្គយកកស្សបទាំង ៣ ជាទីគោរពសក្ការៈរបស់អ្នកស្រុកមកធ្វើជាមធ្យោបាយ ដើម្បីដឹកនាំអ្នកស្រុកឲ្យចុះចូល មកកាន់ពុទ្ធសាសនមណ្ឌលបានដោយងាយ ដោយឥតមានការលំបាកដល់ព្រះអង្គ ។

ស. ៧៨– វត្តអារាមជាមជ្ឈមណ្ឌលរបស់ព្រះពុទ្ធ និងពុទ្ធសាសនិកជន ៗ តាំងពីព្រះពុទ្ធបានត្រាស់មក យើងពុំទាន់ឃើញថាព្រះពុទ្ធអង្គទ្រង់គង់ក្នុងវត្តណា ១ នោះ ដូច្នេះតើពេលទ្រង់បានប្រោសព្រះបាទពិម្ពិសារហើយ ទ្រង់មានវត្តអារាមណាជាទីគង់នៅដែរ ? វត្តណាកើតជាដំបូងបង្អស់ ? អ្នកណាសាងថ្វាយ ?

ច – ព្រះពុទ្ធអង្គទ្រង់ពុំទាន់មានវត្តអារាមជាទីគង់ប្រចាំនៅឡើយ ។ នៅវស្សាទី ១ ពេលត្រាស់ហើយ ៗ យាងទៅប្រោសបញ្ចវគ្គិយភិក្ខុ ទ្រង់ក៏គង់នៅចាំវស្សាក្នុងព្រៃឥសិបតនៈ កាលចេញវស្សាហើយក៏ទ្រង់យាងមកឧរុវេលនិគម រួចយាងទៅកាន់ក្រុងរាជគ្រឹះទៀត ។ កាលព្រះអង្គទ្រង់ប្រោសព្រះបាទពិម្ពិសារនិងបរិវារហើយ ព្រះរាជាក៏ទ្រង់ថ្វាយ

www.budinst.gov.kh www.elibraryofcambodia.org

ឧទ្យានវេឡុវ័ន (ព្រៃឬស្សី) របស់ព្រះអង្គទៅព្រះសាស្ដា ។ ទទួលហើយព្រះរាជាក៏កសាងវត្តនៅទីនោះឈ្មោះថា ''វេឡុវនារាម,, ជាទីគង់ប្រចាំរបស់ព្រះពុទ្ធនិងពុទ្ធសាវ័ក ។ វត្តវេឡុវ័ននេះហើយ ដែលកើតជាបឋមក្នុងពុទ្ធសាសនា ដោយព្រះបាទពិម្ពិសារទ្រង់បានកសាងថ្វាយ នៅជៀមក្រុងរាជគ្រឹះដែនមគធៈ ។

- ស ៧៩ - កាលព្រះអង្គគង់នៅក្នុងវត្តវេឡុវ័ន តើទ្រង់បានប្រោសជនណា ក្រៅពីព្រះរាជានឹងរាជបរិពារដែរ ?

ច.- ទ្រង់បានទទួលព្រះសារីបុត្រនិងព្រះមោគ្គល្លាន និងបរិពារ ២៥០ នាក់ ឲ្យចូលបួសក្នុងសំណាក់ព្រះអង្គ ។

ស - ៨០ - ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន មានប្រវត្តិរូបយ៉ាងណាខ្លះ ? កាលបានបួសហើយបានជាអ្វី ? ចូរអធិប្បាយឲ្យល្មមស្ដាប់ បើសិនជាមានហេតុចម្លែក !

ច- ប្រវត្តិដ៏សង្ខេបរបស់ព្រះសារីបុត្តនិងព្រះមោគ្គល្លានមានយ៉ាងនេះគឺ ៖

លោកជាបុត្រនៃត្រកូលអ្នកមានទ្រព្យនៅក្នុងមគធរដ្ឋ គឺព្រះសារីបុត្តនាមដើមជា ឧបតិស្សមាណព ជាបុត្រនៃនាងសារីព្រាហ្មណី នៅឧបតិស្សគ្រាម ។ ព្រះមោគ្គល្លាន នាមដើមជាកោលិតមាណព ជាបុត្រនៃ

www.budinst.gov.kh www.elibraryofcambodia.org

ទាន់មោគ្គល្លី នៅកោលិតគ្រាម ។ លោកជាសំឡាញ់ដ៏ជិតស្និទ្ធនឹងគ្នា តាំងពីតូចមក ។ ថ្ងៃមួយមាណពទាំងពីរបានទៅមើលមហោស្រពជាមួយគ្នា ក៏កើតសេចក្តីសង្វេគស្លុតមុខដូចៗគ្នា ហើយបានលាមាតាបិតា ក៏គ្នាចូលទៅបួសជាបរិព្វាជកក្នុងសំណាក់មេលទ្ធិម្នាក់ ឈ្មោះសញ្ជ័យ ។ កាលលោកទាំងពីរបួសរួច បានសិក្សាវិជ្ជាផ្សេង ៗ អស់ពីគ្រូនោះហើយ ពុំបានឃើញអ្វី ទើបសួរគេទីបំផុតនៃធម៌ដែលខ្លួនសិក្សារួចហើយនោះ ហាកគ្រូសញ្ជ័យតាល់ឆ្លើយមិនរួច ដោយលោកបានពោលថា ធម៌របស់ខ្ញុំអស់ត្រឹមនេះឯង ។

ឧបតិស្សនឹងកោលិត គិតថា ធម៌ដែលយើងសិក្សាក្នុងសំណាក់លោកគ្រូសញ្ជ័យនេះ មានតែដើមទីងកណ្តាល នៅខ្វះខាងចុងចុះ លទ្ធិនេះមិនមែនជាផ្លូវនាំឲ្យយើងរកឃើញនូវទីបំផុតទុក្ខតទៅទៀត គួរយើងប្រប្រួលគំនិតស្វែងរកមេលទ្ធិតទៅទៀត ដើម្បីរកទីបំផុតនៃធម៌ឲ្យឃើញ ។ កាលពិភាក្សាហើយក៏បែកផ្លូវគ្នាដើរទៅក្នុងផ្សេង ៗ ដោយបានសន្យាថា ថ្ងៃនោះ ៗ នឹងជួបគ្នា នៅកន្លែងនេះកន្លែងនោះ ។

ពេលនោះឧបតិស្សមាណព បានដើរចូលទៅក្រុងរាជគ្រឹះ ក៏បានឃើញព្រះអស្សជិត្ថេរ និមន្តបិណ្ឌបាតប្រកបដោយឥន្ទ្រិយ៍ នឹងប្ដូរកា

ថេរោម ក៏គិតថា ,, អ្នកនេះប្រហែលជាអ្នកបានសម្រេចធម៌អ្វីមួយហើយ គួរតែអញចូលទៅសួរមើល តែពេលនេះលោកកំពុងត្រាច់បិណ្ឌបាត្រ ,, មាណពកំណត់ក្នុងចិត្តហើយក៏ដើរតាមព្រះអស្សជិត្ថេរ លុះដល់ទីស្ងាត់ ក៏សំពែងសេចក្តីគួរសមហើយសួរព្រះថេរថា '' បពិត្រលោកដ៏មានអាយុ ឥន្ទ្រិយ៍និងឫកពាររបស់លោក មានអាការថ្លាណាស់ ប្រហែលជាលោកបានសម្រេចធម៌អ្វីមួយហើយ ។ តើលោកបួសក្នុងសំណាក់គ្រូណា ? ព្រះអស្សជិត្ថេរឆ្លើយថា '' ខ្ញុំជាសិស្សរបស់ព្រះសាមណៈគោតមដែលចេញពីសាក្យត្រកូលហើយបួស ព្រះអង្គជាគ្រូរបស់ខ្ញុំ ,, ឧបតិស្សមាណពទូលតទៅទៀតថា គ្រូរបស់លោកបានទូន្មានយ៉ាងណាខ្លះ ? ចំពោះលោកដ៏មានអាយុ ? សូមលោកប្រាប់ខ្ញុំផងបានទេ ? ព្រះអស្សជិត្ថេរថា ,, មាណពនេះសួរអញជ្រៅណាស់ បើអញឆ្លើយក៏បានតែល្ហើយចុះពេលនេះខ្លីផង ហើយមិនគួរនឹងឆ្លើយឲ្យយូរផង ដូច្នេះមានតែអញនិយាយឲ្យខ្លី ហើយជ្រៅតែ១ម៉ាត់ឲ្យមាណពនេះទូន់ត្រចៀកសិន បើសង្ស័យយ៉ាងណាឲ្យទៅជួបព្រះបរមគ្រូផ្ទាល់ទៅចុះ ។ គិតរួចព្រះថេរពោលថា ៖

យេ ធម្មា ហេតុប្បភវា　　តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច　　ឯវំ វាទី មហាសមណោ

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ទាំងឡាយណាតែងកើតពីហេតុ , ព្រះតថាគតជាមហាសមណៈ ទ្រង់ជ្រាបនូវហេតុនៃធម៌នោះផង ហើយទ្រង់ចេះនូវឧបាយសម្រាប់រលត់នៃធម៌ទាំងឡាយនោះផង ។

ឧបតិស្សមាណពគ្រាន់តែឮប៉ុណ្ណោះ ក៏បានធម្មចក្ខុសម្រេចនូវសោតាបត្តិផលភ្លាម ហើយក៏ទូលព្រះអស្សជិត្ថេរថា “ សូមព្រះថេរៈសំដែងប៉ុណ្ណោះចុះ ខ្ញុំព្រះករុណាស្តាប់បានហើយ ។ ខ្ញុំព្រះករុណានឹងទៅនាំសម្លាញ់ម្នាក់ទៀត ដើម្បីចូលគាល់ព្រះសាស្តាចារ្យ ។ ចារ់រួចក៏ស្តាត់រកកោលិតមាណពជាសំឡាញ់ កាលបានជួបហើយក៏ថ្លែងរឿងពីរទិនធម្មកថានោះប្រាប់កោលិតមាណព ។ ស្តាប់ហើយ ក៏បានសម្រេចធម្មចក្ខុដែរ រួចក៏ទៅកាន់សំណាក់អាចារ្យសញ្ជ័យ ហើយនិយាយអង្វរថា ‘សុំឲ្យលោកគ្រូនិមន្តទៅសំណាក់ព្រះសមណគោតម ជាព្រះបរមសាស្តាចារ្យដែលទើបនឹងបានត្រាស់ដឹងរកឃើញទីបំផុតនៃធម៌ ដែលសព្វថ្ងៃទ្រង់នឹងក្រុងរាជគ្រឹះ,, អាចារ្យសញ្ជ័យមិនព្រមសោះ ទោះជាមាណពអង្វរយ៉ាងណាក៏ដោយ យូរ ៗ ទៅអាចារ្យសញ្ជ័យសួរមាណពបរិព្វាជកទាំងពីរថា “ ក្នុងលោកនេះតើមានអ្នកចេះច្រើនជាងអ្នកល្ងង់ ឬ មានអ្នកល្ងង់ច្រើនជាងអ្នកចេះ ? មាណពឆ្លើយថា ‘អ្នកល្ងង់ច្រើនជាង, ចារ្យសញ្ជ័យក៏ឆ្លើយថា “ បើដូច្នោះអ្នកឯងយកអ្នកចេះទៅចុះ ទុកអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ល្វង់ឡើញ,, ។ មាណពជាសម្លាញ់ទាំងពីរនាក់ក៏នាំបរិព្វាជក២៥០នាក់ ចូលទៅកាន់សំណាក់ព្រះពុទ្ធឯវត្តវេឡុវ័នក្រុងរាជគ្រឹះដោយសុវត្ថិភាព ។

គ្រានោះ ព្រះសាស្តាទ្រង់ទតឃើញមាណពទាំងពីរហើយ ក៏ប្រាប់សាវ័ករបស់ព្រះអង្គថា “ អ្នកទាំងពីរនេះនឹងបានជាអគ្គសាវ័ករបស់តថាគតទៅអនាគត ។ មាណពកាលបានជួបនឹងព្រះពុទ្ធជាម្ចាស់ហើយ ក៏សូមឧបសម្បទាជាភិក្ខុជាមួយបរិវាររបស់ខ្លួន ។ កាលបានបួសហើយ ឧបតិស្សក៏មាននាមថា សារីបុត្ត ( កូននៃនាងសារីព្រាហ្មណី ) ឯកោលិតមាននាមថា “ មោគ្គល្លាន ( កូននៃនាងព្រាហ្មណីឈ្មោះមោគ្គលី )។ ៧ ថ្ងៃក្រោយពីបួសហើយ ព្រះមោគ្គល្លាន ក៏បានសម្រេចព្រះអរហត្តផល ដោយបានស្តាប់នូវធាតុកម្មដ្ឋានអំពីព្រះពុទ្ធបរមគ្រូ នៅស្រុកកល្លវាឡគ្រាម ដែនមគធៈ ឯព្រះសារីបុត្រ ក៏បានសម្រេចព្រះអរហត្ត ដោយបានស្តាប់វេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាសំដែងដល់ទីឃនខបរិព្វាជកជាក្មួយរបស់លោក នៅក្នុងគុហាឈ្មោះសូករខាតៈ ក្រោយពីពេលដែលលោកបួសហើយបានកន្លះខែ គឺក្រោយព្រះមោគ្គល្លាន៨ថ្ងៃ។

កាលលោកទាំងពីរបានសម្រេចព្រះអរហត្តហើយ ព្រះសាស្តាក៏ធ្វើសាវកសន្និបាតនៅក្នុងវត្តវេឡុវ័នក្នុងក្រុងរាជគ្រឹះ ដោយមានព្រះអរហន្តចំនួន ១.២៥០ អង្គមកប្រជុំគ្នា ហើយព្រះអង្គបានតាំងព្រះសារីបុត្ត

www.budinst.gov.kh www.elibraryofcambodia.org

ជាអគ្គសាវ័កស្តាំ , ព្រះមហាមោគ្គល្លាន ជាអគ្គសាវ័កឆ្វេង ។ មហាសាវ័កសន្និបាត និងការតាំងអគ្គសាវ័កនេះទ្រង់ធ្វើនៅវត្តវេឡុវ័ន នៅថ្ងៃពេញបូរមីខែមាឃឆ្នាំរកា ពេលព្រះអង្គបានត្រាស់ដឹងហើយ ១ វស្សា គឺក្រោយពេលទ្រង់ត្រាស់ដឹង ៩ ខែ ( រាប់ពីពេញបូរមីខែវិសាខ មកទល់ពេញបូរមីខែមាឃ មានក្បាលខែ ១០ តែគិតតាមថ្ងៃបានតែ ៩ ខែ ប៉ុណ្ណោះ ) ។

(ក្នុងរឿងនេះ មានពុទ្ធប្បវត្តិខ្លះដាក់ថា ទ្រង់ធ្វើមហាសន្និបាត ដើម្បីសំដែងបាតិមោក្ខនៅថ្ងៃពេញបូរមីខែមាឃឆ្នាំរកាទៅវិញ ។ ចំពោះឆ្នាំនេះ បើគិតតាមខ្មែរយើងមិនត្រូវទេ ព្រោះខ្មែរយើងចូលឆ្នាំនៅខែចេត្រ ឬដើមខែពិសាខ ឯព្រះពុទ្ធទ្រង់បានត្រាស់ដឹងនៅថ្ងៃពេញបូរមីខែពិសាខ ឆ្នាំរកា គឺចូលឆ្នាំចទៅហើយ ។ បើរាប់ពីខែពិសាខ មកដល់ខែមាឃ ក៏ឃើញថានៅក្នុងឆ្នាំរកាដដែល ហើយថាឆ្នាំរកានោះ រឹតតែឃ្លាតឆ្ងាយពីការពិតទៅទៀត ព្រោះខ្មែរយើងត្រូវរាប់ថា វក-រកា មិនមែនរាប់ថារកា-វកទេ ។ បើគិតថាពីឆ្នាំរកាហូតទល់ឆ្នាំរកាទៀត ក៏ឃើញថាឆ្ងាយពីគ្នារហូតទល់ ១២ ឆ្នាំឯណោះ ឯការសំដែងឱវាទបាតិមោក្ខ និងការប្រជុំមហាសាវ័កសន្និបាតវិញ គឺធ្វើនៅពេលក្រោយទ្រង់បានត្រាស់តែ ៩ ខែ ហើយដែលទើបនឹងមាន

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអរហន្តតែ ១២៥០ អង្គប៉ុណ្ណោះ ។ កាលត្រាស់ដឹងហើយបានពីរខែទ្រង់ទៅសំដែងធម្មចក្រប្រោសបញ្ចវគ្គិយភិក្ខុ ហើយទ្រង់ចាំវស្សានៅក្នុងឥសិបតនមិគទាយវ័ន ១ វស្សា លុះដល់ពេលចេញវស្សាទ្រង់យាងទៅប្រោសជដិល ១០០៣ នាក់រួច ក៏យាងចូលទៅប្រោសព្រះបាទពិម្ពិសារទៀត ទើបព្រះរាជាថ្វាយឧទ្យានវេឡុវ័ន ធ្វើជាអារាម ហើយព្រះអង្គក៏ធ្វើមហាសន្និបាត សំដែងបាដិមោក្ខនៅទីនោះ ។

ដូច្នេះ គួរសន្និដ្ឋានថាព្រះអង្គធ្វើសាវកសន្និបាត និងទ្រង់សំដែងឱវាទបាដិមោក្ខនៅថ្ងៃពេញបូណ៌មីខែមាឃឆ្នាំរកាវិញ ឃើញថាសមហេតុផង ។ ទ្រង់ធ្វើមុនពេលយាងទៅកាន់ក្រុងកបិលព័ស្តុ ១ ខែ ព្រោះទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុជាលើកដំបូង នៅថ្ងៃពេញបូណ៌មីខែផល្គុនឆ្នាំរកា ) ។

ស- ៨១ .– ព្រះអគ្គសាវ័កទាំងគូនេះ មានគុណសម្ប័ទយ៉ាងណាខ្លះ ? បានជួយព្រះសាស្តាដូចម្តេចដែរ ក្នុងការប្រកាសព្រះពុទ្ធសាសនា ?

ព្រះសារីបុត្ត ជាសាវ័កដែលមានប្រាជ្ញាបារមីដ៏ច្រើនលើសលុប អាចសំដែងធម៌បានពិស្តារដូចព្រះអង្គដែរ ដូចធម្មចក្កនិងអរិយសច្ចជាដើម ព្រមទាំងអាចដឹកនាំបរិស័ទឲ្យតាំងនៅក្នុងមគ្គផលជាន់ដំបូងទៀតផង

www.budinst.gov.kh www.elibraryofcambodia.org

ឯព្រះមហាមោគ្គល្លាន ជាសាវ័កដ៏ឆ្នើមខាងមានឫទ្ធិច្រើន អាចធ្វើអ្វីបានគ្រប់យ៉ាង ហើយអាចញ៉ាំងត្រកូលដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាថែមទាំងមិនធ្វើឲ្យខូចត្រកូលដែលលោកចូលទៅអាស្រ័យនោះទៀតផង ប្រៀបដូចឃ្មុំដែលចូលទៅក្រេបយកលំអងនៃផ្កាអំពីផ្កា តែមិនធ្វើឲ្យផ្កាខូចស្រពោនឡើយ ។ លោកអាចដឹកនាំបរិស័ទឲ្យតាំងនៅក្នុងមគ្គផលខាងលើតទៅទៀតបាន ។

សូមបញ្ជាក់ថា ព្រះសារីបុត្តនេះ មានសេចក្តីគោរពចំពោះព្រះអស្សជិត្ថេរណាស់ ដោយហោចទៅ សូម្បីតែនឹងដំណឹងថា ព្រះអស្សជិត្ថេរគង់នៅក្នុងទិសណា ក៏តែងសឹងបែរព្រះសិរសាទៅរកទិសនោះដែរ ព្រោះអស្សជិជាគ្រូរបស់លោកដែលបានផ្តល់នូវព្រះធម៌ ឲ្យលោកយល់ជាដំបូងបង្អស់ ។

ស- ៨២ . — មហាសាវ័កសន្និបាត នៃព្រះពុទ្ធទ្រង់ធ្វើនៅវត្តវេឡុវ័ននោះ ហៅថាអ្វីផ្សេងទៀតបានទេ ? ចូរអធិប្បាយ ។

ច - ហៅថា ចតុរង្គសន្និបាតក៏បាន ដែលជា ការប្រជុំប្រកបដោយអង្គ ៤ គឺ ៖

១ — មាឃនក្ខត្តេន យុត្តោ បុណ្ណមី ឧបោសថទិវសោ = ប្រជុំនៅថ្ងៃពេញបូណ៌មី ជាថ្ងៃឧបោសថ ប្រកបដោយផ្កាយនក្ខត្តឫក្សប្រចាំ

www.budinst.gov.kh www.elibraryofcambodia.org

ខែមាឃ ។

២ — កេនចំ អនាមន្តិតានំ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានំ អឌ្ឍតេរសានំ ភិក្ខុសតានំ = មានភិក្ខុសង្ឃ ១២៥០ អង្គ និមន្តមកប្រជុំដោយខ្លួនឯង តាមធម្មតារបស់ខ្លួន ឥតអ្នកណានិមន្តមកឡើយ ។

៣ — តេសុ ឯកោ បុថុជ្ជនោ វា សោតាបន្នសកទាគាមិអនាគាមិសុក្ខវិបស្សអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆឡភិញ្ញាវ = ភិក្ខុទាំង១.២៥០អង្គ សូម្បីមានឋានៈត្រឹមតែជា បុថុជ្ជន ឬ ជាសោតាបន្នបុគ្គល , ជាសកទាគាមី , អនាគាមី ឬជាអរហន្តគ្រាន់តែស្ងួតកិលេស ( សុក្ខវិបស្សក ) ក៏គ្មានឡើយ គឺសុទ្ធតែព្រះអរហន្តបានអភិញ្ញា៦គ្រប់រូបទាំងអស់ ។

៤ — ឯកោបិ ខេត្ត សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ = ភិក្ខុទាំងអស់ គ្មានភិក្ខុរូបណាមួយកោរសក់ដោយកាំបិតហើយបួសទេ គឺសុទ្ធតែជាឯហិភិក្ខុទាំងអស់ ។

ស - ៨៣. — បាតិមោក្ខ មានប៉ុន្មានយ៉ាង? អ្វីខ្លះ ? ព្រះពុទ្ធទ្រង់សំដែងបាតិមោក្ខណា ?

ច — មាន២យ៉ាងគឺ ឱវាទបាតិមោក្ខ១ អាណាបាតិមោក្ខ១ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធទ្រង់សំដែងទុកឲ្យបាដិមោក្ខមាន "សព្វបាបស្ស អករណំ = ការមិនធ្វើបាបគ្រប់យ៉ាងជាដើម ។

ស. ៩៤ . អាណាបាដិមោក្ខ គឺអ្វី ?

ច - អាណាបាដិមោក្ខ គឺ បញ្ញត្តិដែលទ្រង់ហាមឃាត់ខាតចំពោះសាវ័ក គឺសិក្ខាបទ ២២៧ ជាដើម ។

**សេចក្តីសន្និដ្ឋាន.**- រួចមកហើយ យើងបានឃើញថា ការត្រាស់ដឹងរបស់ព្រះសិទ្ធត្ថ បានជាសព្វញ្ញុពុទ្ធបរមគ្រូ ដែលទើបនឹងបាន ៤ ខែប៉ុណ្ណោះ ឃើញថាព្រះអង្គបាននាំមកនូវប្រយោជន៍យ៉ាងច្រើនសន្ធឹកដល់សត្វលោក, ដោយទ្រង់បានធ្វើឲ្យមនុស្សខ្លះដែលមានចិត្តមានះរឹងត្អឹង ប្រកាន់ថាខ្លួនជាមនុស្សវិសេសវិសាលជាព្រះអរហន្តក្នុងលោក ឲ្យបាក់បបខ្លួនបង្គួចព្រះអង្គ រួចនាំគ្នាចូលជាសាវ័ករបស់ព្រះអង្គ ហើយបានសម្រេចធម៌ជាន់ខ្ពស់ៗទៀតផង ដូចជា ជដិលបងប្អូន ៣ នាក់ជាដើម ចំណែកខាងផងខ្លះ ដូចជាបញ្ចវគ្គិយភិក្ខុ, យសនឹងសំឡាញ់, ភទ្ទិយកុមារ, ព្រះសារីបុត្ត, មោគ្គល្លាន ជាដើមដែលមានបារមីប្រាជ្ញាចាស់ក្លាស្រាប់ ក៏បានសម្រេចធម៌ដោយឆាប់ហ័សដែរ ដូចផ្កាឈូកដែលដុះផុតពីទឹកមានរូបរាងធំទៅហើយ កាលត្រូវកំដៅរស្មីព្រះអាទិត្យភ្លាម ក៏រីកភ្លាមមួយរំពេច ។ ការបានផលប៉ុណ្ណោះ គឺនៅក្នុងរយកាលដ៏ខ្លី ហើយក្នុង

www.budinst.gov.kh www.elibraryofcambodia.org

សកម្មភាពដ៏ពិចល្អមរបស់ព្រះសាស្តាតែប៉ុណ្ណោះ ។

**ឃ្លាភ្ជាប់សេចក្តី**.— ពុទ្ធសកម្មភាពតទៅមុខទៀត មុខជានឹងបានផលយ៉ាងច្រើនលើមហាជន ដែលមានទិដ្ឋិផ្សេងនានា ជាមិនខានព្រោះម្យ៉ាងព្រះអង្គមានមធ្យោបាយគ្រប់គ្រាន់ក្នុងការដឹកនាំបរិស័ទ ម្យ៉ាងទៀតទ្រង់មានសាវ័កពិសេសៗ ដ៏ច្រើនល្មមធួននឹងដើរប្រកាសព្រះសាសនារបស់ព្រះអង្គឲ្យផ្សាយទូទៅគ្រប់ទិសទីតាមព្រះពុទ្ធបំណងយ៉ាងពិតប្រាកដ ។

x

x x


សៀវភៅ " ប្រជុំនិទានពុទ្ធសាវ័ក ", មាន
ប្រវត្តិរបស់សាវ័កសំខាន់ ៗ, ជាតកផ្សេង ៗ ជាច្រើន
ដោយ **វិសម–សួរ**
**នឹងផ្សាយចេញជាប់ ៗ នេះ**

ភាគទី១០

# ការយាងទៅកាន់កបិលព័ស្ដុបុរី
# ជាលើកទី១និងការដឹកនាំសាក្យរាជនានា

ស-៨៥-- មាតាបិតា, មាតុប្រទេស ជាអ្នកមានគុណ, ជាកន្លែងដែលត្រូវតែយាងទៅ ប៉ុន្តែព្រះពុទ្ធជាម្ចាស់វិញ តាំងពីពេលបានត្រាស់មក ទ្រង់ពុំទាន់យាងទៅប្រោសបិតា ឬ យាងទៅក្រុងកបិលពស្ដុម្ដងសោះ តើដោយហេតុអ្វី ?

ច- ព្រះពុទ្ធជាម្ចាស់ ពុំបានភ្លេចដល់ព្រះបិតា ឬ មាតុប្រទេសទេ ក៏ប៉ុន្តែទ្រង់ប្រោសសត្វលោកទៅតាមឧបនិស្ស័យ ម្យ៉ាងទៀតព្រះបាទពិម្ពិសារជាមហាក្សត្រ ដែលមានក្សត្រប្រទេសឯទៀត ៗ ជាច្រើននៅចំណុះ សូម្បីព្រះសុទ្ធោទនជាពុទ្ធបិតា ក៏ជាក្សត្រចំណុះព្រះបាទពិម្ពិសារដែរ ដូច្នេះបានជាព្រះពុទ្ធជាម្ចាស់ទ្រង់ ធ្វើការទាក់ទងប្រោសមហាក្សត្រដ៏មានអានុភាពច្រើនឲ្យបានជាមុនទើបយាងទៅប្រោសក្សត្រឯទៀត ៗ ជាខាងក្រោយ ទើបបានផលល្អ ឧទាហរណ៍ក្នុងឃុំ ឬ ស្រុក ១ បើយើងស្គាល់មេឃុំ ឬ ចៅហ្វាយស្រុកហើយ មុខជានឹងទាក់ទងស្គាល់ប្រជាជនក្នុងឃុំ ឬ ស្រុកនោះបានដោយងាយមិនខាន ។ ដូច្នេះបានជាទ្រង់យាងទៅទាក់ទងប្រោសព្រះបាទពិម្ពិសារជាមុន ព្រះរាជាក៏ចុះចូល ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ថ្វាយតាំងពីឧទ្យាន ១ សាងវត្តថ្វាយព្រះអង្គទៀតផង ។

ស- ៨៦ – ទ្រង់យាងទៅកាន់ក្រុងកបិលពស្តុនៅពេលណា ? ដោយមានហេតុយ៉ាងណា ឬ ទ្រង់យាងទៅដោយព្រះអង្គឯង ។

ច- ទ្រង់យាងទៅនៅថ្ងៃពេញបូរមីខែផល្គុន ដោយកាឡុទាយីដែលព្រះបាទសុទ្ធោទនៈ ចាត់ឲ្យនាំអាមាត្យជាបរិវារ ១ ពាន់មកអារាធនា ។ លុះពេលដែលកាឡុទាយីនិងបរិវារ មួយពាន់នាក់បួសហើយ ក៏អារាធនាព្រះសាស្ដាតាមបណ្ដាំព្រះរាជា ។ តាមសេចក្ដីដំណាលថា កាលព្រះសាស្ដាគង់នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទសុទ្ធោទនៈទ្រង់ជ្រាបដំណឹងហើយ ក៏ចាត់អាមាត្យម្នាក់នាំបរិវារមួយពាន់នាក់ទៅនិមន្តព្រះសាស្ដាអស់៩ដង តែអាមាត្យនិងបរិវារ កាលជួបនឹងព្រះសាស្ដាហើយ ក៏បួសអស់ គ្មានអ្នកណាម្នាក់ នឹកឃើញព្រះរាជបណ្ដាំសោះ ។ ព្រះបាទសុទ្ធោទនៈទ្រង់បញ្ជូនអាមាត្យហូតដល់ទីដប់ឲ្យទៅអារាធនានិមន្តទៀត ទើបបានសម្រេច ។

ស – ៨៧ ព្រះសាស្ដាទ្រង់យាងទៅដល់ក្រុងកបិលពស្តុ តែមួយព្រះអង្គឯង ឬមានសាវកនិមន្តទៅជាមួយដែរ ទ្រង់គង់នៅទីណា ? ទ្រង់ប្រោសព្រះពុទ្ធបិតានិងពពួកញាតិដោយវិធីដូចម្ដេច ? ចូរអធិប្បាយឲ្យល្អមស្ដាប់ ។

ច- នៅពេលទ្រង់យាងទៅក្រុងកបិលពស្តុនេះ ទ្រង់យាងទៅជា

www.budinst.gov.kh www.elibraryofcambodia.org

ព្រមព្រះអរហន្ត ២ ម៉ឺនអង្គជាបរិវារ ទ្រង់គង់នៅក្នុងឧទ្យានឈ្មោះនិ-គ្រោធ ។ ពេលនោះព្រះពុទ្ធបិតាក្តី ញាតិវង្សក្តី ឥតបានថ្វាយបង្គំព្រះអង្គទេ ព្រោះយល់ថាព្រះអង្គក្មេងជាង ព្រះសាស្តាជ្រាបដូច្នោះក៏ធ្វើយមកបាដិហារនិម្មិតទីចង្ក្រម ហើយនិម្មិតព្រះពុទ្ធមួយព្រះអង្គឲ្យធ្វើជាក្រៈធ្លុយបញ្ហារបស់ព្រះអង្គ, ព្រះបិតានិងពួកញាតិឃើញដូច្នោះ ក៏ថ្វាយបង្គំព្រះសាស្តា ។ ទ្រង់យាងចុះពីពុទ្ធាសនៈ, ភ្លៀងបោក្ខរពស័ក៏បង្អុរចុះលើពួកញាតិក្នុងទីប្រជុំយ៉ាងខ្លាំង ។ ភ្លៀងនោះបើអ្នកណាចង់ឲ្យទទឹកក៏ទទឹក បើអ្នកមិនចង់ឲ្យទទឹកក៏មិនទទឹក ដូចទឹកធ្លាក់លើស្លឹកឈូក, ព្រះសាស្តាទ្រង់ប្រារព្ធភ្លៀងនោះ ហើយទ្រង់សំដែងមហាវេស្សន្តរជាតកប្រោសពួកញាតិ ។

ព្រឹកឡើងព្រះសាស្តា ទ្រង់ត្រាច់បិណ្ឌបាត្រជាមួយសាវ័កក្នុងព្រះនគរ ព្រះបិតាទ្រង់ឃាត់ តែព្រះសាស្តាទ្រង់ត្រាស់ថា " ការត្រាច់បិណ្ឌបាត្រនេះ ជាកិច្ចរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ មិនមែនជាកិច្ចរបស់វង្សក្សត្រទេ ,, ព្រះបិតាកាលស្តាប់ហើយ ក៏បានសម្រេចសោតាបត្តិផល ។

នៅថ្ងៃទីបី ទ្រង់ប្រោសនាងបជាបតីគោតមី ឲ្យស្ថិតនៅក្នុងសោតាបត្តិផល ឯព្រះបាទសុទ្ធោទនៈ ក៏ស្ថិតនៅក្នុងសកិទាគាមិផល ។

www.budinst.gov.kh www.elibraryofcambodia.org

ដល់ថ្ងៃទី ២ ពេលព្រឹកទ្រង់សំដែងធម្មបាលជាតកថ្វាយព្រះបិតា ។ ក៏បានសម្រេចអនាគាមិផល ។ តមកទ្រង់យាងទៅប្រោសមាតានាងពិម្ពាជាមួយពុទ្ធបិតានិងសាវ័ក ហើយសម្តែងកិន្នរីជាតកប្រោសនាងពិម្ពា ។ ក៏បានសម្រេចសោតាបត្តិផល ។ នៅថ្ងៃទី ៣ ទ្រង់ប្រោសនន្ទជាព្រះអនុជម្រិតា ក្នុងពេលដែលនន្ទនេះរៀបមង្គលការជាមួយនាងជនបទកល្យាណី ។ កាលព្រះសាស្តាទ្រង់ធ្វើភត្តានុមោទនា ហើយទ្រង់ក៏ប្រទានបាត្រទៅនន្ទ ។ ទទួលហើយដើរតាមក្រោយព្រះសាស្តា ទ្រង់សួរថា នន្ទឯងបួសឬ ? នន្ទឆ្លើយដោយវៈវិសគាល់ថាបួស , ព្រះសាស្តាទ្រង់បំបួសនន្ទក្នុងថ្ងៃនោះ ហើយក្រោយមកមិនយូរនន្ទក៏បានសម្រេចអរហត្តផល ។

នៅថ្ងៃទី ៧ ព្រះសាស្តាបានបញ្ជាឲ្យសារីបុត្រ បំបួសរាហុលកុមារជាសាមណេរដែលមានអាយុទើបបាន ៧ ឆ្នាំ ហើយដែលនាងពិម្ពាជាមាតាបញ្ចូនឲ្យទៅសុំកំណប់ទ្រព្យពីព្រះសាស្តាជាបិតា ។

ក្នុងកាលជាខាងក្រោយមក កាលព្រះសាស្តាទ្រង់គង់ក្នុងអនុបិយម្ពវ័ន មានក្សត្រ ៦ អង្គទៀតគឺ ភទ្ទិយ ១ អនុរុទ្ធ ១ ភគុ ១ កិមិល ១ អានន្ទ ១ ទេវទត្ត ១ ជាព្រះញាតិនឹងព្រះអង្គ បានចូលទៅបួសដោយបាន

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជូនខាន់ព្រះកេស ( ជាងកាត់សក់ ) ម្នាក់ឈ្មោះឧបាលិ (១) ឲ្យទៅបួសមុន ។ តាមសេចក្ដីដំណាលថា ក្សត្រទាំង ៦ អង្គនេះបា·បួណាំដោយសេចក្ដីសុខណាស់ តែដោយទើសទាល់នឹងពាក្យសន្យា·របស់ខ្លួនក៏ចេញទៅបួសទៅ ។ មុននឹងបួសបានដោះគ្រឿងអាភរណៈឲ្យទៅឧបាលិទាំងអស់ តែឧបាលិយល់ថា ក្រែងក្សត្រសាក្យត្រកូលធ្វើបាបខ្លួន ក៏វេចគ្រឿងអាភរណៈហើយព្យួរពេលនឹងដើមឈើ ហើយបានទៅទូលរឿងហេតុដោយសព្វគ្រប់ចំពោះក្សត្រទាំង ៦ អង្គ ។ ក៏បានបញ្ជូនឧបាលិឲ្យទៅបួសមុនៗ ចំណែកក្សត្រ៦បួសក្រោយ លុះបួសហើយព្រះភទ្ទិយៈបានសម្រេចវិជ្ជា ៣ , ព្រះអនុរុទ្ធបានទិព្វចក្ខុ ក្រោយមកបានស្ដាប់មហាបុរិសវិតក្កសូត្រ ក៏បានសម្រេចអរហត្តផល , ព្រះអានន្ទ(២)

---

១— ព្រះឧបាលិនេះជាព្រះមហាថេរដ៏ស្ទាត់ជំនាញខាងវិន័យបិដក ព្រះសាស្ដាទ្រង់តាំងជាឯតទគ្គខាងវិជ្ជានេះ ហើយបានជាអ្នកឆ្លើយវិន័យបិដក នៅពេលធ្វើបឋមសង្គាយនាផង ។

២— ព្រះអានន្ទនេះបានសម្រេចតែត្រឹមសោតាបត្តិផលនេះរហូត តែជាអ្នកពូកែចាំណាស់ ពីធម៌ទាំង ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ព្រះអានន្ទចាំទាំងអស់ ។ លោកបានសម្រេចព្រះអរហត្តនៅពេលទ្រង់មានព្រះជន្ម ៨០ ឆ្នាំនិង ៣ ខែ ពេលមុនធ្វើបឋមសង្គាយនា ២–៣ ម៉ោងប៉ុណ្ណោះ ។ ព្រះអានន្ទជាអ្នកឆ្លើយព្រះសូត្រ និងព្រះអភិធម្មនៅពេលធ្វើបឋមសង្គាយនានោះ ។

www.budinst.gov.kh www.elibraryofcambodia.org

បានសម្រេចសោតាបត្តិផល , ព្រះភគុ និងកិម្ពិលៈ បានសម្រេចអរហត្ត, ទេវទត្ត[1]បានឫទ្ធិជាបុថុជ្ជនអាចហោះបាន ។

ស. ៨៨- ព្រះអានន្ទបានសម្រេចព្រះអរហត្តនៅឯណា ?

ច- នៅវត្តជេតពនក្រុងសាវត្ថី ។

ស. ៨៩ វត្តជេតពននេះអ្នកណាសាងថ្វាយព្រះពុទ្ធ ? អស់ប្រាក់ប៉ុន្មាន ? នៅឯណា ?

ច. សេដ្ឋីឈ្មោះអនាថបិណ្ឌិក បានទិញដីព្រៃរបស់ព្រះអង្គម្ចាស់ជេត ហើយកសាងវត្តថ្វាយព្រះសាស្ដានិងសាវ័ក អស់ប្រាក់៥៤កោដិកហាបណៈ ។ វត្តនេះនៅទៀបក្រុងសាវត្ថីកោសលរដ្ឋ ។

ស. ៩០- ព្រះសាស្ដា ទ្រង់ដែលយាងទៅគង់នៅវត្តជេតពននោះញឹកទេ ? ព្រោះអ្វី ?

ច- ទ្រង់យាងទៅគង់ញឹក ព្រោះជាវត្តដែលស្ថិតនៅលើផ្លូវនិងក្រុងដ៏ធំមានប្រជាជនច្រើន ស្មើគ្នានឹងមគធរដ្ឋដែរ ។ ម្យ៉ាង

---

១– ទេវទត្តនេះជាជីដូនមួយនឹងព្រះពុទ្ធនិងព្រះអានន្ទ ហើយជាបុត្តព្រះសុប្បពុទ្ធ ជាបងនាងពិម្ពា ។ កាលបានឫទ្ធិជាបុថុជ្ជនហើយ ៗ កើតសេចក្ដីប្រណែន នឹង ព្រះសាស្ដាពីលាភសក្ការៈ ក៏ប្រទូស្តសាហាវនឹងព្រះពុទ្ធយ៉ាងខ្លាំងរហូតរលាយឫទ្ធិបុថុជ្ជន ហើយត្រូវព្រះធរណីស្រូបនៅជិតវត្តជេតពន ។

www.budinst.gov.kh www.elibraryofcambodia.org

ទៀត តាមសូត្រនានាមានជាដើមថា « គតោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ... » ។ ព្រះសាស្តាទ្រង់គង់ចាំវស្សាក្នុងវត្តនេះនៅវស្សាទី ១៤ មួយវស្សានិងពីវស្សាទី ២០ ដល់ ២៤ ហើយនិងពីវស្សា ៣៦ ដល់ផុតវស្សាទី ៤៤ បានចាំងអស់ ២០ វស្សា ឃើញថាច្រើនជាងវត្តឯទៀតៗ ទាំងអស់ ។

ស ៩១ - នៅក្រុងកបិលពស្តុព្រះសាស្តាដែលទ្រង់គង់ចាំវស្សាដែរ មានវត្តឬទេ? អ្នកណាសង់ថ្វាយ ?

ឆ – ទ្រង់ដែលគង់ចាំវស្សានៅវត្តនិគ្រោធារាមជិតទីក្រុងតែ ១ វស្សាគត់គឺនៅវស្សាទី ១៥ ដើម្បីប្រោសពួកព្រះញាតិ ។ វត្តនេះពួកសាក្យវង្សបានសាងថ្វាយព្រះអង្គ ។

ស ៩២ កាលព្រះសាស្តាទ្រង់យាងទៅកាន់ក្រុងកបិលពស្តុ ជា–លើកទី ២ ទ្រង់បានប្រោសអ្នកណាខ្លះ?

ឆ - កាលទ្រង់យាងទៅកាន់ក្រុងកបិលពស្តុជាលើកទី ២ ទ្រង់ពុំបានប្រោសជនណាឲ្យពិតប្រាកដទេ តែប៉ុន្តែពេលនោះ នាងបជាបតិគោតមីជាម្តាយមីងព្រះអង្គបានយកសំពត់សាដកពីរផ្ទាំង គឺមួយផ្ទាំងៗមានបណ្តោយ ១៤ ហត្ថ ទទឹង ៨ ហត្ថ ដែលនាងធ្វើដោយខ្លួននាងផ្ទាល់ ទៅថ្វាយព្រះសាស្តាដើម្បីឲ្យព្រះអង្គប្រោសទទួល តែព្រះសាស្តាពុំព្រមទទួលទេ

www.budinst.gov.kh www.elibraryofcambodia.org

តោះជាអាន់អង្វរយ៉ាងណាក៏ដោយ ៗ ព្រះអង្គបានសំដែងអំពីបាដិបុគ្គ-លិកាន និងសង្វាធានឲ្យនាងគោតមីស្តាប់ នាងក៏ប្រគេនទៅព្រះមហាថេរនានា តែលោកពុំព្រមទទួលសោះ លុះដល់ភិក្ខុទើបនឹងបួសថ្មីមួយរូបនាមអជិតជាកូនបុត្រព្រះបាទអជាតសត្រូវ(១)និងនាងកាញ្ចនា លោកក៏ព្រមទទួលយក តែនាងគោតមីកើតទោមនស្សខ្លាំងណាស់ព្រោះពុំសមតាមប្រាថ្នា ប៉ុន្តែព្រះសាស្តាកាលទ្រង់ជ្រាប ទ្រង់ក៏បោះបាត្រទៅក្នុងអាកាសឲ្យសាវ័កចាំងអស់គេ តែគ្មានសាវ័កណាអាចរកឃើញ លុះអជិតភិក្ខុទៅរកក៏បានឃើញ ។ ព្រះសាស្តាទ្រង់បានប្រកាសគុណសម្បត្តិរបស់ភិក្ខុនោះថា “ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គនាមមេត្តេយ្យ ក្នុងអនាគតកាលនេះ” នាងគោតមីឃើញទិន្នផលដូច្នេះក៏មានសេចក្តីត្រេកអរយ៉ាងក្រៃលែង ។

ព្រះសាស្តាទ្រង់ធ្វើយ៉ាងនេះ ក៏ដើម្បីប្រោសនាងគោតមី ១ ផ្នែក និងដើម្បីបង្ហាញឲ្យអជិតភិក្ខុថាជាតួអង្គពោធិសត្វ ១ ផ្នែក ៗ

---

១—ព្រះបាទអជាតសត្រូវជាបុត្រព្រះបាទពិម្ពិសារនិងនាងវេទេហី មហាក្សត្រនៅមគធរដ្ឋក្រុងរាជគ្រឹះ ។ កាលព្រះកុមារនៅក្នុងផ្ទៃព្រះមាតាទ្រង់ឃ្លានតែឈាមដើមព្រះហស្តព្រះស្វាមី (ពិម្ពិសារ ) រហូតទល់ស្គមរីងរៃ លុះព្រះបាទពិម្ពិសារសួរយូរ ៗ ទៅ នាងក៏ប្រាប់ត្រង់ៗ ព្រះរាជាទ្រង់វះដើមដៃយកឈាមឲ្យព្រះនាងសោយ, ទើបព្រះនាងបានស្បើយ ។ ហោរាទាយថាព្រះកុមារនេះនឹងសម្លាប់ព្រះបិតាយករាជ្យសោយ, ព្រះនាងវេទេហី ក៏រំលូតទារកចោលតែមិនរលូត ។ កាលរាជកុមារប្រសូតហើយគេក៏យកទៅលាក់រហូតទល់ធំ ទើបព្រះនាង

ត—

LIBRARY

ស-៩៣ – នៅក្នុងពុទ្ធចរិយា មានចរិយាមួយ គឺញាតត្ថចរិយា : ការប្រព្រឹត្តធ្វើប្រយោជន៍ចំពោះញាតិ ។ ក្នុងរឿងនេះតើព្រះអង្គបានធ្វើប្រយោជន៍ចំពោះញាតិ ឲ្យច្រើនជាងមហាជនទាំងក្រៅពីព្រះញាតិឬតិចជាង ។

ច- នៅក្នុងរឿងដែលព្រះអង្គធ្វើប្រយោជន៍ចំពោះញាតិៈយើងអាច

---

ជាមាតាឃើញ ក៏ស្រឡាញ់ក្រៃណាស់ ។ កាលព្រះកុមារពេញវ័យ ក៏ចូលដៃជាមួយទេវទត្ត ហើយចាប់ព្រះបាទពិម្ពិសារជាបិតាយកទៅដាក់គុករហូតទល់សុគត ហើយយករាជសម្បត្តិសោយនៅឆ្នាំទី ៣៧ នៃពុទ្ធកាល ។ ៨ ឆ្នាំក្រោយមក ទើបព្រះពុទ្ធបរិនិព្វាន ។ កាលសម្លាប់បិតាហើយ ទេវទត្តក៏ត្រូវព្រះធរណីស្រូបទៅ ព្រះបាទអជាតសត្រូវទ្រង់កោតខ្លាចយ៉ាងខ្លាំង ចំពោះអំពើដែលបានធ្វើគត់បិតា ក៏បានទៅសុំទោសចំពោះព្រះសាស្តា ។ កាលព្រះពុទ្ធបរិនិព្វានទៅបាន ៣ ខែ ព្រះរាជាអង្គនេះទ្រង់ឧបត្ថម្ភពិធីធ្វើបឋមសង្គាយនាអស់ ៧ ខែ ។ ព្រះបាទអជាតសត្រូវសោយរាជ្យបាន ៣២ ឆ្នាំ គឺក្នុងពុទ្ធកាលបាន៨ឆ្នាំ លុះព្រះពុទ្ធបរិនិព្វានហើយ សោយរាជ្យបាន២៤ឆ្នាំទៀត ទើបសុគតទៅកើតក្នុងលោហកុម្ភីនរក ដោយត្រូវព្រះរាជបុត្រនាមឧទយភទ្ទធ្វើគត់ព្រះអង្គហើយសោយរាជ្យបាន១៦ឆ្នាំត្រូវព្រះកុមារនាមអនុរុទ្ធ ជារាជបុត្រធ្វើគតយករាជ្យសោយទៀត ។ ព្រះមុណ្ឌកជាបុត្រអនុរុទ្ធ ធ្វើគត់អនុរុទ្ធជាបិតាយករាជ្យសោយទៀតបាន ៨ ឆ្នាំ ក៏ត្រូវព្រះកុមារនាគទស្សកៈជារាជបុត្រធ្វើគត់ព្រះមុណ្ឌកជាបិតា យករាជ្យសោយបាន ២៤ ឆ្នាំ ទើបអ្នកនគរធ្វើឃាតព្រះនាគទស្សកៈនិងរាជវង្សអស់ហើយថ្វាយរាជ្យទៅសុសុនាគកុមារ ។ ដូច្នេះរាជវង្សព្រះបាទពិម្ពិសារ—អជាតសត្រូវសុទ្ធតែធ្វើគតបិតាខ្លួនយករាជ្យសោយទាំងអស់ចំនួន ៨០ឆ្នាំ ។

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើយបានតាមហេតុពីរយ៉ាងគឺ ៖

១- ទ្រង់អនុញ្ញាតដោយពិសេស ចំពោះញាតិទាំងឡាយក្នុងសាក្យវង្សដែលចូលក្នុងពួកតិរ្ថិយហើយ បើចង់ចូលមកសុំបួសក្នុងព្រះពុទ្ធ-សាសនាវិញ ក៏ចូលបានភ្លាម មិនបានទៅជាតិរ្ថិយបរិវាស ៤ ខែមុន ដូចពួកតិរ្ថិយដទៃ ៗ នោះឡើយ ។ ម្យ៉ាងទៀតទ្រង់ការពារញាតិរបស់ព្រះអង្គក្នុងកាលខ្លះដែរ ដូចកាលទ្រង់ជ្រាបថា ព្រះបាទអជាតសត្រូវ លើកទ័ពទៅវាយក្រុងកបិលពស្តុ ព្រះអង្គក៏យាងទៅស្កាត់ផ្លូវការពារ ។

២- ទ្រង់ធ្វើប្រយោជន៍ឲ្យញាតិ ដោយយោលទៅលើផលកម្មដែរ គួរឃើញដូចកាលព្រះបាទវិឌូឌភៈ[1] លើកទ័ពទៅសម្លាប់ពួកសាក្យ

---

១–ព្រះបាទវិឌូឌភ នេះជាកូនបុត្រព្រះបាទបសេនទិកោសលនិងធីតាម្នាក់ពីសាក្យវង្ស ។ សេចក្តីនិទានថា "ព្រះមហានាមជាក្សត្រក្នុងសាក្យវង្ស បានលបសាហាយស្មន់ជាមួយទាសីម្នាក់ហើយក៏បានធីតាម្នាក់មានរូបល្អណាស់ ប្រែក៏លាក់លៀមរឿងនេះទុកយ៉ាងស្ងាត់កំបាំង រហូតទល់ធីតានោះធំ ។ មាតាមហានាមប្រឡាញ់ធីតាជាចៅនោះណាស់ ។

ពេលនោះព្រះបាទបសេនទិចង់ភ្ជាប់ព្រះរាជវង្សព្រះអង្គទៅនឹងសាច់ញាតិព្រះពុទ្ធ ក៏ឲ្យអាមាត្យទៅដណ្តឹងរាជក្សត្រីពីសាក្យវង្ស ។ ពួកសាក្យវង្សបានលើកនាងធីតាបុត្រីមហានាមនិងទាសីនោះថ្វាយ ។ ព្រះបសេនទិនិងធីតានោះ បានរាជបុត្រ១នាមវិឌូឌភៈនេះ ។ កាលវិឌូឌភៈនឹងក្តីមាភាក់នាំៈទៅលេងក្រុងកបិលពស្តុ លុះត្រឡប់មកវិញទាសីម្នាក់ភ្លេចបង្វិច ក៏បាន

ត—

វង្សព្រះអង្គទ្រង់យាងទៅរាំងការពារផង តែដោយប្រមើលមើលឃើញផលកម្មអកុសលពីអតីតរបស់សាក្យវង្សមកច្រើន ទ្រង់ក៏ឈប់លែងទៅរាំងការពារទៀតទៅ ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុជាញឹកញាប់ ដើម្បីប្រោសព្រះញាតិនៃទ្រង់គង់ចាំវស្សា នៅក្នុងវត្តនិគ្រោធារាមជាអារាមរបស់សាក្យវង្សតែមួយវស្សាគត់ គឺនៅវស្សាទី ១៥ តែមួយប៉ុណ្ណោះ ក្រៅពីនេះទ្រង់គង់ក្នុងទីដទៃ ៗ ទាំងអស់ ។ ដូច្នេះឃើញថា ព្រះអង្គមិនមែនធ្វើប្រយោជន៍ឲ្យតែពួកញាតិច្រើនជាងមហាជននោះទេ ទ្រង់ធ្វើប្រយោជន៍ឲ្យមហាជនច្រើនជាង ។

**សេចក្តីសន្និដ្ឋាន.**—ពួកក្សត្រសាក្យវង្សក្តីជាញាតិភូមិរបស់ព្រះពុទ្ធអង្គក្តី ក៏មិនមែនព្រះសម្មាសម្ពុទ្ធទុកដាក់ឲ្យមានតម្លៃលើសពីមនុស្សក្នុងវង្សដទៃ ឬពួកដទៃដែរ ទ្រង់ប្រោសប្រទានធម៌ ឲ្យនាំទៅតាមលំដាប់លំដោយមិនទៅតាមនិស្ស័យសត្វលោកជាដរាប ។

---

ទៅវិញ ស្រាប់តែឃើញទាសីត្រួតមហាក្សត្រ លាងនោម ហើយនិយាយប្រាប់ថា វិឌូឌភៈជាបុត្រចង្រៃ ។ ពលបរិក្រឡាប់មកទូលព្រះកុមារវិឌូឌភៈទាំងមានវិញ ព្រះវិឌូឌភៈទ្រង់ក្រោធខ្ញាល់ព្រះទ័យយ៉ាងខ្លាំង ហើយឲ្យនិយាយទៅក្នុងក្សត្រិយ៍វិញថា “ពេលនេះសូមឲ្យសាក្យវង្សយកទឹកលាងនោមលាងខ្ទះសិនចុះ ចាំដល់យើងបានសោយរាជ្យ យើងនឹងមកយកឈាមបំពង់កពួកសាក្យវង្សលាងជើងយើងវិញ ។ កាលព្រះវិឌូឌភៈបានសោយរាជ្យហើយ ក៏លើកទ័ពទៅសម្លាប់ពួកសាក្យវង្សចោលស្ទើរទាំងអស់ សល់តែមហានាមជាដើមនិងញាតិខ្លះប៉ុណ្ណោះ ។ ព្រឹត្តិការនេះកើតឡើងនៅពេលមុនព្រះពុទ្ធបរិនិព្វាន ២ ឆ្នាំ ។

www.budinst.gov.kh www.elibraryofcambodia.org

ភាគទី ១១

# បរិនិព្វាននៃពុទ្ធបិតា
# ការប្រោសព្រះពុទ្ធមាតា
# និងពុទ្ធសកម្មក្នុងបឋមពោធិកាល

ស – ៩៤ . – តាំងពីពេលដែលព្រះពុទ្ធទ្រង់បានត្រាស់ដឹង ដល់បរិនិព្វាន តើមានប៉ុន្មានវស្សា ? បើចែកជាកាលមានប៉ុន្មាន ? គេត្រូវរាប់ពីពេលណាទល់ពេលណា ?

ច – មាន ៤៥ វស្សា បើរាប់ជាកាលមានបី គឺ បឋមពោធិកាល រាប់ពីវស្សាទី ១ ដល់ទី ១៥ , មជ្ឈិមពោធិកាល = រាប់ពីវស្សាទី ១៦ ដល់វស្សាទី ៣០ , បច្ឆិមពោធិកាល= រាប់ពីវស្សា៣១ដល់វស្សាទី៤៥។

ស – ៩៥ . – ព្រះពុទ្ធបិតា និព្វាននៅក្នុងពោធិកាលណា ? ពេលដែលព្រះពុទ្ធបានត្រាស់បានប៉ុន្មានឆ្នាំ ? និព្វានក្នុងព្រះជន្មប៉ុន្មាន? នៅឆ្នាំណា ? ទ្រង់បានសម្រេចនូវលោកុត្តរធម៌ត្រឹមថ្នាក់ណាដែរ ?

ច – ពុទ្ធបិតាទ្រង់និព្វានក្នុងបឋមពោធិកាល , នៅពេលដែលព្រះអង្គទ្រង់បានត្រាស់ហើយបាន ៥ វស្សា , ក្នុងព្រះជន្មាយុ ៩៧ព្រះវស្សា នៅឆ្នាំខាល ។ មុននឹងនិព្វានព្រះអង្គបានសម្រេចអរហត្តផល ។

ស – ៩៦ – ចូររៀបរាប់រឿងបរិនិព្វាន នៃព្រះបាទសុទ្ធោទនៈ

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធបិតានេះឲ្យល្មមស្តាប់បានផង ។

៦ – មានសេចក្តីដំណាលថា កាលព្រះអង្គទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន នគរវេសាលី ព្រះបាទសុទ្ធោទនៈ ( បានសម្រេចអនាគាមិផលហើយ ) ទ្រង់ប្រឈួនយ៉ាងខ្លាំង ពេទ្យហ្មក៏ពុំអាចរំងាប់ជម្ងឺបានឡើយ ព្រះអង្គទ្រង់នឹកដល់ព្រះពុទ្ធជាម្ចាស់យ៉ាងខ្លាំង ទ្រង់នឹកថា “បើបានព្រះពុទ្ធអង្គមកស្ទាបព្រះសិរ, ព្រះអានន្ទមកស្ទាបព្រះកាយ, ព្រះរាហុលជាចៅមកស្ទាបខ្នង ជម្ងឺរបស់អាត្មាអញមុខជានឹងបានសះស្បើយមិនខាន” ។ ព្រះសាស្តាទ្រង់ជ្រាបហើយទ្រង់នាំភិក្ខុ ៥០០ រូបអង្គហោះឆ្ពោះទៅកាន់កបិលពស្តុបុរី ហើយចូលទៅស្ទាបព្រះសិរសា ព្រះរោគរបស់ព្រះបិតាក៏បានសះស្បើយភ្លាម ហើយព្រះពុទ្ធទ្រង់ពិចារណាទៅក៏ឃើញថា នៅតែ ៧ ថ្ងៃទៀត ព្រះបិតានឹងបរិនិព្វានហើយ ទ្រង់ក៏សម្តែងព្រះត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា ថ្វាយព្រះបិតាស្តាប់ កាលចប់ហើយ ព្រះរាជាក៏បានសម្រេចអរហត្តផល ។ លុះដល់ថ្ងៃទី ៧ ព្រះអង្គទ្រង់សុំខមាលាទោសចំពោះព្រះសាស្តាជាបុត្រ រួចបរិនិព្វានទៅ ។

ព្រះសម្ពុទ្ធទ្រង់បង្គាប់ឲ្យព្រះមហាកស្សបត្ថេររៀបដំណើរដើម្បីថ្វាយព្រះភ្លើងព្រះបិតា រួចព្រះអង្គទ្រង់លើកព្រះសព ស្រោចសុគន្ធវារីហើយ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ថ្វាយព្រះភ្លើងដោយព្រះអង្គឯង ។

ស ៩៦ . — កាលព្រះបាទសុទ្ធោទនៈទ្រង់និព្វានហើយ តើនាងបជាបតិគោតមី ទ្រង់មានស្វាមីទៀត ឬទៅជាយ៉ាងណា ?

ច — ព្រះនាងឥតយកស្វាមីទេ ទ្រង់ចូលទៅសុំសាងព្រះផ្នួសក្នុងសំណាក់ព្រះសាស្ដាដែលគង់នៅក្នុងវត្តនិគ្រោធារាម តែព្រះអង្គពុំបានអនុញ្ញាតឡើយ លុះព្រះសាស្ដាយាងទៅកាន់កូដាគារសាលាវិញ ព្រះនាងក៏យាងទៅសុំបព្វជ្ជា ដោយមានព្រះអានន្ទជួយអង្វរផង តែព្រះសាស្ដានៅតែមិនអនុញ្ញាត លុះដល់ពេលដែលព្រះសាស្ដាទ្រង់គង់នៅវត្តជេតពនមហាវិហារ ព្រះនាងបាននាំខត្តិយកញ្ញា ៥០០នាក់ទៅសូមបព្វជ្ជាទៀត ព្រះអានន្ទជួយអង្វរ ព្រះសាស្ដា ១ ទ្រង់អនុញ្ញាតឲ្យដោយគរុធម៌ ៨ ប្រការ ។

ព្រះនាងបជាបតិគោតមី ក៏បានបួសជាភិក្ខុនីជាមួយខត្តិយកញ្ញាទាំង ៥០០ នាក់ ហើយនាងបជាបតិគោតមីនេះហើយជាដើមនៃភិក្ខុនីបរិស័ទ ។

ស . ៩៨ — ព្រះនន្ទ ជាបុត្រនៃនាងបជាបតិគោតមី ទ្រង់បានបួស ហើយបានសំរេចអរហត្តផលរួចទៅហើយ , ព្រះនាងគោតមី ក៏បានបួសក្នុងពេលនេះដែរ ចុះនាងរូបនន្ទាជាបុត្រីព្រះនាងគោតមីនោះបានបួស

www.budinst.gov.kh www.elibraryofcambodia.org

នឹងទៅដែរ ?

ច - នាងបានបួសដែរ គឺបួសក្រោយមាតានាង ។

ស. ៩៩ – នាងបានសម្រេចធម៌អ្វីដែរ ? ព្រោះហេតុអ្វី ?

ច នាងបានអរហត្តផលដែរ ព្រោះបានស្តាប់ព្រះគាថា១គាថា ៖ អដ្ឋីនំ នគរំ កតំ ។ ល ។ មានោ មក្ខោ ច ឱហិតោ ហើយនាងក៏មាននាមថា " រូបនន្ទាថេរី " ព្រោះព្រះនាងជាស្ត្រីដែលមានរូបល្អណាស់នៅក្នុងសម័យនោះ ។

ស . ១០០ – ព្រះញាតិវង្សក្តី ព្រះបិតាក្តី សុទ្ធតែព្រះអង្គបានទេសនាប្រោសឲ្យបានសម្រេចមគ្គផលតាមសមគួរអស់ហើយ ចុះព្រះនាងសិរិមហាមាយា ដែលទៅកើតទៅស្ថានតុសិតនោះ ព្រះពុទ្ធទ្រង់បានទៅប្រោសហើយឬនៅ ?

ច . ទ្រង់ពុំទាន់បានយាងទៅប្រោសនៅឡើយ ។

ស . . ១០១ តើព្រះអង្គទ្រង់យាងទៅប្រោស ឬទេ ? មុននឹងយាងទៅទ្រង់បានធ្វើអ្វីនៅស្ថានមនុស្សលោកដែរ ? ទ្រង់ប្រោសព្រះពុទ្ធមាតាដោយធម៌អ្វី ? ទ្រង់សំដែងអស់វេលាប៉ុន្មានទើបចប់ ? នៅវស្សាទីប៉ុន្មាន ? ព្រះមាតាបានសម្រេចអ្វីដែរ ?

ច - ទ្រង់យាងទៅប្រោសដែរ ប៉ុន្តែមុននឹងយាងទៅ ទ្រង់បានធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

យមកប្បាដិហារ្យផ្ចាញ់ពួកនិគ្រន្ថអញ្ញតិត្ថិយ គ្រូទាំង ៦ នាក់ គឺ៖ បូរណកស្សប១ , មក្ខលិគោសាល១ , និគណ្ឋនាដបុត្រ១, សញ្ជយវេលដ្ឋបុត្រ១, បកុធកច្ចាយន១ , អជិតកេសកម្ពល ១ ។ កាលគ្រូទាំង ៦ នោះចាញ់បបខ្ទប់ខ្ទាចហើយទ្រង់ក៏យាងទៅស្ថានតាវត្តិង្ស រួចសំដែងព្រះអភិធម្ម ៧ គម្ពីរប្រោសព្រះពុទ្ធមាតាអស់វេលា ៣ ខែទើបចប់ ព្រះនាងសិរិមហាមាយាបានស្តាប់ហើយ ក៏បានសម្រេចសោតាបត្តិផល ។ ទ្រង់សំដែងធម៌នេះនៅវស្សាទី ៧ គឺទ្រង់គង់ចាំវស្សាទៅទីនោះឯង ។

ស. ១០២— ទ្រង់យាងចុះពីស្ថានតាវត្តិង្សវិញនៅថ្ងៃណា ? ដោយសារអ្វី ? មកគង់នៅទីណា ?

ច— ទ្រង់យាងចុះមកវិញនៅថ្ងៃ ១ កើតខែអស្សុជ ដោយជណ្តើរកែវ ហើយមកគង់នៅត្រង់ទ្វារនៃនគរសង្កស្ស ។

ស. ១០៣— ព្រះសត្តប្បករណាភិធម្ម ព្រះពុទ្ធទ្រង់សំដែងប្រោសពុទ្ធមាតាឯស្ថានតាវត្តិង្សឯណោះ ហេតុម្តេចក៏សាវ័កនៅមនុស្សលោកឯណេះបានចេះដឹងដែរ ?

ច— បានជាចេះដែរ ព្រោះពេលដែលព្រះអង្គទ្រង់យាងចុះមកវិញ ទ្រង់បានសំដែងឲ្យព្រះសារីបុត្តស្តាប់ ព្រះសារីបុត្តក៏យកទៅសំដែងឲ្យភិក្ខុ ៥០០ រូបនៅក្នុងគុហា ១ ស្តាប់តទៅទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

ស. ១៨៤ – អ្នកណាជាមហាឧបាសក-សិកានិងពុទ្ធុបដ្ឋាក-ពុទ្ធុបដ្ឋាយិកាក្នុងព្រះពុទ្ធសាសនៈ ? បានធ្វើអ្វីថ្វាយព្រះអង្គខ្លះ ?

ច – សេដ្ឋីឈ្មោះអនាថបិណ្ឌិក ជាមហាឧបាសកនិងជាពុទ្ធុបដ្ឋាកក្នុងព្រះពុទ្ធសាសនា ។ សេដ្ឋីនេះបានចំណាយទ្រព្យ ៥៤ កោដិសាងវត្តជេតពនថ្វាយព្រះសាស្តា ព្រមទាំងឧបត្ថម្ភព្រះពុទ្ធនិងសាវ័កដោយបច្ច័យ ៤ ទៀតផង ។ សេដ្ឋីនេះបានចំណាយទ្រព្យទាល់តែអស់ពីឃ្លាំងរហូតដល់បរិភោគតែចុងអង្ករនិងជ្រក់ ។ លោកនៅក្នុងក្រុងសាវត្ថី កោសលរដ្ឋ ។

នាងវិសាខាជាឧបាសិកា និងជាពុទ្ធុបដ្ឋាយិកាក្នុងព្រះពុទ្ធសាសនា ។ នាងបានចំណាយទ្រព្យ ២៧ កោដិ សាងវិហារបុព្វារាម ១ ថ្វាយព្រះសាស្តា ។ តាមសេចក្តីដំណាលថា នាងមានរូបល្អណាស់ជាបញ្ចកល្យាណី, ជាស្រ្តីឆ្លាត ។ បិតានាមមេណ្ឌកសេដ្ឋី បានធ្វើគ្រឿងបសាធន គឺគ្រឿងអលង្ការសម្រាប់តែងខ្លួនអស់តម្លៃ ២៧ កោដិ ។ ពេលមានមង្គលក្នុងនគរ អ្នកនគរតែងអញ្ជើញនាងទៅធ្វើជាអធិបតី, ជាកិត្តិយសជាដរាប ។ ពេលមួយនាងត្រឡប់ពីមង្គលហើយ ក៏ចូលទៅវត្តជេតពនដើម្បីស្តាប់ធម៌ក្នុងវេលាយប់ ។ លុះត្រឡប់ទៅវិញ នាងភ្លេចបន្ទោចគ្រឿងបសាធនក្នុងវត្ត ព្រះអានន្ទឃើញក៏យកព្យួរទុក

លើមែកឈើ លុះនាងប្រើពាសីមកយកវិញ ព្រះអានន្ទក៏បង្ហាញពា- សី ។ យកទៅហើយ ប្រាប់ដល់នាងវិសាខាដោយសព្វគ្រប់ ។ ដោយនាងមានប្រពៃណី ១ ថា " គ្រឿងបសាធនៈនោះ បើកាលណាសម- ណៈណាកាន់ពាល់ហើយ នឹងទៅជារបស់សៅហ្មង ហើយនាងត្រូវតែលក់ចោលនោះ នាងក៏ប្រកាសលក់តែគ្មានអ្នកណាអាចទិញបាន នាងក៏ចេញប្រាក់ ៩៧ កោដិទិញលោះយកគ្រឿងបសាធនៈនោះវិញ ឯទ្រព្យ ៩៧ កោដិនោះក៏យកទៅសាងវត្តបុព្វារាមនោះឯង ។ នាងមានអាយុ ១២០ឆ្នាំ ក៏នៅមានរូបរាងល្អហើយក្មេង ដូចនារីដែលមានវ័យ១៦ ឆ្នាំនោះដែរ ។

ស. ១០៩= ភិក្ខុរូបណាជាពុទ្ធុបដ្ឋាក ?

ច កាលពីមុន ភិក្ខុឈ្មោះមេឃិយជាពុទ្ធុបដ្ឋាក ក្រោយមកព្រះអានន្ទជាពុទ្ធុបដ្ឋាករហូតដល់បរិនិព្វាន ។

**សេចក្តីសន្និដ្ឋាន**.— ព្រះពុទ្ធកិច្ចចំពោះមាតាបិតា និងពួកញាតិសំខាន់ៗ ព្រះពុទ្ធជាម្ចាស់ទ្រង់បានបំពេញរួចអស់ហើយ ។ ក្រៅពីនេះព្រះអង្គបានធ្វើព្រះសកម្មភាពជាច្រើន ដើម្បីជាប្រយោជន៍ដល់សត្វលោកក្នុងត្រៃភព ។ មនុស្សនិងទេវតារាប់សែនកោដិនាក់ សឹងបានរំដោះខ្លួនចេញពីវាលវដ្តសង្សារនេះ ហើយមានមនុស្សនិងទេវតា

www.budinst.gov.kh www.elibraryofcambodia.org

ជាច្រើនសែនកោដិទៀត ដែលកំពុងប្រព្រឹត្តធ្វើខ្លួនឲ្យប្រែបាកទុក្ខ ។

ដូច្នេះ ការបានត្រាស់ជាព្រះពុទ្ធហើយបានដឹកនាំសត្វលោកនេះ ជាមហាសុខដ៏វិសេសវិសាលណាស់ ដូចពុទ្ធភាសិតមួយថា "សុខា ពុទ្ធានមុប្បាទោ= ការកើតឡើងនៃព្រះពុទ្ធកល់ព្រះអង្គតែងនាំមកនូវសេចក្តីសុខ ។

x

x x

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធកិច្ច
# និងព្រះពុទ្ធបរិនិព្វាន

ស–១០៦.– ចាប់តាំងពីពេលបានត្រាស់ដឹងហូតទល់បរិនិព្វាន តើមានរយៈវេលាប៉ុន្មានវស្សា ? រយៈពេលប៉ុណ្ណោះតើព្រះអង្គបានធ្វើកិច្ចណាខ្លះ ដែលទៀងទាត់ជានិច្ច ?

ច– មានរយៈវេលា៤៥វស្សា ។ ក្នុងរយៈពេលប៉ុណ្ណោះព្រះអង្គទ្រង់ធ្វើពុទ្ធកិច្ច ៥ យ៉ាង ជាទៀងទាត់ ឥតមានឡោះខានគឺ៖

១– ពេលព្រឹកទ្រង់និមន្តបិណ្ឌបាត្រគ្រប់ច្រកល្ហក ឥតរើសអើងថាផ្ទះណាត្រកូលណាទេ ហើយទោះជាគេដាក់ក្តីមិនដាក់ក្តី ឲ្យគ្រឿងសៅហ្មងក្តី គ្រឿងប្រណីតក្តីក៏ព្រះអង្គតែងយាងទៅ ហើយទទួលទាំងអស់ ។

២– ពេលរសៀលទ្រង់សំដែងធម៌ទេសនាប្រោសសត្វលោក ជាបរិស័ទក្តី ជាអ្នកទើបនឹងចុះចូលធម៌វិន័យក្តីឲ្យស្តាប់ដោយចំពោះខ្លះ មិនចំពោះខ្លះ តាមនិស្ស័យរបស់សត្វ ។

៣ ពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុបរិស័ទតែមួយផ្នែក ពោលគឺធ្វើការដាស់តឿនក្រើនរំលឹកភិក្ខុបរិស័ទ ដែលខិលខូចឲ្យបោះបង់អំពើអាក្រក់ចោល ។

www.budinst.gov.kh www.elibraryofcambodia.org

៤- ពេលកាព្រាត្រទ្រង់ដោះប្រស្នារបស់ពួកទេវតា ដែលនាំគ្នាចុះមកសួរចំពោះព្រះអង្គ ។

៥- ពេលជិតភ្លឺទ្រង់ប្រមើលមើលនូវឧបនិស្ស័យរបស់សត្វលោកទូ-ទៅបើទ្រង់ឃើញសត្វណាមានត័ពូនិស្ស័យក៏យាងទៅប្រោសសត្វនោះ ។

ស- ១០៧- សត្វលោកដែលគួរប្រោសដឹកនាំមានប៉ុន្មានពួក ?

ឆ- មាន ៣ ពួកដែលហៅថាវេនេយ្យសត្វគឺ ៖

១- ពុទ្ធវេនេយ្យ.- សត្វខ្លះមាននិស្ស័យនឹងព្រះពុទ្ធៗក៏ទ្រង់យាងទៅប្រោសដោយព្រះអង្គឯង ។

២- សាវកវេនេយ្យ សត្វខ្លះមាននិស្ស័យនឹងសាវ័ករបស់ព្រះអង្គៗក៏ប្រើសាវ័កខ្លះៗដូចជាព្រះសារីបុត្រ,មោគ្គល្លាន, ព្រះមហាកស្សបជាដើមឲ្យទៅដឹកនាំ ។ សត្វជំពូកនេះបើព្រះពុទ្ធជាម្ចាស់ទ្រង់យាងទៅខ្ជាន ដឹកនាំដោយព្រះអង្គឯង ខ្លះក៏ឆាយពេកខ្លះលំបាកពេក,មិនដូនល្មមដល់ពុទ្ធវិស័យ មានតែសាវ័កប៉ុណ្ណោះ ទើបដឹកនាំតាមវិស័យបាន ។

៣- ធាតុវេនេយ្យ .- សត្វខ្លះ មាននិស្ស័យនឹងព្រះធាតុរបស់ព្រះសម្ពុទ្ធ គឺកាលឃើញហើយ ក៏កើតសេចក្ដីសង្វេគ, កើតចិត្តជ្រះថ្លា ហើយក៏ជឿ, ប្រតិបត្តិតាមពុទ្ធោវាទ ។

ស - ១៦៨ - ទុក់ទៃដែលព្រះពុទ្ធបរមគ្រូទ្រង់ប្រទានដល់បព្

www.budinst.gov.kh www.elibraryofcambodia.org

ដឹកនាំគ្រហស្ថដូចគ្នាឬផ្សេងៗគ្នា ? ចូរបង្ហាញ !

ច - ផ្សេងគ្នា គឺបើបំរើសង្ឃជាបព្វជិតត្រូវនាំប្រដៅទូន្មានសីល, សមាធិ បញ្ញា ។ បើបំរើសង្ឃជាគ្រហស្ថត្រូវនាំប្រដៅទូន្មានប្រយោជន៍បច្ចុប្បន្ន ៤ គឺ ឧដ្ឋានតា = ការប្រកបការងារ, សតីមតា = ចេះរក្សាទុកដាក់ទ្រព្យដែលរកបានហើយ, សមជីវិតា ចេះចិញ្ចឹមជីវិតតាមគួរ, កល្យាណមិត្តតា = ចេះសេពគប់មិត្តល្អ និងប្រយោជន៍ក្នុងលោកខាងមុខ៤ យ៉ាងគឺ សទ្ធា = ការជឿ, សីល = ការរក្សារបៀបរៀបរយ, ចាគ = ការចំណាយទ្រព្យឲ្យទាន, បញ្ញា = ការចេះគិតគូរ ។

ស - ១០៩ ក្នុងរយៈវេលាតាំង៤៥ វស្សានោះព្រះពុទ្ធបរមគ្រូទ្រង់គង់ចាំវស្សានៅទីណាខ្លះ ?

ច - កន្លែងដែលធ្លាប់ចាំវស្សាមាន១៨, វស្សាទី១ ទ្រង់គង់នៅព្រៃឥសិបតនមិគទាយដើម្បីប្រោសបញ្ចវគ្គិយភិក្ខុ ។

វស្សាទី ២ - ៣ - ៤ ទ្រង់គង់នៅវត្តវេឡុវ័នជិតក្រុងរាជគ្រឹះ មគធរដ្ឋ ។

វស្សាទី ៥ - ទ្រង់គង់នៅកូដាគារសាលាជិតក្រុងវេសាលី វជ្ជីរដ្ឋ ។

វស្សាទី ៦ ទ្រង់គង់នៅមកុលបព៌តក្នុងមគធរដ្ឋ ។

វស្សាទី ៧ ទ្រង់គង់នៅស្ថានតាវត្តិង្សដើម្បីសំដែងអភិធម្មប្រោស

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធមាតា ។

វស្សាទី ៨ ទ្រង់គង់នៅក្នុងភេសកលាវ័នភគ្គកជនបទ ។

វស្សាទី៩ ទ្រង់គង់ក្នុងព្រៃបាលិលេយ្យក (១) ជិតក្រុងកោសម្ពីវង្សរដ្ឋ ។

វស្សាទី ១០–១១ ទ្រង់គង់ក្នុងដងព្រៃជិតស្រុកព្រាហ្មណ៍ឈ្មោះសាលេយ្យកៈ ។

វស្សាទី ១២ ទ្រង់គង់ក្រោមដើមស្ដៅ ដើម្បីប្រោស នឡេរុយក្ស ។

វស្សាទី ១៣ ទ្រង់គង់ចាំវស្សានៅភ្នំបាលិលេយ្យក ។

វស្សាទី ១៤ ទ្រង់គង់ចាំវស្សានៅវត្តជេតពន ទៀបក្រុងសាវត្ថីកោសលរដ្ឋ ។

វស្សាទី ១៥ ទ្រង់គង់នៅវត្តនិគ្រោធារាមជិតក្រុងកបិលព័ស្តុ សក្កជនបទ ដើម្បីប្រោសព្រះញាតិ ។

វស្សាទី ១៦ ទ្រង់ចាំវស្សាក្នុងស្រុកអាឡវី ដើម្បីប្រោសពួកអាឡវកយក្ស ។

វស្សាទី ១៧ - ១៨ - ១៩ ទ្រង់មកគង់ចាំវស្សាក្នុងវត្តវេឡុវ័នវិញ ។

---

១— បានជាគង់នៅទីនេះ ព្រោះមានភិក្ខុជាវិនយធរនិងធម្មកថិកឈ្លោះគ្នា នៅឯឃោសិតារាម ។

វស្សាទី ២០ - ២១ - ២២ - ២៣ - ២៤ . ២៥ : ២៦ . ២៧ . ២៨ និងទី ២៩ ទ្រង់គង់ក្នុងវត្តជេតពនវិញ ។

វស្សាទី ៣០ - ៣១ - ៣២ - ៣៣ - ៣៤ និងទី ៣៥ ទ្រង់គង់ចាំវស្សាក្នុងវត្តបុព្វារាម ដែលនាងវិសាខាសាងថ្វាយ ។

វស្សាទី ៣៦ . ៣៧ . ៣៨ ៣៩ . ៤០ - ៤១ . ៤២ . ៤៣ និងទី ៤៤ ទ្រង់គង់នៅវត្តជេតពនវិញ ។

វស្សាទី ៤៥ ទ្រង់គង់នៅវេឡុគ្រាម ។

ដូច្នេះកន្លែងដែលទ្រង់គង់ច្រើនជាងគេគឺ :

វត្តវេឡុវ័ន មាន ៦ វស្សា ,

វត្តជេតពន ,, ២០ វស្សា(១)

វត្តបុព្វារាម ,, ៦ វស្សា ។

ស. ១១០— ក្នុងវេលា ៤៥ វស្សានេះ តើព្រះអង្គយាងទៅកាន់នគរណាខ្លះ ?

ច— ព្រះអង្គបានយាងទៅកាន់នគរ :

១— ពារាណសី រដ្ឋកាសី

២— រាជគ្រឹះ រដ្ឋមគធៈ

៣— សាវត្ថី រដ្ឋកោសល

---

១—ក្នុងបាលីថា [illegible] ១៩ ទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

៤ - កបិលព័ស្តុ — សក្កជនបទ

៥ – វេសាលី — រដ្ឋវជ្ជី

៦ - បាតលិបុត្ត — រដ្ឋអស្សក

៧ – កោសម្ពី — រដ្ឋវង្ស:

៨ – វេរញ្ញា — ( មិនប្រាកដ )

៩ – កុសិនារា — រដ្ឋមល្ល:

១០ – បាវា — រដ្ឋមល្ល:(១)

១១ – សាកេត — ( រដ្ឋមិនប្រាកដ )

១២ – ចម្បា — រដ្ឋអង្គ :

១៣ – វេដ្ឋទីបក : — ( រដ្ឋមិនប្រាកដ )

១៤ – អល្លកប្ប: — រដ្ឋពូលិ

១៥ – មោរិយ: — ព្រៃបិប្ផលិ

ទ្រង់ដែលយាងទៅក្នុងរដ្ឋដទៃខ្លះទៀតតែមិនមានឈ្មោះប្រាកដ ។

ទ្រង់ដែលយាងទៅលង្កាទ្វីប ៣ ដងគឺ ម្តង ពេលត្រាស់ដឹងហើយបាន ៩ ខែ ទ្រង់និមន្តទៅកោះនោះតែ ១ ព្រះអង្គឯង ទ្រង់ប្រថាប់កណ្តាលអាកាស កណ្តាលទីប្រជុំពួកយក្ស ( កាលនោះលង្កាទ្វីបគ្មានមនុស្ស

---

១— រដ្ឋមល្លៈមានក្រុង១គឺ កុសាវតី ក្រោយមកបែកជាពីរគឺ កុសិនារានិងបាវា ។

www.budinst.gov.kh www.elibraryofcambodia.org

នៅទេ មានសុទ្ធតែពួកយក្សបិសាចនៅ ) ។ ទ្រង់បណ្ដាលឲ្យភ្លៀងធ្លាក់ឲ្យពួកយក្សរងាហើយចុះចាញ់ ព្រមទាំងប្រគេនទ្វីបនេះដល់ព្រះអង្គ ។ ទ្រង់ហោះវិល ៣ ជុំ ហើយប្រទានព្រះកេសធាតុដល់ពួកយក្សបិសាច ។

លើកទី ២ ក្នុងពេលបានត្រាស់ហើយបាន ៥ ឆ្នាំ ទ្រង់យាងទៅតែ ១ ព្រះអង្គឯង ដើម្បីសម្រុះសម្រួលនាគឈ្មោះចូឡោទរនិងមហោទរ ជាមានិងក្មួយ ដែលទាស់ទែងគ្នាព្រោះរឿងបល្ល័ង្កកែវ ។

លើកទី៣ ពេលទ្រង់បានត្រាស់ហើយបាន៨ឆ្នាំ ទ្រង់និមន្តទៅកោះនេះ ជាមួយភិក្ខុសាវ័ក ៥០០ រូប ដោយមណិអក្ខិនាគរាជអារាធនានិមន្ត ។ ទ្រង់ទុកស្នាមព្រះបាទនៅលើភ្នំសុមនកូដ ហើយយាងត្រឡប់មកវិញ ។ ទ្រង់ពុំដែលគង់ចាំវស្សានៅទីនោះទេ ។

ស. — ១១១ កាលចេញព្រះវស្សាទី ៤៥ ហើយ តើព្រះសាស្ដាទ្រង់យាងទៅកាន់ទីណាទៀត ? ទ្រង់បានធ្វើអ្វីខ្លះ ? នៅថ្ងៃខែឆ្នាំណា ?

ច. ព្រះសាស្ដាទ្រង់យាងចេញពីស្រុកវេឡុវ ( វេឡុវគ្គ ) ហើយទ្រង់យាងប្រោសសត្វជាលំដាប់លំដោយរហូតដល់ថ្ងៃពេញបូណ៌មី ខែមាឃ ឆ្នាំរោង (១) ទើបយាងទៅគង់នៅចាបាលចេតិយ ។ នៅទីនោះ មារចូល

---

១. – ទោះជាទៅឆ្នាំម្សាញ់ ។ បើគិតតាមខ្មែរយើងមិនមែនឆ្នាំម្សាញ់ទេ គឺខែមាឃឆ្នាំរោង រាប់ពីបូរមី ខែមាឃទៅដល់ខែពេញបូរមីខែពិសាខ មានត្រឹម ៨៨ ថ្ងៃ គិតតាមក្បាលខែ

www.budinst.gov.kh www.elibraryofcambodia.org

ទៅអាកាសថា ព្រះអង្គឡើងបរិនិព្វាន ព្រះអង្គក៏មានព្រះពុទ្ធដីការដាក់អាយុសង្ខារថា ‹‹កន្លងទៅ ៣ ខែទៀតតថាគតនឹងបរិនិព្វានហើយ ។ ពេលនោះក្រឡាមហាប្រថពីក៏កម្រើកញាប់ញ័រ ពួកសាវ័កក៏កើតសេចក្ដីសង្វេគគ្រប់អង្គ ។

ស- ១១៤ . ព្រះសម្ពុទ្ធទ្រង់យាងទៅកាន់ទីណាទៀត បន្ទាប់ពីនោះទៅ ?

ច - ទ្រង់យាងទៅបិណ្ឌបាត្រក្នុងក្រុងវេសាលី ហើយទ្រង់មានបន្ទូលនឹងព្រះអានន្ទថា ‹‹ តថាគតឃើញក្រុងវេសាលី (១) លើកនេះជា

---

មាន៤ លុះដល់ខែពិសាខ ទើបចូលមកឆ្នាំម្សាញ់ ។ ដូច្នេះបានជាយើងត្រូវរាប់ឆ្នាំកេងវិញ ដែលព្រះអង្គទ្រង់ដាក់អាយុសង្ខារ លុះចូលឆ្នាំម្សាញ់ពេញបូរមីខែពិសាខទើបបរិនិព្វាន ។

១—ក្រុងវេសាលីស្ថិតនៅក្នុងក្រុងដែនវជ្ជី ជាប្រទេសសហរដ្ឋ មានជនជាតិ ៨ ត្រកូលរួមគ្នា ត្រកូលធំជាងគេមានពីរគឺ ត្រកូលលិច្ឆវី តាំងរាជធានីឈ្មោះវេសាលី សព្វថ្ងៃហៅថា ពេសារហ៍ (Besarh) ចម្ងាយ ៤៤ គ.ម. ពីក្រុងបត្នៈ (បាតលីបុត្ត) តាំងនៅលើត្រើយស្ទឹងគន្ធកៈ និងត្រកូលវិទេហៈ តាំងរាជធានីឈ្មោះមិថិលា ។

លោកគួម៉ាស ថាក្រុងវេសាលីនេះតាំងនៅត្រង់ដីដែលប្រាសាទបាក់បែក ១ ហៅថា បាហារ ក្នុងក្រុងមុស្សាភ្វាបុរ ខេត្តតិរហុត សព្វថ្ងៃនៅលើត្រើយខាងកើតនៃស្ទឹងគន្ធកៈ ជាប់នឹងដែនខេបល្វ ។

*លើកចុងក្រោយបង្អស់ហើយ ទ្រង់ត្រាស់ថា ក្រុងវេសាលី មានសោភ័ណភាពល្អស្មើនឹងស្ថានទេវតាឈ្មោះអាឡកមន្ទា បើភិក្ខុទាំងឡាយ មិនដែលឃើញស្ថាននោះចូលមើលក្រុងវេសាលីនេះចុះ ។*

---

លោករីសដាវីត ថាក្រុងវេសាលី ចំរើនជាងក្រុងឯទៀតក្នុងសម័យជាមួយគ្នា មានកំពែង៣ជាន់ ឆ្ងាយពីគ្នា១គាវុត (១សម្រែកគោ) ពីក្រោយក្រុង មានព្រៃធំ១ឈ្មោះមហាវ័ន រហូតទៅដល់ភ្នំហេមពាន្ត ។ ពួកលិច្ឆវី បានសាងកូដាគារសាលាថ្វាយព្រះពុទ្ធនិងសាវ័កគង់ ។ ក្នុងកូដាគារសាលានេះមានកើតអស្ចារ្យរឿងជាច្រើន ដូចក្នុងធម្មបទអដ្ឋកថាជាដើម ក៏មាននិយាយអំពីរឿងព្រះអង្គប្រើមហាអានន្ទឲ្យទៅរម្ងាប់រោគនិងទុរ្ភិក្សភ័យក្នុងដែននេះដែរ ។ ព្រះពុទ្ធទ្រង់បញ្ញត្តសាវ័កមិនឲ្យឆាន់ទឹកដោយមិនបានត្រងនោះទេ ។ គ្រូពេទ្យឈ្មោះជីវកកោមារភច្ច ដែលមានឈ្មោះល្បីល្បាញក្នុងសម័យពុទ្ធកាល ធ្លាប់ព្យាបាលព្រះរោគព្រះអង្គនិងសាវ័ក ក៏មានកំណើតនៅក្រុងវេសាលីនេះដែរ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សព្វព្រះទ័យគង់នៅក្រុងវេសាលីនេះច្រើន ហើយកាលមុនបរិនិព្វាន ទ្រង់កង្វល់នឹងទីនេះយ៉ាងខ្លាំង ព្រោះទ្រង់ជ្រាបថា ព្រះបាទអជាតសត្រូវនឹងចូលវាយយកក្រុងវេសាលីនេះ ព្រះអង្គក៏ទៅគង់ប្រថាប់នៅជិតក្រុងវេសាលីនេះ១ឆ្នាំគត់ ។ ព្រះមហាអានន្ទក៏សព្វព្រះទ័យនឹងក្រុងនេះណាស់ដែរ ទ្រង់ព្យាយាមនិមន្តទៅនិព្វាននៅក្រុងនេះ តែកាលដល់លើស្ទឹង ជាព្រំដែនមគធៈនិងវជ្ជី ក៏ពិចារណាថា កុំឲ្យអ្នកដែនមគធខូចចិត្ត លោកក៏និព្វានលើអាកាសពីលើស្ទឹងនោះទៅ ។

ដែនវជ្ជី (ក្រុងវេសាលីនិងមិថិលា) មានការគ្រប់គ្រងប្រទេសល្អណាស់ គឺគ្រប់គ្រង

www.budinst.gov.kh www.elibraryofcambodia.org

ស ១១៣.– កាលទ្រង់យាងចេញពីក្រុងវេសាលីទៅ តើព្រះអង្គទ្រង់យាងទៅទីណាទៀត?

ច –ព្រះសាស្តាទ្រង់យាងទៅកាន់ភណ្ឌគ្រាមទៀត ហើយទ្រង់យាងទៅប្រោសសត្វតាមលំដាប់លំដោយរហូតទល់នៅដល់ដែនមល្ល. ហើយយាងចូលទៅកាន់សាលវ័នរបស់ក្សត្រមល្ល ជិតក្រុងកុសិនារា ទើបទ្រង់ប្រាប់ព្រះអានន្ទឲ្យរៀបចំគ្រែនៅក្រោមដើមសាលព្រឹក្សទាំងគូ ដើម្បីព្រះអង្គចូលបរិនិព្វាន ព្រមទាំងឲ្យព្រះអានន្ទចូលទៅថ្វាយពត៌មានដល់មល្លក្សត្រនៅក្រុងកុសិនារាថាព្រះអង្គនឹងបរិនិព្វានក្នុងថ្ងៃអង្គារពេញបូណ៌មីខែពិសាខឆ្នាំ

---

ជារដ្ឋាធិបតេយ្យ ដោយគ្មានមហាក្សត្រទេ តែមានក្សត្រជាច្រើនអង្គប្រកបដោយសភាជាទីប្រជុំសម្រាប់វិនិច្ឆ័យសេចក្តីផ្សេងៗតាមមតិភាគច្រើន ។ ព្រះពុទ្ធបានសំដែងអបរិហានិយធម៌៧ប្រការ ជាប្រយោជន៍ដល់ក្សត្រលិច្ឆវីនេះដែរ ។ វិធីគ្រប់គ្រងដែននេះមានលក្ខណៈល្អណាស់ សូម្បីប្រទេសខ្លួនតូចដោយ ក៏អាចការពារការរុករានពីប្រទេសធំៗបានដែរ ប៉ុន្តែជាអកុសល ពេលក្រោយពុទ្ធបរិនិព្វាន ព្រះបាទអជាតសត្រូវបានប្រើសេនាធិការចូលវាយមិនបាន ក៏ប្រើកលល្បិចឲ្យព្រាហ្មណ៍ឈ្មោះវស្សការទៅញុះញង់បំបែកសាមគ្គីជនជាតិលិច្ឆវីទាល់តែបែកបាក់ខ្ទេចខ្ទីអស់ ទើបចូលវាយទន្ទ្រានបានក្នុងកាលជាខាងក្រោយ ។

លោកវិមល ចរ័នឡ និយាយថាក្សត្រលិច្ឆវី ជាសាខាសាក្យវង្សដែរ តែជាសាក្យវង្សវាសិដ្ឋគោត្រ មិនមែនសាក្យវង្ស គោតមគោត្រទេ ពេលដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ជាមួយក្សត្រលិច្ឆវីទ្រង់ហៅថាវាសិដ្ឋ ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាញ់នេះផង ។

ស—១១៤— ហេតុដូចម្ដេចបានជាព្រះអង្គទៅបរិនិព្វាននៅទីនោះទៅវិញ ម្ដេចក៏មិនយាងទៅបរិនិព្វាននៅទីឯទៀតៗដែលមានទីក្រុងធំៗទៅបរិនិព្វានឯក្រុងកបិលព័ស្ដុដែលជាជាតិភូមិរបស់ព្រះអង្គវិញ ? ទ្រង់មានគម្រោះយ៉ាងណា ? ព្រះអង្គបានប្រឹក្សានឹងព្រះអានន្ទដូចម្ដេចខ្លះ ?

ច—ហេតុបានជាទ្រង់ចូលទៅបរិនិព្វាននៅទីនោះព្រោះក្រុងកុសិនារា(១)នេះកាលពីដើមឈ្មោះថាក្រុងកុសាវតីៗ មានសេចក្ដីដំណាលថា "មុនពេលបរិនិព្វាននោះ ព្រះសាស្ដាទ្រង់ប្រឹក្សារើសទីកន្លែងសម្រាប់បរិនិព្វាននឹងព្រះអានន្ទ ក្រាបទូលព្រះអង្គថា „មិនគួរព្រះអង្គយាងមកបរិនិព្វានក្នុងទីក្រុងកុសិនារា ជាក្រុងតូចដូច្នេះទេ„ ហើយព្រះអានន្ទបានថ្វាយយោបល់ចំពោះព្រះអង្គថា គួរព្រះអង្គយាងទៅបរិនិព្វាននៅក្រុងធំៗទាំង ៦ ក្រុងណាមួយក៏បានគឺ ៖

---

១—ក្រុងកុសិនារានេះ ស្ថិតនៅក្នុងដែនមល្លៈ ។ ដែនមល្លៈនៅខាងជើងដែនវជ្ជី និងខាងកើតដែនសក្កៈ ។ ពួកមល្លៈជាត្រកូល១មកពីដែនបាវា និងកុសិនគរ រាជធានីឈ្មោះកុសិនគរឬកុសិនារា តាំងនៅទីប្រជុំស្ទឹងរប្តិនិងគណ្ឌកៈ នៅក្នុងដែននេបាល់សព្វថ្ងៃ ។ ដែនមល្លៈនេះ កាលពីដើមមានរាជធានីឈ្មោះកុសាវតី តែក្រោយមកចែកជា២ គឺរាជធានីកុសិ–

www.budinst.gov.kh www.elibraryofcambodia.org

១- ក្រុងចម្បា ដែន អង្គៈ

២- រាជគ្រឹះ ,, មគធៈ

៣- សាវត្ថី ,, កោសល

៤- សាកេត ,, កោសល

៥- កោសម្ពី ,, វង្សៈ

៦- ពារាណសី ,, កាសី

ដែលជាក្រុងធំៗមានមហាជនច្រើននោះវិញ ដែលព្រះអង្គគួរបរិនិព្វាន– ប៉ុន្តែព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាសថា "ក្រុងកុសិនារានេះ កាលពីដើមជាក្រុងធំផុតណាស់ឈ្មោះកុសាវតី មានស្តេចចក្រពត្តិសោយរាជ្យនាមព្រះ

---

នារា និងបាវា ។ កុសិនារា សព្វថ្ងៃហៅថាកាស្យា (Kacia) ឯក្រុងបាវាហៅថា បទ្រីអូនៈ (Padraona) ។

លោក រីស-ដាវីត សរសេរថាភូមិភាគខាងដែនពួកមល្លៈមានពីរគឺ កុសិនារា១ បាវា១ ហើយផ្លាស់ប្តូរវេនប្រជុំម្តងម្នាក់ ៗ និងមានរបៀបគ្រប់គ្រងរដ្ឋដូចដែនវជ្ជីរបស់លិច្ឆវី និងវិទេហៈដែរ ។ នៅវេលាចែកព្រះបរមសារីរិកធាតុ ដែនមល្លៈបានពីរចំណែកគឺ ក្រុងកុសិនារា១ចំណែក បាវា ១ចំណែក ។

លោកវិមលចរ័នឡ សរសេរថាដែនមល្លៈមានរាជធានីធំពីរគឺ រាជធានីកុសិនារា១ បាវា ១ ហើយមានក្រុងធំដទៃពីរកន្លែងទៀតគឺ អនុបិយា១ ឧរុវេលកប្ប១ ហើយក្សត្រមល្លៈ ក៏ជាវាសិដ្ឋគោត្រដូចពួកលិច្ឆវីដែរ ព្រោះកាលព្រះអានន្ទទៅថ្វាយពត៌មានអំពីពុទ្ធបរិនិព្វាននោះ

គឺ—

www.budinst.gov.kh www.elibraryofcambodia.org

បាទសុទស្សនៈ ដូច្នេះបានជាតថាគតមកបរិនិព្វាននៅទីនេះ ។

ម្យ៉ាងទៀត តាមសេចក្តីដំណាលថា បានជាទ្រង់មកបរិនិព្វាន នៅទីនោះព្រោះក្រុងកុសិនារានេះមានអាចារ្យម្នាក់ឈ្មោះទោណព្រាហ្មណ៍ ដែលមានឈ្មោះល្បីល្បាញ មានសមត្ថភាពអាចចែកព្រះបរមសារីរិកធាតុបាន ។ ដូច្នេះហើយបានជាពេលបូជាសពព្រះអង្គរួច មានកើតជម្លោះរហូតទល់ជិតច្បាំងគ្នា តែបានទោណព្រាហ្មណ៍ដោះស្រាយ ចែកព្រះបរមសារីរិកធាតុឲ្យស្រួល រឿងនោះក៏ស្ងប់ទៅវិញ ។

ស ១១៩. មុននឹងបរិនិព្វានព្រះអង្គបានមានព្រះពុទ្ធដីកានឹងព្រះអានន្ទយ៉ាងណាខ្លះ? ព្រះអានន្ទអាចដោះស្រាយរួចឬទេ ?

ច- ទ្រង់សួរព្រះអានន្ទដោយន័យផ្សេង ១ អំពីឥទ្ធិបាទធម៌ ៤ ក៏

---

លោកក៏ប្រើពាក្យហៅមល្លក្សត្រថា វាសិដ្ឋ ។ ព្រះពុទ្ធបរិនិព្វាននៅមលរដ្ឋខាងក្រុងកុសិនារា មិនមែនមល្លក្សត្រខាងក្រុងបាវាទេ ។

លោកវិមលចរ័ន្ទ្យ អាងដល់គម្ពីរមហាវង្សនិងកុសិនារាកថា ក្រុងកុសាវតីជាឈ្មោះក្រុង ដែលព្រះបាទឧក្កាករាជដើមវង្សសក្យៈគ្រប់គ្រងរាជសម្បត្តិតាំងពីអតីតកាលមក ។ កាលមានរឿងរាជសម្បត្តិកើតស្មុគ្រស្មាញ ព្រះអង្គក៏បញ្ជូនរាជបុត្រ—ធីតា៩អង្គឲ្យចេញសាងនគរថ្មីទៀត ។ ដូច្នេះបានជាក្នុងគម្ពីរដីកាថា សក្កជនបទចែកជា៣នគរគឺ នគរដើមរបស់ព្រះបាទឧក្កាករាជ១ នគរកបិលពស្តុ១ នគរទេវទហៈ១ ។

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែព្រះអានន្ទពុំយល់ ទើបព្រះអង្គពន្យល់ដោយសព្វគ្រប់ រួចត្រាស់ថា " តថាគតនឹងបរិនិព្វានក្នុងថ្ងៃនេះ ,, ។ ព្រះអានន្ទទ្រង់ចេញទៅគង់យំនៅក្លោងទ្វារខគរយ៉ាងខ្លាំង ទើបព្រះអង្គត្រាស់ហៅព្រះអានន្ទមក ហើយត្រាស់សរសើរព្រះអានន្ទថា ជាអ្នកមានគុណសម្បត្តិយ៉ាងច្រើនរួច ទ្រង់ឲ្យព្រះអានន្ទទៅថ្វាយដំណឹងដល់មល្លក្សត្រ ។

(រឿងនេះ កាលការកសង្ឃធ្វើបឋមសង្គាយនា (ការប្រជុំរៀបចំ-ធម៌វិន័យ ជាលើកដំបូងនៅក្រុងរាជគ្រឹះនារដូវភ្លៀង) រួចហើយព្រះមហាកស្សបត្ថេរទ្រង់ចោទទោសព្រះអានន្ទថា " ព្រះអានន្ទមិនបានទូលសុំឲ្យព្រះពុទ្ធបរមគ្រូគង់បន្តព្រះជន្មាទៅទៀត នៅពេលដែលព្រះអង្គទ្រង់ឲ្យន័យ ដល់ព្រះអានន្ទ ) ។

ស ១០៦ កាលមុនបរិនិព្វាន ព្រះសាស្តាទ្រង់ហៅអានន្ទមកសរសើរហើយ តើទ្រង់ទូន្មានផ្តាំព្រះឱវាទចុងក្រោយបង្អស់យ៉ាងណាដែរ ?

ច– ទ្រង់ផ្តាំព្រះអានន្ទថា " ម្នាលអានន្ទ ! ធម៌និងវិន័យទាំងឡាយ ដែលតថាគត បានសម្តែងហាមប្រាមរួចហើយ នឹងបានជាគ្រូបាអាចារ្យរបស់អ្នកនៅពេលអស់តថាគតទៅ , ជនណា, អ្នកណា ដែលបានបូជាដល់តថាគតដោយគ្រឿងអាមិស ជននោះមិន

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះថា ជាអ្នកស្រឡាញ់រាប់អានបូជាតថាគតទេ លុះតែជនណាបាន ប្រតិបត្តិឲ្យផិតផល់តាមធម៌វិន័យ ដែលតថាគតបានហាមប្រាមសំដែងហើយ ទើបឈ្មោះថា ជាអ្នកគោរពស្រឡាញ់រាប់អានបូជាដល់តថាគតយ៉ាងពិតប្រាកដ ដូច្នេះចូរអ្នកទាំងឡាយ ប្រឹងប្រែងធ្វើប្រយោជន៍របស់ខ្លួនឯង អ្នកដទៃឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ នេះជាសំដីជាទុកចុងក្រោយបង្អស់របស់តថាគត ។

ស- ១១៧ ក្រៅពីនេះ តើមានអ្នកណាចូលទៅសួរទាក់ទងពីរឿងអ្វីនឹងព្រះអង្គទៀតដែរ ?

ច- មានសុភទ្ទបរិព្វាជក បានចូលទៅសួរប្រស្នាព្រះអង្គ ។ ប្រទានធម៌ចប់ សុភទ្ទបរិព្វាជក ក៏បានសម្រេចព្រះអរហត្តផល បានជាសាវ័កពៅបង្អស់របស់ព្រះអង្គ ( សាវ័កច្បងគឺព្រះកោណ្ឌញ្ញត្ថេរ ) ។

ស- ១១៨ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ចូលបរិនិព្វាន ដោយអាការដូចម្តេច ? មានហេតុចម្លែកយ៉ាងណាទេ ?

ច- ព្រះអង្គទ្រង់ផ្ទំផ្អៀងទៅខាងស្តាំបែរព្រះសិរទៅខាងជើង ព្រះភក្ត្រទៅលិចនៅចន្លោះដើមរាំងទាំងគូ ។

មុនបរិនិព្វានទ្រង់ចូលបឋមជ្ឈាន , ទុតិយជ្ឈាន , តតិយជ្ឈាន , ចតុត្ថជ្ឈាន រួចចូលអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមា

www.budinst.gov.kh www.elibraryofcambodia.org

បត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ, នេវសញ្ញានាសញ្ញាយតនសមាបត្តិ. សញ្ញាវេទយិតនិរោធ រួចចេញពីសញ្ញាវេទយិតនិរោធ មកកាន់អាកិញ្ចញ្ញាយតនសមាបត្តិ ( រំលងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ) ព្រាសហួតដល់បឋមជ្ឈាន ហើយចូលបណ្តោយទៅវិញដល់ចតុត្ថជ្ឈាន, រួចចេញពីចតុត្ថជ្ឈាន ក៏ទ្រង់ចូលបរិនិព្វាននៅពេលនោះ ព្រះធរណីក៏កក្រើករំពើកយ៉ាងខ្លាំង ។

ស— ១១៩— មុនពេលទ្រង់បរិនិព្វានព្រះអង្គទ្រង់ប្រឈួនដែរ ឬគ្មានទេ ?

ប— ទ្រង់ប្រឈួនដែរ ។

ស— ១២០· ទ្រង់ប្រឈួនដោយរោគអ្វី ?

ប= ទ្រង់ប្រឈួនដោយរោគធ្លាក់ឈាម ។

ស= ១២១ រោគធ្លាក់ឈាមនោះជារោគធម្មតាទេ ឬ ដោយមានហេតុយ៉ាងណាដែរ ?

ប= ដោយមកពីព្រះអង្គមានពៀរពីអតីតជាតិ ។ មានសេចក្តីដំណាលថា “ កាលពីអតីតជាតិយូរលង់ណាស់មកហើយ ទ្រង់កើតជាឈ្មួញរទេះ បានបររទេះទៅដល់ស្ទឹងមួយ គោក៏ស្រេកទឹកទាញរទេះទៅរកទឹកផឹក តែព្រះអង្គទ្រង់ក្រោធក៏ទាញគោបង្អត់ទឹក ។ លុះ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គរៀបចូលបរិនិព្វាន ទ្រង់ស្រេកទឹកណាស់ បានប្រើព្រះអានន្ទឲ្យទៅដងទឹកយកមកសោយ ព្រះអានន្ទរកទឹកល្អពុំបាន ព្រោះទឹកស្ទឹងជិតនោះ ល្អក់ទាំងអស់ ដោយមានឈ្មួញរទេះ ៥០០ ទើបនឹងបររទេះទៅថ្មីៗ, ទៅត្រង់ណាក៏ទឹកល្អក់ទាំងអស់, ព្រះអានន្ទមកទូលព្រះអង្គថា៖ គ្មានទឹកល្អទេ ព្រះអង្គទ្រង់ធ្លាក់ឈាមហើយស្រេកទឹកខ្លាំង ក៏បង្គាប់ព្រះអានន្ទថា ទឹកនោះមិនល្អក់ទេ ចូរអានន្ទដងមកចុះ ព្រះអានន្ទក៏ដងតាមព្រះពុទ្ធដីកាយកមកថ្វាយព្រះអង្គ ទឹកក៏ថ្លាវិញ ហើយព្រះអង្គទ្រង់សោយទៅ ។

ស- ១៦៦ - ព្រះបរមសាស្ដាយាងទ្រង់បរិនិព្វាន ទៅថ្ងៃខែឆ្នាំណា ? រដូវណា ? នៅទីណា ? ក្នុងព្រះជន្មប៉ុន្មាន ? ក្រោយពេលបានដឹងហើយប៉ុន្មានឆ្នាំ ?

ច- ទ្រង់បរិនិព្វាន នៅថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ នាគិម្ហរដូវ នៅក្រោមដើមសាលព្រឹក្សទាំងគូ (១) លើផ្ទាំងថ្ម ក្នុងសាលវ័ន ជិតក្រុងកុសិនារារបស់ពួកមល្លក្សត្រ ក្នុងដែនមល្លៈ នៅព្រះជន្ម ៨០ ឆ្នាំគត់ ក្រោយពេលបានត្រាស់ដឹងហើយ ៤៥ ឆ្នាំ ។

---

(១)—ធ្លាប់ឮមកថា ដើមសាលព្រឹក្សទាំងគូនិងផែនថ្មនេះ កើតយូរហើយនៅត្រង់កន្លែងនេះ



www.budinst.gov.kh www.elibraryofcambodia.org

ស · ១៦៣ . — ព្រះបរមសពនៃព្រះសម្ពុទ្ធ គេដំកល់ទុកប៉ុន្មា

ាម ?

ច - គេដំកល់ទុកចំនួន ៧ ថ្ងៃ ។

ស - ១៦៤ . — ដំកល់ទុកនៅទីណា ? បានធ្វើអ្វីខ្លះដល់ព្រះ

ព ? អ្នកណាជាអ្នកចាត់ការ ?

ច · គេដំកល់ទុកនៅមកុដពន្ធនចេតិយ ត្រង់ទិសបូព៌ានៃទីក្រុង
ាយមល្លក្សត្រ និងទេវតាព្រមទាំងមហាជន បានធ្វើសក្ការបូជាដោយ
ចាំតន្ត្រី គ្រឿងក្រអូបអស់រយៈវេលា ៦ ថ្ងៃ ។ អ្នកចាត់ការផ្នែកសាវ័ក
នព្រះអនុរុទ្ធ និងព្រះអានន្ទជាប្រធាន ព្រមទាំងពួកគ្រហស្ថ មានពួក
មល្លក្សត្រ ៨ អង្គជាសមាជិក ។

ស - ១៦៥ . — គេធ្វើពិធីថ្វាយព្រះភ្លើងនៅថ្ងៃណា ? នៅទីណា ?
នហេតុចម្លែកអស្ចារ្យអ្វីដែរឬទេ ? ព្រោះហេតុអ្វី ?

---

កាលពីពេលកន្លងយូរយារណាស់មកហើយ ក្មេងគង្វាលគោ (ប្រហែលជាព្រះពោធិសត្វនៃ
បឹង) បាននាំគោទៅឃ្វាលនៅទីនោះ ។ កាលក្មេងចុះក្នុងទឹកស្លើងក៏ទាមជាប់ ហើយចាប់
ឃ្លឹងនោះយកមែកសាលព្រឹក្សពីរដោតសន្ទឹងទៅជើងទៅត្បូង . ។ ស្លើងក៏ក្លាយជាផែនថ្ម
មែកសាលព្រឹក្សក៏ដុះធំឡើង ហើយនៅរហូតទល់ព្រះពុទ្ធបរិនិព្វាន ។ នេះជារឿងព្រេងនិទាន
នៃភ្នំតាងកន្ទ្រខ្មែរយើងនៅខេត្តកំពង់ឆ្នាំងដែរមើលទៅ ! ។

www.budinst.gov.kh www.elibraryofcambodia.org

៥ - គេធ្វើពិធីថ្វាយព្រះភ្លើងនៅថ្ងៃអង្គារ ៧ កើត ខែពិសាខ នៅមកុដពន្ធនចេតិយ ខាងកើតទីក្រុង ៗ មានសេចក្ដីដំណាលថា កាលពួកមល្លក្សត្រទាំង ៨ អង្គដែលជាអ្នកចាត់ការបុណ្យ បានគិតលើកព្រះសពដង្ហែចេញទៅទិសខាងត្បូង ហើយនឹងថ្វាយព្រះភ្លើងនៅខាងត្បូងព្រះរាជវាំង លុះគិតហើយក៏លើកព្រះសព តែពុំរួចសោះ ៗ មល្លក្សត្រសួរព្រះអនុរុទ្ធ ៗ ថ្វាយពរមានថា មកពីខុសបំណងទេវតា ៗ តមកមល្លក្សត្រក៏ព្រមព្រៀងគ្នាថានឹងលើកសពដង្ហែចេញទៅទិសខាងជើងបត់ទៅលិចរួចចូលទៅកាន់ក្រុងតាមទ្វារខាងជើង កាត់ទីក្រុងរួចចេញតាមទ្វារខាងកើត ហើយដំកល់ព្រះសពនៅមកុដពន្ធនចេតិយដដែលរួចថ្វាយព្រះភ្លើង ៗ គិតរួចក៏លើកព្រះសពបានកក្រើកដោយស្រួល រួចធ្វើតាមដំណើរនោះ ៗ នៅពេលបូជាព្រះភ្លើងពុំឆេះឡើយ មល្លក្សត្រសង្ស័យក៏ទូលសួរព្រះអនុរុទ្ធ ៗ ថ្វាយពរមានថា ព្រះមហាកស្សបត្ថេរ[1]ពុំទាន់និមន្តមកដល់ ៗ កាលលោកនិមន្តមកដល់ ព្រះបាទទាំងគូរបស់ព្រះបរមសព ក៏លៀនចេញពីមឈូសមាស ព្រះមហាកស្សបបានថ្វាយបង្គំរួច ព្រះអគ្គិក៏ឆេះ

---

១—ព្រះមហាកស្សបត្ថេរនេះមានព្រះវ័យចាស់ជាងព្រះអង្គ ហើយជាទីទុកព្រះទ័យរបស់ព្រះអង្គណាស់។ព្រះអង្គកាលគង់ព្រះជន្មនៅ ធ្លាប់ផ្លាស់ប្ដូរប្រគេនចីពរជាមួយព្រះកស្សបៈ

www.budinst.gov.kh www.elibraryofcambodia.org

ឯងនឹងភ្លាម ។

ស - ១២៦ .- ព្រះបរមសព បានឆេះអស់ ឬ នៅសល់អ្វីដែរ ?

ច - នៅសល់ព្រះអដ្ឋិធាតុទាំងអស់ឥតឆេះទេ ។

ស - ១២៧ .- ព្រះអដ្ឋិធាតុដែលនៅសល់នោះមានលក្ខណៈយ៉ាងណាខ្លះ ប៉ុន ៗ ណា ?

ច - ព្រះអដ្ឋិធាតុដែលនៅនោះមានពីរចំណែកគឺ ព្រះអដ្ឋិធាតុដែលនៅល្អ មិនបាក់បែក ១ ផ្នែក, ព្រះអដ្ឋិធាតុដែលបាក់បែក ១ ផ្នែក ។

ព្រះធាតុដែលមិនបាក់បែកមាន ៧ ព្រះអង្គ គឺ ៖ ធ្មេញថ្គាម ( ព្រះ

---

ប្រើប្រាស ។ លោកជាប្រធានសង្ឃក្នុងបឋមសង្គាយនា ជាអ្នកចោទសួរបញ្ហាទាំង៣ចំពោះព្រះឧបាលី និងព្រះអានន្ទ ។ កាលលោកបរិនិព្វានទៅ គេយកព្រះសពលោកទៅបញ្ចុះឥតបូជាទេ ។ មឈូសនៃព្រះសពនេះនៅរហូតទល់ព្រះសិអារ្យមេត្រីបានត្រាសហើយហៀបបរិនិព្វានទៅវិញ ។

សេចក្តីដំណាលថា កាលពីអតីតជាតិព្រះសិអារ្យបានកើតជាហ្មចារ ព្រះកស្សបកើតជាដំរី ។ ពេលមួយហ្មចារបានប្រើដំរីឡើងបង្អែកក្តៅក្វាយព្រះភជាទុត ។ កម្មពៀរក៏ពុំទាន់ស្ងប់នៅឡើយ ។ ដល់ពេលព្រះសិអារ្យបានត្រាសទេសនាប្រោសសត្វគ្រប់ ៩០០០ ឆ្នាំហើយហៀបបរិនិព្វាន មឈូសព្រះសពព្រះមហាកស្សបក៏ផុះពីដីអណ្តែតទៅរកព្រះសិអារ្យ ទតឃើញក៏យកព្រះហស្តទ្រមឈូសរក៏ឆេះលើព្រះហស្តព្រះសិអារ្យ ។ ក៏ចូលព្រះនិព្វាននៅពេលនោះឯង ។ ដោះមកពីកម្មពៀរកាលហ្មចារប្រើដំរីឡូងបង្អែកក្តៅពីមុននោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧណ្ហីសធាតុ ) ១ , ព្រះចង្កូមកែវ ( ព្រះទាឋាធាតុ ) ទាំង ៤ និងឆ្អឹងដង កាំបិត (ព្រះអក្ខកធាតុទាំង២) ។

ព្រះធាតុក្រៅពីនេះសុទ្ធតែបែកបាក់ជាបំណែកធំខ្លះតូចខ្លះ គឺ ៖

ព្រះធាតុខ្នាតធំផុតមានទំហំប៉ុនមួយកំណាត់គ្រាប់សណ្តែកបាយមា ពណ៌ដូចមាសហើយមានទម្ងន់ ៥ តាំឡឹង ។

ព្រះធាតុខ្នាតកណ្តាលមានទំហំប៉ុនមួយកំណាត់គ្រាប់អង្ករ មានពណ៌ ដូចកែវផ្លែកហើយមានទម្ងន់ ៦ តាំឡឹង ។

ព្រះធាតុខ្នាតតូចមានទំហំប៉ុនគ្រាប់ស្ពៃ មានពណ៌ដូចផ្កាផ្គុល មា ទម្ងន់ ៥ តាំឡឹង ។

ស ២៨ .– កាលគេបូជាហើយ តើគេយកព្រះធាតុទៅដំកល់ ទុកនៅទីណា ?

ច- ពួកមល្លក្សត្របានរើសព្រះបរមសារីរិកធាតុដង្ហែយកទៅ ដំកល់ទុ នៅក្នុងព្រះរាជមន្ទីរនាព្រះរាជវាំង ហើយធ្វើសក្ការបូជាអស់ ៧ ថ្ងៃទៀត

ស - ១២៩ .– ព្រះសារីរិកធាតុទាំងអស់តើគេដំកល់ទុកតែ កន្លែង ឬ ចែកទៅនគរផ្សេងទៀតដែរ ?

ច– គេចែកទៅតាមនគរចំនួន ៨ គឺ

១= នគររាជគ្រឹះ មគធរដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

២= នគរវេសាលី វជ្ជីរដ្ឋ

៣= នគរកបិលព័ស្ដុ សក្កជនបទ

៤= នគរអល្លកប្ប: ពូលិរដ្ឋ

៥= នគររាមគ្រាម កោលិយរដ្ឋ

៦= ពួកព្រាហ្មណ៍ នៅវេដ្ឋទីបករដ្ឋ

៧= នគរបាវា មល្លរដ្ឋ

៨= នគរកុសិនារា មល្លរដ្ឋ

នគរទាំង ៨ នេះបានចំណែកនៃព្រះបរមសារីរិកធាតុស្មើ ១ គឺ នគរមួយបានពីរនាឡិ ។

នៅពេលគេចែកព្រះសារីរិកធាតុរួច ក្សត្រមោរិយ: ពួកអ្នកក្រុងបុប្ផលិវ័នបានបញ្ជូនទូតទៅដែរ តែមិនបានទាន់ទីនគេទេ ពួកមល្លក្សត្របានឲ្យតែព្រះអង្គារ ( ធ្យូង ) ដល់ពួកទូតមោរិយ: ។ ក៏ព្រមយក ។

ស. ១៣០– អ្នកណាជាអ្នកចែកព្រះបរមសារីរិកធាតុ , បើគ្មានអ្នកនោះទេតើគេអាចចែកបានទេ ?

ច– អាចារ្យឈ្មោះទោណព្រាហ្មណ៍ជាអ្នកចែក ។ បើគ្មានទោណព្រាហ្មណ៍នេះទេ ទីនកើតចម្បាំងយ៉ាំងខ្លាំងមិនខាន ។

ស ១៣១– អាចារ្យទោណព្រាហ្មណ៍ជាវេចចំណែក បានចំណែក

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសារីរិកធាតុទីដទៃទេ ?

ឆ ឥតបានទេ បានតែកុម្ភសម្រាប់រាល់ព្រះបរមសារីរិកធាតុប៉ុណ្ណោះ ហើយគាត់ក៏យកកុម្ភនោះទៅធ្វើចេតិយបញ្ចុះក្នុងក្រុងកុសិនារាដែរ (១)។

ក្សត្រទាំង ៨ នគរ និងនគរបិប្ផលិវ័ន ១ ទៀតជា ៩ បានយកព្រះបរមសារីរិកធាតុ ទៅធ្វើជាស្តូបបញ្ចុះនៅក្នុងក្រុងរបស់ខ្លួនរៀងរាល់អង្គ ។ រាប់ទាំងព្រះស្តូបដែលបញ្ចុះព្រះកុម្ភរបស់ទោណព្រាហ្មណ៍ ១ផងទៀត ព្រះស្តូបមាន ១០ ដែលស្ថិតនៅក្នុងជម្ពូទ្វីបនេះ ។

ស. ១៣៦= ព្រះធាតុដែលបាក់សុទ្ធតែបានចែកទៅតាមនគរអស់ទៅហើយ ចុះព្រះធាតុដែលមិនបាក់បែក តើបានទៅទីណាខ្លះ ?

ឆ = ព្រះធាតុទាំងនេះបានទៅប្រតិស្ឋានក្នុងដែនទាំងនេះគឺ ៖

| | | |
|---|---|---|
| ព្រះចង្កូមកែវស្តាំលើ | ប្រតិស្ឋាននៅ | ស្ថានត្រៃត្រឹង្ស |
| ព្រះចង្កូមកែវស្តាំក្រោម | ,, | សីហឡទ្វីប |
| ព្រះចង្កូមកែវឆ្វេងលើ | ,, | ដែនគន្ធារៈ |
| ព្រះចង្កូមកែវឆ្វេងក្រោម | ,, | នៅពិភពនាគ |

១—ឮតមកថា ទោណព្រាហ្មណ៍បានយកព្រះចង្កូមកែវ១ទៅលាក់នៅផ្នួងសក់ តែទេព-តាបានយកទៅទៀត ហើយយកទៅបញ្ចុះនៅក្នុងចូឡាមណិចេតិយនៅស្ថានតាវត្តិង្ស ។

www.budinst.gov.kh www.elibraryofcambodia.org

ធ្មេញចង្កូមខាងឆ្វេងទាំងពីរអង្គ ប្រតិស្ឋានទៅព្រហ្មលោក ឯធ្មេញចង្កូមខាងស្តាំ មិនប្រាកដថាជាប្រតិស្ឋានទៅទីណា ឯព្រះឧណ្ហីសធាតុ (ធ្មេញថ្គាម) ក៏មិនឮថាជាប្រតិស្ឋានទៅទីណាដែរ ។

ចំណែកខាងព្រះកេសធាតុ, ព្រះទន្តធាតុ ៤០, ព្រះលោមធាតុ (រោម) ព្រះនខធាតុ (ក្រចក) ពួកទេវតានាំយកមួយអង្គ ១ ទៅចក្រវាឡដទៃទាំងអស់ ។

**ស.** ១៣៣= ចុះព្រះពុទ្ធបរិក្ខារតើមានប៉ុន្មាន? កាលព្រះអង្គបរិនិព្វានទៅ គេយកពុទ្ធបរិក្ខារទាំងនោះទៅបញ្ចុះទុកក្នុងទីណា ?

ច - ពុទ្ធបរិក្ខារមាន ១០ យ៉ាង ។ កាលព្រះអង្គបរិនិព្វានទៅ គេយកពុទ្ធបរិក្ខារទាំងនោះទៅក្នុងទីផ្សេង ៗ គឺ ៖

| | | |
|---|---|---|
| ១ - ត្រៃចីវរ | បានទៅប្រទេស | គន្ធ |
| ២ - សំពត់ទទកសាដក | " | បញ្ចាលរាជ |
| ៣ - សំពត់បម្រុងខ្លួន | " | កោសល |
| ៤ - កាយពន្ធ និងបាត្រ | " | បាតលិបុត្ត |
| ៥ - ច្រនាប់ព្រះបាទនិងស្នោកបាត្រ | " | ស្រុកទសសព្រាហ្មណ៍ |
| ៦ - គ្រឿងកម្រាល | " | នគរមកុដ |
| ៧ - និសីទនសន្ថត | " | កុរុរដ្ឋ |

www.budinst.gov.kh www.elibraryofcambodia.org

៨ - កាំបិតកោរ ទ័ងបំពង់ម្ជុល បានទៅប្រទេស ឥន្ទបត្ត

៩ - សំពត់តម្រងទឹក ,, វិទេហរដ្ឋ

១០- ឈើស្ទួន ,, មិថិលា ។

ស - ១៣៤. – កាលមុនព្រះសាស្តាទ្រង់ចូលបរិនិព្វាន តើព្រះអង្គបានតាំងព្រះមហាថេរអង្គណាជាសង្ឃការី (អ្នកគ្រប់គ្រងសង្ឃ) ដែរ? ព្រោះហេតុអ្វី ?

ច - ទ្រង់ពុំបានតាំងព្រះមហាថេរអង្គណាជាសង្ឃការីទេ ព្រោះទ្រង់ក្រែងសង្ឃការីនោះពុំបានធ្វើកិច្ចការផ្សេង ៗ ឲ្យបានដូចព្រះអង្គផង ហើយពុំមានសមត្ថភាពឲ្យស្មើនឹងព្រះអង្គផង ម្យ៉ាងទៀតព្រះអង្គគ្រាន់តែទ្រង់ផ្តាំផ្ញើនូវបច្ឆិមពុទ្ធវចនៈចំពោះព្រះអានន្ទ ប៉ុណ្ណោះហើយ ក្រោយបឋមសង្គាយនា ព្រះអានន្ទក៏បាននិមន្តទៅទេសនាប្រោសមហាជន ប្រហាក់ប្រហែលនឹងព្រះអង្គដែរ ។ ដូច្នេះព្រះមហាអានន្ទដែលជាពុទ្ធុបដ្ឋាករបស់ព្រះអង្គនេះ ក៏ទុកស្មើនឹងសង្ឃការីដែរ ។ មួយចំណែកពិសេសទៅទៀត ព្រះពុទ្ធសាសនាយើង បើយោលទៅតាមព្រះបរមពុទ្ធោវាទជាបច្ឆិមពុទ្ធវចនៈ ក៏យើងអាចយល់បានថា មិនចាំបាច់មានសង្ឃការីក៏បានដែរ ឲ្យតែអ្នកណាបានប្រតិបត្តិត្រឹមត្រូវតាមធម៌ដែលព្រះអង្គទ្រង់បញ្ញត្តសំដែងហើយ ក៏ឈ្មោះថាគោរពព្រះសាស្តាហើយអាចធ្វើឲ្យពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

សាសនារុងរឿងបានដែរ ឯព្រះធម៌ទាំង ៨៤.០០០ ព្រះធម្មក្ខន្ធនេះឯង ក៏អាចទុកស្មើនឹងព្រះពុទ្ធអង្គទ្រង់គង់ព្រះជន្មនៅដែរ ។ អាស្រ័យហេតុនេះ ហើយបានជាព្រះសាស្ដាទ្រង់ពុំបានតាំងព្រះមហាថេរណា ជា សន្ស្យការីដូចសាសនាដទៃៗឡើយ ។

ស-១៣៩.–ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាទុកប៉ុន្មានឆ្នាំ ហើយព្រះពុទ្ធសាសនានឹងគ្រប់នៅឆ្នាំណា ?

ច - ព្រះពុទ្ធសមណៈគោតមទ្រង់បានប្រតិស្ឋានព្រះពុទ្ធសាសនាទុក ៥.០០០ ព្រះវស្សាហើយព្រះពុទ្ធសាសនា នឹងគ្រប់ ៥.០០០ នៅឆ្នាំជូត ។

**សេចក្ដីសន្និដ្ឋាន** –– ការបានត្រាស់ជាព្រះពុទ្ធ ,ការយាងប្រោសសត្វជាពុទ្ធសកម្មនៅគ្រប់ទីកន្លែងប្រកបល្អ បាននាំមកនូវផលប្រយោជន៍ដ៏សំខាន់ពីរយ៉ាង ម្យ៉ាងប្រយោជន៍នៅក្នុងបច្ចុប្បន្ន គឺដឹកនាំសត្វលោកឲ្យមានសណ្ដាប់ធ្នាប់ប្រកបដោយរបៀបរៀបរយដ៏ល្អ ដែលជាហេតុនាំឲ្យបានសន្តិសុខសន្តិភាព មានវិន័យថ្លៃថ្នូរ ប្រកបដោយមនុស្សធម៌ដ៏ខ្ជាប់ខ្ជួន ម្យ៉ាងទៀត គឺនាំសត្វលោកឲ្យបាននូវសម្បត្តិដ៏ពិសេសគឺលោកុត្តរសម្បត្តិមានមគ្គផល រហូតដល់ព្រះនិព្វាន ជាស្ថានក្សេមផុតពាក់ទុក្ខទាំងពួង ហើយមិនត្រឡប់ប្រែមករកទុក្ខសោកវិញឡើយ ។ ព្រះបរមពុទ្ធវចនៈទាំង ៨៤.០០០ ព្រះធម្មក្ខន្ធដែលព្រះអង្គទ្រង់សំដែងហើយអស់រយៈ

www.budinst.gov.kh www.elibraryofcambodia.org

ពេល ៤៥ ឆ្នាំ បើប្រមូលមកមានតែ ៣ យ៉ាង គឺ

១– សព្វបាបស្ស អករណំ= ការមិនធ្វើអំពើបាបគ្រប់យ៉ាង បានដល់ព្រះវិនយបិដក ។

២– កុសលស្សូបសម្បទា= ការបំពេញធ្វើអំពើជាកុសលបាន ដល់ព្រះសុត្តន្តបិដក ។

៣–– សចិត្តបរិយោទបនំ - ការញុំាងចិត្តឲ្យផូរផង់ គឺ ការជម្រះចិត្តឲ្យស្អាតចាកគ្រឿងសៅហ្មង បានដល់អភិធម្មបិដក ។

ដូច្នេះព្រះពុទ្ធសកម្មនាគា ដែលទ្រង់បានបំពេញរួចហើយ គឺ ជាទឹកព្រះទ័យដ៏ស្អាតបរិសុទ្ធ ឬ ជាពុទ្ធហឫទ័យដែលព្រះអង្គបានលាតត្រដាងគ្របដណ្តប់ចំពោះសត្វលោក ដោយមេត្តាករុណាគេសាស្តាណាមកប្រដូចឲ្យស្មើគ្នានឡើយ ។

---

បន្ទាប់ពីនេះនឹងប្រគេនជូននូវ " **បញ្ហាប្រវត្តិ-ពុទ្ធសាសនា** ,, ជាសៀវភៅដែលពុទ្ធបរិស័ទគួរតែមាន ដើម្បីនឹងដឹងនូវសង្គាយនា ៥ , ការផ្សាយពុទ្ធសាសនានៅក្រោយពុទ្ធបរិនិព្វានជាដើម ។

រៀបរៀងដោយ សែម-សួរ

www.budinst.gov.kh www.elibraryofcambodia.org

ភាគអវសាន

# ពុទ្ធកាលបរិច្ឆេទនិងស្ថានហេតុនានា ដែលអ្នកសិក្សាពុទ្ធប្បវត្តិគួរចាំទុក

១.– កាលព្រះពោធិសត្វទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ ហើយទ្រង់អភិសេកជាលីនិងនាងក្រឹស្នាជាតូកស្តា – មហេសីហើយ ព្រះវេស្សន្តរទ្រង់សោយទិវង្គតទៅយកព្រះកំណើត ក្នុងស្ថានតុសិតនាមសន្តុសិតទេវបុត្ត មានព្រះជន្ម ៤ ពាន់ឆ្នាំទិព្វ ត្រូវជា ៥៧ កោដិនិង ៦ សែនឆ្នាំមនុស្ស ទើបចូលមកយកព្រះបដិសន្ធិក្នុងផ្ទៃនៃនាងសិរិមហាមាយា. ជាមហេសីនៃព្រះ ព្រះបាទសិរីសុទ្ធោទនៈ នៅក្រុងកបិលពស្តុ នៅថ្ងៃព្រហស្បតិ៍ ១៥ កើតខែអាសាឍឆ្នាំរកា ។

២.– ទ្រង់ប្រសូតនៅសួនលុម្ពិនី នៅថ្ងៃសុក្រពេញបូរមីខែពិសាខឆ្នាំចវេលាថ្ងៃជិតត្រង់ ។

៣.– ទ្រង់ឡើងសោយរាជសម្បត្តិនៅថ្ងៃសៅរ៍ពេញបូរមីខែអាសាឍឆ្នាំជូត ក្នុងព្រះជន្ម ១៦ វស្សា មាននាងពិម្ពាជាមហេសី ។

៤.– ទ្រង់យាងចេញសាងព្រះផ្នួសនៅថ្ងៃព្រហស្បតិ៍ពេញបូរមីខែអាសាឍ ឆ្នាំថោះ (សសេ បព្វជិតោ ជរា) ជាមួយឆន្នអាមាត្យ នៅជិតស្ទឹងអនោមា ក្នុងព្រះជន្ម ២៩ វស្សា ក្រោយទ្រង់សោយ

www.budinst.gov.kh www.elibraryofcambodia.org

កាលបាន ១៣ ឆ្នាំ ។

៥.- ទ្រង់បានត្រាស់ជាព្រះពុទ្ធនៅថ្ងៃពុធពេញបូរមីខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ វស្សា នៅគយាសីសប្រទេស ឧរុវេលនិគម មគធរដ្ឋ ។

៦.- ទ្រង់សំដែងធម្មចក្រ នៅថ្ងៃពេញបូរមីខែអាសាធឆ្នាំរកា នៅឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី កាសីរដ្ឋ ។

៧.- ទ្រង់ធ្វើមហាសាវ័កសន្និបាត នៅថ្ងៃពេញបូរមីខែមាឃ ឆ្នាំរកា នៅវត្តវេឡុវ័នជិតក្រុងរាជគ្រឹះ មគធរដ្ឋ ។

៨.- ទ្រង់យាងទៅកាន់ក្រុងកបិលពស្តុជាលើកដំបូង នៅថ្ងៃពេញបូរមីខែផល្គុនឆ្នាំរកា ។

៩.- ទ្រង់ដាក់អាយុសង្ខារនៅថ្ងៃអាទិត្យពេញបូរមីខែមាឃឆ្នាំរកានៅចាបាលចេតិយ ។

១០- ទ្រង់យាងចូលបរិនិព្វាននៅថ្ងៃអង្គារពេញបូរមីខែពិសាខឆ្នាំម្សាញ់ នៅក្រុងកុសិនារាមល្លរដ្ឋក្នុងព្រះជន្ម ៨០ វស្សា ។

១១- គេធ្វើពិធីបូជាថ្វាយព្រះភ្លើងនៅថ្ងៃអង្គារ ៧ កើតខែពិសាខ ឆ្នាំម្សាញ់ នៅមកុដពន្ធនចេតិយ ពីខាងកើតរាជមន្ទីរនៃក្រុងកុសិនារា ។

១២- ពេលព្រះពោធិសត្វទ្រង់ចាប់បដិសន្ធិ ១ ពេលព្រះពោធិ-

www.budinst.gov.kh www.elibraryofcambodia.org

សត្វទ្រង់ប្រសូត១ ពេលព្រះពុទ្ធអង្គទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ១ ពេលព្រះពុទ្ធទ្រង់ដាក់អាយុសង្ខារ១ ពេលព្រះពុទ្ធអង្គទ្រង់ចូលបរិនិព្វាន ១ ទាំង ៦ ពេលនេះ ព្រះធរណីតែងកម្រើករំពើកជាដរាប ដើម្បីសំដែងការកើតឡើងនូវការសាទរគោរពបូជាព្រះពុទ្ធអង្គ ។

១៣.- សំវេជនីយដ្ឋាន= ទីគួរឲ្យកើតសេចក្តីសង្វេគមាន ៤ កន្លែងគឺ ១-ទីប្រសូត, ២- ទីទ្រង់បានត្រាស់, ៣- ទីទ្រង់សំដែងធម្មចក្រ, ៤- ទីទ្រង់បរិនិព្វាន ។

## បរិយោសានកថា

ការសិក្សាអំពីបញ្ហាពុទ្ធប្បវត្តិខាងលើមកហើយនេះ បាននាំឲ្យយើងឃើញថាព្រះពុទ្ធជាអគ្គបុគ្គល, ជាកំពូលនៃអ្នកប្រាជ្ញ, ជាបរមសាស្តាឯកនៅក្នុងលោក ឥតមានបុគ្គលណាម្នាក់សាស្តាណាយកមកប្រៀបធៀបឲ្យស្មើបានឡើយ សកម្មភាពនិងព្រះពុទ្ធវចនៈទាំងប៉ុន្មាន សុទ្ធតែមានប្រយោជន៍នាំមកនូវសេចក្តីសុខគ្រប់យ៉ាងដល់សត្វលោកទាំងអស់ ។

ដោយអានុភាពនៃការនិយាយរៀបរាប់នូវព្រះប្រវត្តិរបស់ព្រះសាក្យមុនីសម្មាសម្ពុទ្ធជាព្រះអរហន្តដ៏ប្រសើរវិសេសនេះ សូមឲ្យ ៖

—សព្វសត្វទាំងឡាយប្រចាកទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

គ ព្រះពុទ្ធសាសនាបានចំរើនគង់វង់ទៅដូចកាលព្រះសាស្ដាចារ្យ ទ្រង់គង់ព្រះជន្មនៅ ។

–សូមឲ្យពិភពលោកបានសន្តិភាពជានិច្ច ។

- សូមខេមរជននិងពុទ្ធបរិស័ទគ្រប់ជាតិសាសន៍ក្នុងសាកលលោក បានសុខចំរើន ។

–សូមព្រះប្រជាធិបាលជាអគ្គប្រមុខរដ្ឋនៃកម្ពុជាណាចក្រខ្មែរ ទ្រង់ប្រកបដោយព្រះមហាសុភមង្គលវិបុលសុខ និង មានព្រះជន្មច្រើនជាន់រយព្រះវស្សា ដើម្បីនឹងបានជាទីពឹងពំនាក់នៃពលរដ្ឋខ្មែរ ។

–សូមសេចក្ដីសុខកើតមានដល់ខ្ញុំអ្នកប្រមូលចងក្រងនូវពុទ្ធប្រវត្តិពិស្ដារនេះ ។

អ្នករៀបរៀង

សែម-សួរ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org